ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
# ឆ្នាំ ២០១៦ - ២០២៥



បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី

ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២១ ខែតុលា ឆ្នាំ២០១៦

**រាជរដ្ឋាភិបាលកម្ពុជា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
# ឆ្នាំ ២០១៦-២០២៥

រាជរដ្ឋាភិបាលកម្ពុជា

ឆ្នាំ ២០១៦

# មាតិកា

**អារម្ភកថា** ........ vii

**សេចក្តីថ្លែងអំណរគុណ** ........ xi

**ខ្លឹមសារសង្ខេប** ........ xv

*ក. សមិទ្ធផលសំខាន់ៗអនុវត្តបានក្នុងរយៈពេល ១៥ឆ្នាំ ចុងក្រោយ* ........ xvi

*ខ. ការត្រៀមលក្ខណៈដោះស្រាយ បញ្ហាប្រឈម* ........ xvii

*គ. គោលដៅ និងយុទ្ធសាស្ត្រ* ........ xviii

**ជំពូក១**: **ទិដ្ឋភាពទូទៅ** ........ ១

I. **សេចក្តីផ្តើម** ........ ១

II. **ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច** ........ ១

III. **វិស័យហិរញ្ញវត្ថុ** ........ ៤

IV. **រចនាសម្ព័ន្ធ និងការរៀបចំឯកសារយុទ្ធសាស្ត្រ** ........ ៤

**ជំពូក ២**: **វិស័យធនាគារ** ........ ៧

I. **ប្រតិបត្តិការធនាគារ** ........ ៧

*ក. ទិដ្ឋភាពទូទៅ* ........ ៧

*ខ. វឌ្ឍនភាព និងសមិទ្ធផល* ........ ៨

*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ........ ១០

*ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត* ........ ១២

II. **ប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ** ........ ១៥

*ក. ទិដ្ឋភាពទូទៅ* ........ ១៥

*ខ. វឌ្ឍនភាព និងសមិទ្ធផល* ........ ១៦

*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ........ ១៨

*ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត* ........ ១៩

III. **ប្រតិបត្តិការបង់រំលស់** ........ ២០

*ក. ទិដ្ឋភាពទូទៅ* ........ ២០

*ខ. វឌ្ឍនភាព និងសមិទ្ធផល* ........ ២១

*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ........ ២១
*ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត* ........ ២១
IV. **ទីផ្សារអន្តរធនាគារ និងទីផ្សាររូបិយវត្ថុ** ........ ២២
*ក.ទិដ្ឋភាពទូទៅ* ........ ២២
*ខ. វឌ្ឍនភាព និងសមិទ្ធផល* ........ ២២
*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ........ ២២
*ឃ.យុទ្ធសាស្ត្រ និងផែនការអនាគត* ........ ២៣
V. **ប្រតិបត្តិការគតិសន្យាហិរញ្ញវត្ថុ** ........ ២៣
*ក. ទិដ្ឋភាពទូទៅ* ........ ២៣
*ខ. វឌ្ឍនភាព និងសមិទ្ធផល* ........ ២៤
*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ........ ២៤
*ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត* ........ ២៤
**ជំពូកទី៣: វិស័យមិនមែនធនាគារ** ........ ២៧
I. **ទីផ្សារមូលធន** ........ ២៧
*ក.ទិដ្ឋភាពទូទៅ* ........ ២៧
*ខ. វឌ្ឍនភាព និងសមិទ្ធផល* ........ ២៧
*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ........ ៣០
*ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត* ........ ៣០
II. **អ្នកផ្តល់សេវាកម្មអន្តរការី និងវិជ្ជាជីវៈជំនាញ** ........ ៣៣
*ក. ទិដ្ឋភាពទូទៅ* ........ ៣៣
*ខ. វឌ្ឍនភាព និងសមិទ្ធផល* ........ ៣៣
*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ........ ៣៣
*ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត* ........ ៣៤
III. **វិស័យធានារ៉ាប់រង** ........ ៣៤
*ក. ទិដ្ឋភាពទូទៅ* ........ ៣៤
*ខ. វឌ្ឍនភាព និងសមិទ្ធផល* ........ ៣៥
*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ........ ៣៧
*ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត* ........ ៣៨
IV. **វិស័យសោធន (ប្រព័ន្ធគាំពារសង្គម)** ........ ៤០
*ក. ទិដ្ឋភាពទូទៅ* ........ ៤០

*ខ. វឌ្ឍនភាព និងសមិទ្ធផល* ........ ៤០
*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ........ ៤១
*ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត* ........ ៤៣
V. **វិស័យអភិវឌ្ឍអចលនវត្ថុ និងសេវាកម្មវាយតម្លៃអចលនវត្ថុ** ........ ៤៤
*ក. ទិដ្ឋភាពទូទៅ* ........ ៤៤
*ខ. វឌ្ឍនភាព និងសមិទ្ធផល* ........ ៤៥
*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ........ ៤៥
*ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត* ........ ៤៦
VI. **អាជីវកម្មទទួលបញ្ចាំ** ........ ៤៧
*ក.ទិដ្ឋភាពទូទៅ* ........ ៤៧
*ខ.វឌ្ឍនភាព និងសមិទ្ធផល* ........ ៤៧
*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ........ ៤៨
*ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត* ........ ៤៨
**ជំពូក ៤: ការគាំទ្រផ្នែកហេដ្ឋារចនាសម្ព័ន្ធ** ........ ៤៩
I. **សេចក្តីផ្តើម** ........ ៤៩
II. **ក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម** ........ ៤៩
*ក. ទិដ្ឋភាពទូទៅ* ........ ៤៩
*ខ. វឌ្ឍនភាព និងសមិទ្ធផល* ........ ៥០
*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ........ ៥២
*ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត* ........ ៥២
III. **អភិបាលកិច្ច** ........ ៥៤
*ក. ទិដ្ឋភាពទូទៅ* ........ ៥៤
*ខ. វឌ្ឍនភាព និងសមិទ្ធផល* ........ ៥៥
*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ........ ៥៦
*ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត* ........ ៥៧
IV. **ការអនុវត្តក្នុងទីផ្សារ / កិច្ចការពារអ្នកប្រើប្រាស់** ........ ៥៨
*ក. ទិដ្ឋភាពទូទៅ* ........ ៥៨
*ខ. វឌ្ឍនភាព និងសមិទ្ធផល* ........ ៥៩
*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ........ ៦១
*ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត* ........ ៦២

V. **គណនេយ្យ និងសវនកម្ម** ......... ៦៣
*ក. ទិដ្ឋភាពទូទៅ* ......... ៦៣
*ខ. វឌ្ឍនភាព និងសមិទ្ធផល* ......... ៦៤
*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ......... ៦៤
*ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត* ......... ៦៥
VI. **ច្បាប់ និងបទប្បញ្ញត្តិ** ......... ៦៦
*ក. ទិដ្ឋភាពទូទៅ* ......... ៦៦
*ខ. វឌ្ឍនភាព និងសមិទ្ធផល* ......... ៦៦
*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ......... ៦៧
*ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត* ......... ៦៧
VII. **ការិយាល័យឥណទានកម្ពុជា** ......... ៦៨
*ក. ទិដ្ឋភាពទូទៅ* ......... ៦៨
*ខ. វឌ្ឍនភាព និងសមិទ្ធផល* ......... ៦៩
*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ......... ៦៩
*ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត* ......... ៦៩
VIII. **ការធានាឥណទាន និងកិច្ចការពារអ្នកដាក់ប្រាក់បញ្ញើ** ......... ៧០
*ក. ទិដ្ឋភាពទូទៅ* ......... ៧០
*ខ. វឌ្ឍនភាព និងសមិទ្ធផល* ......... ៧១
*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ......... ៧២
*ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត* ......... ៧៣
IX. **បរធនបាលកិច្ច** ......... ៧៤
*ក. ទិដ្ឋភាពទូទៅ* ......... ៧៤
*ខ. វឌ្ឍនភាព និងសមិទ្ធផល* ......... ៧៥
*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ......... ៧៥
*ឃ. យុទ្ធសាស្ត្រ និងផែនការនាពេលអនាគត* ......... ៧៥
X. **ប្រព័ន្ធ និងស្តង់ដា** ......... ៧៦
*ក. ទិដ្ឋភាពទូទៅ* ......... ៧៦
*ខ. វឌ្ឍនភាព និងសមិទ្ធិផល* ......... ៧៦
*គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ* ......... ៧៨
*ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត* ......... ៧៩

XI. **សមាហរណកម្ម** ........ ៨១
*ក. សេចក្តីផ្តើម* ........ ៨១
*ខ. សមាហរណកម្មគោលនយោបាយសង្គម* ........ ៨២
*គ. ការធ្វើសមាហរណកម្មនៅក្នុងវិស័យ និងតំបន់* ........ ៨២
**ជំពូក ៥: ការកសាងសមត្ថភាព** ........ ៨៥
I. **ទិដ្ឋភាពទូទៅ** ........ ៨៥
II. **ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ** ........ ៨៦
III. **យុទ្ធសាស្ត្រ និងផែនការអនាគត** ........ ៨៦
**ជំពូក៦: ផែនការសកម្មភាពអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥** ........ ៨៧
I. **វិស័យធនាគារ** ........ ៨៧
*ក. ប្រតិបត្តិការធនាគារ* ........ ៨៧
*ខ. ប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ* ........ ៩១
*គ. ទីផ្សារអន្តរធនាគារ/រូបិយវត្ថុ* ........ ៩៣
*ឃ. ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ* ........ ៩៤
II. **វិស័យមិនមែនធនាគារ** ........ ៩៤
*ក. ទីផ្សារមូលធន* ........ ៩៤
*ខ. អន្តរការី និងអ្នកផ្តល់សេវាវិជ្ជាជីវៈជំនាញ* ........ ១០៥
*គ. វិស័យធានារ៉ាប់រង* ........ ១០៥
*ឃ. វិស័យសោធន (ប្រព័ន្ធគាំពារសង្គម)* ........ ១០៨
*ង. ការអភិវឌ្ឍអចលនវត្ថុ និងសេវាកម្មវាយតម្លៃអចលនវត្ថុ* ........ ១១៣
*ច. អាជីវកម្មទទួលបញ្ចាំ* ........ ១១៧
III. **គាំទ្រហេដ្ឋារចនាសម្ព័ន្ធ** ........ ១២១
*ក. ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម* ........ ១២១
*ខ. អភិបាលកិច្ច* ........ ១២៥
*គ. ការប្រព្រឹត្តទៅរបស់ទីផ្សារ/កិច្ចការពារអ្នកប្រើប្រាស់* ........ ១២៦
*ឃ. គណនេយ្យ និងសវនកម្ម* ........ ១២៦
*ង. ច្បាប់និងបទប្បញ្ញត្តិ* ........ ១៣០
*ច. ប្រព័ន្ធនិងស្តង់ដា* ........ ១៣៥
IV. **ការកសាងសមត្ថភាព** ........ ១៣៦
**ឧបសម្ព័ន្ធ** ........ ១៣៩

# អារម្ភកថា

ក្នុងរយៈពេលជាង ២ទសវត្សរ៍កន្លងមក ប្រទេសកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សម្រេចបាននូវវឌ្ឍនភាពគួរជាទីមោទនៈលើគ្រប់វិស័យ ជាពិសេស ការរក្សាបាននូវសន្តិភាពពេញលេញ ស្ថិរភាពនយោបាយរឹងមាំនិងកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាពក្នុងអត្រាជាមធ្យមជិត៨% ក្នុងមួយឆ្នាំ ដែលបានធ្វើឲ្យអត្រាភាពក្រីក្រថយចុះយ៉ាងលឿនពីជាង ៥៣% ក្នុងឆ្នាំ២០០៤ មកត្រឹម ១៣.៥% នៅឆ្នាំ២០១៤។ ការអភិវឌ្ឍយ៉ាងឆាប់រហ័សបាននាំកម្ពុជាឈានចូលទំព័រប្រវត្តិសាស្ត្រថ្មី ដោយប្រែក្លាយមុខមាត់ពីប្រទេសមានចំណូលទាបទៅជាប្រទេសមានចំណូលមធ្យម និងត្រូវបានធនាគារពិភពលោកចាត់ទុកជាប្រទេសក្នុងក្រុមឯតទគ្គករកំណើនទាំងប្រាំបីក្នុងពិភពលោក។ ទាំងនេះកើតចេញពីជម្រើសនិងការអនុវត្តគោលនយោបាយត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ក្នុងការបង្កបរិស្ថានអំណោយផលសម្រាប់វិស័យឯកជន និងការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចតាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុនិងគោលនយោបាយសារពើពន្ធប្រកបដោយភាពប្រុងប្រយ័ត្ន គួបផ្សំនឹងការអនុវត្តបានយ៉ាងខ្ជាប់ខ្ជួនតាមកម្មវិធីកំណែទម្រង់ស៊ីជម្រៅចាំបាច់នានាលើគ្រប់វិស័យ។

សមិទ្ធផលដ៏ត្រចះត្រចង់នេះ ក៏ឆ្លុះបញ្ចាំងពីការរួមចំណែកយ៉ាងសកម្មពីវិស័យហិរញ្ញវត្ថុដែលបាននិងកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគំនិតផ្តួចផ្តើមដ៏សំខាន់ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុដ៏ក្មេងខ្ចីរបស់កម្ពុជា ពោលគឺការអនុម័តនូវ "ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០០១-២០១០" កាលពីឆ្នាំ២០០១ និងធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រនេះជាបន្តបន្ទាប់ចំនួន២លើកទៅជា "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥" និង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០" ដើម្បីជាមគ្គុទ្ទេសក៍ចង្អុលផ្លូវសម្រាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុរយៈពេលវែង។

ក្នុងរយៈពេលនៃការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនេះ ប្រព័ន្ធហិរញ្ញវត្ថុមានវឌ្ឍនភាពជាច្រើនគួរឲ្យកត់សម្គាល់។ ជាក់ស្តែង វិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុបន្តមានកំណើនខ្ពស់ទាំងវិសាលភាពនិងទំហំប្រតិបត្តិការ ស្របពេលដែលវិស័យធានារ៉ាប់រងក៏មានការរីកចម្រើនជាលំដាប់ក្នុងការផ្តល់សេវាធានារ៉ាប់រងទូទៅ ធានារ៉ាប់រងលើយានយន្ត ធានារ៉ាប់រងអាយុជីវិត និងសេវាធានារ៉ាប់រងខ្នាតតូច។ ចំណែកឯផ្សារមូលបត្រកម្ពុជា ក៏ចាប់ផ្តើមដំណើរការនៅឆ្នាំ២០១២ និងកំពុងស្ថិតនៅក្នុងដំណាក់កាលអភិវឌ្ឍនិងកសាងសមត្ថភាព។ ការរីកចម្រើននៃហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ក្នុងនោះការធ្វើទំនើបកម្មប្រព័ន្ធទូទាត់ ការពង្រឹងក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ អភិបាលកិច្ច និងតម្លាភាព និងបណ្តាញសុវត្ថិភាពក្នុងវិស័យ ក៏បានគាំទ្រមួយចំណែកធំក្នុងការធ្វើឲ្យប្រព័ន្ធហិរញ្ញវត្ថុដំណើរការប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពផងដែរ។

ទន្ទឹមនឹងនេះ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ក៏ជួបប្រទះបញ្ហាប្រឈមដែលទាមទារឲ្យមានការដោះស្រាយនិងការដាក់ចេញនូវយុទ្ធសាស្ត្រថ្មីៗបន្ថែមទៀត ដើម្បីឲ្យស្របតាមការវិវត្តដ៏លឿននៃទីផ្សារហិរញ្ញវត្ថុនៅកម្ពុជា ការប្រែប្រួលនៃនិម្មាបនកម្មហិរញ្ញវត្ថុអន្តរជាតិ និងសន្ទុះនៃសមាហរណកម្មតំបន់និងសកល ក៏ដូចជាផ្អែកលើបទពិសោធ បញ្ហាប្រឈម និងមេរៀនថ្មីៗដែលបានជួបប្រទះក្នុងការអនុវត្តកន្លងមក។ ឈរលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលបានសម្រេចធ្វើបច្ចុប្បន្នកម្ម "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០" ទៅជា "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥" ដោយមានជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី។

យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ មានគោលដៅសម្រេចឲ្យបានប្រព័ន្ធហិរញ្ញវត្ថុមួយប្រកបដោយប្រសិទ្ធភាព ដោយផ្អែកលើគោលការណ៍ទីផ្សារ ហើយមានលក្ខណៈពិពិធភាព ភាពរឹងមាំ និងបរិយាបន្នដែលផ្តល់លទ្ធភាពទូលំទូលាយក្នុងការបំពេញតម្រូវការសេវាហិរញ្ញវត្ថុនៅក្នុងប្រទេស ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងប្រសិទ្ធភាព កាត់បន្ថយភាពក្រីក្រ បង្កើនចំណូលរបស់ប្រជាជន ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការធ្វើសមាហរណកម្មសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅក្នុងតំបន់។ រាជរដ្ឋាភិបាល ក៏ប្រកាន់យកភាពបត់បែនក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ ដើម្បីឆ្លើយតបនឹងការវិវត្តនៃស្ថានភាពបច្ចុប្បន្ននិងតម្រូវការជាក់ស្តែង។

ឯកសារ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥" នេះ ត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការនេះដែលមានសមាសភាពមកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ក្រុមការងារបច្ចេកទេស ជាសេនាធិការឲ្យគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ បានសហការជាមួយក្រុមបេសកកម្មនៃធនាគារអភិវឌ្ឍន៍អាស៊ី រៀបចំ ពិនិត្យ កែសម្រួល និងសម្រិតសម្រាំងយ៉ាងផ្ចិតផ្ចង់ប្រកបដោយការទទួលខុសត្រូវខ្ពស់ចាប់តាំងពីត្រីមាសទី៤ ឆ្នាំ២០១៥។ ក្នុងដំណើរការនៃការធ្វើបច្ចុប្បន្នកម្មនេះ ក៏មានការពិភាក្សាពិគ្រោះយោបល់យ៉ាងសកម្មជាមួយបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងៗ ដៃគូអភិវឌ្ឍ និងវិស័យឯកជនតាមរយៈកិច្ចប្រជុំដោយឡែកផង កិច្ចប្រជុំរួមផងជាច្រើនលើក និងសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈតាមអនុវិស័យនីមួយៗចំនួន ៥ដងផងដែរ សំដៅស្តាប់ និងប្រមូលនូវមតិយោបល់បន្ថែម ដើម្បីបំពេញឲ្យការរៀបចំឯកសារនេះកាន់តែគ្រប់ជ្រុងជ្រោយ និងជាពិសេសឆ្លុះបញ្ចាំងពីតម្រូវការជាក់ស្តែងរបស់វិស័យឯកជន។

ឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ នេះ ត្រូវបានគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុប្រជុំពិនិត្យ និងអនុម័តកាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ និង

ត្រូវបានដាក់ចូលទៅក្នុងកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងអនុម័តនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ ព្រមទាំងបានដាក់ឆ្លងទីស្តីការគណៈរដ្ឋមន្ត្រីប្រជុំអនុម័ត នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៦។

ជារួមដំណើរការរៀបចំឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ នេះ បានប្រព្រឹត្តទៅដោយរលូនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ពីក្រសួងស្ថាប័នពាក់ព័ន្ធ ជាពិសេស ក្រុមការងារបច្ចេកទេស។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងស្ថាប័នរបស់ រាជរដ្ឋាភិបាល ដែលបានខិតខំរួមចំណែកយ៉ាងសកម្មក្នុងការរៀបចំ សម្របសម្រួល និងផ្តល់ជាធាតុ ចូលចំពោះយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ របស់រាជរដ្ឋាភិបាលនេះ។

ជាថ្មីម្តងទៀត យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានផ្តល់ជំនួយបច្ចេកទេសសមស្រប ព្រមទាំងភាគីពាក់ព័ន្ធទាំងអស់ដែលបានចូលរួមរៀបចំ ឯកសារយុទ្ធសាស្ត្រ តាំងពីដើមរហូតដល់សម្រេចបានលទ្ធផលយ៉ាងល្អនាពេលនេះ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**អគ្គទេសាភិបាល**
**ធនាគារជាតិនៃកម្ពុជា**

ជា-ចាន់តូ

# សេចក្តីថ្លែងអំណរគុណ

រាជរដ្ឋាភិបាលកម្ពុជា សូមថ្លែងអំណរគុណចំពោះគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ព្រមទាំងក្រសួងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដែលបានចូលរួមចំណែកក្នុងការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ នេះ។

រាជរដ្ឋាភិបាល សូមថ្លែងអំណរគុណចំពោះធនាគារអភិវឌ្ឍន៍អាស៊ី និងក្រុមបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានផ្តល់ធាតុចូលទាំងផ្នែកបច្ចេកទេស និងយុទ្ធសាស្ត្រក្នុងការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥។

# អក្សរកាត់

| | | |
|---|---|---|
| ACCA | សមាគមគណនេយ្យករជំនាញ | Association of Chartered Certified Accountants |
| ACMF | វេទិកាទីផ្សារមូលធនអាស៊ាន | ASEAN Capital Markets Forum |
| ACU | អង្គភាពប្រឆាំងអំពើពុករលួយ | Anti-Corruption Unit |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី | Asian Development Bank |
| AEC | សហគមន៍សេដ្ឋកិច្ចអាស៊ាន | ASEAN Economic Community |
| AML | ការប្រឆាំងការសម្អាតប្រាក់ | Anti-Money Laundering |
| APG | ក្រុមអាស៊ីប៉ាស៊ីហ្វិកស្ដីពីការសម្អាតប្រាក់ | Asia/Pacific Group on Money Laundering |
| APN or AsiaPay | បណ្ដាញទូទាត់សងប្រាក់អាស៊ី | Asia Payment Network |
| ATM | ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ | Automated Teller Machine |
| BIS | ធនាគារសម្រាប់ការទូទាត់អន្តរជាតិ | Bank for International Settlements |
| BSRS | ប្រព័ន្ធរាយការណ៍ធនាគារសម្រាប់ការត្រួតពិនិត្យ | Bank Supervisory Reporting System |
| CAFIU | អង្គភាពស៊ើបការហិរញ្ញវត្ថុកម្ពុជា | Cambodian Financial Intelligence Unit |
| CFA | អ្នកវិភាគហិរញ្ញវត្ថុជំនាញ | Chartered Financial Analyst |
| CFT | ការប្រឆាំងហិរញ្ញប្បទានភេរវកម្ម | Combating the Financing of Terrorism |
| CISAA | ស្តង់ដារអន្តរជាតិនៃកម្ពុជាទាក់ទងនឹងសវនកម្ម និងការធានារ៉ាប់រង | Cambodian International Standards on Auditing and Assurance |
| CIFRS | ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា | Cambodian International Financial Reporting Standards |
| CPA | គណនេយ្យករជំនាញ | Certified Public Accountant |
| DB | របបសោធនកំណត់តាវកាលិក | Defined Benefit |
| DC | របបសោធនកំណត់ភាគទាន | Defined Contribution |
| DNFBPs | វិជ្ជាជីវៈនិងមុខរបរមិនមែនហិរញ្ញវត្ថុ | Designated Non-Financial Businesses and Professions |
| EFT | ការផ្ទេរមូលនិធិជាអេឡិចត្រូនិក | Electronic Funds Transfer |
| FATF | ក្រុមការងារសកម្មភាពហិរញ្ញវត្ថុ | Financial Action Task Force on Money Laundering |
| FRTI | គំនិតផ្ដួចផ្ដើមសម្រាប់ការបណ្ដុះបណ្ដាលដល់និយតករហិរញ្ញវត្ថុ | Financial Regulators Training Initiative |
| GDP | ផលិតផលក្នុងស្រុកសរុប | Gross Domestic Product |

| | | |
|---|---|---|
| IAC | សមាគមធានារ៉ាប់រងកម្ពុជា | Insurance Association of Cambodia |
| IOSCO | អង្គការអន្តរជាតិនៃគណៈកម្មការមូលបត្រ | International Organization of Securities Commissions |
| IPO | ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | Initial Public Offering |
| IVSC | ស្តង់ដាវាយតម្លៃរបស់ក្រុមប្រឹក្សាវាយតម្លៃអន្តរជាតិ | International Valuation Standards Council |
| KICPAA | វិទ្យាស្ថានគណនេយ្យករ និងសវនករជំនាញនៅកម្ពុជា | Kampuchea Institute of Certified Public Accountants and Auditors |
| MOU | អនុស្សរណៈយោគយល់គ្នា | Memorandum of Understanding |
| MPTC | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | Ministry of Post and Telecommunication |
| NAC | ក្រុមប្រឹក្សាជាតិគណនេយ្យ | National Accounting Council |
| NDTIs | គ្រឹះស្ថានមិនទទួលប្រាក់បញ្ញើ | Non Deposit Taking Institutions |
| NFV | បេឡាជាតិអតីតយុទ្ធជន | National Fund for Veterans |
| NSSF | បេឡាជាតិរបបសន្តិសុខសង្គម | National Social Security Fund |
| NSSFC | បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល | National Social Security Fund for Civil Servants |
| QIP | គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ | Qualified Investment Project |
| ROA | ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម | Return on Asset |
| ROE | ប្រាក់ចំណេញធៀបនឹងដើមទុន | Return on Equity |
| RTGS | ប្រព័ន្ធទូទាត់ដុលភ្លាមៗ | Real Time Gross Settlement |
| SMEs | សហគ្រាសធុនតូចនិងមធ្យម | Small and Medium-Sized Enterprises |
| SOEs | សហគ្រាសរដ្ឋ | State Owned Enterprises |
| WEL | គ្រឹះស្ថានអប់រំអូស្ត្រាលីពិភពលោក លីមីតធីត | World Education Australia Limited |

# ខ្លឹមសារសង្ខេប

I. **ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុកម្ពុជាឆ្នាំ២០០១-២០១០** កន្លងមក បានផ្តោតសំខាន់លើការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមួយដ៏រឹងមាំ និងផ្អែកលើយន្តការទីផ្សារ ដើម្បីពង្រឹងការកៀរគរ និងបែងចែកធនធានសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ នៅឆ្នាំ២០០៦ ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុកម្ពុជាឆ្នាំ២០០១-២០១០ ត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជា **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥**។ យុទ្ធសាស្ត្រនេះ ក៏ត្រូវបានធ្វើបច្ចុប្បន្នកម្មលើកទី២ នៅឆ្នាំ២០១១ ទៅជា **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**។

II. ដើម្បីឆ្លើយតបនឹងការវិវត្តរីកចម្រើននៃសេដ្ឋកិច្ចជាតិ និងស្របតាមការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោក និងតំបន់ រាជរដ្ឋាភិបាលបានសម្រេចធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រខាងលើជាលើកទី៣ ទៅជា **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥** ដោយដាក់ចេញនូវគោលដៅសម្រេចឲ្យបានប្រព័ន្ធហិរញ្ញវត្ថុមួយប្រកបដោយប្រសិទ្ធភាព ដោយផ្អែកលើគោលការណ៍ទីផ្សារ ហើយមានលក្ខណៈពិពិធភាព ភាពរឹងមាំ និងបរិយាបន្នដែលផ្តល់លទ្ធភាពទូលំទូលាយក្នុងការបំពេញតម្រូវការសេវាហិរញ្ញវត្ថុនៅក្នុងប្រទេស ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងប្រសិទ្ធភាព កាត់បន្ថយភាពក្រីក្រ បង្កើនចំណូលរបស់ប្រជាជន ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅក្នុងតំបន់។

III. យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ នេះ ឆ្លុះបញ្ចាំងពីសមិទ្ធផលផ្នែកសេដ្ឋកិច្ចរបស់កម្ពុជារហូតមកដល់បច្ចុប្បន្ន ព្រមទាំងវាយតម្លៃពីឧបសគ្គ និងបញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងដាក់ចេញជាផែនការសកម្មភាពសម្រាប់ពេលអនាគត។ យុទ្ធសាស្ត្រនេះធ្វើសំយោគនិងកំណត់គោលដៅអាទិភាពនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់អនុវិស័យនីមួយៗនៃប្រព័ន្ធហិរញ្ញវត្ថុ ដើម្បីធានាឲ្យយុទ្ធសាស្ត្រ និងផែនការសកម្មភាពទាំងនេះដើរស្របតាមទស្សនវិស័យរយៈពេលវែងរបស់វិស័យហិរញ្ញវត្ថុទាំងមូល។ ឯកសារនេះ ក៏ជាមគ្គុទ្ទេសក៍ដែលអនុញ្ញាតឲ្យដៃគូអភិវឌ្ឍអាចសម្របសម្រួលផ្តល់ការកសាងសមត្ថភាព និងជំនួយបច្ចេកទេសក្នុងទម្រង់ផ្សេងៗផងដែរ។

IV. ឯកសារយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើលទ្ធផល ក៏ដូចជាមេរៀន បទពិសោធ និងបញ្ហាប្រឈមក្នុងការអនុវត្តនាពេលកន្លងមក ហើយក៏ត្រូវបានរៀបចំឡើងឲ្យមានលក្ខណៈបត់បែនដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ច សង្គម និងនយោបាយនៅ

កម្ពុជា ក៏ដូចជាការវិវត្តនៃវិស័យហិរញ្ញវត្ថុ ការផ្លាស់ប្តូរ និងបញ្ហាប្រឈមនានាដែលជាលទ្ធផលនៃសន្ទុះសមាហរណកម្មកម្ពុជាទៅក្នុងទីផ្សារតំបន់ និងសកល។

## គ. សមិទ្ធផលសំខាន់ៗអនុវត្តបានក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយ

V. រាជរដ្ឋាភិបាល សម្រេចបានសមិទ្ធផលជាច្រើនក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយនេះ តាមរយៈការធ្វើកំណែទម្រង់ជាច្រើនជាបន្តបន្ទាប់។ សមិទ្ធផលសំខាន់ៗរួមមាន៖

- ការអនុម័តច្បាប់សំខាន់ៗទាក់ទងនឹងវិស័យពាណិជ្ជកម្មនិងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឲ្យរឹងមាំនិងផ្អែកលើយន្តការទីផ្សារ
- កំណែទម្រង់រចនាសម្ព័ន្ធវិស័យធនាគារនិងការពង្រឹងគ្រឹះស្ថានហិរញ្ញវត្ថុសំខាន់ៗ
- ការបង្កើតហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ដល់សកម្មភាពទីផ្សារហិរញ្ញវត្ថុ និងពង្រីកសេវាហិរញ្ញវត្ថុដល់ជនបទ
- ការបង្កើតនិងដាក់ឲ្យដំណើរការនូវវិស័យហិរញ្ញវត្ថុផ្សេងទៀត ដូចជា វិស័យមូលបត្រ ធានារ៉ាប់រងអាយុជីវិត សោធន ទទួលបញ្ចាំ និងវិស័យអចលនវត្ថុ
- ការអភិវឌ្ឍធនធានមនុស្សនិងការធ្វើឯកទេសកម្មជំនាញបច្ចេកទេស និង
- ការពង្រីកតួនាទីវិស័យហិរញ្ញវត្ថុ ដើម្បីកៀរគរធនធានហិរញ្ញវត្ថុក្នុងស្រុកសម្រាប់បំពេញតម្រូវការសេដ្ឋកិច្ចដែលកាន់តែរីកចម្រើនយ៉ាងឆាប់រហ័ស។

VI. ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានកន្លងមក យុទ្ធសាស្ត្រ២០១៦-២០២៥នេះ ក៏មានគោលដៅដោះស្រាយបញ្ហាប្រឈមសំខាន់ៗដូចជា៖

- ហានិភ័យនិងបញ្ហាប្រឈមពីកត្តាខាងក្រៅដែលអាចប៉ះពាល់ដល់សមិទ្ធផលសេដ្ឋកិច្ចជាតិបច្ចុប្បន្ន
- ហានិភ័យផ្ទៃក្នុងដែលកើតឡើងដោយសារភាពយឺតយ៉ាវក្នុងការធ្វើកំណែទម្រង់មួយចំនួនដែលអាចប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុ
- ការសម្របសម្រួលគោលនយោបាយ នៅមានកម្រិតដែលពន្យារពេលក្នុងការដោះស្រាយភាពខ្វះចន្លោះនៃក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្ថាប័នដើម្បីឲ្យស្របតាមការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យនេះ
- តម្រូវការជាបន្តបន្ទាប់ក្នុងការកសាងធនធានមនុស្សក្នុងវិស័យហិរញ្ញវត្ថុ និងការរក្សានូវការរីកចម្រើននេះ
- តម្រូវការក្នុងការធ្វើសុខដុមនីយកម្មក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធឲ្យស្របតាមការរីកចម្រើននៃវិស័យហិរញ្ញវត្ថុ និង

- តម្រូវការកិច្ចសហការពីអាជ្ញាធរពាក់ព័ន្ធ ដើម្បីជៀសវាងហានិភ័យប្រទាក់ក្រឡាដែលអាចជះឥទ្ធិពលដល់សេដ្ឋកិច្ចទាំងមូល។

## ខ. ការត្រៀមលក្ខណៈដោះស្រាយបញ្ហាប្រឈម

VII. ដើម្បីត្រៀមលក្ខណៈដោះស្រាយបញ្ហាប្រឈម ដែលអាចនឹងកើតមានឡើងក្នុងអំឡុងពេលនៃការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ ទាមទារនូវ៖

- ការយល់ដឹង ការត្រៀមលក្ខណៈ និងការសម្របសម្រួលដ៏ជិតស្និទ្ធរវាងភាគីពាក់ព័ន្ធសំខាន់ៗ
- ការតាមដានសមិទ្ធផលជាប្រចាំ និងការកំណត់បញ្ហាទាន់ពេលវេលា ដើម្បីដោះស្រាយជាបន្ទាន់ និងសមស្រប
- ការបែងចែកធនធានចាំបាច់សម្រាប់ទ្រទ្រង់ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ
- ការលើកកម្ពស់ភាពម្ចាស់ការរបស់អាជ្ញាធរពាក់ព័ន្ធលើផែនការយុទ្ធសាស្ត្រនេះ
- ការកំណត់ឲ្យបានច្បាស់ពីការទទួលខុសត្រូវ និងគណនេយ្យភាពរបស់ក្រសួងស្ថាប័នដែលអនុវត្តផែនការសកម្មភាព
- កិច្ចសហប្រតិបត្តិការរវាងស្ថាប័នអន្តរជាតិ និងដៃគូអភិវឌ្ឍដែលផ្តល់ជំនួយបច្ចេកទេស និងជំនួយក្នុងទម្រង់ផ្សេងៗតាមការចង្អុលទិសរបស់អាជ្ញាធរពាក់ព័ន្ធ និង
- ការរៀបចំមូលដ្ឋានរឹងមាំសម្រាប់ការអភិវឌ្ឍសមត្ថភាព។

VIII. បញ្ហាប្រឈមបន្ថែមទៀតដែលគួរចាប់អារម្មណ៍ រួមមាន៖

- ការសម្របតាមស្តង់ដាអន្តរជាតិក្នុងការត្រួតពិនិត្យដោយផ្អែកលើហានិភ័យ ស្របតាមការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ និងការពង្រឹងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរពាក់ព័ន្ធដើម្បីជួយសម្រួលដល់ការចែករំលែកព័ត៌មាន និងគ្រប់គ្រងវិបត្តិដែលអាចកើតមានឡើងប្រកបដោយប្រសិទ្ធភាព
- ការរៀបចំក្របខ័ណ្ឌស្ថាប័នសម្រាប់បញ្ញត្តិកម្ម និងត្រួតពិនិត្យវិស័យហិរញ្ញវត្ថុទាំងមូល ក៏ដូចជាការធ្វើបច្ចុប្បន្នកម្មក្របខ័ណ្ឌច្បាប់ជាធរមាន ទាមទាររយៈពេលច្រើនឆ្នាំដើម្បីទទួលបានការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ
- តម្រូវការពង្រឹងសមត្ថភាពបច្ចេកទេសជំនាញក្នុងវិស័យគន្លឹះ ដើម្បីឈានឲ្យទាន់ការកើនឡើងនៃភាពប្រទាក់ក្រឡាក្នុងវិស័យធនាគារ មូលបត្រ និងវិស័យធានារ៉ាប់រង ក៏ដូចជាការកើនឡើងហានិភ័យថ្មីៗដែលអាចគំរាមកំហែងដល់ស្ថិរភាពហិរញ្ញវត្ថុ
- តម្រូវការនូវជំនាញបច្ចេកទេសល្អ និងការត្រួតពិនិត្យដែលមានគុណភាព ព្រមទាំងការសម្របសម្រួលល្អដើម្បីវាយតម្លៃ និងដោះស្រាយហានិភ័យទីផ្សារ ហានិភ័យប្រតិបត្តិការ និងហានិភ័យសន្ទនីយភាពជាដើម

- ការបង្កើនការយល់ដឹងឲ្យបានស៊ីជម្រៅពីហានិភ័យ និងសមត្ថភាពក្នុងការធ្វើសុភវិនិច្ឆ័យសម្រាប់មន្ត្រីត្រួតពិនិត្យគ្រប់ថ្នាក់
- ការបង្កើតយន្តការលើកទឹកចិត្ត ដើម្បីរក្សាទុកមន្ត្រីជំនាញដែលទទួលបានការបណ្តុះបណ្តាលពីអាជ្ញាធរបញ្ញត្តិកម្មនានា ដើម្បីទប់ទល់នឹងតម្រូវការខ្ពស់ពីវិស័យឯកជន
- ការអនុវត្តតាមស្តង់ដាអន្តរជាតិ ដើម្បីធ្វើសុខដុមនីយកម្ម និងជំរុញសមាហរណកម្មប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ាន
- ការអនុវត្តបទប្បញ្ញត្តិនានាឲ្យមានប្រសិទ្ធភាព សំដៅពង្រឹងគុណភាពទិន្នន័យ តម្លាភាពអភិបាលកិច្ចសាជីវកម្ម ក្រមសីលធម៌វិជ្ជាជីវៈ ការបើកចំហព័ត៌មានចំពោះទីផ្សារ និងសាធារណជន និងការប្រកួតប្រជែងស្មើភាពក្នុងវិស័យហិរញ្ញវត្ថុ និង
- ការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិនៅក្នុងសេដ្ឋកិច្ច និងតាមដានហានិភ័យពាក់ព័ន្ធ។

## គ. គោលដៅនិងយុទ្ធសាស្រ្ត

IX. យុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥នេះ មានគោលដៅអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ដោយផ្អែកលើគោលការណ៍ទីផ្សារ ហើយមានលក្ខណៈពិពិធភាព ភាពរឹងមាំ និងបរិយាបន្នដែលផ្តល់លទ្ធភាពទូលំទូលាយក្នុងការបំពេញតម្រូវការសេវាហិរញ្ញវត្ថុនៅក្នុងប្រទេស ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងប្រសិទ្ធភាព បង្កើនចំណូលរបស់ប្រជាជន កាត់បន្ថយភាពក្រីក្រ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការធ្វើសមាហរណកម្មសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅក្នុងតំបន់។

X. ដើម្បីសម្រេចគោលដៅខាងលើនេះ រាជរដ្ឋាភិបាលនឹងតម្រូវឲ្យអាជ្ញាធរហិរញ្ញវត្ថុមានការកែសម្រួលនូវក្របខ័ណ្ឌស្ថាប័ន ដើម្បីសម្របតាមការវិវត្តថ្មីៗនៃវិស័យហិរញ្ញវត្ថុ។ ដោយសារប្រតិបត្តិការរវាងវិស័យធនាគារ វិស័យធានារ៉ាប់រង និងវិស័យមូលបត្រ មានភាពប្រទាក់ក្រឡាគ្នា អាជ្ញាធរហិរញ្ញវត្ថុត្រូវធានាឲ្យបាននូវការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព តាមរយៈការបង្កើតឲ្យមានយន្តការសហប្រតិបត្តិការរវាងអាជ្ញាធរពាក់ព័ន្ធ។

XI. រាជរដ្ឋាភិបាលនឹងរៀបចំឡើងវិញនូវក្របខ័ណ្ឌច្បាប់ជាធរមានទាំងឡាយដែលមានអសង្គតិភាពជាមួយគ្នា និងមិនទាន់ត្រឹមត្រូវតាមស្តង់ដាអន្តរជាតិ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏នឹងរៀបចំឲ្យមានយន្តការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ដើម្បីជៀសវាងភាពត្រួតគ្នានៃការគ្រប់គ្រង និងការត្រួតពិនិត្យនៅក្នុងវិស័យហិរញ្ញវត្ថុ។

XII. ក្របខ័ណ្ឌគ្រប់គ្រងវិបត្តិកំពុងត្រូវបានអភិវឌ្ឍនិងតម្រូវឲ្យមានការធ្វើតេស្តប្រចាំគ្រា ដើម្បីឲ្យស្របតាមស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា និងដោះស្រាយហានិភ័យថ្មីៗដែលអាចកើតមានឡើងពីការកើនឡើងនៃភាពប្រទាក់ក្រឡាគ្នានៅក្នុងវិស័យហិរញ្ញវត្ថុ។ ដោយសារកម្រិត

ដុល្លារូបនីយកម្មខ្ពស់ ការយកចិត្តទុកដាក់ខ្ពស់លើហានិភ័យជាប្រព័ន្ធពិតជាមានសារៈសំខាន់។ ការបង្កើតក្រុមការងារស្ថិរភាពហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា និងប្រព័ន្ធផ្តល់ព័ត៌មានជាមុននៅក្នុងប្រព័ន្ធធនាគារ នឹងរួមចំណែកកំណត់អត្តសញ្ញាណហានិភ័យនានា។ ចំណែកឯគណៈកម្មាធិការស្ថិរភាពហិរញ្ញវត្ថុថ្នាក់ជាតិ នឹងត្រូវបានបង្កើតឡើង។

XIII. ផ្អែកទៅលើគោលដៅរយៈពេលវែងរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ការបន្តអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្ន និងការអភិវឌ្ឍហេដ្ឋា-រចនាសម្ព័ន្ធគាំទ្រដល់ទីផ្សារពិតជាចាំបាច់នាទសវត្សរ៍ខាងមុខ។ ដោយសារឧបករណ៍រូបិយវត្ថុនៅមានកម្រិត ធនាគារជាតិនៃកម្ពុជាចាំបាច់ត្រូវអភិវឌ្ឍឧបករណ៍ថ្មីៗ កសាងសមត្ថភាពផ្ទៃក្នុង និងបង្កើនស្វ័យភាពក្នុងការរៀបចំ និងអនុវត្តគោលនយោបាយរូបិយវត្ថុ ដើម្បីធានាបាននូវស្ថិរភាពរូបិយវត្ថុ ស្ថិរភាពហិរញ្ញវត្ថុ និងកំណើនសេដ្ឋកិច្ច។

XIV. អនុវិស័យធនាគារនៅតែបន្តគ្របដណ្តប់ វិស័យហិរញ្ញវត្ថុទាំងមូល និងនៅតែជាផ្នែកមួយសំខាន់ក្នុងវិស័យ។ អាទិភាពក្នុងវិស័យធនាគារ រួមមាន ការរក្សាស្ថិរភាពរូបិយវត្ថុ ស្ថិរភាពហិរញ្ញវត្ថុ ការជំរុញបរិយាបន្នហិរញ្ញវត្ថុ និងការលើកកម្ពស់អនុលោមភាពតាមគោលការណ៍គ្រឹះរបស់គណៈកម្មាធិការបាសែលលើការត្រួតពិនិត្យធនាគារ។

XV. ចក្ខុវិស័យសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ គឺសំដៅជំរុញបរិយាបន្នហិរញ្ញវត្ថុ ដែលមានន័យថាជួយឲ្យប្រជាពលរដ្ឋក្រីក្រអាចទទួលបានសេវាហិរញ្ញវត្ថុក្នុងតម្លៃសមស្រប ដើម្បីបង្កើនចំណូល និងកាត់បន្ថយភាពក្រីក្រ។ គោលដៅនៅទសវត្សរ៍ខាងមុខ គឺបន្តអភិវឌ្ឍវិស័យនេះ ដើម្បីផ្តល់សេវាហិរញ្ញវត្ថុឲ្យកាន់តែទូលំទូលាយដល់ប្រជាពលរដ្ឋដែលមានចំណូលទាប។

XVI. យុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍវិស័យធានារ៉ាប់រង គឺបន្តអនុវត្តផែនការសកម្មភាពដែលមានចែងនៅក្នុងចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ ក៏ដូចជាបង្កើតផលិតផលថ្មីៗ និងពង្រីកការប្រើប្រាស់ផលិតផលដែលមានស្រាប់ ព្រមទាំងពង្រឹងបទប្បញ្ញត្តិ និងសមត្ថភាពត្រួតពិនិត្យស្របតាមឧត្តមានុវត្តភាព។

XVII. ទីផ្សារមូលបត្រដែលត្រូវបានដាក់ឲ្យដំណើរការជាផ្លូវការ កាលពីខែកក្កដា ឆ្នាំ២០១១ គឺជាចំណុចចាប់ផ្តើមមួយដ៏សំខាន់នៃយុទ្ធសាស្ត្រធ្វើពិពិធកម្មវិស័យហិរញ្ញវត្ថុ។ យុទ្ធសាស្ត្របច្ចុប្បន្នមានផែនការសកម្មភាពជាច្រើនដែលលើកទឹកចិត្តដល់ការចុះបញ្ជី និងដើម្បីសម្រេចបានសមិទ្ធផលច្រើននៅក្នុងទីផ្សារមូលបត្រ។ គណៈកម្មការមូលបត្រកម្ពុជាកំពុងបំពេញការងារឲ្យសម្រេចបានតាមគោលដៅកំណត់របស់វេទិកាទីផ្សារមូលធនអាស៊ាន និងកំពុងរៀបចំការវាយតម្លៃលើគោលការណ៍ស្នូលរបស់អង្គការអន្តរជាតិនៃគណៈកម្មការមូលបត្រ ក៏ដូចជាអនុវត្តជំហានបន្តបន្ទាប់ដើម្បីក្លាយជាសមាជិក។

XVIII. ប្រព័ន្ធទូទាត់និងផាត់ទាត់ បាននិងកំពុងអភិវឌ្ឍដើម្បីលើកកម្ពស់ការភ្ជាប់បណ្តាញ បង្កើនសេវាដល់អតិថិជន និងគាំទ្រដល់ប្រតិបត្តិការមូលបត្ររដ្ឋនាពេលអនាគត។ ការប្រើប្រាស់ស្តង់ដានិងប្រព័ន្ធរួម មានសារៈសំខាន់ក្នុងការកាត់បន្ថយការចំណាយ និងសម្របសម្រួលដល់ការអភិវឌ្ឍ។ បណ្ណូដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ បណ្ណឥណពន្ធ និងប្រព័ន្ធធនាគារតាមទូរស័ព្ទចល័ត និងតាមអ៊ីនធឺណិត កំពុងត្រូវបានដាក់ឲ្យប្រើប្រាស់។ ទន្ទឹមនេះ ដើម្បីធានាឲ្យបានឧត្តមានុវត្តភាព ធនាគារជាតិនៃកម្ពុជានឹងដាក់ឲ្យប្រើប្រាស់ប្រព័ន្ធទូទាត់ដុលភ្លាមៗ (RTGS) ផងដែរ។

XIX. ឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥នេះ ដាក់ចេញនូវផែនការសកម្មភាពក្នុងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងវិស័យធនាគារនិងវិស័យពាក់ព័ន្ធផ្សេងទៀត ដូចជា៖

- ការកសាងសមត្ថភាពដើម្បីធ្វើការតាមដាននិងត្រួតពិនិត្យគួបសរុប
- ការការពារប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុពីការប្រើប្រាស់ជាមធ្យោបាយសម្រាប់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង
- ការលើកកម្ពស់អភិបាលកិច្ចល្អ គុណភាពទិន្នន័យ ប្រព័ន្ធគណនេយ្យ និងសវនកម្ម ក៏ដូចជាការវាយតម្លៃលើអចលនទ្រព្យ សេវាកម្មអចលនទ្រព្យ និងទីផ្សារអចលនវត្ថុ។

XX. ជារួម យុទ្ធសាស្ត្រកំណែទម្រង់និងផែនការសកម្មភាពសម្រាប់វិស័យនីមួយៗ មានសារៈសំខាន់និងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ។ រាជរដ្ឋាភិបាលទទួលស្គាល់ថា ភាពយឺតយ៉ាវក្នុងការសម្រេចគោលដៅរបស់វិស័យណាមួយ នឹងអាចបង្អាក់ដល់ដំណើរការកំណែទម្រង់នៅក្នុងវិស័យផ្សេងទៀត។ យោងតាមបទពិសោធនៃការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុកន្លងមក ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរពាក់ព័ន្ធ ស្ថាប័នអន្តរជាតិ និងដៃគូអភិវឌ្ឍ គឺជាកត្តាសំខាន់ដើម្បីធានាឲ្យបានជោគជ័យក្នុងកំណែទម្រង់។ ការតាមដានជាទៀងទាត់ពីវឌ្ឍនភាពនៃកម្មវិធីកំណែទម្រង់ និងបញ្ហាប្រឈមថ្មីៗដែលកើតមានពីការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃទីផ្សារហិរញ្ញវត្ថុត្រូវធ្វើឡើងឲ្យទាន់ពេលវេលា និងមានផែនការសមស្រប។

# ជំពូក១
# ទិដ្ឋភាពទូទៅ

## I. សេចក្តីផ្តើម

**១-** ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច គឺការធានាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព បរិយាបន្ន និងសមធម៌ សំដៅលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រ ព្រមទាំងប្រែក្លាយមុខមាត់កម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ វិស័យហិរញ្ញវត្ថុដើរតួនាទីយ៉ាងសំខាន់ ក្នុងការគាំទ្រឲ្យមានការកៀរគរ និងបែងចែកធនធានហិរញ្ញវត្ថុសម្រាប់ទ្រទ្រង់សកម្មភាពសេដ្ឋកិច្ច។

**២-** ក្នុងស្មារតីនេះ ឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ គឺជាឯកសារយុទ្ធសាស្ត្រសម្រាប់បន្តអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុមួយដ៏មានប្រសិទ្ធភាព ផ្អែកតាមគោលការណ៍ទីផ្សារ ហើយមានភាពរឹងមាំ ពិពិធកម្មខ្ពស់ និងប្រកបដោយបរិយាបន្ន ដែលផ្តល់លទ្ធភាពកាន់តែទូលំទូលាយក្នុងការកៀរគរ និងបែងចែកធនធាន សំដៅទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ច ចូលរួមលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រ ព្រមទាំងឆ្លើយតបនឹងសមាហរណកម្មតំបន់ និងពិភពលោក។

**៣-** ក្នុងកំលុងពេលមួយទសវត្សរ៍ដែលបានដាក់ឲ្យអនុវត្តយុទ្ធសាស្ត្រនេះ កម្ពុជាសម្រេចបានសមិទ្ធផលដ៏ធំធេង ប៉ុន្តែទន្ទឹមនេះ ក៏មានបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលត្រូវដោះស្រាយ រួមមានការធ្វើពិពិធកម្មវិស័យហិរញ្ញវត្ថុ ការពង្រឹងបទប្បញ្ញត្តិ និងការត្រួតពិនិត្យឲ្យមានកម្រិតស្តង់ដាអន្តរជាតិ ការបង្កើតយន្តការដោះស្រាយវិបត្តិជាផ្លូវការ និងការជំរុញវិស័យហិរញ្ញវត្ថុឲ្យផ្តល់ហិរញ្ញប្បទាន និងសេវាហិរញ្ញវត្ថុតាមតម្រូវការរបស់ប្រជាជនដែលមានចំណូលទាប។ ឯកសារយុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដោយយោងតាមបទពិសោធ និងឯកសារដែលបានសិក្សាពីវិបត្តិហិរញ្ញវត្ថុអាស៊ានឆ្នាំ១៩៩៧-១៩៩៨ និងវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ២០០៨-២០០៩ ក៏ដូចជាពីការអនុវត្តយុទ្ធសាស្ត្រកន្លងមកក្នុងការធ្វើសមាហរណកម្មប្រទេសកម្ពុជាទៅក្នុងវិស័យហិរញ្ញវត្ថុតំបន់។

## II. ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច

**៤-** ឯកសារបច្ចុប្បន្នកម្មយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំក្នុងបរិបទសំខាន់ចំនួន៣៖ (១) ការអភិវឌ្ឍរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលជាង២ទសវត្សរ៍កន្លងមកប្រកបដោយសន្តិភាព ស្ថិរភាពនយោបាយ និងភាពប្រសើរឡើងនៃសុខុមាលភាពសង្គម (២) ការប្រែប្រួលនៃសេដ្ឋកិច្ចសកល ជាពិសេសក្រោយពីវិបត្តិសេដ្ឋកិច្ចសកលឆ្នាំ២០០៨-២០០៩ និង (៣) តម្រូវការឲ្យមានវិធីសាស្ត្រថ្មី ដើម្បីធានា

បានកំណើនសេដ្ឋកិច្ចលើគ្រប់វិស័យ ដែលក្នុងនោះ វិស័យហិរញ្ញវត្ថុដើរតួនាទីគន្លឹះក្នុងការគាំទ្រ និងធ្វើសមាហរណកម្មវិស័យទាំងនោះ។

**៥-** ចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ៩០ នៅពេលមានសន្តិភាពពេញលេញបន្ទាប់ពីសង្គ្រាម និងភាពឯកោជាច្រើនទសវត្សរ៍ កម្ពុជាសម្រេចបាននូវវឌ្ឍនភាពសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ ប្រជាជនកម្ពុជាទូទាំងប្រទេសមានមោទនភាព និងការជឿជាក់លើខ្លួនឯងឡើងវិញ ព្រមទាំងមានទស្សនវិស័យចំពោះអនាគតថ្មីដ៏រុងរឿង រួមមានការងារដ៏ល្អ និងកម្រិតជីវភាពរស់នៅល្អប្រសើរដែលទទួលបានពីផលនៃការអភិវឌ្ឍសេដ្ឋកិច្ច។ យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលដើម្បីសម្រេចទស្សនវិស័យនេះ ជាពិសេស តាមរយៈការលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងតំបន់ និងលើឆាកអន្តរជាតិ។

**៦-** ក្នុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាត្រូវបានចាត់ទុកជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ជាងគេក្នុងពិភពលោក។ សេដ្ឋកិច្ចជាតិបានងើបឡើងយ៉ាងឆាប់រហ័សក្រោយពីវិបត្តិសេដ្ឋកិច្ចសកលឆ្នាំ២០០៨-២០០៩ និងបានក្លាយជាប្រទេសដែលទទួលការទាក់ទាញពីវិនិយោគិន។ សមិទ្ធផលសេដ្ឋកិច្ចនេះ កើតចេញពីការអភិវឌ្ឍរីកចម្រើនយ៉ាងឆាប់រហ័សនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលត្រូវបានកសាងចាប់តាំងពីការបោះឆ្នោតសកលឆ្នាំ១៩៩៣ មក។ រាជរដ្ឋាភិបាល បានអនុវត្តកម្មវិធីកំណែទម្រង់ទ្រង់ទ្រាយធំលើគ្រប់វិស័យ ដើម្បីសម្រេចបាននូវគោលដៅសេរីភាវូបនីយកម្មសេដ្ឋកិច្ច និងផ្តល់គោលនយោបាយលើកទឹកចិត្ត ដើម្បីជំរុញឲ្យមានការវិនិយោគទាំងក្នុងស្រុក និងបរទេសក្នុងវិស័យឯកជន។ សេដ្ឋកិច្ចជាតិ ដែលពីមុនពឹងផ្អែកតែលើវិស័យកសិកម្ម ក្នុងពេលបច្ចុប្បន្ន ត្រូវបានគាំទ្របន្ថែមដោយវិស័យសេវាកម្ម និងឧស្សាហកម្ម។

**៧-** ចាប់តាំងពីឆ្នាំ១៩៩៩មក រាជរដ្ឋាភិបាលបានផ្តោតកិច្ចខិតខំប្រឹងប្រែងក្នុងការពន្លឿនការអភិវឌ្ឍវិស័យឯកជនផ្អែកលើគោលការណ៍ទីផ្សារ និងបានទទួលលទ្ធផលល្អគួរឲ្យកត់សម្គាល់។ ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចនូវកំណើនសេដ្ឋកិច្ចគួរជាទីមោទនៈ គឺក្នុងរង្វង់៧,៧% ដែលគាំទ្រមួយផ្នែកធំដោយវិស័យកាត់ដេរ អចលទ្រព្យ សំណង់ ដឹកជញ្ជូន និងគមនាគមន៍ ពាណិជ្ជកម្មក្នុងស្រុក និងទេសចរណ៍។ រាជរដ្ឋាភិបាលបានវិនិយោគជាច្រើនលើហេដ្ឋា-រចនាសម្ព័ន្ធ ដែលធ្វើឲ្យវិនិយោគផ្ទាល់បរទេសកើនឡើងគួរឲ្យកត់សម្គាល់។ ការគ្រប់គ្រងម៉ាក្រូ-សេដ្ឋកិច្ច តាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុ និងសារពើពន្ធប្រកបដោយភាពប្រុងប្រយ័ត្នគួបផ្សំនឹងការធ្វើកំណែទម្រង់វិស័យហិរញ្ញវត្ថុ បានរួមចំណែកក្នុងការសម្រេចបាននូវសមិទ្ធផលសេដ្ឋកិច្ចទាំងនេះ។

**៨-** កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការធ្វើសមាហរណកម្មក្នុងតំបន់ ក៏បានរួមចំណែកដល់កំណើនសេដ្ឋកិច្ចខ្ពស់ នៅក្នុងទសវត្សរ៍កន្លងមកផងដែរ។ ប៉ុន្តែស្របពេលជាមួយគ្នានេះដែរ កម្ពុជា

នៅតែប្រឈមនឹងការប្រកួតប្រជែងកាន់តែស្វិតស្វាញនៅក្នុងទីផ្សារសកល ជាពិសេស ជាមួយប្រទេសជិតខាងដែលមានសេដ្ឋកិច្ចខ្លាំងជាង។ ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់ប្រទេសជាដៃគូប្រកួតប្រជែងកម្ពុជា និងការចំណាយខ្ពស់ក្នុងធុរកិច្ចនៅកម្ពុជា ជាពិសេសថ្លៃអគ្គិសនី និងសេវាដឹកជញ្ជូននៅបន្តជាឧបសគ្គដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ ដើម្បីរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់សំដៅកាត់បន្ថយភាពក្រីក្រ កម្ពុជាត្រូវបន្តខិតខំប្រឹងប្រែង ដើម្បីដោះស្រាយបញ្ហាប្រឈមគន្លឹះៗរបស់សេដ្ឋកិច្ច ពោលគឺការធ្វើពិពិធកម្មសេដ្ឋកិច្ចទាំងផលិតផលនិងទីផ្សារនាំចេញ ការលើកកម្ពស់ផលិតភាព ការធ្វើសមាហរណកម្មចូលទៅខ្សែចង្វាក់តម្លៃនិងផលិតកម្មសកល ក៏ដូចជាការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍទាំងអស់ ដើម្បីរក្សាឲ្យបាននូវសមត្ថភាពប្រកួតប្រជែងក្នុងការទាក់ទាញវិនិយោគិនបរទេស។ ក្នុងគោលដៅនេះ ការលើកកម្ពស់ប្រព័ន្ធហិរញ្ញវត្ថុឲ្យមានកម្រិតស្តង់ដាអន្តរជាតិ គឺជាការងារចាំបាច់ដើម្បីទាញយកផលចំណេញជាសក្តានុពលពីចរន្តនៃសកលភាវូបនីយកម្ម។

**៩-** ចំពោះសេដ្ឋកិច្ចកម្ពុជា ដែលមានកម្រិតដុល្លារូបនីយកម្មខ្ពស់ គោលនយោបាយសារពើពន្ធដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច។ នៅចន្លោះឆ្នាំ១៩៩៥-១៩៩៨ កម្ពុជាធ្លាប់ជួបប្រទះបញ្ហាអតិផរណាខ្ពស់ដល់១៤,៧% នៅឆ្នាំ១៩៩៨ ដែលកើតឡើងដោយសារកត្តាខាងក្រៅ និងឱនភាពថវិកាខ្ពស់។ ការអនុវត្តវិន័យថវិកាជាតិបានជួយរួមចំណែករក្សាអតិផរណាឲ្យមានកម្រិតទាប និងជៀសពីវិបត្តិសេដ្ឋកិច្ចតាមរយៈការធ្វើវិចារណកម្មចំណាយ កិច្ចខិតខំប្រឹងប្រែងកៀរគរប្រមូលចំណូលការលុបបំបាត់ការធ្វើហិរញ្ញប្បទានឱនភាពថវិកាពីធនាគារជាតិនៃកម្ពុជា និងការស្វែងរកហិរញ្ញប្បទានពីកម្ចីសម្បទាន ជាពិសេសលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់។ តាមរយៈគោលនយោបាយទាំងនេះ ការគ្រប់គ្រងបំណុលសាធារណៈរបស់កម្ពុជាសម្រេចបាននូវសមិទ្ធផលគួរជាទីពេញចិត្ត។ ផ្អែកតាមលទ្ធផលនៃការវិភាគចីរភាពបំណុល ស្ថានភាពបំណុលសាធារណៈរបស់កម្ពុជាបច្ចុប្បន្នមានចីរភាព និងហានិភ័យកម្រិតទាប។ លទ្ធផលនេះក៏ត្រូវបានវាយតម្លៃនិងទទួលស្គាល់ដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ីផងដែរ។ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលបាននិងកំពុងអនុវត្តកន្លងមក គឺជាឧបករណ៍សំខាន់មួយសម្រាប់ធ្វើទំនើបកម្ម និងលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយសារពើពន្ធ។

**១០-** ចំណែកឯគោលនយោបាយរូបិយវត្ថុមានគោលដៅចម្បង គឺរក្សាស្ថិរភាពថ្លៃ សំដៅរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ដើម្បីសម្រេចគោលដៅនេះ ធនាគារជាតិនៃកម្ពុជាបានអនុវត្តគោលនយោបាយរូបិយវត្ថុដោយធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់ កំណត់ប្រាក់បម្រុងកាតព្វកិច្ចលើគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដើម្បីគ្រប់គ្រងលើកម្រិតសន្ទនីយភាពរបស់វិស័យធនាគារនិងហិរញ្ញវត្ថុទាំងមូល និងជំរុញការប្រើប្រាស់ប្រាក់រៀល។ សេដ្ឋកិច្ចកម្ពុជាងាយទទួលរងឥទ្ធិពលពីកត្តាខាងក្រៅ ដោយសារកម្ពុជាជាប្រទេសនាំចូលផលិតផលប្រើប្រាស់ដូចជា ប្រេងឥន្ធនៈ ហើយទីផ្សារប្តូរប្រាក់នៅមិនទាន់អភិវឌ្ឍ។ ស្ថិតក្រោមរបបរូបិយវត្ថុបច្ចុប្បន្ន

ការប្រែប្រួលនៃអត្រាប្តូរប្រាក់ និងថ្លៃទំនិញលើទីផ្សារអន្តរជាតិមានផលប៉ះពាល់ភ្លាមៗដល់ថ្លៃទំនិញក្នុងស្រុកនិងសេដ្ឋកិច្ចជាតិ។

**១១-** កម្ពុជាប្រកាន់យករបបអត្រាប្តូរប្រាក់ដែលមានលក្ខណៈស្ថិរភាព (Stabilized Exchange Rate Regime) ដែលបានផ្តល់លក្ខណៈល្អប្រសើរដល់ការគរពូនទុនបម្រុងអន្តរជាតិ។ ក្នុងបរិការណ៍នៃសេដ្ឋកិច្ចដុល្លារូបនីយកម្មខ្ពស់ ធនាគារជាតិនៃកម្ពុជា មិនទាន់មានឧបករណ៍គោលនយោបាយរូបិយវត្ថុគ្រប់គ្រាន់នៅឡើយទេ ក្រៅពីការកំណត់អត្រាប្រាក់បម្រុងកាតព្វកិច្ច និងអន្តរាគមន៍លើទីផ្សារប្តូរប្រាក់។

**១២-** ដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចដែលជាកត្តាចាំបាច់ក្នុងការគ្រាំទ្រ និងរក្សាកំណើនសេដ្ឋកិច្ចទាមទារឲ្យមានការសម្របសម្រួលរវាងគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយសារពើពន្ធ។ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តគោលនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន គួបផ្សំនឹងការអនុវត្តវិន័យថវិកាជាតិ។

## III. វិស័យហិរញ្ញវត្ថុ

**១៣-** លើកលែងតែធនាគារអភិវឌ្ឍន៍ជនបទ គ្រឹះស្ថានធនាគារនៅកម្ពុជា គឺជាកម្មសិទ្ធិឯកជន និងមានភាគទុនិកភាគច្រើនជាបរទេស។ វិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា បន្តមានកំណើនខ្ពស់ក្នុងរយៈពេល១៥ឆ្នាំចុងក្រោយនេះ។ ចំណែកឯទីផ្សារមូលបត្រកម្ពុជាក៏បានចាប់ផ្តើមដំណើរការនៅឆ្នាំ២០១២ ស្របពេលដែលវិស័យធានារ៉ាប់រងមានការរីកចម្រើនជាលំដាប់ក្នុងការផ្តល់សេវាធានារ៉ាប់រងទូទៅ ធានារ៉ាប់រងជីវិត ធានារ៉ាប់រងលើយានយន្ត និងសេវាធានារ៉ាប់រងខ្នាតតូច។ ការធ្វើទំនើបកម្មប្រព័ន្ធទូទាត់ជាតិ បានជួយឲ្យទីផ្សារធនាគារតាមប្រព័ន្ធធនាគារចល័ត និងការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក និងសេវាចេញផ្សាយរូបិយវត្ថុជាអេឡិចត្រូនិកមានការរីកចម្រើន។ ចំណែកឯវិស័យសោធន និងភតិសន្យាត្រូវបានរំពឹងថានឹងមានកំណើនប្រសើរក្នុងរយៈពេល១០ឆ្នាំ ទៅមុខទៀត។

## IV. រចនាសម្ព័ន្ធ និងការរៀបចំឯកសារយុទ្ធសាស្ត្រ

**១៤-** ការរៀបចំឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ នេះ មានការពិគ្រោះយោបល់យ៉ាងទូលំទូលាយរវាងក្រសួងស្ថាប័នពាក់ព័ន្ធ រួមមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក្រសួងពាណិជ្ជកម្ម គណៈកម្មការមូលបត្រកម្ពុជា ក្រសួងយុត្តិធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ ក៏ដូចជា ជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនមូលបត្រ និងអង្គការក្រៅរដ្ឋាភិបាល។ ដៃគូអភិវឌ្ឍន៍

សំខាន់ៗ រួមមាន ធនាគារអភិវឌ្ឍន៍អាស៊ី សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ មូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក ក៏បានចូលរួមពិគ្រោះយោបល់ផងដែរ។

**១៥-** ទិន្នន័យដែលប្រើប្រាស់ ដើម្បីរៀបចំឯកសារយុទ្ធសាស្រ្តនេះ ទទួលបានពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ និងគណៈកម្មការមូលបត្រកម្ពុជា ព្រមទាំងទទួលបានពីស្ថាប័នពាក់ព័ន្ធផ្សេងទៀតនៅក្នុងវិស័យហិរញ្ញវត្ថុ។ ធាតុចូលសម្រាប់យកមកវិភាគ និងរៀបចំឯកសារយុទ្ធសាស្រ្តនេះរួមមាន ឯកសារពិគ្រោះយោបល់មាត្រា៤ រវាងរាជរដ្ឋាភិបាល និងមូលនិធិរូបិយវត្ថុអន្តរជាតិ។ លើសពីនេះ សិក្ខាសាលាពិគ្រោះយោបល់មួយចំនួនត្រូវបានរៀបចំឡើងជាមួយអ្នកចូលរួមក្នុងទីផ្សារហិរញ្ញវត្ថុ ដើម្បីផ្តល់ធាតុចូលក្នុងការរៀបចំសេចក្តីព្រាងឯកសារយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ នេះ។

**១៦-** យុទ្ធសាស្រ្តជារួម និងផែនការសកម្មភាពសម្រាប់កំណែទម្រង់មួយផ្នែកធំមានភាពប្រទាក់ក្រឡាគ្នា។ ដំណើរការ និងការពង្រឹងគោលនយោបាយកំណែទម្រង់ទាមទារឲ្យមានពេលវេលាកំណត់មួយសមស្រប។ ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរដែលមានសមត្ថកិច្ច អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍ គឺជាកត្តាចាំបាច់សំខាន់ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ប្រកបដោយប្រសិទ្ធភាព និងទទួលបានជោគជ័យ ។

**១៧-** យុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ ត្រូវបានរៀបចំដូចខាងក្រោម៖

- ជំពូក១ : ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច
- ជំពូក២ : វិស័យធនាគារដែលរួមមានវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុ
- ជំពូក៣ : វិស័យហិរញ្ញវត្ថុមិនមែនធនាគារដែលរួមមានទីផ្សារមូលបត្រ ធានារ៉ាប់រង និងសោធន
- ជំពូក៤ : អភិបាលកិច្ចនិងក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធវិស័យហិរញ្ញវត្ថុ គណនេយ្យនិងសវនកម្ម និងប្រព័ន្ធទូទាត់
- ជំពូក៥ : ការកសាងសមត្ថភាពនិង
- ជំពូក៦ : ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥។

# ជំពូក ២
# វិស័យធនាគារ

## I. ប្រតិបត្តិការធនាគារ

### ក. ទិដ្ឋភាពទូទៅ

**១៨-** ធនាគារជាតិនៃកម្ពុជា គឺជាអាជ្ញាធររូបិយវត្ថុ និងអាជ្ញាធរត្រួតពិនិត្យលើប្រតិបត្តិការធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា។ បេសកកម្មចម្បងរបស់ខ្លួនគឺកំណត់និងដឹកនាំគោលនយោបាយរូបិយវត្ថុ ក្នុងគោលដៅរក្សាឲ្យបាននូវស្ថិរភាពថ្លៃ និងសំដៅបង្កលក្ខណៈងាយស្រួល ដើម្បីឲ្យសេដ្ឋកិច្ចរីកចម្រើន។ មុខងារសំខាន់ៗរបស់ធនាគារជាតិនៃកម្ពុជា មានដូចតទៅ: (១) ជាអាជ្ញាធររូបិយវត្ថុនិងអនុវត្តគោលនយោបាយរូបិយវត្ថុ (នៅពេលដែលចាំបាច់ធនាគារជាតិនៃកម្ពុជាអាចធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ដើម្បីធានាឲ្យមានស្ថិរភាពអត្រាប្តូរប្រាក់ និងធានាបានស្ថិរភាពថ្លៃ) (២) ទទួលភារៈផ្តាច់មុខជាអ្នកបោះផ្សាយរូបិយវត្ថុជាតិ (៣) ជាអាជ្ញាធរត្រួតពិនិត្យប្រព័ន្ធទូទាត់ និង (៤) ជាអាជ្ញាធរត្រួតពិនិត្យប្រព័ន្ធធនាគារ។

**១៩-** នៅពេលដែលយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ ត្រូវបានចាប់ផ្តើមអនុវត្តនាឆ្នាំ២០១១ ធនាគារពាណិជ្ជមានចំនួន៣១ (ដែលក្នុងនោះ ធនាគារ ៦ ជាសាខាធនាគារបរទេស)។ គិតត្រឹមចុងឆ្នាំ២០១៥ ធនាគារពាណិជ្ជមានចំនួន៣៦ (ក្នុងនោះធនាគារ ១១ ជាសាខាធនាគារបរទេស)។ ក្នុងកំលុងពេលដូចគ្នានេះដែរ ចំនួនធនាគារឯកទេស ក៏មានការកើនឡើងពី ៧ ដល់១២។ ចំនួនម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) កើនឡើងពី៥៨៨ ទៅ១.១១៨ និងបណ្ណឥណពន្ធកើនឡើងពី ៧៦១.៨៧៦ ទៅ ១.៤៣៩.៨៨៧។ អនុបាតឥណទានមិនដំណើរការនៅតែរក្សាបានក្នុងកម្រិតទាបជាមធ្យម២,០% ក្នុងឆ្នាំ២០១៥។ ចំពោះស្ថានភាពប្រាក់ចំណេញរបស់ធនាគារ ក៏មានភាពល្អប្រសើរ។ ជាក់ស្តែងសម្រាប់ឆ្នាំ២០១៥ ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម (Return on asset) គឺស្មើ២,០% និងប្រាក់ចំណេញធៀបនឹងដើមទុន(Return on equity) មាន១០,៩%។

**២០-** ទ្រព្យសកម្មសរុបនៅក្នុងប្រព័ន្ធធនាគារបានកើនឡើងពី៧,៩ប៊ីលានដុល្លារអាមេរិកគិតត្រឹមដំណាច់ឆ្នាំ២០១១(ស្មើ៦០% នៃផលិតផលក្នុងស្រុកសរុប [ផ.ស.ស.]) ដល់ ១៩,៩ ប៊ីលានដុល្លារអាមេរិក គិតត្រឹមដំណាច់ឆ្នាំ២០១៥ (ប្រមាណ១១០% នៃផ.ស.ស.)។ ទន្ទឹមនឹងនោះ ប្រាក់បញ្ញើអតិថិជនសរុបធៀបផ.ស.ស. ក៏មានកំណើនដូចគ្នាដែរ ពោលគឺកើនឡើងពី៤១%នៅឆ្នាំ២០១១ ទៅដល់៦២% នៅដំណាច់ឆ្នាំ២០១៥។

## ខ. វឌ្ឍនភាពនិងសមិទ្ធផល

**២១-** ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ និងអាជ្ញាធរត្រួតពិនិត្យលើគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ បានចូលរួមយ៉ាងសកម្មក្នុងការរក្សាស្ថិរភាពហិរញ្ញវត្ថុ តាមរយៈការធ្វើឲ្យប្រសើរឡើងនូវភាពរឹងមាំនិងប្រសិទ្ធភាពនៃវិស័យធនាគារ។ ធនាគារជាតិនៃកម្ពុជា តែងតែពង្រឹងបទប្បញ្ញត្តិនិងការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាប់ជាប្រចាំ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ និងតម្លាភាពនៅក្នុងប្រព័ន្ធធនាគារ និងពង្រឹងការកសាងសមត្ថភាពធនធានមនុស្សជាប្រចាំ។

**២២-** ចាប់តាំងពីកម្រងច្បាប់ និងបទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានធ្វើបច្ចុប្បន្នកម្មក្នុងឆ្នាំ២០១១ មក បទប្បញ្ញត្តិមួយចំនួនត្រូវបានដាក់ឲ្យអនុវត្ត និងបទប្បញ្ញត្តិមួយចំនួនត្រូវបានកែសម្រួលឡើងវិញ ស្របតាមការអភិវឌ្ឍនៃវិស័យធនាគារ និងស្របតាមស្តង់ដាអន្តរជាតិជាពិសេស ក្របខ័ណ្ឌបទប្បញ្ញត្តិរបស់គណៈកម្មាធិការបាសែល។ បទប្បញ្ញត្តិទាំងនេះចែងអំពីបទប្បញ្ញត្តិប្រុងប្រយ័ត្នសម្រាប់គាំទ្រក្របខ័ណ្ឌបទប្បញ្ញត្តិត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា និងពង្រឹងស្ថិរភាពហិរញ្ញវត្ថុក្នុងនោះ ដូចជា ប្រកាសស្តីពីការផ្តល់សន្ទនីយភាពចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ប្រកាសស្តីពីការផ្តល់សន្ទនីយភាពចំពោះសមាជិកសភាផាត់ទាត់ជាតិ ប្រកាសស្តីពីអនុបាតក្របខ័ណ្ឌសន្ទនីយភាព និងប្រកាសស្តីពីដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**២៣-** ចំពោះការត្រៀមទប់ទល់វិបត្តិនិងការគ្រប់គ្រងវិបត្តិ ធនាគារជាតិនៃកម្ពុជាសម្រេចបានស្នាដៃសំខាន់ៗជាច្រើនក្នុងរយៈកាល៥ឆ្នាំចុងក្រោយ ដូចជា ការបង្កើតប្រព័ន្ធផ្តល់សញ្ញាជាមុន (Early Warning System) និងការបង្កើតក្រុមការងារស្ថិរភាពហិរញ្ញវត្ថុ។ ធនាគារជាតិនៃកម្ពុជា ក៏បានសិក្សាជាប្រចាំលើការវិភាគហានិភ័យ និងអនុវត្តការធ្វើស្ត្រេសតេស្ត ដោយផ្អែកតាមកម្មវិធីវាយតម្លៃវិស័យហិរញ្ញវត្ថុរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ។ ទន្ទឹមនឹងការដាក់ឲ្យអនុវត្តប្រកាសស្តីពីអនុបាតក្របខ័ណ្ឌសន្ទនីយភាព ធនាគារជាតិនៃកម្ពុជា កំពុងតែរៀបចំប្រកាសមួយផ្សេងទៀតទាក់ទងនឹងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាព សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ជាងនេះទៅទៀតធនាគារជាតិនៃកម្ពុជា ក៏បានពង្រឹងតួនាទីរបស់ខ្លួនជាអ្នកឲ្យខ្ចីចុងក្រោយ តាមរយៈការដាក់ឲ្យអនុវត្តនូវប្រកាសស្តីពីការផ្តល់សន្ទនីយ-ភាពចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ប្រកាសនេះមានគោលបំណងបង្ការជាមុននូវហានិភ័យជាប្រព័ន្ធ ដែលអាចនាំឲ្យមានវិបត្តិសន្ទនីយភាពកើតឡើងដោយសារនិន្នាការថ្លៃ ឬស្ថានភាពទីផ្សារប្រែប្រួលខ្លាំង និងមិនអាចព្យាករទុកជាមុនបាន។

**២៤-** ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មការមូលបត្រកម្ពុជាបានបង្កើតក្រុមការងារមួយក្នុងគោលដៅផ្តួចផ្តើមឲ្យមានយន្តការគ្រប់គ្រងវិបត្តិក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា និងបានកំណត់កត្តាគន្លឹះនានា ក្នុងការចាប់ផ្តើមអនុវត្តយន្តការគ្រប់គ្រងវិបត្តិរួចរាល់ផងដែរ។

នៅឆ្នាំ២០១៤ ស្ថាប័នទាំង៣នេះ បានចុះអនុស្សរណៈយោគយល់គ្នា ដើម្បីផ្លាស់ប្តូរព័ត៌មាននានាទាក់ទងនឹងការត្រៀមខ្លួនទប់ទល់នឹងវិបត្តិ។

**២៥-** ក្នុងឆ្នាំ២០១១ ធនាគារជាតិនៃកម្ពុជា បានបង្កើតគណៈកម្មការស្ថិរភាពហិរញ្ញវត្ថុ និងក្រុមការងារស្ថិរភាពហិរញ្ញវត្ថុ ដើម្បីតាមដាន និងវាយតម្លៃហានិភ័យនានាក្នុងវិស័យហិរញ្ញវត្ថុ និងផ្តល់អនុសាសន៍ជាគោលនយោបាយ ដើម្បីបង្ការហានិភ័យជាប្រព័ន្ធ និងរក្សាស្ថិរភាពហិរញ្ញវត្ថុ។ វិសាលភាពនៃការវិភាគត្រូវបានពង្រីកបន្តិចម្តងៗ មិនត្រឹមតែលើវិស័យធនាគារប៉ុណ្ណោះទេ ថែមទាំងទៅលើវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។

**២៦-** គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានអាជ្ញាបណ្ណទាំងអស់ បញ្ជូនទិន្នន័យ និងរបាយការណ៍នានាទៅក្នុងប្រព័ន្ធរាយការណ៍ធនាគារសម្រាប់ការត្រួតពិនិត្យ (BSRS) ជាប្រចាំ។ ធនាគារជាតិនៃកម្ពុជា កំពុងរៀបចំសៀវភៅណែនាំ សម្រាប់គ្រប់គ្រងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានបញ្ហា និងមិនអាចសងបំណុលបាន និងបទប្បញ្ញត្តិស្តីពីនីតិវិធីនៃវិធានការត្រួតពិនិត្យ។

**២៧-** ដោយមានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី ប្រព័ន្ធផាត់ទាត់ជាតិត្រូវបានដាក់ឲ្យដំណើរការនៅឆ្នាំ២០១២។ ជាងនេះទៅទៀត ធនាគារជាតិនៃកម្ពុជាបានទទួលជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍនានា ដូចជាធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិរូបិយវត្ថុអន្តរជាតិ មជ្ឈមណ្ឌលស៊ាសិន រតនាគារអាមេរិក និងធនាគារពិភពលោក។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានបន្តកិច្ចសហប្រតិបត្តិការជាមួយធនាគារពិភពលោក ក្នុងការពង្រឹងប្រសិទ្ធភាពត្រួតពិនិត្យធនាគារ រួមមានការធ្វើលំហាត់សាកល្បងក្នុងការគ្រប់គ្រងវិបត្តិ។ នាពេលបច្ចុប្បន្ន មូលនិធិរូបិយវត្ថុអន្តរជាតិបានបញ្ជូនជំនាញការបច្ចេកទេសប្រចាំនៅធនាគារជាតិនៃកម្ពុជា ដើម្បីជួយកសាងសមត្ថភាពត្រួតពិនិត្យធនាគារ។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជា ក៏ទទួលបានការបណ្តុះបណ្តាលធនធានមនុស្ស ក្រោមរូបភាពជាកិច្ចសហប្រតិបត្តិការទ្វេភាគីពីភ្នាក់ងាររដ្ឋាភិបាលបរទេស និងស្ថាប័នក្នុងតំបន់ និងអន្តរជាតិដ៏ច្រើនទៀត។

**២៨-** អគ្គនាយកដ្ឋានត្រួតពិនិត្យ រួមជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានពង្រីកការយល់ដឹងបន្ថែមក្នុងចំណោមធនាគារទាំងអស់ អំពីការអនុវត្តបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ការគ្រប់គ្រងហានិភ័យលើការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មត្រូវបានយកចិត្តទុកដាក់កាន់តែខ្លាំងក្នុងការត្រួតពិនិត្យ និងតាមដានគ្រឹះស្ថានធនាគារ។ រាល់គ្រឹះស្ថានធនាគារទាំងអស់បានបំពេញកម្រងសំណួរ និងផ្ញើរបាយការណ៍ទាក់ទងនឹងការវាយតម្លៃហានិភ័យលើភាពគំរាមកំហែង និងភាពងាយរងគ្រោះដោយសារការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**២៩-** ធនាគារជាតិនៃកម្ពុជា បានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការជាច្រើន ជាមួយអាជ្ញាធរត្រួតពិនិត្យដទៃទៀត ដែលមានគ្រឹះស្ថានធនាគារធ្វើប្រតិបត្តិការជាសាខា ឬជាបុត្រសម្ព័ន្ធនៅកម្ពុជា។ ធនាគារ

ជាតិនៃកម្ពុជា ក៏បានពង្រីកកិច្ចសហប្រតិបត្តិការជាមួយមន្ត្រីត្រួតពិនិត្យធនាគារនៅបណ្តាប្រទេសអាស៊ាន ដើម្បីស្វែងរកជំនួយបច្ចេកទេសនានាផងដែរ។

**៣០-** ប្រទេសកម្ពុជា មានភាពសកម្មក្នុងការស្វែងរកកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុក្នុងតំបន់ និងបានចូលរួមក្នុងវេទិកាជាច្រើន ដូចជា សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងអាស៊ាន+៣។ ធនាគារជាតិនៃកម្ពុជា ក៏ជាសមាជិកពេញសិទ្ធិរបស់ស៊ាសិន ចាប់តាំងពីឆ្នាំ២០០៦ និងបានចូលរួមយ៉ាងសកម្មនៅក្នុងក្រុមការងារសមាហរណកម្មវិស័យធនាគាររបស់អាស៊ាន ដែលជាផ្នែកមួយយ៉ាងសំខាន់ ក្នុងការគាំទ្រដល់ក្របខ័ណ្ឌសមាហរណកម្មវិស័យហិរញ្ញវត្ថុអាស៊ាន។ ទន្ទឹមនឹងនេះ ធនាគារជាតិនៃកម្ពុជា ក៏បានចូលជាសមាជិកពេញសិទ្ធិរបស់សមាគមឥណទានកសិកម្មជនបទអាស៊ីប៉ាស៊ីហ្វិក នៅឆ្នាំ២០០០ និងសម្ព័ន្ធបរិយាបន្នហិរញ្ញវត្ថុ នៅឆ្នាំ២០១៥។

**៣១-** ក្រសួងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជា បានផ្តួចផ្តើមកសាងទំនុកចិត្តលើការប្រើប្រាស់ប្រាក់រៀលក្នុងវិស័យសេដ្ឋកិច្ច និងប្រតិបត្តិការហិរញ្ញវត្ថុ ដោយបានអនុវត្តវិធានការមួយចំនួន រួមមាន៖ (១) ការតម្រូវឱ្យគ្រប់ប្រតិបត្តិការរបស់រាជរដ្ឋាភិបាលត្រូវធ្វើឡើងជាប្រាក់រៀល (២) ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ (៣) ការបង្កើនគុណភាពនៃធនបត្រ (ក្រដាសប្រាក់) និង (៤) ការបែងចែកប្រាក់រៀលតាមតម្រូវការទៅគ្រប់តំបន់ និងគ្រប់វិស័យ។ វិធានការទាំងនេះបានគាំទ្រដល់គោលដៅនៃការលើកកម្ពស់តម្រូវការប្រាក់រៀលនៅក្នុងទីផ្សារ។

**៣២- ការកសាងសមត្ថភាព**: ការកសាងសមត្ថភាព គឺជាការយកចិត្តទុកដាក់ខ្ពស់របស់ធនាគារជាតិនៃកម្ពុជា ដោយផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីបុគ្គលិក ទាំងនៅក្នុងស្ថាប័ន ក្នុងប្រទេស និងក្រៅប្រទេសជាដើម។ ការបណ្តុះបណ្តាលមិនត្រឹមតែផ្តោតទៅលើវិធីសាស្ត្រនៃការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការវិភាគម៉ាក្រូសេដ្ឋកិច្ចប៉ុណ្ណោះទេ ថែមទាំងការបណ្តុះបណ្តាលលើផ្នែកគ្រប់គ្រងទុនបម្រុងអន្តរជាតិ ប្រព័ន្ធព័ត៌មានវិទ្យា និងការគ្រប់គ្រងធនធានមនុស្សផងដែរ។ការបណ្តុះ-បណ្តាលភាគច្រើនត្រូវបានរៀបចំ និងគាំទ្រដោយមជ្ឈមណ្ឌលស៊ាសិន មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក ព្រមទាំងធនាគារកណ្តាល និងអាជ្ញាធរត្រួតពិនិត្យនៃប្រទេសទាំងក្នុង និងក្រៅតំបន់។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**៣៣- គោលនយោបាយរូបិយវត្ថុនិងស្ថិរភាពហិរញ្ញវត្ថុ**: ដុល្លារូបនីយកម្មមានគុណសម្បត្តិមួយចំនួន ដូចជា អត្រាប្តូរប្រាក់មានស្ថិរភាព ដែលជំរុញដល់កំណើនវិនិយោគបរទេស និងបានផ្តល់នូវបរិស្ថានស្ថិរភាពក្នុងការអនុវត្តគោលនយោបាយសារពើពន្ធដ៏ប្រុងប្រយ័ត្ន។ ប៉ុន្តែ ដុល្លារូបនីយកម្មក៏បានបណ្តាលឱ្យខាតបង់ផងដែរនូវស៊ីញ៉ូរ៉ាជ្យ (Seigniorage) និងជាឧបសគ្គដល់ការប្រើប្រាស់ឧបករណ៍គោល

នយោបាយមួយចំនួនដែលផ្អែកលើទីផ្សារ ដើម្បីអនុវត្តគោលនយោបាយរូបិយវត្ថុដូចជាប្រតិបត្តិការទីផ្សារចំហ ព្រមទាំងបានកាត់បន្ថយលទ្ធភាពរបស់រាជរដ្ឋាភិបាលក្នុងការចាត់វិធានការតបទៅនឹងវិបត្តិក្នុងករណីមានវិបត្តិ។ ទន្ទឹមនេះ កម្ពុជាមិនទាន់មានក្របខ័ណ្ឌស្ថាប័ន និងយន្តការសម្របសម្រួលច្បាស់លាស់ ដើម្បីធានាស្ថិរភាពហិរញ្ញវត្ថុនៅឡើយ។ ការទទួលបានទិន្នន័យគ្រប់ជ្រុងជ្រោយ ទាន់ពេលវេលា និងមានភាពត្រឹមត្រូវ ក៏នៅមានកម្រិតក្នុងការឈានដល់ការតាមដាន ប្រកបដោយប្រសិទ្ធភាពទៅលើហានិភ័យដែលអាចប៉ះពាល់ស្ថិរភាពហិរញ្ញវត្ថុ។ ការណ៍នេះគូសបញ្ជាក់ពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល និងការកំណត់ក្របខ័ណ្ឌច្បាស់លាស់ដើម្បីដោះស្រាយវិបត្តិដែលអាចកើតឡើង។

**៣៤- ការជំរុញការប្រើប្រាស់ប្រាក់រៀល:** បរិមាណនៃប្រាក់បញ្ញើនិងរូបិយវត្ថុក្នុងចរាចរណ៍ជាប្រាក់រៀលមានកម្រិតទាបធៀបនឹងប្រាក់ដុល្លារអាមេរិក។ ប្រតិបត្តិការរបស់រាជរដ្ឋាភិបាលមួយចំនួននៅតែធ្វើឡើងជាប្រាក់ដុល្លារអាមេរិក ហើយអាជីវករជាច្រើនបានផ្សព្វផ្សាយលក់ផលិតផលរបស់ខ្លួនជាប្រាក់ដុល្លារអាមេរិកតែប៉ុណ្ណោះ ជាពិសេស នៅតំបន់ទីប្រជុំជន។

**៣៥- បណ្ណកម្មសិទ្ធិអចលនទ្រព្យនិងចលនទ្រព្យ:** នៅកម្ពុជាឥណទានភាគច្រើន ត្រូវបានធានាដោយអចលនទ្រព្យ។ ជាទូទៅ អ្នកឲ្យខ្ចីគឺជាអ្នករក្សាទុកឯកសារបណ្ណកម្មសិទ្ធិនោះ។ បណ្ណកម្មសិទ្ធិមានពីរប្រភេទគឺ (១) បណ្ណកម្មសិទ្ធិរឹងជាបណ្ណដែលចេញដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និង (២) បណ្ណកម្មសិទ្ធិទន់ជាបណ្ណដែលចេញដោយអាជ្ញាធរមូលដ្ឋាន។ បណ្ណកម្មសិទ្ធិទន់មានហានិភ័យខ្ពស់ជាងបណ្ណកម្មសិទ្ធិរឹង ដោយសារបណ្ណប្រភេទនេះអាចត្រូវបានចេញចំនួនច្រើនចំពោះអចលនទ្រព្យតែមួយហើយអាចត្រូវបានយកទៅធានាជាមួយអ្នកឲ្យខ្ចីច្រើន ដោយអ្នកឲ្យខ្ចីផ្សេងទៀតមិនបានដឹង។ ជាទូទៅ ឥណទានដែលធានាដោយបណ្ណកម្មសិទ្ធិទន់ ត្រូវបានគិតការប្រាក់ខ្ពស់ជាងឥណទានដែលមានវត្ថុធានាជាបណ្ណកម្មសិទ្ធិរឹង។ ដំណើរការនៃការទទួលបានបណ្ណកម្មសិទ្ធិរឹង គឺត្រូវប្រើប្រាស់រយៈពេលយូរ។ ម្យ៉ាងវិញទៀត ការចុះបញ្ជីចលនទ្រព្យដែលប្រើប្រាស់សម្រាប់ទទួលបានឥណទានពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅមិនទាន់បានដំណើរការពេញលេញនៅឡើយ ដែលធ្វើឲ្យមានហានិភ័យចំពោះការផ្ដល់ឥណទាន និងធ្វើឲ្យលទ្ធភាពប្រើប្រាស់ជាវត្ថុបញ្ចាំនៅមានកម្រិត។

**៣៦-** ការអភិវឌ្ឍលើអគារសហកម្មសិទ្ធិ (Condominium) ក៏មានកំណើនយ៉ាងឆាប់រហ័ស។ ការចេញកម្មសិទ្ធិប្រភេទតូចៗលើអគារសហកម្មសិទ្ធិ នៅមានបញ្ហានៅឡើយ ដែលគួរត្រូវបានចេញឲ្យដោយងាយស្រួល។ ក្រៅពីនេះ ក៏មានបញ្ហាពាក់ព័ន្ធនឹងការចុះបញ្ជីអចលនទ្រព្យ នៅនាយកដ្ឋានចុះបញ្ជីទ្រព្យធានា។

**៣៧- អត្តសញ្ញាណបណ្ណ:** ការិយាល័យព័ត៌មានឥណទានកម្ពុជា ដែលបង្កើតឡើងតាំងពីឆ្នាំ២០១២ មកបានរក្សាទុកព័ត៌មានរបស់អតិថិជនខ្ចីប្រាក់ជាឯកត្តជនជាង២,៣លាននាក់។ មធ្យោបាយដ៏ងាយស្រួល

បំផុតក្នុងការកំណត់អតិថិជន ដែលមានឈ្មោះដូចគ្នា គឺត្រូវប្រើប្រាស់លេខអត្តសញ្ញាណបណ្ណ។ ចាប់តាំងពីឆ្នាំ២០១២ ដល់បច្ចុប្បន្ន រាជរដ្ឋាភិបាលបានចេញអត្តសញ្ញាណបណ្ណថ្មីបានចំនួន៦,៦លានបណ្ណ។ ប៉ុន្តែការបង្កើនល្បឿនបន្ថែមទៀតក្នុងការផ្តល់អត្តសញ្ញាណបណ្ណ នឹងជួយឲ្យអតិថិជនទាំងអស់មានអត្តសញ្ញាណបណ្ណគ្រប់ៗគ្នា។

**៣៨- ការត្រួតពិនិត្យធនាគារ:** ធនាគារជាតិនៃកម្ពុជានៅតែបន្តអនុវត្តការត្រួតពិនិត្យ ដោយផ្អែកលើមូលដ្ឋានហានិភ័យ និងទស្សនអនាគត តាមរយៈការដាក់ឲ្យអនុវត្តប្រកាសស្តីពីការអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យ និងទស្សនអនាគត ។ ការប្តេជ្ញាខាងលើរបស់ធនាគារជាតិនៃកម្ពុជានៅជួបបញ្ហាប្រឈមមួយចំនួន ដូចជា កង្វះបុគ្គលិកដែលមានឯកទេសកម្មក្នុងការអនុវត្តវិធីសាស្ត្រត្រួតពិនិត្យថ្មីនេះ និងការខ្វះខាតបច្ចេកវិទ្យាព័ត៌មាន។ ទន្ទឹមនេះ ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិទាមទារឲ្យមានការពិនិត្យជាប្រចាំដើម្បីតាមទាន់ការវិវត្តនៃស្ថានភាពទីផ្សារ។

**៣៩-** ភាពមិនច្បាស់លាស់នៃមូលដ្ឋានគិតពន្ធចំពោះការធ្វើសំវិធានធន និងការបង្វែរប្រាក់ចំណេញរក្សាទុកនៅជាដើមទុនចុះបញ្ជី ដែលអាចមិនលើកទឹកចិត្តឲ្យគ្រឹះស្ថានធនាគារបង្គរសំវិធានធនគ្រប់គ្រាន់ដើម្បីបង្ការហានិភ័យជាយថាហេតុ។

**៤០-** កង្វះប្រព័ន្ធព័ត៌មានវិទ្យា និងធនធានមនុស្ស សម្រាប់អនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS)។

## ឃ. យុទ្ធសាស្ត្រនិងផែនការអនាគត

**៤១- ស្ថិរភាពហិរញ្ញវត្ថុ:** ធនាគារជាតិនៃកម្ពុជាមានផែនការពង្រឹងជំនាញ និងសមត្ថភាពរបស់ក្រុមការងារតាមដានស្ថិរភាពហិរញ្ញវត្ថុ។ ប្រព័ន្ធផ្តល់សញ្ញាជាមុន (Early Warning Stysem) ជាឧបករណ៍មួយក្នុងចំណោមឧបករណ៍ជាច្រើនដែលត្រូវបានប្រើ ដើម្បីផ្តល់សញ្ញាជាមុនអំពីការធ្លាក់ចុះនៃភាពរឹងមាំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលរួមបញ្ចូលការវិភាគលើមូលដ្ឋានហានិភ័យនិងទស្សនៈអនាគត និងការតាមដានវឌ្ឍនភាពថ្មីៗនៃវិស័យហិរញ្ញវត្ថុ។ អាជ្ញាធរទាំងអស់នៅក្នុងប្រព័ន្ធហិរញ្ញវត្ថុនឹងផ្តល់ទិន្នន័យនិងព័ត៌មាន ចាំបាច់ដើម្បីរៀបចំរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុមួយ ដែលគ្រប់ជ្រុងជ្រោយនិងមានគុណភាពខ្ពស់។ រាជរដ្ឋាភិបាលគ្រោងនឹងបង្កើតគណៈកម្មាធិការស្ថិរភាពហិរញ្ញវត្ថុថ្នាក់ជាតិ ដែលនឹងបង្កើតក្របខ័ណ្ឌស្ថាប័នច្បាស់លាស់ដើម្បីតាមដាន និងធានាស្ថិរភាពហិរញ្ញវត្ថុ។

**៤២- ការត្រៀមបង្ការដោះស្រាយវិបត្តិ:** អាជ្ញាធរត្រួតពិនិត្យនានានឹងអនុម័តក្របខ័ណ្ឌនិងនីតិវិធីសហប្រតិបត្តិការដោះស្រាយវិបត្តិ។ អាជ្ញាធរនីមួយៗនឹងបង្កើតផែនការយថាភាព(Contingency Plan) រៀងៗខ្លួន និងចូលរួមបង្កើតផែនការយថាភាពជាតិមួយ។ ការផ្លាស់ប្តូរទិន្នន័យ និងព័ត៌មានរវាងអាជ្ញាធរនឹងត្រូវពង្រឹងបន្ថែមទៀត ហើយការធ្វើតេស្តគ្រប់គ្រងវិបត្តិសាកល្បងនឹងត្រូវធ្វើឡើងឲ្យបានទៀងទាត់។

កិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរអន្តរជាតិស្តីពីការត្រៀមខ្លួនដោះស្រាយវិបត្តិ និងគ្រប់គ្រងវិបត្តិ ក៏ត្រូវបង្កើនបន្ថែមទៀតផងដែរ។

**៤៣-** នាពេលអនាគត ធនាគារជាតិនៃកម្ពុជានឹងសិក្សាពីលទ្ធភាពបង្កើតយន្តការការពារប្រាក់បញ្ញើរបស់អតិថិជនដើម្បីបង្កើនជំនឿទុកចិត្តសាធារណជនមកលើប្រព័ន្ធធនាគារ ជាពិសេស អតិថិជនដែលមានប្រាក់បញ្ញើតូចៗ។ យោងតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ដឹកនាំការងារបង្កើតយន្តការការពារប្រាក់បញ្ញើរបស់អតិថិជន ដោយសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ស្ថានភាពអភិវឌ្ឍប្រព័ន្ធធនាគារបច្ចុប្បន្ន ទាមទារឲ្យមានការរៀបចំជាស្រេចនូវក្របខ័ណ្ឌដោះស្រាយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានបញ្ហា ពោលគឺអាចអនុញ្ញាតឲ្យធនាគារជាតិនៃកម្ពុជាមានជម្រើសច្រើនជាងមុនក្នុងការដោះស្រាយបញ្ហាបានឆាប់រហ័សទាន់សភាពការណ៍និងចំណាយទាប។

**៤៤- ការត្រួតពិនិត្យធនាគារ:** ការអនុវត្តតាមគោលការណ៍គ្រឹះស្នូលបាសែលស្តីពីការត្រួតពិនិត្យធនាគារ និងស្តង់ដាពិភពលោកនានា គឺជាធាតុដ៏សំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពការត្រួតពិនិត្យធនាគារ។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាទទួលបានលទ្ធផលល្អក្នុងការឈានទៅរកការអនុវត្តបានពេញលេញនូវគោលការណ៍ស្នូលទាំង២៩ ស្តីពីការត្រួតពិនិត្យធនាគារ។ ធនាគារជាតិនៃកម្ពុជា នឹងបន្តពង្រឹងការអនុវត្តតាមគោលការណ៍ស្នូលបាសែល ជាពិសេស លើដំណើរការគ្រប់គ្រងហានិភ័យដូចជាហានិភ័យអធិបតេយ្យ ហានិភ័យផ្ទេរប្រាក់ ហានិភ័យប្រតិបត្តិការ ហានិភ័យអត្រាការប្រាក់ និងការត្រួតពិនិត្យគួបសរុប។

**៤៥-** ក្នុងពេលឆាប់ៗខាងមុខ ធនាគារជាតិនៃកម្ពុជានឹងពិនិត្យឡើងវិញនូវបទប្បញ្ញត្តិស្តីពីអនុបាតសាធនភាព និងស្តីពីសកម្មភាពកែតម្រូវបន្ទាន់។ ធនាគារជាតិនៃកម្ពុជានឹងជ្រើសរើសនិងបណ្តុះបណ្តាលបុគ្គលិកថ្មីលើផ្នែកត្រួតពិនិត្យធនាគារ និងរៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញនានាបន្ថែមទៀត។ ធនាគារជាតិនៃកម្ពុជានឹងលើកកម្ពស់ប្រសិទ្ធភាពនៃការត្រួតពិនិត្យធនាគារ សំដៅទៅអនុវត្តឲ្យបានពេញលេញនូវវិធីសាស្ត្រត្រួតពិនិត្យធនាគារលើមូលដ្ឋានហានិភ័យ និងទស្សនអនាគត។ ដំណើរការនេះទាមទារឲ្យមានការបណ្តុះបណ្តាលនិងការធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានបន្ថែមទៀត។

**៤៦- ការប្រើប្រាស់ប្រាក់រៀល:** រាជរដ្ឋាភិបាលនឹងជំរុញការប្រើប្រាស់ប្រាក់រៀលបន្ថែមទៀតតាមរយៈការដាក់ចេញនូវគោលនយោបាយជាតិ ក្នុងការជំរុញការប្រើប្រាស់ប្រាក់រៀល។ រាជរដ្ឋាភិបាលមានផែនការបង្កើតក្រុមការងារចម្រុះដើម្បីវាយតម្លៃទីផ្សារ ប្រតិបត្តិការថ្មីៗ និងឧបករណ៍ថ្មីៗ ដើម្បីជំរុញការប្រើប្រាស់ប្រាក់រៀលផងដែរ។

**៤៧- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម:** ធនាគារជាតិនៃកម្ពុជា រួមជាមួយនឹងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានលើកឡើងពីបញ្ហាពាក់ព័ន្ធនឹងការបំពេញកាតព្វកិច្ចប្រឆាំងនឹងការសម្អាតប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ ការ

គ្រប់គ្រងហានិភ័យនៃការសម្អាតប្រាក់ គឺជាផ្នែកមួយនៃការត្រួតពិនិត្យ និងតាមដានរបស់ធនាគារ ដែលកន្លងមកធនាគារបានបញ្ចប់ និងធ្វើរបាយការណ៍ស្តីពីការវិភាគហានិភ័យនៃការគំរាមកំហែងនៃការសម្អាតប្រាក់។

**៤៨- បណ្ណកម្មសិទ្ធិអចលនទ្រព្យនិងចលនទ្រព្យ**: រាជរដ្ឋាភិបាលមានផែនការបង្កើនប្រសិទ្ធភាពនៃដំណើរការចេញបណ្ណកម្មសិទ្ធិ និងសិក្សាពីថ្លៃចំណាយ និងលទ្ធភាពកាត់បន្ថយថ្លៃចំណាយលើការចេញបណ្ណកម្មសិទ្ធិ ជាដើម។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏មានផែនការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការចេញកម្មសិទ្ធិប្រភេទតូចៗលើអគារសហកម្មសិទ្ធិ និងការចុះបញ្ជីអចលនទ្រព្យនៅនាយកដ្ឋានចុះបញ្ជីទ្រព្យធានា។ ជាមួយគ្នានេះ រាជរដ្ឋាភិបាល នឹងជំរុញដំណើរការចុះបញ្ជីចលនទ្រព្យ សម្រាប់ប្រើប្រាស់ក្នុងការស្នើសុំឥណទានពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

**៤៩- កិច្ចការពារអ្នកប្រើប្រាស់**: ធនាគារជាតិនៃកម្ពុជា នឹងពិនិត្យឡើងវិញនូវតម្រូវការនៃការពង្រីកគោលការណ៍កិច្ចការពារអ្នកប្រើប្រាស់នៅក្នុងបទប្បញ្ញត្តិ ដែលមានស្រាប់ដោយចែងឲ្យកាន់តែច្បាស់ពីលក្ខខណ្ឌនានាចំពោះផលិតផលឥណទាន ការផ្សព្វផ្សាយពាណិជ្ជកម្ម នីតិវិធីប្តឹងនិងតវ៉ា កម្រៃសេវាការគណនាការប្រាក់ និងនីតិវិធីនៃការប្រមូលឥណទាន។

**៥០- បរិយាបន្នហិរញ្ញវត្ថុ**: បរិយាបន្នហិរញ្ញវត្ថុកើតមានឡើងនៅពេលដែលប្រជាពលរដ្ឋមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុទូលំទូលាយ។ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុដោយ (១) កាត់បន្ថយអត្រាប្រជាជន ដែលពុំមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ (២) ជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន (៣) ជំរុញការអភិវឌ្ឍបរិស្ថាន ដែលគាំទ្រដល់បរិយាបន្នហិរញ្ញវត្ថុ និង (៤) ធ្វើឲ្យប្រជាពលរដ្ឋទាំងអស់អាចទទួលបានអត្ថប្រយោជន៍ពីបរិយាបន្នហិរញ្ញវត្ថុ។

**៥១-** យុទ្ធសាស្ត្របរិយាបន្នហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល រួមមាន ការបង្កើត និងការពង្រឹងគោលនយោបាយហិរញ្ញវត្ថុ និងបទប្បញ្ញត្តិនានាដែលនឹង (១) ផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍ និងការច្នៃប្រឌិតដើម្បីឈានទៅរកបរិយាបន្នហិរញ្ញវត្ថុ (២) ធានាការអនុវត្តតាមគោលការណ៍កិច្ចការពារអ្នកប្រើប្រាស់ (៣) ផ្តួចផ្តើមកម្មវិធីលើកកម្ពស់និងគាំទ្របរិយាបន្នហិរញ្ញវត្ថុ ដូចជា កម្មវិធីអប់រំហិរញ្ញវត្ថុ (៤) ការលើកកម្ពស់ការធ្វើពិពិធកម្មផលិតផលហិរញ្ញវត្ថុនៃវិស័យធនាគារ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ (៥) ពង្រឹងកិច្ចសហប្រតិបត្តិការរវាងអ្នករៀបចំគោលនយោបាយស្ថាប័នរាជរដ្ឋាភិបាល និងវិស័យឯកជនដែលពាក់ព័ន្ធ និង (៦) បង្កើតនិងប្រើប្រាស់ការផ្សព្វផ្សាយតាមបណ្តាញសង្គមដើម្បីធ្វើឲ្យបរិយាបន្នហិរញ្ញវត្ថុកាន់តែមានប្រជាប្រិយភាពបន្ថែមទៀត។ ដើម្បីសម្រេចបានចក្ខុវិស័យរបស់ខ្លួនរាជរដ្ឋាភិបាលនឹងអនុម័ត និងអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ។

**៩២- គណនេយ្យ:** ធនាគារជាតិនៃកម្ពុជា សហការជាមួយនឹងក្រុមប្រឹក្សាជាតិគណនេយ្យ នឹងបន្តចាត់វិធានការអប់រំ និងណែនាំគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក៏ដូចជាបុគ្គលិករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អំពីការអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS)។

**៩៣- ពន្ធដារ:** ធនាគារជាតិនៃកម្ពុជា នឹងបន្តពិភាក្សាជាមួយនឹងស្ថាប័នពាក់ព័ន្ធ ជាពិសេស អគ្គនាយកដ្ឋានពន្ធដារ ដើម្បីស្វែងរកដំណោះស្រាយ និងបញ្ជាក់ឲ្យបានច្បាស់អំពីការគណនាមូលដ្ឋានគិតពន្ធចំពោះការធ្វើសំវិធានធន និងការបង្វែរប្រាក់ចំណេញរក្សាទុកនៅជាដើមទុនចុះបញ្ជី។

## II. ប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ

### ក. ទិដ្ឋភាពទូទៅ

**៩៤- សារៈសំខាន់នៃវិស័យមីក្រូហិរញ្ញវត្ថុ:** រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់នូវតួនាទីសំខាន់របស់វិស័យមីក្រូហិរញ្ញវត្ថុក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងជាពិសេស ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ការពង្រីកការផ្តល់ឥណទានសម្រាប់កំណើននៅតំបន់ជនបទ គឺនៅតែជាការងារអាទិភាព។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មីក្រូឥណទានក៏ត្រូវបានពង្រីកដល់តំបន់ប្រជុំជនដែរ ។ មីក្រូហិរញ្ញវត្ថុផ្តល់ឥណទានក្នុងអត្រាការប្រាក់ទាបជាងកម្ចីផ្តល់ដោយឈ្មួញឲ្យខ្ចីចងការ។ កម្ចីមីក្រូហិរញ្ញវត្ថុដែលភាគច្រើនបានផ្តល់ដល់ស្ត្រី បានផ្តល់ឱកាសដល់ប្រជាពលរដ្ឋអាចទិញទំនិញដែលមានតម្លៃខ្ពស់ ដូចជា សន្និធិឧបករណ៍ប្រើប្រាស់សម្ភារៈសាងសង់ និងការកែលម្អ លំនៅស្ថាន។ ប្រាក់កម្ចីបន្ទាន់ជួយឲ្យអ្នកខ្ចីអាចប្រើប្រាស់សម្រាប់រ៉ាប់រងចំណាយផ្សេងៗនៅពេល មានវិបត្តិហិរញ្ញវត្ថុបន្ទាន់។ បច្ចុប្បន្ន បន្ថែមលើផលិតផលឥណទាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ក៏ផ្តល់នូវផលិតផលសំខាន់ៗមួយចំនួនទៀតផងដែរ រួមមាន សេវាសន្សំប្រាក់ សេវាផ្ទេរប្រាក់ និងសេវា ធានារ៉ាប់រងខ្នាតតូច។

**៩៥- ការវិវត្តនៃវិស័យមីក្រូហិរញ្ញវត្ថុ:** វិស័យមីក្រូហិរញ្ញវត្ថុផ្លូវការនៅកម្ពុជាបានកកើតឡើង នៅទសវត្សរ៍ទី១០នៃសតវត្សទី២០ ពីគម្រោងមីក្រូឥណទានមួយចំនួន ដែលបានបង្កើតឡើងដោយម្ចាស់ជំនួយអន្តរជាតិអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នផ្សេងៗ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានក្លាយជាផ្នែកសំខាន់មួយនៃវិស័យហិរញ្ញវត្ថុផ្លូវការក្នុងរយៈពេលជាងមួយទសវត្សរ៍មកនេះ។ ទោះយ៉ាងណា ក៏នៅមានអង្គការ សមាគម ក្រុមហ៊ុន និងអ្នករកស៊ីចងការប្រាក់មួយចំនួន កំពុងធ្វើប្រតិបត្តិការប្រមូលប្រាក់សន្សំ និងផ្តល់ប្រាក់កម្ចីដោយពុំមានច្បាប់អនុញ្ញាតត្រឹមត្រូវ។ លើសពីនេះ ការយល់ដឹងរបស់ប្រជាពលរដ្ឋកម្ពុជាភាគច្រើនក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុ និងសារប្រយោជន៍នៃការប្រើប្រាស់សេវាហិរញ្ញវត្ថុ នៅមានកម្រិត។

## ខ. វឌ្ឍនភាពនិងសមិទ្ធផល

**៥៦- កំណើនរបស់វិស័យមីក្រូហិរញ្ញវត្ថុ:** វិស័យមីក្រូហិរញ្ញវត្ថុបានរីកចម្រើនយ៉ាងខ្លាំងចាប់តាំងពីការអនុម័តនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០។ ចំនួនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (មិនទទួលប្រាក់បញ្ញើ) បានកើនឡើងពី២៣ នៅក្នុងឆ្នាំ២០១១ដល់៣២ ក្នុងឆ្នាំ២០១៥។ ចំនួនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើកើនឡើងពី៧ ក្នុងឆ្នាំ២០១១ដល់៨ក្នុងឆ្នាំ២០១៥។

**៥៧-** ក្នុងកំលុងពេលពីឆ្នាំ២០១១-២០១៥ ទ្រព្យសកម្មសរុបរបស់វិស័យនេះបានកើនឡើងពី ៣ ០២៥ ប៊ីលានរៀល (៧៥៣លានដុល្លារអាមេរិក) ដល់ ១៤ ៦២៦ប៊ីលានរៀល (៣,៦ ប៊ីលានដុល្លារអាមេរិក) ខណៈដែលអត្រាឥណទានមិនដំណើរការស្ថិតក្នុងកម្រិតទាប (ជាមធ្យម០,៧៧% ក្នុងឆ្នាំ២០១៥)។ លទ្ធភាពរកចំណូលរបស់វិស័យនេះនៅតែរឹងមាំដែលប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម (ROA) និងប្រាក់ចំណេញធៀបនឹងដើមទុន (ROE) ជាមធ្យមមានចំនួន ៣,៦៨% និង ១៨,៦២% រៀងគ្នាក្នុងឆ្នាំ២០១៥។ រីឯអត្រាឥណទានមិនដំណើរការសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានអត្រាជាមធ្យមទាបជាង ១%។

**៥៨-** ចំនួនអតិថិជនដែលបានសន្សំប្រាក់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបានកើនឡើងពី ២៤២.១១៦ នាក់ក្នុងឆ្នាំ២០១១ ដល់ចំនួន ១,៣៣លាន នាក់ក្នុងឆ្នាំ២០១៥។ សមតុល្យប្រាក់បញ្ញើសរុបបានកើនឡើងជាលំដាប់ពីចំនួន ៤៦០ ប៊ីលានរៀល (១១៥ លានដុល្លារអាមេរិក) ដល់ចំនួន ៥.៤១០ ប៊ីលានរៀល (ប្រមាណ១,៣៥ ប៊ីលានដុល្លារអាមេរិក)។ បច្ចុប្បន្ន ប្រាក់សន្សំជាង៧០% ជាប្រាក់សន្សំមានកាលកំណត់។ ចំនួនបុគ្គលិករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកើនឡើងទ្វេដងពី៩.៧៤៤នាក់ក្នុងឆ្នាំ២០១១ដល់ចំនួន២៦.២៦៨នាក់ក្នុងឆ្នាំ២០១៥។

**៥៩- ពិពិធកម្មផលិតផល:** គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានផ្តល់នូវផលិតផលថ្មីៗជាច្រើនក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ ហើយបច្ចុប្បន្នគ្រឹះស្ថានភាគច្រើនបានផ្តល់សេវាផ្ទេរប្រាក់ និងសេវាធនាគារចល័តយ៉ាងសកម្ម។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន៣ បានទទួលការអនុញ្ញាតធ្វើជាភ្នាក់ងារណែនាំសេវាធានារ៉ាប់រងខ្នាតតូចដល់អតិថិជនរបស់ខ្លួន។ គ្រឹះស្ថានក៏ផ្តល់សេវាហិរញ្ញប្បទានសម្រាប់ទិញលំនៅស្ថាន សេវាប្រាក់កម្ចីសម្រាប់ការសិក្សា និងសេវាប្រាក់កម្ចីទៅសហគ្រាសធុនតូចនិងមធ្យមផងដែរ។ បច្ចុប្បន្ន សេវាប្រាក់កម្ចី សេវាប្រាក់សន្សំ និងសេវាផ្ទេរប្រាក់ ក៏ត្រូវបានពង្រីកដល់ប្រជាពលរដ្ឋក្រីក្រ និងដល់ប្រជាពលរដ្ឋទូទៅដែលពុំទាន់ទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ។

**៦០- ការផ្តល់ហិរញ្ញប្បទានរបស់ធនាគារពាណិជ្ជគាំទ្រដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ:** បច្ចុប្បន្ន ធនាគារពាណិជ្ជក្នុងស្រុកជាង១០ បានផ្តល់ប្រាក់កម្ចីជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកដល់គ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។

**៦១- សមាគមមីក្រូហិរញ្ញវត្ថុ:** សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដើរតួនាទីយ៉ាងសកម្មក្នុងការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ និងបានពង្រីកចំនួនសមាជិករបស់ខ្លួន ដោយរួមបញ្ចូលគ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណនិងចុះបញ្ជី ព្រមទាំងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុទាំងអស់ផងដែរ។ ទន្ទឹមនេះ សមាគមក៏ផ្តល់នូវការបណ្តុះបណ្តាលជាប្រចាំដល់សមាជិករបស់ខ្លួន ក្នុងគោលដៅពង្រឹងនូវក្រមសីលធម៌វិជ្ជាជីវៈ និងគោលការណ៍កិច្ចការពារអ្នកប្រើប្រាស់។

**៦២- បទប្បញ្ញត្តិនិងការត្រួតពិនិត្យចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ:** ធនាគារជាតិនៃកម្ពុជា រួមជាមួយនឹងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានលើកកម្ពស់ការយល់ដឹងអំពីការប្រតិបត្តិតាមការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ការគ្រប់គ្រងហានិភ័យនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម គឺជាផ្នែកមួយនៃការត្រួតពិនិត្យ និងតាមដានចំពោះគ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ គិតត្រឹមពាក់កណ្តាលឆ្នាំ២០១៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់បានបញ្ចប់ និងផ្ញើរបាយការណ៍ស្តីពីការវិភាគហានិភ័យនៃការគំរាមកំហែងនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**៦៣- ការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់និងអក្ខរកម្មហិរញ្ញវត្ថុ:** ធនាគារជាតិនៃកម្ពុជាបានចាប់ផ្តើមយុទ្ធនាការលើកកម្ពស់សិទ្ធិ និងការយល់ដឹងរបស់អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ ក្នុងគោលបំណងជំរុញបរិយាបន្នហិរញ្ញវត្ថុ និងជួយគាំទ្រអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ ដែលជាគ្រួសារមានចំណូលទាប និងមានភាពងាយរងគ្រោះឲ្យផុតពីហានិភ័យនៃការធ្លាក់ខ្លួនក្នុងភាពក្រីក្រ។ យុទ្ធនាការទាំងនោះ រួមមាន (១) ការរៀបចំសិក្ខាសាលានៅតាមបណ្តាខេត្តក្រុង ចំនួន១៤ ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងវិស័យឯកជន ដើម្បីផ្សព្វផ្សាយសេចក្តីថ្លែងការណ៍រួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា និងបង្ហាញពីមុខងារភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា (២) ការផ្តល់ជាវេទិកាក្នុងការពន្យល់ណែនាំដល់អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ឲ្យយល់ដឹងពីអត្ថប្រយោជន៍ពីការខ្ចីប្រាក់ក្នុងប្រព័ន្ធពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអង្គការសមាគមដែលមានអាជ្ញាបណ្ណនិងចុះបញ្ជី និងពីហានិភ័យនៃការខ្ចីប្រាក់ក្រៅប្រព័ន្ធពីអង្គការសមាគម ដែលមិនមានអាជ្ញាបណ្ណនិងចុះបញ្ជី (៣) កិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍នានាក្នុងយុទ្ធនាការផ្សព្វផ្សាយជាច្រើនទៀតតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ ក្នុងគោលបំណងជំរុញឲ្យមានការទាក់ទាញដល់អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុឲ្យយល់ពីអត្ថប្រយោជន៍ និងហានិភ័យនៃការប្រើសេវានេះ។

**៦៤- សន្និសីទជាតិមីក្រូហិរញ្ញវត្ថុ:** ធនាគារជាតិនៃកម្ពុជា បានរៀបចំសន្និសីទជាតិស្តីពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា កាលពីថ្ងៃទី១៤-១៥ ខែមីនា ឆ្នាំ២០១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ សន្និសីទនេះមានគោលបំណងលើកកម្ពស់ការយល់ដឹងរបស់សាធារណជន អំពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ

នៅកម្ពុជា និងតួនាទីសំខាន់របស់វិស័យនេះក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រ។ ធាតុចូលសំខាន់ៗនៃសន្និសីទ ត្រូវបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្រ្តជាតិរបស់រាជរដ្ឋាភិបាល ដើម្បីជាផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ។

**៦៥- យុទ្ធសាស្រ្តជាតិស្តីពីវិស័យមីក្រូហិរញ្ញវត្ថុ:** រាជរដ្ឋាភិបាលបានកែសម្រួលគណៈកម្មាធិការឥណទានសម្រាប់អភិវឌ្ឍជនបទ ទៅជាគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍មីក្រូហិរញ្ញវត្ថុ ឲ្យស្របទៅនឹងដំណើរការនៃការវិវត្តវិស័យមីក្រូហិរញ្ញវត្ថុ នៅកម្ពុជានាពេលបច្ចុប្បន្ន។ កាលពីឆ្នាំ២០១៥ គណៈកម្មាធិការនេះ បានកំណត់ពីបញ្ហាប្រឈមនានាក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងបានដាក់ចេញនូវវិធានការគោលនយោបាយ និងវិធានការដោះស្រាយ ដើម្បីឲ្យធនាគារជាតិនៃកម្ពុជា និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ តាមដាន និងអនុវត្ត។ ទន្ទឹមនេះ គណៈកម្មាធិការ បានបង្កើតក្រុមការងារចំនួន២ ដែលក្រុមការងារទី១ ដឹកនាំដោយ ក្រសួងមហាផ្ទៃ និងក្រុមការងារទី២ ដឹកនាំដោយធនាគារជាតិនៃកម្ពុជា។ ចំណែកឯគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) បានសហការជាមួយក្រសួងមហាផ្ទៃ រៀបចំសិក្ខា-សាលាផ្សព្វផ្សាយស្តីពី "ការទប់ស្កាត់កុំឲ្យសាធារណៈ ចាញ់បោកក្រុមហ៊ុនដែលកេងចំណេញក្នុងវិស័យហិរញ្ញវត្ថុ និងគ្មានអាជ្ញាបណ្ណ" នៅតាមបណ្តាខេត្តក្រុងទូទាំងប្រទេស និងបានរៀបចំសិក្ខាសាលាថ្នាក់ជាតិ កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ ស្តីពី "ការបញ្ជ្រាបការយល់ដឹងដល់សាធារណៈក្នុងការវិនិយោគលើវិស័យហិរញ្ញវត្ថុ"។ ជាមួយគ្នានេះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំសេចក្តីព្រាងបច្ចុប្បន្នកម្មយុទ្ធសាស្រ្តជាតិស្តីពីមីក្រូហិរញ្ញវត្ថុក្នុងឆ្នាំ២០១៥ និងបានដាក់ជូនគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ នាខែមីនា ឆ្នាំ២០១៦ កន្លងទៅ។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**៦៦-** ស្របពេលដែលវិស័យមីក្រូហិរញ្ញវត្ថុមានការអភិវឌ្ឍ និងរីកចម្រើនគួរឲ្យកត់សម្គាល់ក្នុងកំលុងពេល ១០ឆ្នាំកន្លងមកនេះ វិស័យនេះនៅតែមានបញ្ហាប្រឈមមួយចំនួនដូចជា៖ (១) ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីវិស័យមីក្រូហិរញ្ញវត្ថុ នៅមានកម្រិតដោយយល់ច្រលំថាគ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុ គឺជាគ្រឹះស្ថានរបស់រដ្ឋ ឬអង្គការមិនស្វែងរកប្រាក់ចំណេញ។ ការយល់ច្រឡំនេះបានធ្វើឲ្យប្រជាពលរដ្ឋខ្វះការគិតគូរអំពីអត្រាការប្រាក់ លទ្ធភាពសងបំណុល និងការប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុឲ្យបានត្រឹមត្រូវ និងចំគោលដៅ (២) ប្រតិបត្តិករឥណទានក្រៅប្រព័ន្ធបានឆ្លៀតឱកាសប្រើឈ្មោះជាអង្គការមិនស្វែងរកប្រាក់ចំណេញ ធ្វើប្រត្តិបត្តិការផ្តល់ឥណទានក្នុងអត្រាការប្រាក់ខ្ពស់ហួសហេតុ ដែលបណ្តាលឲ្យប្រជាពលរដ្ឋមានបំណុលវ័ណ្ឌក។ (៣) អត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅមានតម្លៃខ្ពស់ ដោយសារថ្លៃដើមនៃប្រភពទុន និងការចំណាយប្រតិបត្តិការនៅមានកម្រិតខ្ពស់ (៤) កង្វះប្រព័ន្ធព័ត៌មានវិទ្យា និងធនធានមនុស្សសម្រាប់អនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) និង (៥) ភាពមិនច្បាស់លាស់នៃមូលដ្ឋានគិតពន្ធចំពោះការធ្វើសំវិធានធន និង

ការបង្វែរប្រាក់ចំណេញរក្សាទុកនៅជាដើមទុនចុះបញ្ជី ដែលអាចមិនលើកទឹកចិត្តឲ្យគ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុបង្គរសំវិធានធនគ្រប់គ្រាន់ ដើម្បីបង្ការហានិភ័យជាយថាហេតុ។

## ឃ. យុទ្ធសាស្ត្រនិងផែនការអនាគត

**៦៧- គោលនយោបាយនិងយុទ្ធសាស្ត្រវិស័យមីក្រូហិរញ្ញវត្ថុ**: កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសជាង៣០ ដែលបានអនុម័តយុទ្ធសាស្ត្រជាតិស្តីពីវិស័យមីក្រូហិរញ្ញវត្ថុ។ រាជរដ្ឋាភិបាលនឹងអនុម័តយុទ្ធសាស្ត្រជាតិស្តីពីវិស័យមីក្រូហិរញ្ញវត្ថុ ដែលបានធ្វើបច្ចុប្បន្នកម្ម ព្រមទាំងយុទ្ធសាស្ត្រថ្មីស្តីពីបរិយាបន្នហិរញ្ញវត្ថុ។

**៦៨- ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**: ធនាគារជាតិនៃកម្ពុជា មានផែនការលើកកម្ពស់ការប្រតិបត្តិតាមគោលការណ៍ស្នូលសម្រាប់ការត្រួតពិនិត្យធនាគារ ប្រកបដោយប្រសិទ្ធភាពសម្រាប់សកម្មភាពមីក្រូហិរញ្ញវត្ថុរបស់គណៈកម្មាធិការបាសែល។ ធនាគារជាតិនៃកម្ពុជានឹងបន្តផ្តោតការយកចិត្តទុកដាក់ចំពោះការត្រួតពិនិត្យ និងដាក់ចេញនូវបទប្បញ្ញត្តិដែលស្របតាមស្តង់ដាអន្តរជាតិសម្រាប់ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជានឹងបង្កើនល្បឿននៃការចុះបញ្ជី និងផ្តល់អាជ្ញាបណ្ណដល់ប្រតិបត្តិករឥណទានក្រៅប្រព័ន្ធ។

**៦៩- ការពង្រឹងការអនុវត្តច្បាប់**: ធនាគារជាតិនៃកម្ពុជា នឹងសហការជាមួយនឹងក្រសួងមហាផ្ទៃ និងស្ថាប័នមានសមត្ថកិច្ច ចាត់វិធានការតឹងរឹងដល់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលមិនព្រមមកចុះបញ្ជីហើយនៅបន្តធ្វើអាជីវកម្មខុសច្បាប់។

**៧០- ការពង្រឹងអក្ខរកម្មហិរញ្ញវត្ថុ** ៖ ធនាគារជាតិនៃកម្ពុជានឹងបន្តយុទ្ធនាការផ្សព្វផ្សាយដល់សាធារណជន ពិសេស ប្រជាពលរដ្ឋនៅតំបន់ជនបទ ដើម្បីជំរុញឲ្យមានការយល់ដឹងអំពីផ្នែកហិរញ្ញវត្ថុបន្ថែមទៀត ក្នុងគោលបំណងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ យុទ្ធនាការផ្សព្វផ្សាយនឹងធ្វើតាមមធ្យោបាយនានា រួមមាន ការដាក់បញ្ចូលកម្មវិធីអក្ខរកម្មហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាទូទៅរបស់ប្រព័ន្ធអប់រំជាតិ និងការផ្សព្វផ្សាយអប់រំឲ្យបានទូលំទូលាយ តាមរយៈសារព័ត៌មាន (កាសែត ស្លុតទូរទស្សន៍) ឬសិក្ខាសាលា ជាដើម ដោយបញ្ជាក់ឲ្យប្រជាពលរដ្ឋបានយល់ថា ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុមិនមែនជារបស់រដ្ឋទេ ហើយប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ក៏មិនមែនជាអង្គការមនុស្សធម៌ដែរ។

**៧១- ការកៀរគរប្រភពទុន**: សិក្សាស្វែងរកប្រភពទុនដែលមានតម្លៃទាប និងសិក្សាពីកត្តារួមផ្សំទាំងឡាយដែលធ្វើឲ្យថ្លៃដើមទុនខ្ពស់ និងរិះរកមធ្យោបាយដើម្បីបញ្ចុះអត្រាការប្រាក់ដោយគោរពតាមយន្តការទីផ្សារ។

**៧២- ការកាត់បន្ថយសកម្មភាពធនាគារស្រមោល:** ធនាគារជាតិនៃកម្ពុជានឹងពង្រឹងការប្រមូលព័ត៌មាន និងទិន្នន័យពាក់ព័ន្ធ និងចាត់វិធានការកាត់បន្ថយសកម្មភាពដែលមានលក្ខណៈជាធនាគារស្រមោល ដែលអាចបង្កឲ្យមានហានិភ័យដល់ស្ថិរភាពហិរញ្ញវត្ថុ។

**៧៣- កិច្ចការពារអ្នកប្រើប្រាស់:** ធនាគារជាតិនៃកម្ពុជានឹងពិនិត្យឡើងវិញនូវតម្រូវការនៃការពង្រីកគោលការណ៍កិច្ចការពារអ្នកប្រើប្រាស់នៅក្នុងបទប្បញ្ញត្តិដែលមានស្រាប់ ដោយចែងឲ្យកាន់តែច្បាស់ពីលក្ខខណ្ឌនានាចំពោះផលិតផលឥណទាន ការផ្សព្វផ្សាយពាណិជ្ជកម្ម នីតិវិធីប្ដឹងនិងតវ៉ា កម្រៃសេវាការគណនាការប្រាក់ និងនីតិវិធីនៃការប្រមូលឥណទាន។ លើសពីនេះ ការយល់ដឹងរបស់សាធារណជនអំពីប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ និងហានិភ័យចម្បងៗ ក៏នឹងត្រូវបានពង្រឹងផងដែរ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជានឹងដាក់ចេញនូវវិធានពាក់ព័ន្ធការពារអ្នកប្រើប្រាស់ ស្របពេលដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន កំពុងអនុវត្តគម្រោងកម្មវិធីកិច្ចការពារអ្នកប្រើប្រាស់ អនុលោមតាមគោលការណ៍នៃកិច្ចការពារអ្នកប្រើប្រាស់របស់ SMART Campaign។ លើសពីនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តកិច្ចសហការបន្ថែមទៀតជាមួយអាជ្ញាធរនិងភាគីពាក់ព័ន្ធនានា ក្នុងការអនុវត្តនិងទប់ស្កាត់សកម្មភាពខុសច្បាប់ពាក់ព័ន្ធការប្រមូលប្រាក់សន្សំ និងការឲ្យខ្ចីដែលមានលក្ខណៈបោកប្រាស់ និងកេងប្រវ័ញ្ចពីប្រជាពលរដ្ឋ។

**៧៤- គណនេយ្យ:** ធនាគារជាតិនៃកម្ពុជា សហការជាមួយនឹងក្រុមប្រឹក្សាជាតិគណនេយ្យ នឹងបន្តចាត់វិធានការអប់រំ និងណែនាំគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក៏ដូចជាបុគ្គលិករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអំពីការអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS)។

**៧៥- ពន្ធដារ:** ធនាគារជាតិនៃកម្ពុជា នឹងបន្តពិភាក្សាជាមួយនឹងស្ថាប័នពាក់ព័ន្ធ ជាពិសេសអគ្គនាយកដ្ឋានពន្ធដារ ដើម្បីស្វែងរកដំណោះស្រាយ និងបញ្ជាក់ឲ្យបានច្បាស់អំពីការគណនាមូលដ្ឋានគិតពន្ធចំពោះការធ្វើសំវិធានធន និងការបង្វែរប្រាក់ចំណេញរក្សាទុកនៅជាដើមទុនចុះបញ្ជី។

## III. ប្រតិបត្តិការបង់រំលស់

### ក. ទិដ្ឋភាពទូទៅ

**៧៦-** ប្រតិបត្តិការបង់រំលស់ សំដៅដល់សកម្មភាពនៃការទិញលក់អចលនទ្រព្យ ចលនទ្រព្យ ទំនិញ និងសេវាគ្រប់ប្រភេទ ដែលការទូទាត់តម្លៃនៃការទិញលក់ត្រូវធ្វើឡើងតាមគ្រា ដែលបានកំណត់ជាមុននៅក្នុងកិច្ចសន្យាទិញលក់។ សកម្មភាពផ្តល់សេវាបង់រំលស់ជូនអតិថិជន បាននិងកំពុងរីកដុះដាល ដោយគ្មានការគ្រប់គ្រង។ បច្ចុប្បន្ន ប្រតិបត្តិករបង់រំលស់ទាំងនេះ បានរួមចំណែកបង្កើត

នូវការផ្តល់ជម្រើសក្នុងការទូទាត់ ដើម្បីសម្រួលដល់លទ្ធភាពក្នុងការទិញលក់អចលនទ្រព្យ ចលនទ្រព្យ ទំនិញ និងសេវា រួមមាន ការទិញលក់ឧបករណ៍សម្រាប់បម្រើក្នុងវិស័យកសិកម្ម និងឧស្សាហកម្ម។

## ខ. ចន្លោះនភាព និងសមិទ្ធផល

**៧៧-** ប្រតិបត្តិការបង់រំលស់ បានចូលរួមចំណែកក្នុងការបង្កើនអត្រាបរិយាបន្នហិរញ្ញវត្ថុរហូតដល់ ៧១% ដោយបូកបញ្ចូលសេវាហិរញ្ញវត្ថុក្នុង និងក្រៅប្រព័ន្ធក្នុងឆ្នាំ២០១៦ ។ ស្របពេលជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលបានតាមដានការវិវត្តនៃប្រតិបត្តិការនេះ និងបានសិក្សាវាយតម្លៃ ដើម្បីពិនិត្យលទ្ធភាពក្នុងការរៀបចំបទប្បញ្ញត្តិគ្រប់គ្រង និងត្រួតពិនិត្យ ។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**៧៨-** ភាពខ្វះចន្លោះនៅក្នុងការគ្រប់គ្រងប្រតិបត្តិការបង់រំលស់ អាចនឹងរារាំងដល់ការសម្រេចបាននូវទស្សនវិស័យនៃទីផ្សារហិរញ្ញវត្ថុ ប្រកបដោយការប្រកួតប្រជែងដោយត្រឹមត្រូវ និងស្មើភាព និងរក្សាបាននូវស្ថិរភាពហិរញ្ញវត្ថុ។ ប្រតិបត្តិការបង់រំលស់ដែលគ្មានការគ្រប់គ្រងនឹងបង្កឲ្យមានបញ្ហាប្រឈមដូចខាងក្រោម៖

- ការប្រកួតប្រជែងមិនត្រឹមត្រូវ និងស្មើភាពរវាងប្រតិបត្តិករបង់រំលស់ និងប្រតិបត្តិករធនាគារ និងប្រតិបត្តិករហិរញ្ញវត្ថុដទៃទៀត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ និងការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា
- កង្វះកិច្ចការពារអ្នកប្រើប្រាស់ ស្របតាមគោលការណ៍នៃកិច្ចការពារអ្នកប្រើប្រាស់
- កង្វះការវិភាគត្រឹមត្រូវនូវលទ្ធភាពបង់រំលស់ ដែលអាចបង្កឲ្យអតិថិជនមានបំណុលវ័ណ្ឌក
- ការរីករាលដាលនៃសកម្មភាពធនាគារស្រមោល

## ឃ. យុទ្ធសាស្ត្រនិងផែនការអនាគត

**៧៩-** ធនាគារជាតិនៃកម្ពុជានឹង: (១) រៀបចំគោលនយោបាយ និងដាក់ចេញនូវបទប្បញ្ញត្តិសមស្រប សម្រាប់គ្រប់គ្រងប្រតិបត្តិការបង់រំលស់ (២) រៀបចំយន្តការកិច្ចការពារអ្នកប្រើប្រាស់ (៣) រៀបចំឲ្យមានការបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់សាធារណជនអំពីលក្ខខណ្ឌសមស្របនៃប្រតិបត្តិការបង់រំលស់ រួមមាន អត្រាការប្រាក់ សិទ្ធិអ្នកផ្តល់ និងអ្នកទទួល និងឯកសារគតិយុត្តចាំបាច់ផ្សេងទៀត និង (៤) សហការជាមួយនឹងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំយន្តការ និងបទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងទាក់ទងនឹងប្រតិបត្តិការបង់រំលស់។

## IV. **ទីផ្សារអន្តរធនាគារ និងទីផ្សាររូបិយវត្ថុ**

### **ក.ទិដ្ឋភាពទូទៅ**

**៨០-** ការអភិវឌ្ឍទីផ្សារអន្តរធនាគារនិងទីផ្សាររូបិយវត្ថុមានសារៈសំខាន់ណាស់ក្នុងការផ្តល់ឱកាសឲ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗទៀតគ្រប់គ្រងសន្ទនីយភាពរបស់ខ្លួន។ ធនាគារជាតិនៃកម្ពុជាកំពុងអភិវឌ្ឍមូលបត្រអាចជួញដូរបាន (Negotiable Certificate of Deposits) ឲ្យក្លាយជាឧបករណ៍មួយក្នុងការគាំទ្រគោលនយោបាយរូបិយវត្ថុ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាននិងកំពុងរៀបចំអភិវឌ្ឍក្របខ័ណ្ឌបទប្បញ្ញត្តិ និងយន្តការស្ថាប័នសម្រាប់ទីផ្សារមូលបត្ររដ្ឋ។

### **ខ. វឌ្ឍនភាព និងសមិទ្ធផល**

**៨១-** ធនាគារជាតិនៃកម្ពុជាបានចេញផ្សាយមូលបត្រអាចជួញដូរបានជាប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិកទៅតាមសំណើរបស់អតិថិជន។ ទន្ទឹមនឹងនេះ ធនាគារអាចប្រើមូលបត្រអាចជួញដូរបានដាក់ជាប្រាតិភោគសម្រាប់ទទួលបានសន្ទនីយភាពនៅក្នុងសភាផាត់ទាត់ផងដែរ។ មូលបត្រនេះអាចជួញដូរបានដោយសេរីក្នុងចំណោមសមាជិកដែលបានចុះបញ្ជីទាំងអស់ និងអាចត្រូវបានទទួលទិញត្រឡប់វិញដោយធនាគារជាតិនៃកម្ពុជា តាមរយៈPlatform ដែលបានផ្តល់ឲ្យដោយធនាគារជាតិនៃកម្ពុជា។

**៨២-** ធនាគារជាតិនៃកម្ពុជា បានចេញផ្សាយនូវប្រកាសសម្រាប់កិច្ចសន្យាទទួលទិញវិញក្នុងទីផ្សារអន្តរធនាគារ និងកិច្ចសន្យាទទួលទិញវិញរបស់ធនាគារជាតិនៃកម្ពុជា និងកិច្ចសន្យាមេទទួលទិញវិញ។

**៨៣-** ដើម្បីអនុវត្តច្បាប់ស្តីពីមូលបត្ររដ្ឋដែលបានអនុម័តក្នុងឆ្នាំ២០០៧ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាននិងកំពុងបន្តការងាររៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធ លំហូរប្រតិបត្តិការមូលបត្ររដ្ឋ និងសិក្សាអំពីសមិទ្ធិលទ្ធភាពក្នុងការបោះផ្សាយមូលបត្ររដ្ឋផងដែរ។

**៨៤- គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ**ដំណើរការអភិវឌ្ឍទីផ្សារអន្តរធនាគារនិងរូបិយវត្ថុកំពុងស្ថិតក្នុងដំណាក់កាលដំបូង ដែលនៅមានកង្វះយន្តការនៃកំណត់អត្រាការប្រាក់ កង្វះមន្ត្រីជំនាញដែលមានចំណេះដឹង និងឯកទេសពាក់ព័ន្ធ និងកង្វះខាតឧបករណ៍ហិរញ្ញវត្ថុដទៃទៀតដែលអាចផ្តល់ជាជម្រើសសម្រាប់ទីផ្សារ។

**៨៥-** ការយល់ដឹងរបស់អ្នកចូលរួមទីផ្សារនៅមានកម្រិត ដែលតម្រូវឲ្យមានការពង្រីកការយល់ដឹងឲ្យកាន់តែទូលំទូលាយ។

### ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត

**៨៦- មូលបត្ររដ្ឋ:** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុជាសេនាធិការ នឹងរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិ និងយន្តការស្ថាប័នពាក់ព័ន្ធនឹងការបោះផ្សាយ និងការគ្រប់គ្រងប្រតិបត្តិការមូលបត្ររដ្ឋ។

**៨៧-** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តធ្វើការសិក្សាអំពីសមិទ្ធិលទ្ធភាព ក្នុងការបោះផ្សាយមូលបត្ររដ្ឋ និងរៀបចំឯកសារយុទ្ធសាស្ត្រស្ដីពីការបោះផ្សាយមូលបត្ររដ្ឋ។

**៨៨- ការពង្រីកការចូលរួមនៅក្នុងទីផ្សារ:** នាពេលអនាគត ការអភិវឌ្ឍប្រព័ន្ធទូទាត់អន្តរធនាគារ និងទីផ្សារពាក់ព័ន្ធ នឹងរួមបញ្ចូលទាំងការផ្តល់លទ្ធភាពចូលរួមបន្ថែមពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន និងក្រុមហ៊ុនមូលបត្រធំៗដែលធ្វើការជួញដូរឲ្យអ្នកវិនិយោគដែលជាស្ថាប័ន។

**៨៩- ការផ្តល់ឥណទានដល់ធនាគារតាមអត្រាការប្រាក់គោលដែលបានកំណត់ (Cash Rate):** ធនាគារជាតិនៃកម្ពុជាកំពុងស្វែងរកវិធី ដែលអាចឲ្យធនាគារគ្រប់គ្រងសន្ទនីយភាពប្រកបដោយភាពទន់ភ្លន់របស់ខ្លួន។ ក្រៅពីយន្តការផ្តល់សន្ទនីយភាពនៅក្នុងសភាផាត់ទាត់របស់ខ្លួននាពេលបច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជា នឹងពិនិត្យមើលឡើងវិញនូវលទ្ធភាពផ្តល់ការគាំទ្របន្ថែម ពាក់ព័ន្ធនឹងមធ្យោបាយផ្តល់កម្ចីជាប្រាក់រៀលតាមអត្រាការប្រាក់គោលមូលដ្ឋាន ដើម្បីជំរុញការប្រើប្រាស់ប្រាក់រៀល និងក្លាយទៅជាឧបករណ៍គោលនយោបាយរូបិយវត្ថុមួយ។

## V. ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ

### ក. ទិដ្ឋភាពទូទៅ

**៩០-** ការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចកម្ពុជា បន្តជំរុញកំណើននៃចំនួនក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ។ ជាក់ស្ដែង ក្នុងឆ្នាំ២០១២ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុតែមួយប៉ុណ្ណោះបានទទួលអាជ្ញាបណ្ណប្រកបអាជីវកម្មភតិសន្យាហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា ដែលបានផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុក្នុងទឹកប្រាក់ចំនួន១៤៨ ០០០ដុល្លារអាមេរិក។ រហូតមកដល់ឆ្នាំ២០១៥ ចំនួនក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុបានកើនឡើងរហូតដល់៩ក្រុមហ៊ុន ដែលបានផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ ក្នុងទឹកប្រាក់ចំនួន៨៥,៥លានដុល្លារអាមេរិក។

**៩១-** បច្ចុប្បន្ន សាធារណជនមានការភ័ន្តច្រឡំគ្នាលើការប្រើប្រាស់ពាក្យ "ភតិសន្យាហិរញ្ញវត្ថុ" និងពាក្យ "ភតិសន្យា"។ ការភ័ន្តច្រឡំនេះបណ្តាលមកពីការប្រើប្រាស់ពុំមានភាពស៊ីចង្វាក់គ្នាក្នុងវាក្យសព្ទ

ច្បាប់ដែលគ្របដណ្តប់លើប្រតិបត្តិការភតិសន្យា។ ដើម្បីដោះស្រាយភាពមិនស៊ីចង្វាក់គ្នានេះ គួរប្រើពាក្យ "ភតិសន្យាហិរញ្ញវត្ថុ" ក្នុងប្រតិបត្តិការអាជីវកម្ម។

## ខ. វឌ្ឍនភាពនិងសមិទ្ធផល

**៩២-** ចាប់តាំងពីបានដាក់ឲ្យអនុវត្តច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុក្នុងឆ្នាំ២០០៩ និងការចេញផ្សាយប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុក្នុងឆ្នាំ២០១១ ចំនួនក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុបានកើនឡើងរហូតដល់៩ក្រុមហ៊ុន និងធនាគារពាណិជ្ជមួយ ត្រូវបានផ្តល់សិទ្ធិដោយធនាគារជាតិនៃកម្ពុជា ក្នុងការផ្តល់សេវាកម្មភតិសន្យាហិរញ្ញវត្ថុនេះផងដែរ។

**៩៣-** ក្រុមការងារអន្តរក្រសួងដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាប្រធាន បានប្រជុំដោះស្រាយការអនុវត្តច្បាប់និងបទប្បញ្ញត្តិផ្សេងៗទាក់ទងនឹងអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ដូចជា ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីការដាក់ឲ្យអនុវត្តក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ។ ក្រុមការងារអន្តរក្រសួងបានយល់ស្របឲ្យមានការពិនិត្យនិងធ្វើវិសោធនកម្មឡើងវិញលើច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ដើម្បីសម្រួលដល់ការរឹបអូសចលនទ្រព្យដែលធានាលើភតិសន្យាហិរញ្ញវត្ថុត្រឡប់មកវិញ ដោយពុំចាំបាច់ត្រូវឆ្លងកាត់នីតិវិធីរបស់តុលាការ។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**៩៤- ការរឹបអូសចលនទ្រព្យដែលធានាលើភតិសន្យាហិរញ្ញវត្ថុ:** ជាទូទៅ គុណសម្បត្តិដ៏សំខាន់នៃភតិសន្យា គឺភតិបតីមានសិទ្ធិរឹបអូសយកចលនទ្រព្យ ដែលធានាលើភតិសន្យាហិរញ្ញវត្ថុពីភតិកៈត្រឡប់មកវិញភ្លាមៗ ក្នុងករណីដែលភតិកៈខកខានមិនបានបង់ប្រាក់សង ឬមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះភតិបតី។ ក្នុងការអនុវត្ត ភតិបតីមិនអាចរឹបអូសទ្រព្យមកវិញបាន ដោយសារក្នុងក្រមរដ្ឋប្បវេណី ការរឹបអូសទ្រព្យសម្បត្តិត្រូវឆ្លងកាត់នីតិវិធីរបស់តុលាការ។

**៩៥- ក្របខ័ណ្ឌបទប្បញ្ញត្តិ:** ក្របខ័ណ្ឌបទប្បញ្ញត្តិក្នុងការត្រួតពិនិត្យភតិសន្យាហិរញ្ញវត្ថុ ចាំបាច់ត្រូវតែពិនិត្យមើលឡើងវិញ។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជា បានដាក់ឲ្យអនុវត្តជាបណ្តោះអាសន្ននូវបទប្បញ្ញត្តិប្រុងប្រយ័ត្ន និងទម្រង់នៃរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីត្រួតពិនិត្យក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ។

## ឃ. យុទ្ធសាស្ត្រនិងផែនការអនាគត

**៩៦- ការផ្តោតលើបទប្បញ្ញត្តិក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ជាជាងផលិតផលភតិសន្យាហិរញ្ញវត្ថុ:** ច្បាប់ និងបទប្បញ្ញត្តិមួយចំនួននឹងត្រូវធ្វើវិសោធនកម្ម ដើម្បីឆ្លុះបញ្ចាំងពីបទប្បញ្ញត្តិចំពោះក្រុមហ៊ុនដែលផ្តល់ភតិសន្យាហិរញ្ញវត្ថុទៅសាធារណជន ជាជាងទៅលើផលិតផលភតិសន្យាហិរញ្ញវត្ថុ (ដូចជា

ពាក្យ "ភតិសន្យាហិរញ្ញវត្ថុ" នឹងមានការលំបាកក្នុងការអនុវត្ត ប្រសិនបើមិនមានកំណត់និយមន័យក្នុងច្បាប់ឲ្យបានច្បាស់លាស់)។ ការអនុវត្តបែបនេះ នឹងផ្តល់ក្របខ័ណ្ឌបទប្បញ្ញត្តិដែលរឹងមាំមួយដើម្បីដោះស្រាយលើ (១) បញ្ហាប្រឈមដែលកើតឡើងក្នុងអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ និង (២) ឧបករណ៍ហិរញ្ញវត្ថុថ្មីៗដែលមានលក្ខណៈស្មុគស្មាញ និងត្រូវបានបង្កើតក្នុងទីផ្សារនៅពេលអនាគត។

**៩៧- ការរឹបអូសនិងការរក្សាទុកចលនទ្រព្យភតិសន្យា**: ការអនុវត្តច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា នឹងត្រូវពិនិត្យមើលឡើងវិញ ថាតើមានតម្រូវការចាំបាច់អ្វីខ្លះក្នុងការរឹបអូស និងការរក្សាទុកចលនទ្រព្យភតិសន្យាដែលស្របទៅនឹងកិច្ចសន្យាភតិសន្យាហិរញ្ញវត្ថុ។

**៩៨- ក្របខ័ណ្ឌបទប្បញ្ញត្តិ**: ធនាគារជាតិនៃកម្ពុជា នឹងពង្រឹងបទប្បញ្ញត្តិប្រុងប្រយ័ត្ននានា ដើម្បីកាត់បន្ថយហានិភ័យក្នុងអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ និងទម្រង់របាយការណ៍ ដើម្បីទទួលបានព័ត៌មានគ្រប់គ្រាន់ពីប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ។

# ជំពូកទី៣
# វិស័យមិនមែនធនាគារ

## I. ទីផ្សារមូលធន

### ក.ទិដ្ឋភាពទូទៅ

**៩៩-** គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) ដែលជានិយ័តករមូលបត្រ ត្រូវបានបង្កើតឡើង នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ ក្រោមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។ ចំណែកឯ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ត្រូវបានបង្កើតឡើងដោយការរួមទុនគ្នារវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ នឹងបានដាក់សម្ពោធជាផ្លូវការនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១។ ចាប់តាំងពីពេលដាក់ឲ្យដំណើរការមក ទាំង **គ.ម.ក.** និង **ផ.ម.ក.** ប្រតិបត្តិមុខងាររបស់ខ្លួនដោយរលូន និងគួរឲ្យជឿទុកចិត្ត ដោយគ្មានបញ្ហាគួរឲ្យកត់សម្គាល់ណាមួយកើតឡើងនោះទេ។

**១០០-** ទីផ្សារមូលបត្រមានវឌ្ឍនភាពប្រកបដោយស្ថិរភាព ក៏ប៉ុន្តែទីផ្សារនេះកំពុងស្ថិតនៅក្នុងដំណាក់កាលអភិវឌ្ឍ និងកសាងសមត្ថភាព។

### ខ. វឌ្ឍនភាពនិងសមិទ្ធផល

**១០១-** ច្បាប់ បទប្បញ្ញត្តិនានា និងវិធានចុះបញ្ជីត្រូវបានដាក់ឲ្យអនុវត្ត ដើម្បីគ្រប់គ្រងមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល ព្រមទាំងឧបករណ៍ដែលអាចបំលែងទៅជាមូលបត្រផ្សេងៗទៀតបាន ឬឧបករណ៍និស្សន្ទដែលធ្វើការបោះផ្សាយលក់ជាសាធារណៈ និងចុះបញ្ជីនៅលើទីផ្សារ។ ការជួញដូរនៅលើ ផ.ម.ក. បានចាប់ផ្តើម នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ ជាមួយនឹងការចុះបញ្ជីរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលជាសហគ្រាសសាធារណៈ។ រោងចក្រកាត់ដេរដែលកាន់កាប់ដោយវិស័យឯកជន គឺក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ីនធឺណេសិុនណាល់ (Grand Twins International) បានចុះបញ្ជីជួញដូរនៅលើទីផ្សារនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤។ ចំណែកឯការចុះបញ្ជីរបស់សហគ្រាសទី៣ កំពង់ផែស្វយតភ្នំពេញ ដែលជាសហគ្រាសសាធារណៈ បានធ្វើឡើងនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ ហើយតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ជាក្រុមហ៊ុនចុះបញ្ជីទី៤ បានធ្វើឡើងនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦។ ព្រមជាមួយគ្នានេះ ក៏មានក្រុមហ៊ុនជាច្រើនទៀតដែលកំពុងរៀបចំខ្លួនដើម្បីចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា។

**១០២- ផែនការដើម្បីបង្កើនការចុះបញ្ជីនៅលើទីផ្សារ:** ការបង្កើនចំនួនក្រុមហ៊ុនចុះបញ្ជីជួញដូរនៅលើទីផ្សារត្រូវបានផ្តោតការយកចិត្តទុកដាក់ខ្ពស់តាមរយៈការអភិវឌ្ឍ និងការអនុវត្តផែនការជំរុញការចុះ

បញ្ជីនៅលើទីផ្សារ។ ការផ្តល់ការលើកទឹកចិត្តនានាដល់ក្រុមហ៊ុនចុះបញ្ជីជួញដូរនៅលើទីផ្សារ ដូចជាការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យមូលបត្រ ត្រូវបានដាក់ឲ្យអនុម័ត និងផ្សព្វផ្សាយព្រមជាមួយនឹងការដាក់ឲ្យអនុវត្តកម្មវិធីជំរុញការយល់ដឹងជាសាធារណៈ។ ការសម្របសម្រួលដើម្បីជំរុញឲ្យមានក្រុមហ៊ុនចុះបញ្ជីជួញដូរច្រើននៅលើទីផ្សារ និងមកពីវិស័យចម្រុះ ត្រូវបានធ្វើឡើងប្រកបដោយកិច្ចខិតខំប្រឹងប្រែងខ្ពស់។ វិធាននិងប្រព័ន្ធសម្រាប់ជួញដូរ ត្រូវបានអភិវឌ្ឍឲ្យប្រសើរឡើង នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៤ ដើម្បីជួយសម្រួលដល់ការជួញដូរជានិរន្តរ៍ បន្ថែមទៅលើការជួញដូរថ្លៃតែមួយ និងការជួញដូរមុនការទូទាត់។ **គ.ម.ក.** បានធ្វើវិសោធនកម្មបទប្បញ្ញត្តិ នៅក្នុងខែកញ្ញា ឆ្នាំ២០១៥ ដើម្បីលើកទឹកចិត្តដល់ក្រុមហ៊ុនធ្វើការចុះបញ្ជីជួញដូរនៅលើទីផ្សារ ដោយធ្វើការបែងចែកទីផ្សារជាពីរប្រភេទ (ទីផ្សារគោល (Main Board) សម្រាប់សហគ្រាសធុនធំ និងទីផ្សារកំណើន (Growth Board) សម្រាប់សហគ្រាសធុនតូច និងមធ្យម) តាមរយៈការផ្តល់ភាពងាយស្រួល ក្នុងការចូលទីផ្សារសម្រាប់សហគ្រាសធុនតូច និងមធ្យម និងកាត់បន្ថយលក្ខខណ្ឌអប្បបរមា ព្រមទាំងលក្ខខណ្ឌតម្រូវលើរបាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ។

**១០៣- ក្របខ័ណ្ឌបទប្បញ្ញត្តិ:** អនុក្រឹត្យចំនួន១និងប្រកាសចំនួន១៨ ត្រូវបានអនុម័តក្នុងរយៈពេល ២ (ពីរ) ឆ្នាំកន្លងទៅនេះ។ ទន្ទឹមនឹងនេះដែរ សេចក្តីព្រាងអនុក្រឹត្យចំនួន១និងសេចក្តីព្រាងប្រកាសចំនួន២០ផ្សេងទៀតកំពុងស្ថិតនៅក្នុងដំណាក់កាលស្នើសុំការអនុម័ត ឬរៀបចំជាសេចក្តីព្រាង ក្នុងនោះរួមមាន សេចក្តីព្រាងអនុក្រឹត្យស្តីពីបុននីតិសម្បទា និងការជម្រះបញ្ជីក្នុងវិស័យមូលបត្រ ក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ភ្នាក់ងារវាយតម្លៃលទ្ធភាពសង និងក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ទីផ្សារសញ្ញាបណ្ណសាជីវកម្ម គម្រោងវិនិយោគរួម ព្រមទាំងការឲ្យខ្ចី និងការខ្ចីមូលបត្រដែលពាក់ព័ន្ធជាមួយនឹងការជួញដូរ និងការទូទាត់។ **គ.ម.ក.** បានធ្វើស្វ័យវាយតម្លៃស្របតាមគោលការណ៍ IOSCO ដូចបានកំណត់នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០។ នៅខែកក្កដា ឆ្នាំ២០១៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា និងគណៈកម្មការមូលបត្រកម្ពុជា បានចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការត្រៀមបង្ការ ការទប់ស្កាត់ និងការគ្រប់គ្រងវិបត្តិហិរញ្ញវត្ថុកម្ពុជា។

**១០៤- អ្នកចូលរួមនៅក្នុងទីផ្សារ:** កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០១០ **គ.ម.ក.** បានផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រចំនួន១៥ ក្រុមហ៊ុន។ **គ.ម.ក.** ក៏បានផ្តល់ការទទួលស្គាល់ដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ភ្នាក់ងារទូទាត់ក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវាក្នុងវិស័យមូលបត្រ និងសវនករឯករាជ្យ និងក្រុមហ៊ុនវាយតម្លៃផ្តល់សេវាក្នុងវិស័យមូលបត្រ។ នាពេលបច្ចុប្បន្ននេះ ក្រុមហ៊ុនមូលបត្រមានចំនួន១២ ដែលរួមមានក្រុមហ៊ុនធានាទិញចំនួន៦ ក្រុមហ៊ុនពាណិជ្ជករមូលបត្រចំនួន១ ឈ្មួញជើងសាមូលបត្រចំនួន៣ និងអ្នកផ្តល់ប្រឹក្សាវិនិយោគចំនួន២។ ក្នុងឆ្នាំ២០១៤ និងឆ្នាំ២០១៥ បុគ្គលចំនួន១១៨ រូបបានប្រឡងជាប់ទទួលស្គាល់គុណវុឌ្ឍិដែលរៀបចំដោយ **គ.ម.ក.**។

**១០៥- ការយល់ដឹងនិងការអប់រំជាសាធារណៈ: គ.ម.ក.** បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយវិទ្យាស្ថានហិរញ្ញវត្ថុកម្ពុជា ក្នុងខែមករា ឆ្នាំ២០១១ ដើម្បីផ្តល់ការបណ្តុះបណ្តាល និងអប់រំពាក់ព័ន្ធនឹងមូលបត្រដល់សាធារណជន។ ក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះ **គ.ម.ក.** បានធ្វើសិក្ខាសាលាស្តីពី "ការយល់ដឹងពីទីផ្សារមូលបត្រនៅកម្ពុជា" នៅ ២៥រាជធានីខេត្ត ដល់រដ្ឋបាលរាជធានីខេត្ត។ ព្រមជាមួយគ្នានេះ **គ.ម.ក.** ក៏បានធ្វើការយ៉ាងជិតស្និទ្ធជាមួយ **ផ.ម.ក.** និងក្រុមហ៊ុនមូលបត្រផ្សព្វផ្សាយពីមូលបត្រដល់សាធារណជន តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងការរៀបចំសិក្ខាសាលាតាមសាកលវិទ្យាល័យសមាគមធុរកិច្ច ក្រុមហ៊ុនសក្តានុពល និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ។ **គ.ម.ក.** ក៏បានបង្កើតមជ្ឈមណ្ឌលទទួលពាក្យបណ្តឹងនៅក្នុង **គ.ម.ក.** ផ្ទាល់ដើម្បីទទួលពាក្យបណ្តឹងពីសាធារណជនពាក់ព័ន្ធនឹងវិស័យមូលបត្រ។

**១០៦- ការពង្រឹងការអនុវត្តបទប្បញ្ញត្តិ:** នៅឆ្នាំ២០១៥ **គ.ម.ក.** បានអនុវត្តចំណាត់ការផ្លូវច្បាប់ចំពោះក្រុមហ៊ុនចំនួន១៥ ដែលធ្វើអាជីវកម្មលើឧបករណ៍និស្សន្ទដោយគ្មានអាជ្ញាបណ្ណ ព្រមទាំងបានចេញលិខិតផ្លូវការ ផ្អាកសកម្មភាពអាជីវកម្មពាក់ព័ន្ធនឹងគម្រោងវិនិយោគរួម ដោយគ្មានអាជ្ញាបណ្ណដល់ក្រុមហ៊ុនចំនួន២។

**១០៧- ការធ្វើសមាហរណកម្មហិរញ្ញវត្ថុអាស៊ាន: គ.ម.ក.** ជាអ្នកចូលរួមយ៉ាងសកម្មក្នុងវេទិកាទីផ្សារមូលធនអាស៊ាន (ACMF) និងក្រុមការងាររបស់វេទិកានេះ។ ក្រុមការងារនេះផ្តោតជាសំខាន់ទៅលើការធ្វើសុខដុមនីយកម្មនៃច្បាប់និងបទប្បញ្ញត្តិក្នុងស្រុក និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីផ្សារក្នុងទស្សនៈឆ្ពោះទៅរកសមាហរណកម្មទីផ្សារទុនក្នុងតំបន់។ **គ.ម.ក.** កំពុងសិក្សាពីបទដ្ឋានគតិយុត្ត ដើម្បីកំណត់ពីផ្នែកដែលត្រូវធ្វើសុខដុមនីយកម្ម ផ្នែកត្រូវផ្លាស់ប្តូរ ដើម្បីសម្រួលដល់ការបោះផ្សាយលក់មូលបត្រឆ្លងដែន និងការទទួលស្គាល់រួមក្នុងតំបន់។ តំណភ្ជាប់ទីផ្សារ អាចនឹងត្រូវបង្កើតឡើងនៅពេលដែលប្រតិបត្តិការទីផ្សារឈានដល់កម្រិតមួយ ដែលអាចទ្រទ្រង់ថ្លៃហេដ្ឋារចនាសម្ព័ន្ធទាំងនេះ។ ការធ្វើឲ្យប្រសើរឡើងនូវការផាត់ទាត់ នឹងជួយសម្រួលដល់ការផាត់ទាត់នៃការចុះបញ្ជីឆ្លងដែន។ កម្ពុជានឹងទទួលបានផលប្រយោជន៍ពីការគាំទ្រការកសាងសមត្ថភាព ដែលប្រទេសជាសមាជិកនឹងជួយដល់កម្ពុជា ដើម្បីអាចបំពេញទៅតាមការធ្វើសមាហរណកម្មបទដ្ឋានរបស់វេទិកាទីផ្សារមូលធនអាស៊ាន។

**១០៨- ការកសាងសមត្ថភាព:** គំនិតផ្តួចផ្តើមរបស់ **គ.ម.ក.** ពាក់ព័ន្ធនឹងការកសាងសមត្ថភាព អភិបាលកិច្ច និងការអប់រំ រួមមាន (១) ការផ្តល់ការបណ្តុះបណ្តាលដល់អ្នកសារព័ត៌មាន (២) ការកសាងសមត្ថភាពសម្រាប់មន្ត្រី **គ.ម.ក.** តាមរយៈការចូលរួមក្នុងកម្មវិធីផ្សេងៗដូចជា ការអនុវត្តការងារដល់ទីកន្លែង ការចូលរួមក្នុងសិក្ខាសាលា និងកម្មវិធីបណ្តុះបណ្តាលនៅបរទេស។ **គ.ម.ក.** ក៏បានផ្តល់ការបណ្តុះបណ្តាលផ្ទៃក្នុងដោយមានកិច្ចសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលអន្តរជាតិ ដូចជា មជ្ឈមណ្ឌលតូរ៉ុនតូ គំនិតផ្តួចផ្តើមសម្រាប់ការបណ្តុះបណ្តាលដល់និយតករហិរញ្ញវត្ថុ (FRTI) វិទ្យាស្ថានមូលបត្រថៃ

(TSI) និងអ្នកជំនាញការបរទេស។ បន្ថែមលើនេះទៅទៀត **គ.ម.ក.** បានត្រៀមនូវកញ្ចប់មូលនិធិសម្រាប់អាហារូបករណ៍អ្នកវិភាគហិរញ្ញវត្ថុជំនាញ (CFA) សម្រាប់មន្ត្រីរបស់ខ្លួនចំនួន៣រូប។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**១០៩-** បញ្ហាប្រឈមនាពេលបច្ចុប្បន្នសម្រាប់កិច្ចអភិវឌ្ឍទីផ្សារមូលបត្រ គឺការសម្រេចបាននូវសកម្មភាពផ្សេងៗ ដើម្បីគាំទ្រគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុទាំងមូល។ ការធ្វើទំនើបកម្ម និងការអភិវឌ្ឍទីផ្សារមូលបត្រក្នុងស្រុកចាំបាច់ ត្រូវផ្តោតជាសំខាន់លើការផ្តល់នូវៈ (១) សន្ទនីយភាពនៅក្នុងទីផ្សារ (២) ភាពសាមញ្ញ និងភាពដែលអាចបត់បែនបាន (៣) ការកាត់បន្ថយថ្លៃនៃការចូលទៅកាន់ទីផ្សារ (៤) ការរៀបចំ និងការដាក់ឲ្យអនុវត្តបទប្បញ្ញត្តិដ៏សមរម្យមួយ ដែលឆ្លើយតបទៅនឹងស្ថានភាពទីផ្សារ (៥) ការអប់រំវិនិយោគិន និង (៦) ប្រសិទ្ធភាពនៃប្រព័ន្ធ និងបទដ្ឋានដើម្បីគាំទ្រដល់ការអភិវឌ្ឍថ្មីៗ។ កម្ពុជានឹងទទួលបាននូវផលចំណេញពីផែនការ និងបទដ្ឋានដែលរៀបចំដោយក្រុមការងាររបស់ស្ថាប័នពាក់ព័ន្ធនៅក្នុងក្របខ័ណ្ឌអាស៊ាន។

## ឃ. យុទ្ធសាស្ត្រនិងផែនការអនាគត

**១១០-** ប្រទេសកម្ពុជាមានឱកាសវិនិយោគនិងសន្សំក្នុងស្រុកតិចតួចសម្រាប់ប្រជាជន។ ដូច្នេះ ប្រជាជនរក្សាទុកសាច់ប្រាក់ដោយខ្លួនឯង ដាក់ប្រាក់បញ្ញើនៅធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ឬវិនិយោគទៅក្រៅប្រទេស។ គោលដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលផ្តោតលើការបង្វែរប្រាក់សន្សំក្នុងស្រុកទៅជាការវិនិយោគក្នុងស្រុក កាត់បន្ថយការពឹងផ្អែកលើប្រភពមូលនិធិក្រៅប្រទេស និងកាត់បន្ថយលំហូរប្រាក់សន្សំក្នុងស្រុកទៅវិនិយោគក្រៅប្រទេស។ ដូច្នេះទីផ្សារមូលបត្រក្នុងស្រុកដែលមានភាពរស់រវើក និងប្រសិទ្ធភាពជាតម្រូវការចាំបាច់ ដើម្បីអនុវត្តគោលនយោបាយនេះ។

**១១១-** ជាផ្នែកមួយនៃការជំរុញរបស់រាជរដ្ឋាភិបាល ក្នុងការពង្រីកការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុ **គ.ម.ក.** នឹងជំរុញការចុះបញ្ជីក្រុមហ៊ុន សម្រាប់ការវិនិយោគសាធារណៈ។ អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងមូលបត្រ **គ.ម.ក.** នឹងជំរុញប្រតិបត្តិការនៃគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ និងគម្រោងវិនិយោគរួម ដែលបង្កើតមូលនិធិវិនិយោគរួម និងធ្វើការវិនិយោគមូលនិធិទាំងនោះក្នុងរយៈពេលវែងដូចជា៖ មូលនិធិធានារ៉ាប់រង មូលនិធិសោធននិវត្តនិងមូលនិធិសង្គមផ្សេងទៀត។ ច្បាប់ស្តីពីបរធនបាលកិច្ច ដែលនឹងត្រូវអនុម័តក្នុងរយៈពេលខ្លីខាងមុខ នឹងគាំទ្រដល់ការអភិវឌ្ឍនេះ។ សកម្មភាពវិនិយោគប្រកបដោយវិជ្ជាជីវៈ នឹងត្រូវបានលើកទឹកចិត្ត ដោយអាចនឹងមានមូលនិធិរដ្ឋាភិបាលត្រូវបានដាក់ឲ្យស្ថិតក្រោមបរធនបាល និងយកទៅវិនិយោគ ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ដែលបានព្រមព្រៀងគ្នា។

**១១២-** រាជរដ្ឋាភិបាល មានបំណងជំរុញការអភិវឌ្ឍ និងពង្រីកវិសាលភាពវិស័យមូលបត្រដោយធ្វើការជម្រុះចេញនូវឧបសគ្គសម្រាប់ការចុះបញ្ជីលក់មូលបត្ររបស់ស្ថាប័នហិរញ្ញវត្ថុមួយចំនួនធំ។ **គ.ម.ក.** ស្នើសុំរាជរដ្ឋាភិបាលផងដែរ ដើម្បីពន្លឿនការអភិវឌ្ឍ និងធ្វើពិពិធកម្មវិស័យមូលបត្រ ដោយលើកទឹកចិត្ត ឬតម្រូវឲ្យសហគ្រាសទាំងនោះធ្វើការចុះបញ្ជីលក់មូលបត្រ។ ស្ថាប័នពាក់ព័ន្ធដទៃទៀតដែលកំពុងស្វែងរកការចុះបញ្ជីលក់មូលបត្រ ក៏គួរទទួលបានការអនុញ្ញាតផងដែរ តាមរយៈការបង្កើនដើមទុន និងទុនបម្រុងរបស់ស្ថាប័ន ការបោះផ្សាយលក់មូលបត្រជាសាធារណៈ (មិនតិចជាង២០%នៃមូលធនភាគទុនិកសរុបរបស់ស្ថាប័ន) ឬការរៀបចំសម្រាប់វិនិយោគិនដែលកំពុងកាន់កាប់មូលបត្រ លក់ចំណែកមូលបត្រកម្មសិទ្ធិរបស់ខ្លួនបាន ។

**១១៣- គ.ម.ក.** នឹង (១) ធ្វើការរួមគ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីតាមដានទៅលើជម្រើសសម្រាប់ការចុះបញ្ជីលក់មូលបត្ររបស់សហគ្រាសសាធារណៈបន្ថែម ឬបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមរបស់សហគ្រាសសាធារណៈ រួមមាន ការពិនិត្យមើលឡើងវិញទៅលើភ្នាក់ងារ ដើម្បីពិនិត្យមើលលទ្ធភាពរបស់សហគ្រាសសាធារណៈ និងផ្តោតសំខាន់ទៅលើការគ្រប់គ្រង ការរៀបចំសម្រាប់ការចុះបញ្ជីមូលបត្រកម្មសិទ្ធិបន្ថែម (២) ពិនិត្យឡើងវិញ និងរៀបចំចំណាត់ការសមស្របសម្រាប់ការខ្ចី និងការឲ្យខ្ចីមូលបត្រ ដោយការពិចារណាលើលទ្ធភាពបង្កើតសាជីវកម្មហិរញ្ញវត្ថុមូលបត្រ និង (៣) ធ្វើការរួមគ្នាជាមួយភ្នាក់ងារ និងភាគីពាក់ព័ន្ធ ដើម្បីជាជំនួយក្នុងការបង្កើតទីផ្សាររូបវន្ត សម្រាប់ទីផ្សារខុម៉ូឌីធីនៅក្នុងប្រទេសកម្ពុជា ដើម្បីគាំទ្រដល់ការអភិវឌ្ឍទីផ្សារខុម៉ូឌីធី និងទីផ្សារឧបករណ៍និស្សន្ទនៅពេលអនាគត។ ជំហាននៃការអភិវឌ្ឍបន្ទាប់អាចពាក់ព័ន្ធនឹងការពង្រីកក្របខ័ណ្ឌសម្រាប់ឧបករណ៍និស្សន្ទ គ្របដណ្តប់ដល់ទីផ្សារឧបករណ៍និស្សន្ទ និងទីផ្សារកិច្ចសន្យាអុបសិន និងកិច្ចសន្យានិស្សន្ទដែលគាំទ្រដល់ការកំណត់ថ្លៃ និងការគ្រប់គ្រងហានិភ័យ។

**១១៤-** ដើម្បីផ្តល់ភាពកាន់តែងាយស្រួលចំពោះការចូលទៅកាន់ទីផ្សារមូលបត្រ **គ.ម.ក.**នឹង ៖ (១) ពិនិត្យឡើងវិញ និងរៀបចំសម្រួលនីតិវិធី និងបទប្បញ្ញត្តិសម្រាប់ការចុះបញ្ជីរបស់សហគ្រាសធុនតូច និងមធ្យម (២) ពិនិត្យទៅលើយោបល់ក្នុងការសម្រួលមាតិកានៃឯកសារផ្តល់ព័ត៌មាន និងកែសម្រួលនូវបទប្បញ្ញត្តិ និងនីតិវិធីសម្រាប់ការបោះផ្សាយលក់មូលបត្រក្នុងចំនួនតិច និងការចុះបញ្ជីលក់មូលបត្ររបស់ស្ថាប័នហិរញ្ញវត្ថុឲ្យកាន់តែមានភាពសាមញ្ញ និងងាយស្រួល និង (៣) ធ្វើការស្រាវជ្រាវ និងបង្កើតក្របខ័ណ្ឌគតិយុត្តសម្រាប់ក្រោដហ្វាន់ឌីង និងផ្តល់អាជ្ញាបណ្ណដល់អ្នកផ្តល់សេវា និងវេទិកាក្រោដហ្វាន់ឌីងជាមួយនឹងការបន្តពិនិត្យកិច្ចការពារវិនិយោគិន និងការតភ្ជាប់ទីផ្សារ។

**១១៥-** ដើម្បីធ្វើឲ្យប្រសើរឡើងចំពោះការលើកទឹកចិត្តការចូលរួមនៅក្នុងទីផ្សារមូលបត្រ **គ.ម.ក.** នឹងធ្វើការជាមួយអគ្គនាយកដ្ឋានពន្ធដារ ដើម្បីពិនិត្យឡើងវិញលើអនុក្រឹត្យស្តីពីពន្ធដារ ដែលរួមបញ្ចូលទាំងការពិនិត្យឡើងវិញពីបញ្ហាពន្ធដារ ដែលក្រុមហ៊ុនមានចំណាប់អារម្មណ៍ចុះបញ្ជីជួញដូរនៅលើ

ទីផ្សារមូលបត្រកំពុងជួបប្រទះ និងការពិចារណាលើការផ្តល់នូវផលប្រយោជន៍សម្រាប់ក្រុមហ៊ុនចុះបញ្ជី ដែលអាចនឹងស្មើ ឬដូចនឹងការលើកទឹកចិត្ត ដែលផ្តល់ទៅឲ្យគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ (QIP)។ **គ.ម.ក.** នឹងធ្វើការស្រាវជ្រាវពីការលើកទឹកចិត្តមិនមែនពន្ធដារ និងដាក់ឲ្យអនុវត្តគោលនយោបាយលើកទឹកចិត្តមិនមែនពន្ធដារ។ **គ.ម.ក.** នឹងពិនិត្យឡើងវិញ ដើម្បីឲ្យច្បាស់ថាច្បាប់ ឬបទប្បញ្ញត្តិ ដែលគ្របដណ្តប់វិស័យមូលបត្ររួមបញ្ចូលការប្រឆាំងអំពើពុករលួយ។

**១១៦-** ដើម្បីជំរុញស្ថិរភាព និងទំនុកចិត្តក្នុងទីផ្សារ **គ.ម.ក.** នឹង (១) ធ្វើបច្ចុប្បន្នកម្ម និងអនុវត្តកម្មវិធីបណ្តុះបណ្តាលវិនិយោគិន និងបញ្ជ្រាបការយល់ដឹងដល់សាធារណជន តាមរយៈយោបល់ និងតម្រូវ-ការអភិវឌ្ឍទីផ្សារ/តម្រូវការទីផ្សារ និងសហការជាមួយក្រសួងអប់រំយុវជន និងកីឡា លើការបញ្ចូលមូលដ្ឋានគ្រឹះហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាជាតិ (២) គាំទ្រសមាហរណកម្មហិរញ្ញវត្ថុអាស៊ាន តាមរយៈការពិនិត្យ និងបន្សុីបទប្បញ្ញត្តិចុះបញ្ជីលក់មូលបត្រ និងទីផ្សារមូលបត្រជាមួយបទដ្ឋាន និងគោលការណ៍របស់អាស៊ាន រួមទាំង បទប្បញ្ញត្តិស្តីពីការដោះស្រាយវិវាទ និងសហការដើម្បីឆ្ពោះទៅដល់ការទទួលស្គាល់គ្នាទៅវិញទៅមកលើការផ្តល់អាជ្ញាបណ្ណដល់អ្នកចូលរួមក្នុងទីផ្សារមូលបត្រ (៣) សហការជាមួយក្រុមប្រឹក្សាជាតិគណនេយ្យ ដើម្បីពង្រឹងការត្រួតពិនិត្យក្រុមហ៊ុនគណនេយ្យជំនាញ ដែលទទួលបានការទទួលស្គាល់ក្នុងការផ្តល់សេវាក្នុងវិស័យមូលបត្រ (៤) បំពេញការងារពាក់ព័ន្ធនឹងការដោះស្រាយវិវាទដោយយោងតាមបទដ្ឋានអាស៊ាន និងគោលការណ៍ណែនាំ ក្នុងការគាំទ្រការបោះផ្សាយ និងការចុះបញ្ជីលក់មូលបត្រឆ្លងដែន ព្រមទាំងពិនិត្យកែសម្រួលបទប្បញ្ញត្តិ និងនីតិវិធីដោះស្រាយវិវាទផ្លូវការ (៥) ពង្រឹងកិច្ចសហប្រតិបត្តិការ តាមរយៈការចុះអនុស្សរណៈយោគយល់គ្នា សម្រាប់ការចែករំលែកព័ត៌មាន និងសហប្រតិបត្តិការនៃប្រព័ន្ធផាត់ទាត់និងទូទាត់ ជាមួយនឹងធនាគារជាតិនៃកម្ពុជា និងពង្រឹងភាពជាដៃគូ និងសហប្រតិបត្តិការទៅវិញទៅមកជាមួយនឹងនិយតករ និងផ្សារមូលបត្របរទេស (៦) បន្តផ្សព្វផ្សាយ និងផ្តល់ការបណ្តុះបណ្តាលស្តីពីអភិបាលកិច្ចសាជីវកម្ម និងបទដ្ឋានអភិបាលកិច្ច និង (៧) ដឹកនាំការវាយតម្លៃអំពីលទ្ធភាពក្នុងការចូលជាសមាជិក IOSCO។

**១១៧-** ដើម្បីបន្តការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ **គ.ម.ក.** នឹង (១) បញ្ចប់ការរៀបចំបទប្បញ្ញត្តិសម្រាប់សញ្ញាប័ណ្ណសាជីវកម្ម និងឧបករណ៍និស្សន្ទ (២) បន្តការរៀបចំបទប្បញ្ញត្តិ សម្រាប់គម្រោងវិនិយោគរួមក្នុងនោះរួមទាំងការត្រួតពិនិត្យមូលនិធិ និងបុគ្គលគ្រប់គ្រងមូលនិធិ ព្រមទាំងប្រតិបត្តិការបរធនបាលកិច្ច និង (៣) ពិនិត្យឡើងវិញ និងធ្វើឲ្យប្រាកដថាច្បាប់ ឬបទប្បញ្ញត្តិក្នុងវិស័យមូលបត្រមានចែងអំពីកាតព្វកិច្ចពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលមានសង្គតិភាពជាមួយនឹងច្បាប់ និងប្រកាស ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

## II. អ្នកផ្តល់សេវាកម្មអន្តរការីនិងវិជ្ជាជីវៈជំនាញ

### ក. ទិដ្ឋភាពទូទៅ

**១១៨-** អន្តរការី និងអ្នកផ្តល់សេវាវិជ្ជាជីវៈជំនាញក្នុងវិស័យហិរញ្ញវត្ថុជាអ្នកផ្តល់សេវាប្រឹក្សា និងសេវាអន្តរការី។ បុគ្គលទាំងនេះអាចជាស្ថាប័ន ដែលប្រើប្រាស់រូបវន្តបុគ្គលដែលផ្តល់សេវាទាំងនេះ ឬអាចជារូបវន្តបុគ្គល ។ អន្តរការី រួមមានក្រុមហ៊ុនវិនិយោគ អ្នកផ្តល់ប្រឹក្សា និងបុគ្គលគ្រប់គ្រងមូលនិធិ។

**១១៩-** បុគ្គលផ្តល់សេវាវិជ្ជាជីវៈជំនាញ រួមមាន អ្នកវាយតម្លៃ មេធាវី គណនេយ្យករជំនាញ សវនករ និងបរធនបាល ឬក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស។ ជាទូទៅ បុគ្គលទាំងនោះត្រូវបានគ្រប់គ្រងដោយក្រម និងបទដ្ឋានរបស់សមាគមតាមវិស័យ ព្រមទាំងបទប្បញ្ញត្តិ ដែលពាក់ព័ន្ធនឹងដំណើរការ និងប្រតិបត្តិការរបស់ខ្លួន។ បរធនបាលជាប្រភេទក្រុមហ៊ុនថ្មី ដែលផ្តល់សេវាវិជ្ជាជីវៈជំនាញនៅក្នុងវិស័យហិរញ្ញវត្ថុ និងស្ថិតនៅក្រោមច្បាប់ស្តីពីបរធនបាលកិច្ច (Trust Law)។

**១២០-** ខណៈពេលដែលសកម្មភាពជាច្រើននៅក្នុងវិស័យហិរញ្ញវត្ថុមានការអភិវឌ្ឍ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថាប័នដទៃទៀត ត្រូវបន្តពិនិត្យឡើងវិញពីការចុះបញ្ជីរបស់រូបវន្តបុគ្គល និងនីតិបុគ្គលក្នុងកម្រិតជំនាញ និងមានបទដ្ឋានត្រឹមត្រូវ។

### ខ. វឌ្ឍនភាពនិងសមិទ្ធផល

**១២១-** បទប្បញ្ញត្តិ និងបទដ្ឋានផ្តល់អាជ្ញាបណ្ណដល់អ្នកផ្តល់សេវាវិជ្ជាជីវៈជំនាញត្រូវបានអនុម័ត និងអនុវត្តដោយស្ថាប័នពាក់ព័ន្ធ (**គ.ម.ក.** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងក្រុមប្រឹក្សាជាតិគណនេយ្យ និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា)។

### គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**១២២- គុណភាព និងបទដ្ឋាន:** គុណភាពនៃបទដ្ឋាន និងទម្រង់ ព្រមទាំងការអនុវត្តច្បាប់ជាបញ្ហាទូទៅមួយនៅក្នុងវិស័យហិរញ្ញវត្ថុ ហើយការកសាងសមត្ថភាព និងការត្រួតពិនិត្យក្នុងការអភិវឌ្ឍជំនាញ និងការអនុវត្តច្បាប់ត្រូវបានទទួលស្គាល់ដាច់ដោយឡែកនៅក្នុងផ្នែកពាក់ព័ន្ធផ្សេងទៀតនៃយុទ្ធសាស្ត្រនេះ។

**១២៣- សុខដុមនីយកម្ម:** វិធីសាស្ត្រនៃការទទួលស្គាល់ទៅវិញទៅមក ដែលមានគោលដៅតាមរយៈសមាហរណកម្មហិរញ្ញវត្ថុអាស៊ាន តម្រូវឲ្យមានបទដ្ឋានចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឬការផ្តល់អាជ្ញាបណ្ណ និងការអនុញ្ញាតឲ្យនីតិបុគ្គល និងរូបវន្តបុគ្គលក្នុងការផ្តល់សេវាអន្តរការី និងសេវាវិជ្ជាជីវៈជំនាញក្នុងវិស័យមូលបត្រ ដែលតម្រូវឲ្យមានសុខដុមនីយកម្ម។ ការណ៍នេះនៅតែជាគោលដៅមួយសម្រាប់ដំណើរការសមាហរណកម្មហិរញ្ញវត្ថុអាស៊ាន។

## ឃ. យុទ្ធសាស្រ្ត និងផែនការអនាគត

**១២៤- ការចុះបញ្ជី:** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងបង្កើតគោលនយោបាយជាក់លាក់សម្រាប់ការចុះបញ្ជីបរធនបាលកិច្ចដែលស្ថិតក្រោមច្បាប់បរធនបាលកិច្ច ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងរក្សាការត្រួតពិនិត្យគោលនយោបាយ ព្រមទាំងតម្រូវការក្នុងការចុះបញ្ជីរូបវន្តបុគ្គល និងអង្គភាពនានាក្នុងវិស័យនេះ។

**១២៥- គុណភាពនិងស្តង់ដា:** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងសហការជាមួយស្ថាប័នផ្សេងទៀតក្នុងការពង្រឹងសមត្ថភាពជំនាញ និងស្តង់ដាចំពោះវិស័យហិរញ្ញវត្ថុ។ ក្នុងនោះស្ថាប័នពាក់ព័ន្ធនឹងរៀបចំផែនការអភិវឌ្ឍសមត្ថភាពក្នុងការពង្រឹងជំនាញ និងស្តង់ដាលើការផ្តល់សេវាកម្មសម្រាប់ផ្នែកនីមួយៗ។

**១២៦- សុខដុមនីយកម្ម:** ស្ថាប័នពាក់ព័ន្ធ (គ.ម.ក. និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) នឹងធ្វើការក្នុងក្របខ័ណ្ឌគំនិតផ្តួចផ្តើមសមាហរណកម្មហិរញ្ញវត្ថុអាស៊ាន ជាពិសេស លក្ខខណ្ឌតម្រូវ និងបទដ្ឋានសម្រាប់អន្តរការី និងក្រុមហ៊ុនវិជ្ជាជីវៈជំនាញ ដើម្បីគាំទ្រដល់ការទទួលស្គាល់គ្នាទៅវិញទៅមក។

# III. វិស័យធានារ៉ាប់រង

## ក. ស្ថានភាពទូទៅ

**១២៧-** វិស័យធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមអភិវឌ្ឍ បន្ទាប់ពីច្បាប់ស្តីពីការធានា-រ៉ាប់រងត្រូវបានប្រកាសដាក់ឲ្យអនុវត្តនៅឆ្នាំ២០០០។ ទីផ្សារធានារ៉ាប់រងនេះនៅតូចនៅឡើយ បើធៀបនឹងបណ្តាប្រទេសធំៗដទៃទៀតក្នុងតំបន់អាស៊ាន ប៉ុន្តែមានកំណើនជាលំដាប់ចាប់តាំងពីយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ ត្រូវបានអនុម័តរួចមក។

**១២៨-** ចាប់តាំងពីឆ្នាំ២០១០ មក ក្រុមហ៊ុនធានារ៉ាប់រងទូទៅថ្មីមួយ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតចំនួន៥ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចចំនួន៦ និងប្រតិបត្តិករធានារ៉ាប់រងសហគមន៍ចំនួន ៣ (ប្រតិបត្តិករធានារ៉ាប់រងសុខភាពចំនួន ២ និងប្រតិបត្តិករធានារ៉ាប់រងកសិផលចំនួន ១) ត្រូវបានផ្តល់អាជ្ញាបណ្ណ។ នៅចុងឆ្នាំ២០១៥ មានប្រតិបត្តិករចំនួន២១ ដែលទទួលបានអាជ្ញាបណ្ណក្នុងការផ្តល់ជូននូវផលិតផល និងសេវាធានារ៉ាប់រង ព្រមទាំងជើងសាធានារ៉ាប់រងចំនួន៧ និងភ្នាក់ងារធានារ៉ាប់រងចំនួន១០ ដើម្បីចែកចាយផលិតផលដល់អតិថិជន។

**១២៩-** បរិយាកាសសម្រាប់វិស័យធានារ៉ាប់រងនេះ ត្រូវបានស្វាគមន៍ចំពោះភាពជាកម្មសិទ្ធិបរទេស។ គ្រឹះស្ថានធានារ៉ាប់រងក្នុងស្រុក អាចត្រូវបានកាន់កាប់ពេញលេញដោយវិនិយោគិនបរទេស ដោយកំណត់ថាត្រូវចុះបញ្ជីជាក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិត។ បុព្វលាភធានារ៉ាប់រងដុល

ដែលទទួលបានពីផលិតផលធានារ៉ាប់រងទាំងអស់បានកើនឡើងពី ២៥លានដុល្លារ ក្នុងឆ្នាំ២០១០ ទៅដល់ ៨៦លានដុល្លារនៅចុងឆ្នាំ២០១៥។ សម្រាប់១២ខែ គិតត្រឹមខែធ្នូ ឆ្នាំ២០១៥ បុព្វលាភធានារ៉ាប់រងមិនមែនអាយុជីវិតមានកំណើន ១៨% ដោយឡើងដល់ ៦២លានដុល្លារ បុព្វលាភធានារ៉ាប់រងអាយុជីវិតមានកំណើន ១៩៣% ឡើងដល់ ២២លានដុល្លារ និងបុព្វលាភធានារ៉ាប់រងខ្នាតតូចមានកំណើន ៤៨១% ដោយឡើងដល់ ២លានដុល្លារ។ ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ (ឆ្នាំ២០១១-២០១៥) អត្រាកំណើនជាមធ្យមសម្រាប់បុព្វលាភធានារ៉ាប់រងដុល គឺមានចំនួន ២៨%។

**១៣០-** ការអនុម័តច្បាប់ធានារ៉ាប់រងថ្មីនៅក្នុងឆ្នាំ២០១៤ គឺជាការសម្រេចបាននូវសមិទ្ធផលដ៏ធំមួយ ដែលនឹងបង្កើនសន្ទុះនៃកំណើននៅក្នុងទីផ្សារធានារ៉ាប់រងកម្ពុជា។

## ខ. ចន្លោះភាព និងសមិទ្ធផល

**១៣១-** វិស័យធានារ៉ាប់រងនេះ ត្រូវបានរៀបចំបានយ៉ាងល្អប្រសើរ ដើម្បីទាញយកផលប្រយោជន៍ពីឱកាសថ្មីៗនាពេលខាងមុខ តាមរយៈការអភិវឌ្ឍនៃផលិតផលធានារ៉ាប់រងថ្មីៗ ទីផ្សារល្អប្រសើរជាងមុន និងការយល់ដឹងជាសាធារណៈបន្ថែមទៀត។ ការអភិវឌ្ឍវិស័យធានារ៉ាប់រងខ្នាតតូច បានជួយបង្កើនការយល់ដឹងអំពីការធានារ៉ាប់រងដល់អតិថិជនបានទូលំទូលាយជាង បើធៀបនឹងសេវាធានារ៉ាប់រងធម្មតា។ កាលពីពេលថ្មីៗនេះ នាយកដ្ឋានធានារ៉ាប់រង និងសោធន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសេចក្តីព្រាងប្រកាសចំនួន១៦ និងអនុក្រឹត្យចំនួន៣ ដោយរួមបញ្ចូលទាំងការធានារ៉ាប់រងយានយន្តជាកាតព្វកិច្ចទទួលខុសត្រូវលើតតិយជន ដែលនឹងត្រូវពិគ្រោះយោបល់ជាមួយឧស្សាហកម្មធានារ៉ាប់រង និងភាគីពាក់ព័ន្ធផ្សេងៗទៀត។

**១៣២-** ជាលទ្ធផលនៃកំណើនចំនួនអ្នកផ្តល់សេវាធានារ៉ាប់រងអាយុជីវិត និងធានារ៉ាប់រងខ្នាតតូចទាំងនេះ មន្ត្រីរបស់នាយកដ្ឋានធានារ៉ាប់រង និងសោធន ត្រូវអភិវឌ្ឍចំណេះដឹងរបស់ខ្លួនឲ្យបានឆាប់រហ័សក្នុងបរិបទថ្មីនៃវិស័យធានារ៉ាប់រង។ ក្នុងគោលបំណងដើម្បីលើកទឹកចិត្តដល់ការអភិវឌ្ឍនៅដំណាក់កាលដំបូងនៃធានារ៉ាប់រងខ្នាតតូច វិធីសាស្ត្រត្រូវបានកំណត់ដើម្បីដាក់ចេញនូវក្របខ័ណ្ឌជាមូលដ្ឋានសម្រាប់ការផ្តល់អាជ្ញាបណ្ណ និងបទប្បញ្ញត្តិនៃក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ដែលនឹងជួយឲ្យអាជ្ញាបណ្ណរបស់ពួកគេត្រូវបានផ្តល់ជូនបានឆាប់រហ័ស។ ជាលទ្ធផល វិស័យធានារ៉ាប់រងខ្នាតតូចកំពុងធ្វើបានយ៉ាងល្អ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប។ ទន្ទឹមនឹងនេះ ផ្នែកសំខាន់មួយនៃដំណើរការអាជីវកម្មថ្មីៗរបស់ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច គឺផលិតផល ដែលបានកំណត់គោលដៅជាក់លាក់ និងជោគជ័យក្នុងការឆ្លើយតបទៅនឹងតម្រូវការធានារ៉ាប់រងរបស់ស្ត្រីនៅក្នុងសហគមន៍ជនបទ (ស្ត្រីត្រូវបានលើកទឹកចិត្តក្នុងការទិញធានារ៉ាប់រងអាយុជីវិត ដោយអាចបង់បុព្វលាភរ៉ាប់រងក្នុងកម្រិតទាបជាងបុរស)។

**១៣៣-** សមាគមធានារ៉ាប់រងកម្ពុជា (IAC) ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៥ ដែលមានក្រុមហ៊ុនធានារ៉ាប់រងទូទៅទាំងអស់ដែលកំពុងធ្វើអាជីវកម្មនៅកម្ពុជា ជាសមាជិក។ ដោយឡែកចាប់ពីឆ្នាំ២០១២ មក ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក៏បានចូលជាសមាជិករបស់សមាគមនេះជាបន្តបន្ទាប់ផងដែរ។ សមាគមធានារ៉ាប់រងកម្ពុជា បានធ្វើការយ៉ាងសកម្ម និងសហការជាដៃគូយ៉ាងជិតស្និទ្ធជាមួយនឹងបញ្ញត្តិករ ដើម្បីនាំមកនូវការអភិវឌ្ឍប្រកបដោយភាពជោគជ័យនៃវិស័យធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជា។ ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ នាយកដ្ឋានធានារ៉ាប់រង និងសោធន និងសមាគមធានា-រ៉ាប់រងកម្ពុជា បានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងពីវិស័យធានារ៉ាប់រង ក៏ដូចជាអប់រំសាធារណជនឲ្យបានយល់ដឹងអំពីប្រភេទសេវាកម្មធានារ៉ាប់រងផ្សេងៗផងដែរ។

**១៣៤-** ការអភិវឌ្ឍរបស់ធានារ៉ាប់រងខ្នាតតូច បាននាំមកនូវបណ្តាញចែកចាយថ្មីៗ ហើយបណ្តាញថ្មីៗជាច្រើន ក៏កំពុងត្រូវបានអភិវឌ្ឍសម្រាប់ការធានារ៉ាប់រងធម្មតាផងដែរ ដែលក្នុងនោះធនាគារធំៗមួយចំនួនបានសហការជាដៃគូជាមួយនឹងក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ដើម្បីចែកចាយផលិតផលធានារ៉ាប់រងអាយុជីវិត។ ជាមួយគ្នានេះ បុគ្គលិករបស់ក្រុមហ៊ុនធានារ៉ាប់រង ក៏អាចលក់ផលិតផលធានារ៉ាប់រងនៅតាមបណ្តាសាខារបស់ធនាគារផងដែរ។

**១៣៥-** នាយកដ្ឋានធានារ៉ាប់រង និងសោធន មានការរីកចម្រើនក្នុងការអភិវឌ្ឍដំណើរការធ្វើអធិការកិច្ចធានារ៉ាប់រង។ នាយកដ្ឋានធានារ៉ាប់រង និងសោធន បានបញ្ចប់ការត្រួតពិនិត្យឯកសារក្នុងដំណាក់កាលដំបូងលើស្ថានភាពអាជីវកម្ម និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ និងបានត្រួតពិនិត្យដល់ទីកន្លែងចំនួន២០លើក នៅក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។ លើសពីនេះ មន្ត្រីរបស់នាយកដ្ឋានធានារ៉ាប់រង និងសោធន បានបញ្ចប់ការពិនិត្យឡើងវិញទៅលើប្រតិបត្តិការរបស់ពួកគេស្របតាមគោលការណ៍គ្រឹះធានារ៉ាប់រង។

**១៣៦-** នៅឆ្នាំ២០១៣ នាយកដ្ឋានធានារ៉ាប់រង និងសោធន បានបង្កើតឡើងជាផ្លូវការនូវការិយាល័យនីតិកម្ម និងផ្សះផ្សាវិវាទ ដើម្បីសម្រុះសម្រួលជម្លោះទាក់ទងនឹងសកម្មភាពធានារ៉ាប់រង ក្នុងគោលបំណងជួយដោះស្រាយបណ្តឹង និងបញ្ចៀសការចូលដល់មជ្ឈត្តករ ឬតុលាការ។ ទោះជាយ៉ាងណាក្តី ការងារទាំងនេះនឹងមិនគ្របដណ្តប់ករណី ដែលពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ និងនីតិវិធីរបស់តុលាការឡើយ។

**១៣៧-** កម្ពុជាបានប្តេជ្ញាចិត្តទៅនឹងសកម្មភាពអាស៊ាន និងបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាធានារ៉ាប់រងអាស៊ានលើកទី៤១ និងកិច្ចប្រជុំបញ្ញត្តិករធានារ៉ាប់រងអាស៊ានលើកទី១៨ នៅរាជធានីភ្នំពេញក្នុងខែតុលា ឆ្នាំ២០១៥។ សមាជិកភាពរបស់កម្ពុជានៅក្នុងក្រុមប្រឹក្សានេះ គឺពិតជាមានអត្ថប្រយោជន៍ខ្លាំងណាស់ ពីព្រោះកម្ពុជាអាចរៀនសូត្រពីបញ្ញត្តិករដែលមានបទពិសោធច្រើន និងរក្សាទំនាក់ទំនង

ជាមួយនឹងបញ្ញត្តិករនៅក្នុងតំបន់ផងដែរ ដែលនឹងចាំបាច់ត្រូវធ្វើការរួមគ្នាជាទៀងទាត់ ខណៈដែលសកម្មភាពធានារ៉ាប់រងកាន់តែមានភាពទូលំទូលាយក្នុងសាកលលោក។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**១៣៨- ភាពខ្វះចន្លោះដែលនឹងត្រូវបានដោះស្រាយនៅក្នុងដំណើរការធ្វើផែនការប្រចាំឆ្នាំ:** មានចន្លោះប្រហោងច្រើនកំពុងត្រូវបានដោះស្រាយ ដែលជាផ្នែកមួយនៃដំណើរការធ្វើផែនការប្រចាំឆ្នាំរបស់នាយកដ្ឋានធានារ៉ាប់រងនិងសោធន។ ចន្លោះប្រហោងទាំងនេះរួមមាន៖ (១) ក្របខ័ណ្ឌបទប្បញ្ញត្តិដែលចាំបាច់ត្រូវពិនិត្យ និងកែសម្រួល (២) ជំនាញបច្ចេកទេសចាំបាច់ដែលត្រូវអភិវឌ្ឍ និងកែលម្អ (៣) ដំណើរការត្រួតពិនិត្យដល់ទីកន្លែង (៤) ការបង្កើនអត្រានៃការទទួលបានសេវាធានារ៉ាប់រង (៥) បណ្តាញចែកចាយថ្មីៗ និងការបង្កើនលទ្ធភាពទៅលើការប្រើប្រាស់សេវាធានារ៉ាប់រង និង (៦) ពង្រឹងអភិបាលកិច្ចនៅក្នុងវិស័យធានារ៉ាប់រង។

**១៣៩- អនុវត្តតាមលក្ខខណ្ឌរបស់ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT):** ប្រតិបត្តិករនៅក្នុងឧស្សាហកម្មធានារ៉ាប់រងត្រូវបានសម្រេចថាជាអង្គភាព ដែលត្រូវរាយការណ៍នៅក្រោមច្បាប់ AML/CFT និងផ្សារភ្ជាប់ទៅនឹងប្រកាសព័ត៌មានដែលពាក់ព័ន្ធ។ នាយកដ្ឋានធានារ៉ាប់រង និងសោធន កំពុងធ្វើការរួមគ្នាជាមួយនឹងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (CAFIU) ដើម្បីធានាបាននូវអនុលោមភាពដោយអង្គភាពដែលត្រូវការរាយការណ៍ដែលស្ថិតលើក្របខ័ណ្ឌ AML/CFT សម្រាប់ការពារវិស័យហិរញ្ញវត្ថុពីការគំរាមកំហែង និងភាពងាយរងគ្រោះដោយសារសកម្មភាពលាងលុយកខ្វក់។

**១៤០- ប្រព័ន្ធត្រួតពិនិត្យដោយផ្អែកលើហានិភ័យនិងប្រព័ន្ធត្រួតពិនិត្យការជូនដំណឹងជាមុន:** នាយកដ្ឋានធានារ៉ាប់រង និងសោធន កំពុងប្រើប្រាស់ដំណើរការវិភាគដោយដៃភាគច្រើន ដើម្បីវាយតម្លៃស្ថានភាពស្ថិតិ និងហិរញ្ញវត្ថុនៃក្រុមហ៊ុនធានារ៉ាប់រង។

**១៤១- ជម្រើសដើម្បីដាក់ទុនវិនិយោគ:** ក្រុមហ៊ុនធានារ៉ាប់រងដែលប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាមានជម្រើសមានកំណត់សម្រាប់ការវិនិយោគទុន និងទុនបម្រុងរបស់ពួកគេដោយមួយកន្លែង។ ស្ថានភាពនេះនឹងក្លាយជាការប្រឈមកាន់តែខ្លាំង សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត នៅពេលដែលពួកគេបានកសាងមូលដ្ឋានអតិថិជនរបស់ខ្លួន និងការប្រមូលប្រាក់ទុនដែលចាំបាច់សម្រាប់ការវិនិយោគរយៈពេលវែង។ នេះសបញ្ជាក់ពីសារៈសំខាន់សម្រាប់រាជរដ្ឋាភិបាល ដើម្បីគាំទ្រដល់ការអភិវឌ្ឍទីផ្សារមូលបត្រចម្រុះ និងសំខាន់នៅក្នុងប្រទេសកម្ពុជា ដើម្បីផ្តល់នូវជម្រើសក្នុងការវិនិយោគដែលមានលក្ខណៈសមស្របសម្រាប់ក្រុមហ៊ុនធានារ៉ាប់រងដែលកំពុងខិតខំរិះរកវិធីផ្សេងៗ ក្នុងការវិនិយោគដើមទុន និងទុនបម្រុងរបស់ខ្លួន។

**១៤២- កិច្ចការពារអ្នកប្រើប្រាស់:** ជាមួយនឹងការអភិវឌ្ឍនៃផលិតផល និងសេវាកម្មបន្ថែមរួមជាមួយនឹងអតិថិជនកាន់តែច្រើន វានឹងកាន់តែមានសក្តានុពលសម្រាប់អតិថិជនក្នុងការសាកសួរព័ត៌មាន និងប្តឹងតវ៉ានៅពេលដែលពួកគេយល់ថា មានគ្រឹះស្ថានធានារ៉ាប់រងណាមួយមិនបានផ្តល់ជូននូវផលិតផល ឬក៏សេវាកម្មដ៏ត្រឹមត្រូវមួយ។ ទន្ទឹមនឹងនេះ ការខិតខំប្រឹងប្រែងជាបន្តគឺពិតជាត្រូវការដើម្បីអប់រំអតិថិជន និងធានាថាពួកគេកំពុងត្រូវបានផ្តល់ជូនជាមួយនឹងព័ត៌មានដ៏ជាក់លាក់ ហើយនឹងធានាថា ពួកគេអាចយល់បានដោយការសាកសួរព័ត៌មាន និងការទាមទារសំណងរបស់ពួកគេគឺត្រូវបាន ដោះស្រាយបានត្រឹមត្រូវ និងទាន់ពេលវេលា។

**១៤៣- ការបង្ហាញឲ្យឃើញពីព័ត៌មាននៃឧស្សាហកម្មធានារ៉ាប់រង:** ជាមួយនឹងកំណើននៅក្នុងឧស្សាហកម្មនេះ វានឹងមានតម្រូវការច្រើនជាងមុនសម្រាប់ការបង្ហាញព័ត៌មាន តម្លាភាព និងរបាយការណ៍របស់បញ្ញត្តិករធានារ៉ាប់រង។ កិច្ចខិតខំប្រឹងប្រែងជាបន្ត គឺត្រូវការដើម្បីផ្តល់ជូនអ្នកប្រើប្រាស់ និងឧស្សាហកម្មនេះជាមួយនឹងព័ត៌មានយ៉ាងច្បាស់លាស់អំពីក្រុមហ៊ុនធានារ៉ាប់រង និងវិស័យធានារ៉ាប់រងក្នុងការជួយដល់មនុស្សគ្រប់គ្នា ដើម្បីធ្វើសេចក្តីសម្រេច និងជម្រើសដ៏ត្រឹមត្រូវសម្រាប់ការធានារ៉ាប់រង។

## ឃ. យុទ្ធសាស្ត្រនិងផែនការអនាគត

**១៤៤- បរិស្ថានបទប្បញ្ញត្តិល្អប្រសើរ:** ដើម្បីធានាបាននូវបរិស្ថានបទប្បញ្ញត្តិប្រកបដោយប្រសិទ្ធភាព និងអភិបាលកិច្ចល្អប្រសើរ ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង ដែលស្របតាមគោលការណ៍គ្រឹះធានារ៉ាប់រង។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំពុងកែសម្រួលអនុក្រឹត្យ និងប្រកាសរបស់ខ្លួន ដើម្បីមានវិសាលភាពគ្របដណ្តប់ទៅលើការធានារ៉ាប់រងអាយុជីវិត ធានារ៉ាប់រងទូទៅ ធានារ៉ាប់រងខ្នាតតូច អន្តរការី និងការធានារ៉ាប់រងជាកាតព្វកិច្ច នៅត្រឹមឆ្នាំ២០២០។

**១៤៥- អនុលោមភាពតាមគោលការណ៍គ្រឹះធានារ៉ាប់រង:** បញ្ញត្តិករធានារ៉ាប់រង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំពុងពិនិត្យឡើងវិញនូវគោលនយោបាយ និងដំណើរការត្រួតពិនិត្យរបស់ខ្លួន ដោយក្នុងនោះជំនួយបច្ចេកទេស គឺត្រូវការជាចាំបាច់សម្រាប់ដំណើរការនេះ។ ទោះបីជាបញ្ញត្តិករធានារ៉ាប់រងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លែងជាសមាជិកនៃសមាគមបញ្ញត្តិករធានារ៉ាប់រងអន្តរជាតិ (IAIS) ក៏ដោយ ក៏ការវាយតម្លៃដើម្បីអនុលោមភាពតាមគោលការណ៍គ្រឹះធានារ៉ាប់រង នៅតែបន្តអនុវត្តដដែល។

**១៤៦- អនុវត្តតាមលក្ខខណ្ឌរបស់ AML/CFT:** ការកែប្រែច្បាប់ឬបទប្បញ្ញត្តិនាពេលអនាគតដែលគ្របដណ្តប់ឧស្សាហកម្មធានារ៉ាប់រងនឹងរួមបញ្ចូលបទប្បញ្ញត្តិទាំងឡាយស្តីពី AML/CFT ដែលស្របជាមួយនឹងច្បាប់ និងប្រកាសបច្ចុប្បន្នរបស់AML/CFT។ ប្រសិនបើច្បាប់ ឬបទប្បញ្ញត្តិផ្សេងៗ ស្តីពីឧស្សាហកម្មដែលមានស្រាប់ មិនរួមបញ្ចូលនូវបទប្បញ្ញត្តិរបស់ AML/CFT ទេនោះ គោលការណ៍

ណែនាំអំពីបទប្បញ្ញត្តិក្នុងការសម្របសម្រួលជាមួយនឹង CAFIU នឹងចាំបាច់ត្រូវអនុម័តនៅក្រោមច្បាប់ ឬក៏ប្រកាសគោលរបស់ AML/CFT។ នាយកដ្ឋានធានារ៉ាប់រងនិងសោធន នឹងផ្ដល់ការគាំទ្របន្ថែមទៀត ដើម្បីធានាថាមន្ត្រីរបស់នាយកដ្ឋានត្រូវបានទទួលការបណ្ដុះបណ្ដាលនៅក្នុងឧស្សាហកម្មដែលតម្រូវឲ្យរាយការណ៍តាមច្បាប់ AML/CFT និងដើម្បីធានាថាតម្រូវការសម្រាប់ AML/CFT ទាំងនេះកំពុងត្រូវបានបំពេញដោយក្រុមហ៊ុនធានារ៉ាប់រង។

**១៤៧- ប្រព័ន្ធត្រួតពិនិត្យដោយផ្អែកលើហានិភ័យនិងប្រព័ន្ធត្រួតពិនិត្យការជូនដំណឹងជាមុន:** នាយកដ្ឋានធានារ៉ាប់រងនិងសោធន នឹងកែលម្អដំណើរការត្រួតពិនិត្យទាំងនេះ ដោយអភិវឌ្ឍជំហានទៅកាន់ការត្រួតពិនិត្យ ដោយផ្អែកលើហានិភ័យ ប្រតិបត្តិការប្រព័ន្ធជូនដំណឹងជាមុន ត្រឹមឆ្នាំ២០២២ និងកែលម្អប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួន ដើម្បីធ្វើស្វ័យប្រវត្តិកម្មទៅលើការវិភាគ និងត្រួតពិនិត្យស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រង។

**១៤៨- យុទ្ធសាស្ត្រនិងផែនការអនាគតផ្សេងទៀត:** ដើម្បីពង្រឹងឧស្សាហកម្មធានារ៉ាប់រង ដោយការកែលម្អការប្រកួតប្រជែង និងកិច្ចការពារអ្នកប្រើប្រាស់ និងម្ចាស់ទុនដោយ (១) ធានាឲ្យមានអនុលោមភាពតាមការអនុវត្តសមស្រប ដែលអាចទទួលយកបាននៃកម្រិតសាធនភាព ការវិនិយោគ ការធានារ៉ាប់រងបន្តទុនបម្រុងគណនេយ្យ និងស្តង់ដារបាយការណ៍ (២) ការកម្រិតស្តង់ដា និងរៀបចំបញ្ចូលក្នុងប្រព័ន្ធអេឡិចត្រូនិកនូវព័ត៌មានដែលបង្ហាញអំពីស្ថិតិ និងហិរញ្ញវត្ថុនៅត្រឹមឆ្នាំ២០១៩ (៣) ការបោះពុម្ពផ្សាយនូវរបាយការណ៍អំពីស្ថិតិហិរញ្ញវត្ថុ និងរបាយការណ៍ត្រួតពិនិត្យគ្រឹះស្ថានធានារ៉ាប់រងលើគេហទំព័ររបស់នាយកដ្ឋានធានារ៉ាប់រង និងសោធន ត្រឹមឆ្នាំ២០១៩ (៤) បង្កើនសមត្ថភាពនៃអ្នកត្រួតពិនិត្យដល់ទីកន្លែងតាមរយៈបច្ចេកទេសត្រួតពិនិត្យដែលត្រូវបានកែលម្អ ដោយស្របទៅនឹងការអនុវត្តជាក់ស្តែងក្នុងឧស្សាហកម្មធានារ៉ាប់រង នៅត្រឹមឆ្នាំ២០១៩ (៥) ការបង្កើនទំនុកចិត្តរបស់អតិថិជននៅក្នុងឧស្សាហកម្មធានារ៉ាប់រង ដោយរៀបចំ និងពិនិត្យឡើងវិញលើបទប្បញ្ញត្តិពាក់ព័ន្ធនឹងការអនុវត្តក្នុងទីផ្សារ និងកិច្ចការពារអ្នកប្រើប្រាស់ រួមជាមួយកម្មវិធីផ្សះផ្សាវិវាទធានារ៉ាប់រង ដំណើរការស៊ើបអង្កេត និងពាក្យបណ្ដឹង (៦) បង្កើនការចូលរួមក្នុងទីផ្សារធានារ៉ាប់រង និងដង់ស៊ីតេធានារ៉ាប់រងដោយកម្មវិធីអប់រំអតិថិជនតាមរយៈគេហទំព័រ និងបណ្ដាញសង្គមរបស់នាយកដ្ឋានធានារ៉ាប់រងនិងសោធន (៧) កំណត់ស្តង់ដា និងពង្រឹងដំណើរការទទួល និងអនុម័តផលិតផលធានារ៉ាប់រង ទម្រង់បែបបទ និងអត្រា ដើម្បីធានាការប្រព្រឹត្តដោយត្រឹមត្រូវចំពោះអតិថិជននៅត្រឹមឆ្នាំ២០២០ និង (៨) បង្កើតអង្គភាពគោលនយោបាយមួយនៅក្នុងនាយកដ្ឋានធានារ៉ាប់រង និងសោធន ដែលនឹងទទួលខុសត្រូវចំពោះការតាក់តែងគោលនយោបាយសម្រាប់វិស័យធានារ៉ាប់រងនៅកម្ពុជា។

**១៤៩- បញ្ញត្តិករធានារ៉ាប់រង**: ក្នុងឆ្នាំ២០១៣ នាយកដ្ឋានធានារ៉ាប់រង និងសោធន ត្រូវបានដំឡើងពីថ្នាក់ការិយាល័យ ទៅជានាយកដ្ឋាន ស្ថិតនៅក្រោមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទោះយ៉ាងណានៅតែជួបប្រទះនឹងកង្វះធនធានមនុស្សដែលចាំបាច់ ដើម្បីដំណើរការប្រកបដោយប្រសិទ្ធភាព។

បន្ថែមពីលើនេះចំណុចមួយក្នុងចំណោមតម្រូវការសំខាន់ៗ ដើម្បីអនុលោមតាមគោលការណ៍គ្រឹះធានារ៉ាប់រងទី១ គឺបញ្ញត្តិករធានារ៉ាប់រងត្រូវធ្វើប្រតិបត្តិការក្នុងទម្រង់ជាគណៈកម្មការមួយដែលក្នុងនោះមានប្រទេសចំនួន៧ ក្នុងអាស៊ានបាន និងកំពុងអនុវត្ត។ ក្នុងចន្លោះឆ្នាំ២០១៧ ដល់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងពិនិត្យលទ្ធភាពរៀបចំបង្កើតគណៈកម្មការធានារ៉ាប់រង ដើម្បីទទួលខុសត្រូវទៅលើសកម្មភាពត្រួតពិនិត្យ ដែលបច្ចុប្បន្នត្រូវបានអនុវត្តដោយនាយកដ្ឋានធានារ៉ាប់រង និងសោធន។

## IV. **វិស័យសោធន** ( **ប្រព័ន្ធគាំពារសង្គម** )

## ក. ស្ថានភាពទូទៅ

**១៥០-** រាជរដ្ឋាភិបាលបានបង្កើតបេឡាជាតិចំនួន៣ សម្រាប់គ្រប់គ្រងរបបសោធននៅកម្ពុជាដែលមាន (១) បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស.) (២) បេឡាជាតិអតីតយុទ្ធជន (ប.ជ.អ.) និង (៣) បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.)។

**១៥១-** បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស.) និងបេឡាជាតិអតីតយុទ្ធជន (ប.ជ.អ.) ត្រូវបានបង្កើតឡើងដោយស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ប.ជ.ស. មានតួនាទីផ្តល់តាវកាលិកចំនួន៦ ដល់មន្ត្រីរាជការស៊ីវិលៈ (១) សោធននិវត្តជន (២) សោធនពិការភាព (៣) មាតុភាព (៤) មរណភាព (៥) អ្នកនៅក្នុងបន្ទុក និង (៦) គ្រោះថ្នាក់ការងារ។ ចំណែក ប.ជ.អ. វិញ មានតួនាទីជាអ្នកចាត់ចែងតាវកាលិកសម្រាប់អតីតយុទ្ធជនមួយចំនួន ដូចជា ការចូលនិវត្តន៍ ការបាត់បង់សមត្ថភាពការងារ ការលំហែមាតុភាពអាពាហ៍ពិពាហ៍ដំបូង ពលីមរណភាព និងអ្នកនៅក្នុងបន្ទុក។

**១៥២-** បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) ដែលត្រូវបានបង្កើតឡើង និងស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាស្ថាប័នដែលមានតួនាទីគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមសម្រាប់កម្មករនិយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

## ខ. វឌ្ឍនភាព និងសមិទ្ធផល

**១៥៣-** បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស.) បាននិងកំពុងដំណើរការរបបសន្តិសុខសង្គមសម្រាប់និវត្តជនដែលជាមន្ត្រីរាជការចំនួន៥០ ៤១៦នាក់។ ចំណែកឯបេឡាជាតិអតីតយុទ្ធជន (ប.ជ.អ.) ដែលមានតួនាទីចាត់ចែងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន បាននិងកំពុងដំណើរការរបបរបស់ខ្លួនសម្រាប់អតីតយុទ្ធជនចំនួន២៥ ៤២៥នាក់។

**១៩៤-** បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) បាននិងកំពុងដំណើរការរបបសន្តិសុខសង្គមផ្នែកធានារ៉ាប់រងហានិភ័យការងារ ដែលផ្តល់ការគាំពារដល់កម្មករនិយោជិតប្រមាណ១,២លាននាក់។ ប.ស.ស. គ្រោងនឹងដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់កម្មករនិយោជិត នៅក្នុងឆ្នាំ២០១៦ នេះ។

**១៩៥-** នៅក្នុងឆ្នាំ២០១៥ រាជរដ្ឋាភិបាលបានលើកឡើងនូវចំណុចមួយចំនួន នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដែលបង្ហាញពីភាពចាំបាច់ក្នុងការកែទម្រង់ប្រព័ន្ធគាំពារសង្គមនៅកម្ពុជា។ រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារបច្ចេកទេសអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកដឹកនាំ និងមានសមាជិកមកពីស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍ប្រព័ន្ធគាំពារសង្គម ដែលក្នុងនោះ ប្រព័ន្ធសោធន គឺជាធាតុសំខាន់។ គោលដៅចំបងរបស់ក្រុមការងារនេះ គឺរៀបចំប្រព័ន្ធគាំពារសង្គមមួយដែលមានលក្ខណៈប្រមូលផ្តុំ សង្គតិភាព និងប្រសិទ្ធភាព។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**១៩៦- ក្របខ័ណ្ឌគោលនយោបាយនិងច្បាប់:** ប្រព័ន្ធគាំពារសង្គមនៅកម្ពុជាបច្ចុប្បន្ន នៅមិនទាន់មានលក្ខណៈប្រមូលផ្តុំ និងសង្គតិភាព ដែលទាមទារឲ្យរាជរដ្ឋាភិបាលបង្កើតក្របខ័ណ្ឌគោលនយោបាយរួមមួយសម្រាប់ប្រព័ន្ធទាំងមូល។ លើសពីនេះទៅទៀត ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រង និងត្រួតពិនិត្យប្រព័ន្ធនេះក៏នៅមានភាពខ្វះចន្លោះ។

**១៩៧- ការបង់ភាគទាន:** អនុក្រឹត្យស្តីពីការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ២០១១ បានបញ្ជាក់យ៉ាងច្បាស់ថាមន្ត្រីរាជការស៊ីវិលមានកាតព្វកិច្ចត្រូវបង់ភាគទានមួយចំណែកនៃប្រាក់បៀវត្សមូលដ្ឋានរបស់គេទៅក្នុង ប.ជ.ស. ហើយចំណែកដែលនៅសល់ នឹងត្រូវបង់ដោយរាជរដ្ឋាភិបាល។ ទោះបីជាយ៉ាងណាក៏ដោយ អនុក្រឹត្យនេះនៅមិនទាន់បានយកមកអនុវត្តនៅឡើយ ដោយសារ (១) កង្វះខាតប្រព័ន្ធគ្រប់គ្រងការប្រមូលភាគទានពីសមាជិក និង (២) កម្រិតប្រាក់ខែទាបរបស់មន្ត្រីរាជការ ដែលជាឧបសគ្គក្នុងការបង់ភាគទាន។ របបសោធនរបស់មន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជនបច្ចុប្បន្ន ត្រូវបានរ៉ាប់រងទាំងស្រុងដោយថវិកាជាតិ។ កត្តានេះបានដាក់បន្ទុកយ៉ាងធ្ងន់ធ្ងរទៅលើលទ្ធភាពទ្រទ្រង់របស់ថវិកាជាតិ។

**១៩៨- អសង្គតិភាពរវាងតាវកាលិកនៃរបបសោធន:** ប.ជ.ស. និង ប.ជ.អ. គឺជាស្ថាប័នដែលដំណើរការរបបសោធន។ ដោយសារតែមានការគ្រប់គ្រងដាច់ដោយឡែកពីគ្នានៃបេឡាទាំងពីរនេះ បានធ្វើឲ្យតាវកាលិកនៃរបបសោធនសម្រាប់មន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជនមានលក្ខណៈអសង្គតិភាព។

**១៩៩- ផលប៉ះពាល់នៃរបបសោធនបច្ចុប្បន្ន:** របបសោធន ដែលផ្តល់ការធានាជាមុននូវតាវកាលិករបស់គម្រោងសោធនប្រភេទកំណត់តាវកាលិកជាមុន បង្ហាញអំពីហានិភ័យដែលអាចនឹងមានផល

ប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុនៃមូលនិធិសោធន និងចុងក្រោយធ្លាក់ជាបន្ទុកដ៏ធ្ងន់ធ្ងរ មកលើថវិកាជាតិ ។ ប្រការនេះ ទាមទារឲ្យមានការសិក្សាលើជម្រើសនៃការកែទម្រង់របបសោធននេះ ។

**១៦០- វិសាលភាពនៃរបបសោធន:** រហូតមកទល់បច្ចុប្បន្ន កម្មករនិយោជិត និងពលរដ្ឋដែលស្ថិតនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ នៅមិនទាន់ទទួលបានការគាំពារដោយរបបសោធននៅឡើយ។

**១៦១- ជម្រើសសម្រាប់វិនិយោគមូលនិធិសោធននៅមានកម្រិត:** សមត្ថភាពរបស់ប្រជាពលរដ្ឋកម្ពុជាមួយភាគធំក្នុងការសន្សំប្រាក់ តាមរយៈសេវាកម្មហិរញ្ញវត្ថុ ដូចជាការដាក់ប្រាក់នៅធនាគារ ការទិញធានារ៉ាប់រង និងសោធន នៅមានកម្រិតនៅឡើយ ដោយសារតែចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់ពួកគាត់នៅមិនទាន់មានលក្ខណៈទូលំទូលាយ។ លើសពីនេះទៅទៀត ប្រសិនបើទីផ្សារសម្រាប់របបសោធនមានកំណើន កម្ពុជាក៏នៅមិនទាន់ត្រៀមខ្លួនរួចរាល់សម្រាប់យកភាគទាន ដែលប្រមូលបានទៅធ្វើការវិនិយោគនោះដែរ។ ការរីកចម្រើននៃរបបធានារ៉ាប់រងសុខភាពសោធន និងរបបដទៃទៀតនៃប្រព័ន្ធគាំពារសង្គមមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការអភិវឌ្ឍរបស់ទីផ្សារមូលធន។ រហូតមកទល់ពេលនេះ ភាគទានដែលប្រមូលបានពីរបបធានារ៉ាប់រងហានិភ័យការងាររបស់ ប.ស.ស. ចំនួន៥០លានដុល្លារត្រូវបានយកទៅតម្កល់ក្នុងធនាគារ។ មូលនិធិនេះនឹងបន្តកើនឡើងនៅពេលដែលមានសមាជិកថ្មីចូលរួម។

**១៦២- ជំនាញសម្រាប់គ្រប់គ្រង និងចាត់ចែងមូលនិធិសោធន:** ជំនាញចាំបាច់សម្រាប់អភិវឌ្ឍវិស័យសោធនឲ្យមាននិរន្តរភាព រួមមានការវិភាគស្ថានភាពហិរញ្ញវត្ថុ ការវិភាគហានិភ័យ ការអភិវឌ្ឍផលិតផល ការរៀបចំបទដ្ឋានគតិយុត្តផ្នែកហិរញ្ញវត្ថុ ការដំណើរការផលិតផលហិរញ្ញវត្ថុ ការលក់ផលិតផល ការវិនិយោគ និងការគ្រប់គ្រងទិន្នន័យ។ នៅក្នុងប្រទេសកម្ពុជា ជំនាញមួយចំនួននេះ នៅមិនទាន់ត្រូវបានអភិវឌ្ឍនៅឡើយ។

**១៦៣- ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ទ្រទ្រង់មូលនិធិសោធន:** ប.ជ.ស. និង ប.ជ.អ. នៅមិនទាន់មានប្រព័ន្ធព័ត៌មានវិទ្យាមួយសម្រាប់គ្រប់គ្រងទិន្នន័យរបស់សមាជិក និងអ្នកនៅក្នុងបន្ទុករបស់ពួកគេនៅឡើយ។ ប្រព័ន្ធគ្រប់គ្រងព័ត៌មាន ដែលត្រូវបានប្រើប្រាស់ក្នុងពេលបច្ចុប្បន្នសម្រាប់វិភាគ និងត្រួតពិនិត្យទិន្នន័យនៅមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយ ហើយលើសពីនេះទៅទៀត គឺប្រព័ន្ធនេះពុំមានសមត្ថភាពក្នុងការគ្រប់គ្រងភាគទានដែលប្រមូលបានពីសមាជិកឡើយ។

**១៦៤- បញ្ហាឆ្លងវិស័យ:** ពន្ធដារ មូលនិធិសម្រាប់វិនិយោគ ចំណេះដឹងផ្នែកហិរញ្ញវត្ថុ អភិបាលកិច្ចប្រព័ន្ធព័ត៌មានវិទ្យា និងបញ្ហាយេនឌ័រ នឹងត្រូវបានយកចិត្តទុកដាក់ក្នុងគោលជំហររួមមួយ ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមដែលប្រកបដោយប្រសិទ្ធភាព។

## ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត

**១៦៥- រៀបចំក្របខ័ណ្ឌគោលនយោបាយនិងច្បាប់:** ក្រុមការងារអភិវឌ្ឍន៍ប្រព័ន្ធគាំពារសង្គមនឹងរៀបចំក្របខ័ណ្ឌគោលនយោបាយ ច្បាប់ស្តីពីប្រព័ន្ធគាំពារសង្គម និងច្បាប់ស្តីពីរបបសោធនឯកជនស្ម័គ្រចិត្តដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីធ្វើការពិនិត្យ និងសម្រេច។

**១៦៦- រៀបចំគោលនយោបាយ ដើម្បីកំណត់រចនាសម្ព័ន្ធរបស់មូលនិធិសោធន:** រាជរដ្ឋាភិបាលនឹងធ្វើការកែតម្រង់ប្រព័ន្ធសោធនពីប្រភេទមិនបង់ភាគទាន ទៅប្រភេទបង់ភាគទាន ដើម្បីជៀសវាងការពឹងផ្អែកទាំងស្រុងលើថវិកាជាតិ។ ទន្ទឹមនេះ ការសិក្សាលើប្រភេទនៃរបបសោធនដែលសមស្របនឹងបរិបទរបស់កម្ពុជា គឺជាកត្តាចាំបាច់។ រាជរដ្ឋាភិបាលកម្ពុជា នឹងធ្វើការសម្រេចចិត្តដោយផ្អែកលើលទ្ធផលនៃការសិក្សានេះ ដោយមានរៀបចំផែនការសម្រាប់អនុវត្តឲ្យបានរលូន។

**១៦៧- ដាក់ឲ្យអនុវត្តរបបសោធនសាធារណៈ:** រាជរដ្ឋាភិបាលនឹងចាប់ផ្តើមដាក់ឲ្យអនុវត្តរបបសោធនសាធារណៈ ដែលមានលក្ខណៈកាតព្វកិច្ចសម្រាប់ក្រុមសមាជិកដែលស្ថិតក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ ស្របពេលនេះដែរ រាជរដ្ឋាភិបាល នឹងធ្វើការសិក្សាដើម្បីពិនិត្យលទ្ធភាពក្នុងការដាក់ឲ្យអនុវត្តរបបសោធននេះ សម្រាប់ក្រុមសមាជិកដែលស្ថិតក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ក្នុងដំណាក់កាលដំបូង របបនេះនឹងត្រូវដាក់ឲ្យអនុវត្តក្នុងលក្ខណៈស្ម័គ្រចិត្ត ហើយនៅដំណាក់កាលបន្ទាប់ របបនេះនឹងត្រូវផ្លាស់ប្តូរទៅជាលក្ខណៈកាតព្វកិច្ច។

**១៦៨- ដាក់ឲ្យអនុវត្តរបបសោធនឯកជន:** រាជរដ្ឋាភិបាល នឹងរៀបចំច្បាប់ និងបទប្បញ្ញត្តិ ដើម្បីផ្តល់អាជ្ញាបណ្ណដល់ប្រតិបត្តិករសោធនឯកជន ដើម្បីប្រតិបត្តិរបបនេះ។

**១៦៩- ពង្រឹងការគ្រប់គ្រង និងចាត់ចែងរបបសោធន:** ប.ជ.ស. និង ប.ជ.អ. នឹងពិនិត្យលទ្ធភាពក្នុងការធ្វើសមាហរណកម្មប្រព័ន្ធគ្រប់គ្រងរបស់បេឡាទាំងពីរនេះ។ ទោះបីជាការគ្រប់គ្រងរបបសោធនរបស់បេឡាទាំងពីរ ត្រូវបានច្របាច់បញ្ចូលគ្នាក៏ដោយ កម្ពុជានៅតែត្រូវការស្ថាប័នដាច់ដោយឡែកមួយដើម្បីគ្រប់គ្រង និងត្រួតពិនិត្យសកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងការផ្តល់របបសោធនឯកជន។ ដូច្នេះ ក្រុមការងារអភិវឌ្ឍន៍ប្រព័ន្ធគាំពារសង្គម នឹងពិនិត្យលើជម្រើសណាមួយដែលអាចអនុញ្ញាតឲ្យរាជរដ្ឋាភិបាលគ្រប់គ្រង និងចាត់ចែងរបបសោធនឲ្យបានល្អ និងជាពិសេស ដើម្បីសម្រេចបាននូវគោលដៅរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម។ ជាបទពិសោធន៍របស់ប្រទេសមួយចំនួន រដ្ឋាភិបាលបានបង្កើតស្ថាប័នតែមួយដែលមានតួនាទី ក្នុងការគ្រប់គ្រងគ្រប់មូលនិធិសោធនទាំងអស់ និងប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាតែមួយ។

**១៧០- បង្កើតជម្រើសសម្រាប់វិនិយោគមូលនិធិសោធន:** សម្រាប់ពេលបច្ចុប្បន្ននេះ មូលនិធិសោធននៅកម្ពុជាមិនទាន់ត្រូវបានយកទៅវិនិយោគនៅឡើយទេ។ ភាគទានដែលប្រមូលបានទាំងអស់ គឺត្រូវ

បានតំកល់នៅធនាគារ។ ការធ្វើពិពិធកម្មនៃការវិនិយោគ គឺជាគោលការណ៍សំខាន់មួយសម្រាប់ការគ្រប់គ្រងការវិនិយោគរបស់មូលនិធិសោធន។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងសហការជាមួយគណៈកម្មការមូលបត្រកម្ពុជា ក៏ដូចជាភាគីពាក់ព័ន្ធដទៃទៀត ដើម្បីរៀបចំអភិវឌ្ឍជម្រើសក្នុងការវិនិយោគមូលនិធិសោធនបន្ថែមទៀត។

**១៧១- បណ្តុះបណ្តាលជំនាញសម្រាប់មូលនិធិសោធន:** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបន្តរៀបចំទស្សនកិច្ចសិក្សាសម្រាប់មន្ត្រីរបស់ខ្លួន ដើម្បីសិក្សាពីបទពិសោធពីប្រទេសដទៃដែលទទួលបានជោគជ័យក្នុងការអនុវត្តរបបសោធន និងដើម្បីកំណត់មុខងាររបស់ស្ថាប័នទទួលបន្ទុកនីមួយៗឲ្យបានច្បាស់លាស់។ លើសពីនេះទៅទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងអញ្ជើញអ្នកជំនាញការផ្នែកសោធន ដើម្បីមករៀបចំវគ្គបណ្តុះបណ្តាលនៅកម្ពុជាផ្ទាល់តែម្តង។

**១៧២- អនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ទ្រទ្រង់មូលនិធិសោធន:** ប.ជ.ស. និងប.ជ.អ. នឹងធ្វើការពិនិត្យពីតម្រូវការក្នុងការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគាំទ្រដល់ដំណើរការគ្រប់គ្រងមូលនិធិសោធន។ ប្រព័ន្ធព័ត៌មានវិទ្យានេះ នឹងត្រូវតភ្ជាប់ជាមួយនឹងប្រព័ន្ធព័ត៌មានដែលមានក្នុងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងបណ្ណក្រីក្រ ដោយសារតែគោលដៅរបស់រាជរដ្ឋាភិបាល គឺចង់ឲ្យមានការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យារួមមួយសម្រាប់រាល់មូលនិធិសោធនទាំងអស់។

**១៧៣- ពង្រីកការយល់ដឹងរបស់ប្រជាពលរដ្ឋនៅលើកម្មវិធីទាំងឡាយរបស់ប្រព័ន្ធគាំពារសង្គម:** រាជរដ្ឋាភិបាល នឹងរៀបចំផែនការក្នុងការពង្រីកការយល់ដឹងរបស់ប្រជាពលរដ្ឋ ពាក់ព័ន្ធនឹងអត្ថប្រយោជន៍របស់ប្រព័ន្ធគាំពារសង្គម ដើម្បីជំរុញឲ្យប្រជាពលរដ្ឋចូលរួមឲ្យបានច្រើន ជាពិសេសគឺក្រុមពលរដ្ឋដែលស្ថិតក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

## V. វិស័យអភិវឌ្ឍអចលនវត្ថុ និងសេវាកម្មវាយតម្លៃអចលនវត្ថុ

### ក. ទិដ្ឋភាពទូទៅ

**១៧៤-** ការរីកចម្រើនផ្នែកនគរូបនីយកម្មនៅកម្ពុជា បាននាំមកនូវការកើនឡើងយ៉ាងគំហុកនៃវិស័យអភិវឌ្ឍអចលនវត្ថុ។ កត្តានេះបានរួមចំណែកយ៉ាងសកម្មនៃកំណើនផលិតផលសរុបក្នុងស្រុក (GDP) ស្ថិរភាពនយោបាយ និងលំហូរនៃការវិនិយោគផ្ទាល់ពីបរទេសមកក្នុងប្រទេស។ ជាមួយគ្នានេះដែរ កត្តាពិសេសមួយទៀត គឺបទប្បញ្ញត្តិថ្មីដែលបានបើកទូលាយឲ្យជនបរទេសមានសិទ្ធិទិញនិងកាន់កាប់អចលនវត្ថុនៅកម្ពុជាចាប់ពីជាន់ទី១ឡើងទៅ។

**១៧៥-** ដោយសារវិបត្តិសេដ្ឋកិច្ចសកលកាលពីឆ្នាំ២០០៨-២០០៩ រាជរដ្ឋាភិបាលកម្ពុជា បានអនុញ្ញាតឲ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាសេនាធិការ រៀបចំនិងកសាងក្របខ័ណ្ឌបទប្បញ្ញត្តិផ្សេងៗ ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យសកម្មភាពទាំងឡាយណា ដែលពាក់ព័ន្ធនឹងការធ្វើអាជីវកម្មអភិវឌ្ឍលំនៅឋានសេវាកម្មវាយតម្លៃ និងសេវាកម្មភ្នាក់ងារអចលនវត្ថុ។ ជាក់ស្តែង នៅឆ្នាំ២០០៧ និងឆ្នាំ២០០៩ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់ចេញនូវបទប្បញ្ញត្តិ ដើម្បីបំពេញនូវតម្រូវការចាំបាច់ ក្នុងការគ្រប់គ្រងវិស័យខាងលើនេះ។

## ខ. វឌ្ឍនភាព និងសមិទ្ធផល

**១៧៦- ការអភិវឌ្ឍអចលនវត្ថុ:** គិតរហូតមកដល់ពាក់កណ្តាលឆ្នាំ២០១៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់អាជ្ញាបណ្ណអភិវឌ្ឍអចលនវត្ថុបានចំនួន ១១៦ក្រុមហ៊ុន ដែលស្មើនឹង ១៦៥គម្រោង ដែលមានទុនវិនិយោគសរុបប្រមាណ២ ០១៦ប៊ីលានដុល្លារអាមេរិក។ ការណ៍នេះស្តែងឲ្យឃើញពីការរីកចម្រើនយ៉ាងខ្លាំងលើវិស័យអភិវឌ្ឍអចលនវត្ថុនៅកម្ពុជាក្នុងរយៈពេល ៦ឆ្នាំចុងក្រោយនេះ។

**១៧៧-** បច្ចុប្បន្នក្រសួងបានពង្រឹងការអនុវត្តអាជ្ញាបណ្ណ និងកំណត់វិធានការចុះត្រួតពិនិត្យលើគម្រោងអភិវឌ្ឍអលចនវត្ថុយ៉ាងទៀងទាត់។ ទន្ទឹមនឹងនេះ ក្រសួងបានរៀបចំនិងអភិវឌ្ឍកាន់តែប្រសើរឡើងលើក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននៃទីផ្សារអចលនវត្ថុនេះផងដែរ។

**១៧៨- អ្នកវាយតម្លៃនិងភ្នាក់ងារអចលនវត្ថុ:** ការផ្តល់អាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុនវាយតម្លៃនិងភ្នាក់ងារអចលនវត្ថុ បានចាប់ផ្តើមឡើងក្នុងឆ្នាំ២០០៧។ ជាមួយគ្នានេះដែរ សមាគមអ្នកវាយតម្លៃនិងភ្នាក់ងារអចលនវត្ថុកម្ពុជា ត្រូវបានបង្កើតនៅឆ្នាំ២០០៨ និងបានក្លាយជាសមាជិកទី៨នៃសមាគមអ្នកវាយតម្លៃអាស៊ាននៅឆ្នាំ២០០៩។ គិតរហូតមកដល់ពាក់កណ្តាលឆ្នាំ២០១៦នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈនិងអាជ្ញាបណ្ណសេវាកម្មវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុដល់ក្រុមហ៊ុនបានចំនួន ១៤៩ និងបានចុះត្រួតពិនិត្យជាប្រចាំដល់ក្រុមហ៊ុនទាំងនោះផងដែរ។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**១៧៩-** បច្ចុប្បន្នពុំទាន់មានក្របខ័ណ្ឌច្បាប់រឹងមាំ ដើម្បីផ្តល់សិទ្ធិដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការដាក់ទោសដល់បុគ្គលដែលប្រកបអាជីវកម្មខុសច្បាប់នៅឡើយទេ។ ដូចនេះ ទាមទារឲ្យមានការរៀបចំច្បាប់ និងបទប្បញ្ញត្តិជាច្រើនទៀតដើម្បីពង្រឹងការគ្រប់គ្រង និងការត្រួតពិនិត្យឲ្យបានច្បាស់លាស់ និងអាចកាត់បន្ថយអាជីវកម្មខុសច្បាប់។

**១៨០-** ការកសាងសមត្ថភាព គឺជាសេចក្តីត្រូវការដ៏ចម្បងទាំងវិស័យឯកជន និងសាធារណៈ។ បច្ចុប្បន្ននេះ ពុំទាន់មានគ្រឹះស្ថានបណ្តុះបណ្តាលសម្រាប់អ្នកប្រកបវិជ្ជាជីវៈផ្នែកវាយតម្លៃ ផ្នែកភ្នាក់ងារអចលនវត្ថុ ផ្នែកគ្រប់គ្រងអចលនវត្ថុ និងអ្នកចូលរួមនៅក្នុងទីផ្សារដទៃទៀតឡើយ។ ចំនួននិងសមត្ថភាពមន្ត្រី

ជំនាញនៅមានកម្រិតក្នុងការរៀបចំច្បាប់ និងបទប្បញ្ញត្តិនានា ដើម្បីគ្រប់គ្រង និងអភិវឌ្ឍវិស័យដ៏មានសារៈសំខាន់នេះ។

**១៨១-** រហូតមកដល់ពេលនេះ នៅពុំទាន់មានស្តង់ដាវាយតម្លៃឬក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អ្នកប្រកបសេវាកម្មវាយតម្លៃ និងភ្នាក់ងារសេវាកម្មអចលនវត្ថុ ដើម្បីប្រតិបត្តិនៅឡើយទេ។ កង្វះប្រព័ន្ធសម្រាប់គ្រប់គ្រងទិន្នន័យ និងធ្វើការវិភាគដ៏សមស្របមួយសម្រាប់វិស័យនេះដើម្បីងាយស្រួលតាមដាន គឺជារឿងដែលត្រូវតែធ្វើជាចាំបាច់ និងឲ្យបានទាន់ពេលវេលា ។

**១៨២- ការបំពេញលក្ខខណ្ឌកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម:** កិច្ចសហការអនុវត្ត និងការបណ្តុះបណ្តាលមន្ត្រី និងបុគ្គលិករាយការណ៍ពាក់ព័ន្ធទៅនឹងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅមានកម្រិត។

## ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត

**១៨៣-** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងរៀបចំសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិថ្មីបន្ថែមទៀតដើម្បីបំពេញបន្ថែមនូវភាពខ្វះចន្លោះក្នុងការគ្រប់គ្រង (១) វិស័យអភិវឌ្ឍលំនៅឋាន (២) ការធ្វើប្រតិបត្តិការរបស់អ្នកប្រកបសេវាកម្មវាយតម្លៃ សេវាកម្មភ្នាក់ងារអចលនវត្ថុ និងសេវាកម្មគ្រប់គ្រងអចលនវត្ថុឲ្យមានតម្លាភាព និងប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈកម្រិតខ្ពស់។ ច្បាប់និងបទប្បញ្ញត្តិថ្មីនេះ ក៏នឹងមានបន្ថែមនូវការបង្កើតឲ្យមានកិច្ចសហការរវាងស្ថាប័នពាក់ព័ន្ធ ការគោរពនូវលក្ខខណ្ឌតម្រូវរបស់ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ការកំណត់បទដ្ឋានព័ត៌មាននិងកិច្ចការពារអ្នកប្រើប្រាស់ និងលក្ខខណ្ឌតម្រូវផ្សេងទៀតផងដែរ។

**១៨៤-** ក្រសួងកំពុងរៀបចំវិធានមួយចំនួនដូចជា: ស្តង់ដាវាយតម្លៃ ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អ្នកវាយតម្លៃ និងភ្នាក់ងារសេវាកម្មអចលនវត្ថុ តារាងថ្លៃ និងកម្រៃជើងសា ដើម្បីដាក់ឲ្យប្រតិបត្តិករពាក់ព័ន្ធទៅនឹងវិស័យនេះអនុវត្ត។ ការរៀបចំស្តង់ដាវាយតម្លៃ គឺអនុលោមតាមស្តង់ដារបស់អាស៊ាន និងស្តង់ដាវាយតម្លៃរបស់ក្រុមប្រឹក្សាវាយតម្លៃអន្តរជាតិ (IVSC)។

**១៨៥-** ក្រសួងនឹងពង្រឹងសមត្ថភាពមន្ត្រីជំនាញ និងអ្នកចូលរួមទីផ្សារ តាមរយៈការបណ្តុះបណ្តាលក្នុងប្រទេស និងក្រៅប្រទេស។ ក្រៅពីនេះ ក្រសួង នឹងបង្កើនកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីចែករំលែកព័ត៌មាន ជាពិសេសលើវិស័យអចលនវត្ថុ ដើម្បីគ្រប់គ្រងហានិភ័យ។

**១៨៦-** ក្រសួងនឹងរៀបចំឲ្យមានប្រព័ន្ធសម្រាប់គ្រប់គ្រងទិន្នន័យ និងធ្វើការវិភាគសមស្របមួយសម្រាប់វិស័យអចលនវត្ថុ។

**១៨៧- ការបំពេញលក្ខខណ្ឌកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម៖** អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ដែលមាននាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ជាសេនាធិការ នឹងផ្តល់ការគាំទ្របន្ថែមទៀត ដើម្បីធានាថាកិច្ចសហការអនុវត្ត និងការបណ្តុះបណ្តាល ចំពោះមន្ត្រីបុគ្គលិករាយការណ៍ពាក់ព័ន្ធទៅនឹងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានពង្រឹង។

## VI. អាជីវកម្មទទួលបញ្ចាំ

### ក.ទិដ្ឋភាពទូទៅ

**១៨៨-** ដោយមើលឃើញពីការរីកដុះដាលនៃវិស័យបញ្ចាំនៅឆ្នាំ២០១០ រាជរដ្ឋាភិបាលបានអនុញ្ញាតឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលជាសេនាធិការចេញប្រកាស ស្តីពីការផ្តល់អាជ្ញាបណ្ណទទួលបញ្ចាំ និងទិញលក់ទ្រព្យបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន ដើម្បីគ្រប់គ្រងលើវិស័យនេះ។

### ខ.វឌ្ឍនភាព និងសមិទ្ធផល

**១៨៩-** ចាប់តាំងពីឆ្នាំ២០១០ ដល់ពាក់កណ្តាលឆ្នាំ២០១៦ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តល់អាជ្ញាបណ្ណទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ដល់ក្រុមហ៊ុន/សហគ្រាសចំនួន៣២៨។ ជាមួយគ្នានេះដែរ ការផ្តល់ប្រាក់កម្ចីទៅឲ្យអតិថិជនតាមរយៈក្រុមហ៊ុនទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទាននេះ មានទឹកប្រាក់សរុបចំនួន ៣៧លានដុល្លារអាមេរិក។ ដើម្បីពង្រឹងការគ្រប់គ្រងលើវិស័យនេះ ក្រសួងបានរៀបចំវគ្គបណ្តុះបណ្តាលជាច្រើនលើកច្រើនសារពាក់ព័ន្ធទៅនឹងបទប្បញ្ញត្តិដែលមានស្រាប់ជូនដល់ប្រតិបត្តិករ និងអ្នកចូលរួមទីផ្សារ។ ក្រៅពីនេះ ក្រសួងបានធ្វើកិច្ចសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីពង្រឹងការអនុវត្តច្បាប់ និងលុបបំបាត់អាជីវកម្មដែលគ្មានច្បាប់។

**១៩០-** ក្រសួង បានធ្វើកែសម្រួលឡើងវិញនូវប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ដើម្បីឲ្យស្របទៅនឹងតថភាពជាក់ស្តែងនៃការវិវត្តក្នុងវិស័យនេះ និងបានរៀបចំតាក់តែងនូវសេចក្តីព្រាងច្បាប់ស្តីពីអាជីវកម្មទទួលបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានផងដែរ។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**១៩១-** ដោយសារវិស័យនេះជាវិស័យថ្មី ដូច្នេះ នៅមានកង្វះខាតច្រើនពាក់ព័ន្ធទៅនឹងក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីគ្រប់គ្រងឲ្យបានរឹងមាំ។ ដូច្នេះ ការរៀបចំច្បាប់ និងបទប្បញ្ញត្តិមួយចំនួន គឺជារឿងចាំបាច់ដែលមិនអាចខ្វះបាន។

**១៩២-** បច្ចុប្បន្ន ក្រសួងនៅមិនទាន់មានប្រព័ន្ធព័ត៌មានវិទ្យា និងប្រព័ន្ធជូនដំណឹងជាមុន ដើម្បីជួយសម្រួលដល់ការងារតាមដាន និងត្រួតពិនិត្យរបស់ខ្លួនលើអាជីវកម្មនេះនៅឡើយទេ។

**១៩៣-** ចំពោះមុខក្រសួងកំពុងខ្វះនូវមន្ត្រីជំនាញ និងការបណ្តុះបណ្តាលនានា ដើម្បីពង្រឹងសមត្ថភាពប្រតិបត្តិករលើវិស័យនេះ។

**១៩៤- ការបំពេញលក្ខខណ្ឌកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម:** កិច្ចសហការអនុវត្ត និងការបណ្តុះបណ្តាលមន្ត្រី និងបុគ្គលិករាយការណ៍ពាក់ព័ន្ធទៅនឹងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅមានកម្រិត។

## ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត

**១៩៥-** ក្រសួងនឹងដាក់ឲ្យអនុវត្តប្រកាសថ្មី ស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាននឹងដាក់ឲ្យអនុវត្ត នៅចុងឆ្នាំ២០១៦ នេះ។ ជាមួយគ្នានេះ ក្រសួងនឹងបញ្ចប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ដើម្បីបង្កើតឲ្យមានយន្តការទទួលខុសត្រូវប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងគណនេយ្យភាពរវាងអ្នកទទួលបញ្ចាំ និងអ្នកដាក់បញ្ចាំ។

**១៩៦-** ក្រសួងនឹងបង្កើតប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ប្រមូលចងក្រងទិន្នន័យព័ត៌មាន ដើម្បីសម្រួលដល់ការគ្រប់គ្រង និងការត្រួតពិនិត្យវិស័យទទួលបញ្ចាំនេះ ហើយអាចផ្តល់នូវប្រព័ន្ធជូនដំណឹងជាមុនបាន។

**១៩៧-** ក្រសួងនឹងស្វែងរកជំនួយបច្ចេកទេស ដើម្បី៖ (១) អភិវឌ្ឍលើការកសាងសមត្ថភាពមន្ត្រីជំនាញ (២) ជួយរៀបចំតាក់តែងសេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មលក់ដេញថ្លៃមហាជន និងអាជីវកម្មទំនិញប្រើប្រាស់រួច។

**១៩៨- ការបំពេញលក្ខខណ្ឌកាតព្វកិច្ចការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម:** អគ្គនាយក-ដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ដែលមាននាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ជាសេនាធិការ នឹងផ្តល់ការគាំទ្របន្ថែមទៀត ដើម្បីធានាថាកិច្ចសហការអនុវត្ត និងការបណ្តុះបណ្តាល ចំពោះមន្ត្រីបុគ្គលិករាយការណ៍ពាក់ព័ន្ធទៅនឹងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានពង្រឹង។

# ជំពូក៤
# ការគាំទ្រផ្នែកហេដ្ឋារចនាសម្ព័ន្ធ

## I. សេចក្តីផ្តើម

**១៩៩-** ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា ទាមទារឲ្យមានក្របខ័ណ្ឌគាំទ្រលើផ្នែកសំខាន់ៗមួយចំនួន ដូចជា: (១) ការកសាងសមត្ថភាពទាំងនៅក្នុងវិស័យសាធារណៈ និងវិស័យឯកជន (២) ការជួយគាំទ្រផ្នែកគណនេយ្យនិងសវនកម្ម (៣) ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិរឹងមាំ (៤) ដំណើរការការិយាល័យឥណទាន (៥) យន្តការគាំទ្របរិយាបន្នហិរញ្ញវត្ថុដែលរួមបញ្ចូលទាំងការធានាលើឥណទាន និងការការពារអ្នកដាក់ប្រាក់បញ្ញើ (៦) ការបង្កើតអង្គភាពបរធនបាលកិច្ចសម្រាប់វិស័យហិរញ្ញវត្ថុ (៧) ប្រព័ន្ធនិងស្តង់ដាសមស្រប និង (៨) សមាហរណកម្មជាមួយយុទ្ធសាស្ត្ររាជរដ្ឋាភិបាលផ្សេងទៀត (គោលនយោបាយសង្គម) និងសមាហរណកម្មក្នុងតំបន់។ ក្របខ័ណ្ឌគាំទ្រទាំងនេះចូលរួមចំណែកក្នុងការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុមួយឲ្យរឹងមាំតាមយន្តការទីផ្សារ ដើម្បីកៀរគរធនធានហិរញ្ញវត្ថុ និងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។

**២០០-** ការពិនិត្យលើក្របខ័ណ្ឌគាំទ្រដែលបានកំណត់នៅក្នុងចក្ខុវិស័យ និងផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុលើកដំបូងឆ្នាំ២០០១-២០១០ ដែលរួមមាន: (១) ប្រព័ន្ធគណនេយ្យនិងសវនកម្ម និងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) (២) ច្បាប់ អនុក្រឹត្យ និងប្រកាសត្រូវបានរៀបចំ និងដាក់ចេញដើម្បីគាំទ្រសកម្មភាពបច្ចុប្បន្ន និងអនាគតក្នុងវិស័យពាណិជ្ជកម្ម និងហិរញ្ញវត្ថុ (៣) ប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានអភិវឌ្ឍ និងបន្តធ្វើឲ្យប្រសើរឡើង និង (៤) ការអភិវឌ្ឍធនធានមនុស្សបានបង្កើនសមត្ថភាពជំនាញនៅក្នុងវិស័យនេះ។ បញ្ហាប្រឈមតាមវិស័យបច្ចុប្បន្ន គឺធ្វើយ៉ាងណាជំរុញក្របខ័ណ្ឌគាំទ្រខាងលើនេះទៅមុខ និងបន្តធ្វើសមាហរណកម្មការអនុវត្តប្រព័ន្ធចាំបាច់នានា ការអនុវត្តទៅតាមស្តង់ដា និងការកសាងសមត្ថភាពដែលចាំបាច់សម្រាប់កម្ពុជា ដើម្បីឈានទៅសម្រេចបាននូវផលប្រយោជន៍ពេញលេញពីការចូលក្នុងសហគមសេដ្ឋកិច្ចអាស៊ាន។

## II. ក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

### ក. ទិដ្ឋភាពទូទៅ

**២០១-** ក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT) ដែលបានបង្ហាញក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០ រួមមាន គោលនយោបាយនិងគំនិតផ្តួចផ្តើមដែលមានគោលបំណងបង្ហាញពីការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាល ក្នុងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម រហូតសម្រេចបានតាមឧត្តមានុវត្តរបស់អន្តរជាតិ។

**២០២-** ប្រទេសកម្ពុជាត្រូវបានចាត់ចូលក្នុងបញ្ជីប្រផេះ ដោយសារកង្វះខាតជាយុទ្ធសាស្ត្រនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ប៉ុន្តែកម្ពុជាបានអនុវត្តផែនការសកម្មភាពកែតម្រូវចំណុចខ្វះខាតរបស់ខ្លួនបានទាន់ពេលវេលា។ កម្ពុជាបានធ្វើការតាំងចិត្តខ្ពស់ក្នុងការធ្វើការជាមួយ FATF និងក្រុមអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (APG) ក្នុងការអនុវត្តផែនការសកម្មភាពនេះដែលធាតុផ្សំសំខាន់ៗនៃផែនការសកម្មភាព ត្រូវបានបញ្ចូលទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០។ វិធានការគោលនយោបាយដែលបានគ្រោង រួមមាន (១) ការដាក់ទោសការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (២) ការបង្កើតនិងអនុវត្តនីតិវិធីសម្គាល់ និងបង្កកទ្រព្យសម្បត្តិរបស់ភេរវករ (៣) ការបង្កើតនិងដាក់ឲ្យប្រើប្រាស់នូវនីតិវិធីរឹបអូសមូលនិធិពាក់ព័ន្ធនឹងការសម្អាតប្រាក់ (៤) ការធានាឲ្យអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុមានដំណើរការនិងអនុវត្តមុខងារប្រកបដោយប្រសិទ្ធិភាព និង (៥) ការបែងចែក និងអនុវត្តការត្រួតពិនិត្យប្រតិបត្តិការសាច់ប្រាក់ឆ្លងដែនប្រកបដោយប្រសិទ្ធិភាព។

## ខ. វឌ្ឍនភាពនិងសមិទ្ធផល

**២០៣-** កម្ពុជាមានការវិវត្តយ៉ាងរហ័ស តាមរយៈការអនុវត្តវិធានការនិងគំនិតផ្តួចផ្តើមជាច្រើនក្នុងការកែតម្រូវកង្វះខាត ហើយវិធានការបន្តបន្ទាប់ ដើម្បីពង្រឹងរបបប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ក៏ត្រូវបានបញ្ចូលទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥។ កិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដែលដឹកនាំដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជានៃធនាគារជាតិនៃកម្ពុជា បានធ្វើឲ្យប្រទេសកម្ពុជាចេញផុតពីប្រទេសដែលមានចំណុចខ្វះខាតជាយុទ្ធសាស្ត្រនៅក្នុងមហាសន្និបាតរបស់ FATF កាលពីខែកុម្ភៈ ឆ្នាំ២០១៥។

**២០៤-** វិសោធនកម្មក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិមួយចំនួន ទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មត្រូវបានអនុម័ត។ ការរៀបចំអភិបាលកិច្ចត្រូវបានពង្រឹងតាមរយៈការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដែលជាស្ថាប័នដាក់ចេញគោលនយោបាយអន្តរក្រសួង។ គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិបានបង្កើតឲ្យមានយុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដែលបានដាក់ឲ្យប្រើប្រាស់កាលពីខែមីនា ឆ្នាំ២០១៣ ដោយបានគ្របដណ្តប់ផ្នែកជាយុទ្ធសាស្ត្រចំនួន៧ ដែលបានបំពេញបន្ថែមនៅក្នុងខែធ្នូ ឆ្នាំ២០១៤។ យុទ្ធសាស្ត្រដ៏មានសារៈសំខាន់មួយ គឺការវាយតម្លៃហានិភ័យថ្នាក់ជាតិដែលពាក់ព័ន្ធនឹងការកំណត់ ការវិភាគ ការវាយតម្លៃ និងការកាត់បន្ថយការគំរាមកំហែងនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ដើម្បីអនុវត្តការងារនេះ ក្រុមការងារជំនាញមកពីស្ថាប័នពាក់ព័ន្ធត្រូវ

បានបង្កើតឡើងនៅខែសីហា ឆ្នាំ២០១៤ និងដឹកនាំដោយអគ្គលេខាធិការអង្គភាពស៊ើបការណ៍ហិរញ្ញ-វត្ថុកម្ពុជា។

**២០៥-** ជំនួយមកពីធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក រតនាគារសហរដ្ឋអាមេរិក ការិយាល័យអង្គការសហប្រជាជាតិស្តីពីគ្រឿងញៀននិងបទឧក្រិដ្ឋ (UNODC) និងអ្នកផ្តល់ជំនួយផ្សេងទៀតបានគាំទ្រដល់ការអនុវត្តវិធានការគោលនយោបាយ ព្រមទាំងការកសាងសមត្ថភាព និងស្ថាប័នដែលមាននៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០។ វិធានការសំខាន់ៗត្រូវបានអនុវត្តដើម្បីពង្រឹង និងបង្កើនសមត្ថភាពរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។ ការបង្កើតប្រព័ន្ធរាយការណ៍ប្រតិបត្តិការសង្ស័យ និងប្រតិបត្តិការសាច់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកដែលបានដាក់ឲ្យដំណើរការកាលពីខែមិថុនា ឆ្នាំ២០១៣ បានធ្វើឲ្យដំណើរការវិភាគរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាកាន់តែល្អប្រសើរឡើង។ នៅក្នុងរយៈពេលពីរឆ្នាំកន្លងទៅនេះ មន្ត្រីរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានកើនឡើងរហូតដល់ ១៧រូប ហើយទីតាំងក៏ត្រូវបានពង្រីកផងដែរ។

**២០៦-** អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងភ្នាក់ងារពាក់ព័ន្ធការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មសំខាន់ៗផ្សេងទៀត សុទ្ធតែទទួលបានជំនួយបច្ចេកទេស។ ជំនួយបច្ចេកទេសនេះបានអនុញ្ញាតឲ្យគយអនុវត្តប្រព័ន្ធប្រតិវេទន៍ឆ្លងដែន ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ជំនួយបច្ចេកទេសនេះក៏បានបញ្ជ្រាបការយល់ដឹងដល់ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងភ្នាក់ងារអនុវត្តច្បាប់នានា ឲ្យមានការកាត់ទោសមិនត្រឹមតែលើសម្ពាងនៃបទល្មើសនោះទេ ប៉ុន្តែក៏បានកំណត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មជាករណីអាទិភាពនិងភាពបន្ទាន់ផងដែរ។

**២០៧-** អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានស្នើសុំ និងបន្ទាប់មកទទួលបានសមាជិកភាពរបស់ក្រុម Egmont នៅអំឡុងពេលមហាសន្និបាតនៅកោះ Barbados កាលពីខែមិថុនា ឆ្នាំ២០១៥។ បើប្រៀបធៀបនឹងឆ្នាំ២០១១ នៅពេលចាប់ផ្តើមកាលបរិច្ឆេទនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន ស្ថានភាពទូទៅនៃក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម គឺបានអនុវត្តយ៉ាងល្អប្រសើរតាមតម្រូវការស្តង់ដាអន្តរជាតិរបស់ FATF។

**២០៨-** កម្ពុជាបានចាប់ផ្តើមអនុវត្តការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងទទួលបានជំនួយបច្ចេកទេសពីធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ីលើការងារនេះ។ ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនីមួយៗ បានបញ្ចប់ការវាយតម្លៃហានិភ័យរបស់ខ្លួនហើយ លទ្ធផលនៃការវាយតម្លៃនេះ កំពុងរួមបញ្ចូលគ្នាទៅក្នុងការវាយតម្លៃពីការគំរាមកំហែងរួមនៃវិស័យធនាគារ និងហិរញ្ញវត្ថុ ដើម្បីកំណត់វិធានការកាត់បន្ថយហានិភ័យក្នុងវិស័យនេះ។

**២០៩-** កម្ពុជានឹងបន្តព្យាយាមសម្រេចឲ្យបានការប្រតិបត្តិទាំងស្រុង តាមតម្រូវការនៃស្តង់ដាអន្តរជាតិរបស់ FATF មុនដំណាច់ឆ្នាំ២០២៥។ នៅពេលនោះ កម្ពុជានឹងបានទទួលកេរ្តិ៍ឈ្មោះសម្រាប់ធ្វើប្រតិបត្តិការនៅក្នុងទីផ្សារហិរញ្ញវត្ថុមានសុវត្ថិភាពមួយ ជាមួយវិធានការរុញច្រានឧក្រិដ្ឋជនសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**២១០-** បើទោះជារាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលច្រើនលើក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិក៏ដោយ ក៏នៅតែមានបញ្ហាប្រឈម និងចំណុចខ្វះខាតខ្លះៗដែលទាមទារឲ្យបំពេញបន្ថែម ដើម្បីឲ្យស្របតាមស្តង់ដារបស់ FATF ពិសេសលើផ្នែកប្រសិទ្ធភាពនៃការអនុវត្តក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិទាំងនោះ។

**២១១-** កម្ពុជា ក៏នៅប្រឈមនឹងបញ្ហាដែលបង្កដោយការប្រើប្រាស់សាច់ប្រាក់ និងដុល្លារូបនីយកម្មខ្ពស់ក្នុងសេដ្ឋកិច្ច និងប្រព័ន្ធធនាគារនៅមានកម្រិត ហើយចំណុចខ្វះខាតមានដូចជា ការគ្រប់គ្រងព្រំដែននៅធូររលុង ភាពទន់ខ្សោយនៃប្រព័ន្ធតុលាការ និងអំពើពុករលួយ។

## ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត

**២១២-** កម្ពុជាកំពុងខិតខំប្រឹងប្រែងយ៉ាងសស្រាក់សស្រាំ ក្នុងការផ្តល់ព័ត៌មានចាំបាច់នានា សម្រាប់ទទួលការវាយតម្លៃអញ្ញមញ្ញរបស់ APG នៅចុងឆ្នាំ២០១៦នេះ ដែលត្រូវការជាចាំបាច់នូវការសហការយ៉ាងជិតស្និទ្ធនៅក្នុងចំណោមភាគីពាក់ព័ន្ធនានា ក្នុងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដើម្បីបំពេញកម្រងសំណួរ លើការប្រតិបត្តិតាមបច្ចេកទេស (Technical Compliance) និងប្រសិទ្ធភាពនៃការអនុវត្ត (Effectiveness) របស់ FATF ក្នុងការទប់ស្កាត់សកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**២១៣- ការត្រួតពិនិត្យ:** ការអនុវត្តបទប្បញ្ញត្តិ និងសេចក្តីណែនាំនឹងត្រូវបានបង្កើតឡើង ដើម្បីបញ្ចូលអង្គការក្រៅរដ្ឋាភិបាល ឬអង្គការមិនស្វែងរកប្រាក់ចំណេញទៅក្នុងក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ខណៈពេលដែលច្បាប់ថ្មីសម្រាប់កាស៊ីណូ កំពុងត្រូវបានព្រាងសេចក្តីណែនាំនឹងត្រូវដាក់ចេញ ដើម្បីត្រួតពិនិត្យប្រតិបត្តិការកាស៊ីណូឲ្យបានល្អប្រសើរជាងមុន និងបញ្ជាក់ថាពួកគេបានប្រកាន់ខ្ជាប់នូវវិធានការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**២១៤-** លើសពីនេះ ច្បាប់ និងបទប្បញ្ញត្តិទាំងអស់ដែលអនុវត្តសម្រាប់បុគ្គលរាយការណ៍មិនមែនធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (ក្រុមហ៊ុនមូលបត្រនិងធានារ៉ាប់រង) និងវិជ្ជាជីវៈនិងមុខរបរមិនមែនហិរញ្ញវត្ថុ (DNFBPs) នឹងត្រូវពិនិត្យឡើងវិញ និងធ្វើវិសោធនកម្ម ឬបំពេញបន្ថែម ដើម្បីធានាឲ្យច្បាប់ និងបទប្បញ្ញត្តិទាំងនោះ ស្របនឹងក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ការយក

ចិត្តទុកដាក់ជាពិសេសនឹងត្រូវផ្ដោតលើបទប្បញ្ញត្តិ និងរចនាសម្ព័ន្ធត្រួតពិនិត្យ ដែលគ្របដណ្ដប់លើ អចលនទ្រព្យ សារការី ឈ្មួញមូលបត្រ មេធាវី និងគណនេយ្យករ។

**២១៥- ការកសាងសមត្ថភាព**: អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវបង្កើនសមត្ថភាពវិភាគរបស់ខ្លួនឲ្យបានច្រើន និងដំណើរការព័ត៌មានបានមកពីរបាយការណ៍ប្រតិបត្តិការសាច់ប្រាក់ និងរបាយការណ៍ប្រតិបត្តិការសង្ស័យ និងដើម្បីស្វែងរកនិន្នាការនៃការគំរាមកំហែងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម តាមរយៈការផ្លាស់ប្ដូរព័ត៌មាននៅក្នុងចំណោមភាគីពាក់ព័ន្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មក្នុងស្រុក និងអន្តរជាតិ។ ក្នុងគោលបំណងសម្រេចបានការកែលម្អនេះ សមត្ថភាពត្រួតពិនិត្យ និងតាមដានវិធានការប្រតិបត្តិតាមរបស់បញ្ញត្តិករប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មត្រូវពង្រឹងឲ្យបានឆាប់រហ័ស។

**២១៦- សមត្ថភាពការស៊ើបអង្កេត**: កិច្ចខិតខំប្រឹងប្រែងគួរឲ្យកត់សម្គាល់ និងកាន់តែច្បាស់លើការជំរុញការអនុវត្តច្បាប់ និងប្រព័ន្ធតុលាការនឹងត្រូវធ្វើឡើង ដើម្បីផ្ដោតកាន់តែខ្លាំងលើបទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលជាប់ពាក់ព័ន្ធនឹងផលនៃបទល្មើស។ ប្រការនេះនឹងតម្រូវឲ្យមានជំនួយបច្ចេកទេសសម្រាប់កម្មវិធីបណ្ដុះបណ្ដាលបន្ថែមទៀតនៅក្នុងបច្ចេកទេសស៊ើបអង្កេត និងតម្រូវការព័ត៌មានសម្រាប់ដំណើរការកាត់ទោសបទល្មើស ដែលជាប់ទាក់ទងនឹងបទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**២១៧- ស្ថិតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម**: អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងអាជ្ញាធរពាក់ព័ន្ធនឹងពិនិត្យឡើងវិញ និងកែលម្អព័ត៌មានស្ថិតិអំពីសកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ មូលដ្ឋានទិន្នន័យប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជារក្សាទុក នឹងមានអត្ថប្រយោជន៍ខ្លាំងក្នុងការគាំទ្រដល់ការកែលម្អសមត្ថភាពស៊ើបអង្កេត។

**២១៨- កិច្ចសហប្រតិបត្តិការក្នុងស្រុកនិងអន្តរជាតិ**: ដើម្បីកែលម្អកិច្ចសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការជាមួយនឹងអាជ្ញាធរបទប្បញ្ញត្តិក្នុងស្រុក និងដៃគូអន្តរជាតិ កិច្ចព្រមព្រៀង ឬអនុស្សរណៈយោគយល់គ្នា អាចត្រូវការជាចាំបាច់។ ការបង្កើតពិធីសារសម្រាប់ការផ្លាស់ប្ដូរព័ត៌មាន និងការឆ្លើយតបសំណើសុំចាត់វិធានការនានាអាចធ្វើឡើងនាពេលបន្ទាប់។

**២១៩- ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ**: បន្តពិនិត្យឡើងវិញនូវក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងបើចាំបាច់ ពិចារណាលើវិសោធនកម្ម ឬការបំពេញបន្ថែមនៃច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំដើម្បីជំរុញការអនុវត្តច្បាប់នេះ។

**២២០- ការវាយតម្លៃហានិភ័យថ្នាក់ជាតិ:** នៅក្នុងពេលចំពោះមុខ ធនធានជាច្រើនរបស់ភាគីពាក់ព័ន្ធប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ជាពិសេស អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នឹងត្រូវផ្តោតលើដំណើរការវាយតម្លៃអញ្ញមញ្ញ។ ដំណើរការវាយតម្លៃអញ្ញមញ្ញនេះ រំពឹងថានឹងរួមចំណែកដល់ការពន្លឿនការវាយតម្លៃហានិភ័យថ្នាក់ជាតិ។ កិច្ចខិតខំប្រឹងប្រែងកាន់តែច្រើននឹងត្រូវធ្វើឡើង ដើម្បីជំរុញឲ្យមានការវិវត្តកាន់តែលឿន ជាពិសេស ក្នុងការប្រមូលព័ត៌មានចាំបាច់សម្រាប់ធ្វើការវាយតម្លៃការគំរាមកំហែង និងភាពងាយរងគ្រោះពីហានិភ័យនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**២២១- ការបង្កើនការយល់ដឹង:** ការបង្កើនការយល់ដឹងគឺមានសារៈសំខាន់ ប៉ុន្តែអាចទទួលបានការយកចិត្តទុកដាក់តិចតួច ដោយសារកង្វះខាតធនធានមនុស្សនិងហិរញ្ញវត្ថុ។ ដូច្នេះប្រព័ន្ធនិងគេហទំព័រ (web-based packages) នឹងត្រូវយកមកប្រើប្រាស់។

## III. **អភិបាលកិច្ច**

### **ក. ទិដ្ឋភាពទូទៅ**

**២២២-** អភិបាលកិច្ចល្អត្រូវបានចាត់ទុកថា មានសារៈសំខាន់សម្រាប់ការគ្រប់គ្រងធុរកិច្ចឲ្យបានល្អ កំណើនសេដ្ឋកិច្ច និងពាណិជ្ជកម្ម និងការអភិវឌ្ឍ។

**២២៣-** តម្រូវការអភិបាលកិច្ចល្អនៅកម្ពុជា ត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងការបង្កើតទីផ្សារមូលបត្រ។

**២២៤-** ការអភិវឌ្ឍវប្បធម៌ និងស្ថាប័នដើម្បីគាំទ្រអភិបាលកិច្ចសាជីវកម្មឲ្យមានប្រសិទ្ធភាព តាមរយៈវិស័យពាណិជ្ជកម្ម និងរាជរដ្ឋាភិបាល ត្រូវបានគាំទ្រដោយគំនិតផ្តួចផ្តើមនានា ដូចជាការបង្កើតអនុ-គណៈកម្មការរាជរដ្ឋាភិបាលស្តីពីការអភិវឌ្ឍអភិបាលកិច្ចសាជីវកម្ម ដែលស្ថិតក្រោមគណៈកម្មការនៃវិស័យឯកជននៅឆ្នាំ២០០៩។ ប៉ុន្តែ នៅមានបញ្ហាជាច្រើនទៀតដែលត្រូវដោះស្រាយដើម្បីគាំទ្រការអនុវត្តគោលការណ៍អភិបាលកិច្ចសាជីវកម្មឲ្យបានទូលំទូលាយនៅកម្ពុជា។

**២២៥-** ក្នុងវិស័យធនាគារ អភិបាលកិច្ចគឺជាគោលការណ៍ដ៏សំខាន់មួយ នៃគោលការណ៍គ្រឹះទីក្រុងបាសែលស្តីពីការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាព។ អភិបាលកិច្ចល្អ ដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងធនាគារ ប្រកបដោយការប្រុងប្រយ័ត្ន និងកាត់បន្ថយហានិភ័យក្នុងវិស័យធនាគារ។ ធនាគារជាតិនៃកម្ពុជា ផ្តោតការយកចិត្តទុកដាក់លើអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុជាប្រចាំ ជាពិសេស តាមរយៈការពង្រឹងការត្រួតពិនិត្យ និងការអនុវត្តបទប្បញ្ញត្តិ។

**២២៦-** អាជីវកម្ម និងសេវាកម្មអចលនវត្ថុ ត្រូវបាននិងកំពុងគ្រប់គ្រង និងត្រួតពិនិត្យ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការចង្អុលទិសរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅគ្រប់គ្រងហានិភ័យដែលបណ្តាលមកពីការអភិវឌ្ឍអចលនវត្ថុ និងសេវាកម្មអចលនវត្ថុ មិនគោរពតាមច្បាប់ និងបទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាល។

**២២៧-** អាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ត្រូវបានគិតគូរឲ្យមានការគ្រប់គ្រងច្បាស់លាស់ ដើម្បីធានាបាននូវអភិបាលកិច្ចល្អ និងភាពស្របច្បាប់នៅក្នុងវិស័យនេះ ព្រមទាំងប្រែក្លាយអាជីវកម្មនេះទៅជាយន្តការបម្រើនូវតម្រូវការសាច់ប្រាក់ក្នុងរយៈពេលខ្លី ក្នុងប្រព័ន្ធសេដ្ឋកិច្ចជាតិ។

## ខ. វឌ្ឍនភាព និងសមិទ្ធផល

**២២៨- គ.ម.ក.** បានដាក់ចេញប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយ និងកំពុងធ្វើសេចក្តីព្រាងប្រកាសស្តីពីក្រមអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនមិនបានចុះបញ្ជី។ **គ.ម.ក.** ក៏បានរៀបចំសិក្ខាសាលាជាមួយសមាគមគណនេយ្យករជំនាញនៃកម្ពុជា ទៅលើការវិភាគ និងការអានព័ត៌មានហិរញ្ញវត្ថុសម្រាប់ថ្នាក់ដឹកនាំ និងរៀបចំសិក្ខាសាលាដាច់ដោយឡែកសម្រាប់ក្រុមហ៊ុនមិនបានចុះបញ្ជី។

**២២៩-** ធនាគារជាតិនៃកម្ពុជាក៏បានធ្វើកំណែទម្រង់ជាច្រើនលើក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិទាក់ទងនឹងអភិបាលកិច្ចក្នុងវិស័យធនាគារ ចាប់តាំងពីឆ្នាំ២០០៨មក។ ការកែទម្រង់ រួមមាន ការដាក់ចេញនូវប្រកាសស្តីពីអភិបាលកិច្ចសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ប្រកាសស្តីពីលក្ខណវិនិច្ឆ័យត្រឹមត្រូវ និងសមស្របសម្រាប់បុគ្គលដាក់ពាក្យស្នើសុំ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណ និងប្រកាសស្តីពីការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ជាងនេះទៅទៀត ធនាគារជាតិនៃកម្ពុជាគឺជានិយតករដែលបានតម្រូវឲ្យគ្រឹះស្ថាននៅក្រោមចំណុះ បំពេញលក្ខខណ្ឌក្នុងការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយក្រុមហ៊ុនសវនកម្មឯករាជ្យដំបូងគេបង្អស់នៅកម្ពុជា ដោយមានប្រសិទ្ធិភាព។

**២៣០-** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញនូវប្រកាសស្តីពីគោលការណ៍អភិបាលកិច្ចក្រុមហ៊ុនធានារ៉ាប់រង សំដៅធានាផលប្រយោជន៍សាធារណៈ ទំនុកចិត្តលើសេវាធានារ៉ាប់រង និងផលប្រយោជន៍របស់រូបវន្តបុគ្គល និងនីតិបុគ្គល ដែលត្រូវបានធានារ៉ាប់រង។

**២៣១-** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញនូវអនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ និងប្រកាសស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រងបរធនដែលមានប្រតិបត្តិការនៅក្នុងវិស័យធនាគារនិងវិស័យមីក្រូហិរញ្ញវត្ថុ។

**២៣២-** គិតមកដល់ឆមាសទី១ ឆ្នាំ២០១៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋានចំនួន១៦៥គម្រោង ក្រុមហ៊ុនវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុចំនួន ១៤៩ក្រុមហ៊ុន និងក្រុមហ៊ុនបញ្ចាំនិងប្រាតិភោគដោយអនុប្បទានចំនួន៣២៨ក្រុមហ៊ុន/សហគ្រាស។ តាមរយៈការផ្តល់អាជ្ញាបណ្ណជូនប្រតិបត្តិករទាំងនេះ វិស័យអចលនវត្ថុនៅកម្ពុជាមានការអភិវឌ្ឍ និងបានរួមចំណែកដល់កំណើនសេដ្ឋកិច្ចកម្ពុជា។ ដោយឡែក វិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទានក៏បានសម្រួលដល់ការផ្តល់ទទួលហិរញ្ញប្បទានរយៈពេលខ្លី។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**២៣៣-** សមាជិកអភិបាលកិច្ចមួយចំនួននៅគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៅមិនទាន់បានបំពេញតួនាទីរបស់ខ្លួនបានពេញលេញ និងប្រកបដោយការទទួលខុសត្រូវនៅឡើយទេ។ ការណ៍នេះបានរារាំងដល់ប្រសិទ្ធភាពនៃអាជីវកម្មរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ រួមមាន ការអនុវត្តតាមបទប្បញ្ញត្តិជាធរមាន។ ម្យ៉ាងវិញទៀត សមាជិកអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមួយចំនួនមានបទពិសោធ និងជំនាញមានកម្រិត ដែលមិនអាចចូលរួមចំណែកប្រកបដោយប្រសិទ្ធភាពក្នុងការងារដឹកនាំ និងគ្រប់គ្រងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនោះទេ។

**២៣៤-** ព្រមជាមួយនេះផងដែរ ការយល់ដឹង ការអនុវត្ត និងការផ្សព្វផ្សាយស្តីពីអភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមិនទាន់បោះផ្សាយលក់មូលបត្រជាសាធារណៈ នៅមានកម្រិត។

**២៣៥-** ការគ្រប់គ្រងលើអាជីវកម្មអចលនវត្ថុ អាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ដោយផ្អែកលើប្រកាស និងលិខិតបទដ្ឋានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានសព្វថ្ងៃ គឺមិនទាន់មានអានុភាពគ្រប់គ្រាន់សម្រាប់ការគ្រប់គ្រង និងការអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់នៅឡើយទេ។

**២៣៦-** បរធនបាល មិនទាន់ទទួលបាននូវការវាយតម្លៃអំពីគុណវឌ្ឍិ និងមិនមានការទទួលស្គាល់ក្រម-សីលធម៌វិជ្ជាជីវៈ។ ជាមួយគ្នានេះ សមត្ថភាពនៃការគ្រប់គ្រងរបស់បរធនបាលនៅមានកម្រិតព្រមទាំងកង្វះក្របខ័ណ្ឌបទប្បញ្ញត្តិ យន្តការនៃការត្រួតពិនិត្យ ការផ្សព្វផ្សាយ និងតាមដានការអនុវត្ត ទាមទារឲ្យវិស័យនេះត្រូវមានការគ្រប់គ្រងច្បាស់លាស់។

**២៣៧-** នៅលើទិដ្ឋភាពអនុវត្តជាក់ស្តែង មានផលវិបាកមួយចំនួនអំពីការកំណត់មិនទាន់ច្បាស់លាស់អំពីតួនាទីរបស់ថ្នាក់ដឹកនាំសំខាន់ៗរបស់ក្រុមហ៊ុនធានារ៉ាប់រង ព្រមទាំងកង្វះយន្តការនៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ដើម្បីសម្របទៅនឹងបរិបទថ្មីៗនៃការរីកចម្រើនរបស់វិស័យធានារ៉ាប់រង។

**២៣៨-** លិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ បានផ្តល់ត្រឹមតែក្របខ័ណ្ឌសម្រាប់ដាក់ឲ្យដំណើរការរបបសោធនកាតព្វកិច្ចប៉ុណ្ណោះ ។ រីឯក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រង និងត្រួតពិនិត្យ ដំណើរការរបប

សោធនទាំងសម្រាប់វិស័យសាធារណៈ និងឯកជន នៅមិនទាន់ត្រូវបានរៀបចំសមស្របទៅតាមគោលការណ៍បច្ចេកទេស និងចីរភាពហិរញ្ញវត្ថុ។

## ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត

**២៣៩- ការយល់ដឹង:** វិទ្យាស្ថាននានាក្នុងប្រទេសកម្ពុជា មិនបានផ្តល់វគ្គបំពាក់បំប៉នជំនាញគ្រប់គ្រង និងអភិបាលកិច្ចដល់គណៈគ្រប់គ្រងជាន់ខ្ពស់ និងមន្ត្រីរាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាពគ្រប់ពេលវេលានោះទេ។ ដូច្នេះ ដើម្បីដោះស្រាយបញ្ហានេះ កម្មវិធីបំពាក់បំប៉នមួយនឹងត្រូវបានផ្តួចផ្តើមឡើងដោយក្រសួង និងអាជ្ញាធរត្រួតពិនិត្យពាក់ព័ន្ធនានា។ កម្មវិធីនេះ នឹងផ្តល់ដល់គណៈគ្រប់គ្រងជាន់ខ្ពស់ដោយផ្តោតលើមុខងារ និងទំនួលខុសត្រូវខាងអភិបាលកិច្ច និងការយល់ដឹងអំពីការអនុវត្ត រួមទាំងតម្រូវការនានាក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ កិច្ចសម្របសម្រួលជាមួយគណៈគ្រប់គ្រងដែលត្រូវបានជ្រើសរើសពីវិស័យឯកជន នឹងត្រូវបានចាត់ចែងតាមរយៈក្រុមការងាររបស់គណៈកម្មការនៃវិស័យឯកជន។ រាជរដ្ឋាភិបាល នឹងពិចារណាក្នុងការជំរុញឲ្យមានការបង្កើតវិទ្យាស្ថានសម្រាប់គណៈគ្រប់គ្រង (Institute of Directors) ដែលជាចលករក្នុងការពង្រឹងអភិបាលកិច្ច និងតួនាទីជាអភិបាល។

**២៤០- វិស័យធនាគារ:** គណៈគ្រប់គ្រងធនាគារ ត្រូវឲ្យមានការអប់រំអំពីគោលការណ៍អភិបាលកិច្ចសម្រាប់ធនាគារ ដែលមានចែងនៅក្នុងគោលការណ៍ថ្មីៗរបស់ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS)។ គណៈគ្រប់គ្រងរបស់គ្រឹះស្ថានហិរញ្ញវត្ថុដែលទទួលអាជ្ញាបណ្ណស្របច្បាប់នឹងតម្រូវឲ្យចូលរួមសិក្ខាសាលាចាំបាច់នានាផ្តោតលើគោលការណ៍អភិបាលកិច្ចរបស់គណៈកម្មការបាសែល។

**២៤១-** សមាគមធនាគារកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា នឹងពង្រឹងការអនុវត្តក្រមសីលធម៌ធនាគារិក ដើម្បីលើកកម្ពស់សង្គតិភាពប្រតិបត្តិការក្នុងវិស័យធនាគារ ពង្រឹងតម្លាភាព និងជំរុញការអនុវត្តវប្បធម៌សាជីវកម្មបែបសមធម៌ក្នុងការប្រតិបត្តិការងាររបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

**២៤២-** ធនាគារជាតិនៃកម្ពុជា នឹងបន្តពង្រឹងជំនាញអភិបាលកិច្ចដល់ក្រុមប្រឹក្សាភិបាលគណៈគ្រប់គ្រង និងបុគ្គលិករបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ព្រមទាំងមន្ត្រីត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា តាមរយៈការបណ្តុះបណ្តាល និងការរៀបចំផែនការសកម្មភាពអភិបាលកិច្ចរយៈពេលវែងក្នុងវិស័យធនាគារ។

**២៤៣- បរធនបាល:** តាមរយៈការចូលជាធរមាននៃច្បាប់ស្តីពីបរធនបាលកិច្ច បរធនបាលត្រូវមានការយល់ដឹងពេញលេញពីតួនាទី ការទទួលខុសត្រូវ និងអភិបាលកិច្ច។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង **គ.ម.ក.** នឹងតម្រូវឲ្យមានការចូលរួមក្នុងកម្មវិធីអភិបាលកិច្ច សម្រាប់មន្ត្រីបុគ្គលិកពាក់ព័ន្ធនឹងការអនុវត្ត តាមដាន និងត្រួតពិនិត្យ ក៏ដូចជាសម្រាប់បុគ្គលដែលអាចក្លាយជាបរធនបាលនៅថ្ងៃអនាគត។

**២៤៤-** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើការកែសម្រួលប្រកាស និងលិខិតបទដ្ឋានដែលមានស្រាប់ និងបានដាក់ឲ្យអនុវត្តក្នុងពេលបច្ចុប្បន្ន ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្ត និងរៀបចំតាក់តែងសេចក្តីព្រាងច្បាប់មួយចំនួនទៀត មានដូចជា (១) ច្បាប់ស្តីពីការគ្រប់គ្រងអាជីវកម្មអចលនវត្ថុ (២) ច្បាប់ស្តីពីការគ្រប់គ្រងអាជីវកម្មសេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ និង (៣) ច្បាប់ស្តីពីការគ្រប់គ្រងអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ជាមួយនឹងលិខិតបទដ្ឋានគាំទ្រអនុវត្តផ្សេងៗទៀត។

**២៤៥-** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើវិសោធនកម្មប្រកាសស្តីពីគោលការណ៍អភិបាលកិច្ចក្រុមហ៊ុនធានារ៉ាប់រង ដោយឈរលើបទពិសោធន៍នៃការអនុវត្តជាក់ស្តែង និងនិន្នាការនៃការរីកចម្រើននៃវិស័យធានារ៉ាប់រងទាំងនៅក្នុងតំបន់ និងអន្តរជាតិដើម្បីឲ្យគោលការណ៍អភិបាលកិច្ចត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។

**២៤៦-** រាជរដ្ឋាភិបាល នឹងរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រង និងត្រួតពិនិត្យ និងដាក់ឲ្យដំណើរការរបបសោធនសាធារណៈទាំងអស់ ដែលជាផ្នែកមួយនៃច្បាប់ស្តីពីប្រព័ន្ធគាំពារសង្គម ដើម្បីធានាឲ្យបាននូវការគ្រប់គ្រង និងការចាត់ចែងរបបសោធន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ បន្ថែមលើនេះ រាជរដ្ឋាភិបាលក៏នឹងរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងនឹងដាក់ឲ្យដំណើរការរបបសោធនឯកជនស្ម័គ្រចិត្តផងដែរ។

## IV. ការអនុវត្តក្នុងទីផ្សារ / កិច្ចការពារអ្នកប្រើប្រាស់

### ក. ស្ថានភាពទូទៅ

**២៤៧-** វិធាននៃការអនុវត្តទីផ្សារសម្រាប់អ្នកចូលរួម និងវិធាននៃកិច្ចការពារអ្នកប្រើប្រាស់ (ដែលការពារប្រឆាំងទៅនឹងការរំលោភបំពាន ដូចជាការក្លែងបន្លំព័ត៌មាន ឬការបង្ហាញព័ត៌មានក្លែងក្លាយ) មានសារៈសំខាន់ក្នុងការផ្តល់សុចរិតភាព និងសមភាព ដើម្បីបង្កើនភាពជឿជាក់ និងទំនុកចិត្តដល់អ្នកប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុទាំងអស់។ វិធាននៃការអនុវត្តទីផ្សារ អាចត្រូវបានប្រើប្រាស់តាមរយៈបទប្បញ្ញត្តិសម្រាប់អ្នកចូលរួម (ដូចជាធនាគារ ឬក្រុមហ៊ុនមូលបត្រនៅក្នុងទីផ្សារភាគហ៊ុន) តាមរយៈក្រមប្រតិបត្តិសម្រាប់អ្នកជំនាញវិជ្ជាជីវៈដែលមានអាជ្ញាបណ្ណ និងតាមរយៈច្បាប់ដែលតម្រូវឲ្យមានការប្រព្រឹត្តតាមក្រមប្រតិបត្តិដ៏ត្រឹមត្រូវពីសំណាក់បុគ្គល ដែលចូលរួមក្នុងកិច្ចសន្យា ឬទំនាក់ទំនងហិរញ្ញវត្ថុដទៃទៀត ។

**២៤៨-** អតិថិជនទាំងអស់ នឹងទទួលបាននូវអត្ថប្រយោជន៍ពីការកំណត់ស្តង់ដា ជាពិសេសការបង្ហាញព័ត៌មានអំពីផលិតផលដែលធ្វើឲ្យអតិថិជនងាយស្រួលក្នុងការវាយតម្លៃទៅលើជម្រើសនានា និង

យល់ដឹងអំពីអ្វីដែលកំពុងត្រូវបានផ្តល់ឲ្យពួកគេ។ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុមានសារៈសំខាន់សម្រាប់ផ្តល់ភាពងាយស្រួលដល់មនុស្សទូទៅក្នុងការបង្កើត យល់ដឹង និងប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុ។

**២៨៩-** ការអប់រំមានសារៈសំខាន់ដូចគ្នា ក្នុងការបង្កើនការយល់ដឹងអំពីផលិតផលក្នុងទីផ្សារហិរញ្ញវត្ថុ (និងផ្នែកផ្សេងទៀត) និងយល់ដឹងអំពីលក្ខណៈ អត្ថប្រយោជន៍និងគុណសម្បត្តិ ព្រមទាំងថ្លៃដើមនិងបំណុល។ កម្មវិធីអក្ខរកម្មផ្នែកហិរញ្ញវត្ថុជួយដល់ការផ្លាស់ប្តូរព័ត៌មានរវាងអ្នកលក់ និងអ្នកទិញ ម្ចាស់បំណុល និងកូនបំណុល ភ្នាក់ងារនិងរវាងពាណិជ្ជករទាំងអស់។

**២៩០-** ដោយមានការចង្អុលបង្ហាញពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំនូវយន្តការ នីតិវិធី និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ សេវាកម្មវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុ ក្នុងគោលដៅរក្សានូវស្ថិរភាព និងការកសាងទំនុកចិត្តរបស់សាធារណជនលើវិស័យនេះ។

**២៩១-** ពេលដែលទីផ្សារធានារ៉ាប់រងនៅមានទំហំតូច និងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍ កិច្ចការពារអ្នកប្រើប្រាស់ និងអក្ខរកម្មហិរញ្ញវត្ថុ នៅមិនទាន់អនុវត្តឲ្យបានទូលំទូលាយនៅឡើយ។ ការការពារអត្ថប្រយោជន៍របស់អ្នកប្រើប្រាស់ គឺជាការងារចម្បងមួយ ដើម្បីធានាបាននូវជំនឿទុកចិត្តចំពោះទីផ្សារហិរញ្ញវត្ថុ ដែលកំពុងមានការប្រកួតប្រជែង។

## ខ. វឌ្ឍនភាព និងសមិទ្ធផល

**២៩២- វិធានការអនុវត្តទីផ្សារ និងក្រុមប្រតិបត្តិ:** ក្នុងឆ្នាំ២០១៥ ក្រុមប្រតិបត្តិសម្រាប់គ្រឹះស្ថានធនាគារត្រូវបានបង្កើតឡើងដោយសមាគមធនាគារកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។ គណៈកម្មការមូលបត្រកម្ពុជាបានអនុម័តបទប្បញ្ញត្តិពាក់ព័ន្ធ ដើម្បីគ្រប់គ្រងការប្រព្រឹត្តរបស់ក្រុមហ៊ុន ដែលមានអាជ្ញាបណ្ណក្នុងទីផ្សារមូលបត្រ។ គណៈកម្មការមូលបត្រកម្ពុជាក៏បានដាក់ចេញនូវតម្រូវការផ្នែកអភិបាលកិច្ចសម្រាប់ក្រុមហ៊ុនដែលចុះបញ្ជីផងដែរ។ ក្រមសីលធម៌របស់ KICPAA កំពុងត្រូវបានជំនួសដោយក្រមសីលធម៌សម្រាប់គណនេយ្យករជំនាញ ដែលចេញដោយសហព័ន្ធគណនេយ្យករអន្តរជាតិ។

**២៩៣- កិច្ចការពារអ្នកប្រើប្រាស់:** ក្រោមជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី ក្រសួងពាណិជ្ជកម្មបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។ ច្បាប់ថ្មីនេះមានចំណុចសំខាន់ដូចខាងក្រោម៖(១) រៀបចំឡើងក្នុងគោលបំណងការពារអ្នកប្រើប្រាស់ពីអំពើ និងសកម្មភាពមិនសុចរិតរបស់បុគ្គលទាំងឡាយក្នុងធុរកិច្ច និងវិជ្ជាជីវៈ (២) ផ្តល់តារាងលម្អិតស្តីពីបទដ្ឋានព័ត៌មានដែលត្រូវផ្តល់ជូនអ្នកប្រើប្រាស់ ដែលបុគ្គលក្នុងធុរកិច្ច និងវិជ្ជាជីវៈ ត្រូវតែអនុវត្តតាមក្នុងការទំនាក់ទំនងជាមួយអតិថិជនរបស់ខ្លួន (៣) អនុញ្ញាតអោយក្រសួង និងស្ថាប័នដែលជាបញ្ញត្តិករពាក់ព័ន្ធធ្វើការអភិវឌ្ឍបន្ថែមនូវបទដ្ឋានព័ត៌មាននានាតាមរយៈប្រកាស ដើម្បីគ្រប់គ្រងលើសកម្មភាពធុរកិច្ច និងវិជ្ជាជីវៈដែល

ក្រសួងនិងស្ថាប័ននោះបានចេញអាជ្ញាបណ្ណឲ្យនិងគ្រប់គ្រង (៤) បង្កើតស្ថាប័នការពារអ្នកប្រើប្រាស់ ដើម្បីស៊ើបអង្កេត និងដាក់ទោសទណ្ឌលើអំពើ និងសកម្មភាពមិនសុចរិតរបស់បុគ្គលក្នុងធុរកិច្ច និង វិជ្ជាជីវៈ និង (៥) បង្កើតសមាគមអ្នកប្រើប្រាស់ដើម្បីតំណាងទស្សនៈរបស់អ្នកប្រើប្រាស់ក្នុងវិស័យ ផ្សេងៗ។ ការផ្តោតសំខាន់នៃច្បាប់នេះ គឺការកំណត់នូវបទប្បញ្ញត្តិអំពីព័ត៌មានដែលត្រូវផ្តល់ជូនអ្នក ប្រើប្រាស់ និងមិនបានកំណត់នូវបទប្បញ្ញត្តិដែលពាក់ព័ន្ធដល់ប្រតិបត្តិការនោះទេ។

**២៩៤- កិច្ចការពារអ្នកប្រើប្រាស់ផ្នែកហិរញ្ញវត្ថុ**: ធនាគារជាតិនៃកម្ពុជា បានដាក់ចេញនូវប្រកាសមួយ ចំនួនដូចជា៖(១) ប្រកាសស្តីពីការគណនាការប្រាក់ចំពោះឥណទានមីក្រូហិរញ្ញវត្ថុ កាលពីឆ្នាំ២០០១ ដោយតម្រូវឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវគណនាការប្រាក់ដោយផ្អែកលើមូលដ្ឋាននៃចំនួនប្រាក់ ឥណទានដែលបានផ្តល់ ដោយដកចេញនូវចំនួនប្រាក់ដើមដែលបានសង (២) ប្រកាសស្តីពីការ ផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ កាលពីឆ្នាំ២០០៤ ដោយតម្រូវឲ្យគ្រឹះស្ថានត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានបញ្ជាក់ដោយសវនកម្ម និងត្រូវ ចេញផ្សាយនិងត្រូវផ្តល់ជូនអតិថិជននិងសាធារណជន (៣) ប្រកាសស្តីពីតម្លាភាពក្នុងការផ្តល់សេវា ឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ កាលពីឆ្នាំ២០១១ ដើម្បីការពារអតិថិជន តាមរយៈការ តម្រូវឲ្យគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុធ្វើប្រតិបត្តិការជាមួយអតិថិជន ប្រកបដោយតម្លាភាព យុត្តិធម៌ ភាពសមហេតុផល និងភាពទទួលខុសត្រូវក្នុងការផ្តល់ឥណទាន។ ធនាគារជាតិនៃកម្ពុជា ក៏ បានបង្កើតការិយាល័យមួយដោយឡែក ដោយស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានត្រួតពិនិត្យ ដើម្បីរៀបចំក្របខណ្ឌច្បាប់ បទប្បញ្ញត្តិ និងការទទួលបណ្តឹងផ្សេងៗ សម្រាប់អភិវឌ្ឍកិច្ចការពារអ្នក ប្រើប្រាស់ផ្នែកហិរញ្ញវត្ថុ និងការបង្ហាញព័ត៌មានបន្ថែមសម្រាប់វិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុ។

**២៩៥- អក្ខរកម្មផ្នែកហិរញ្ញវត្ថុ៖** ធនាគារជាតិនៃកម្ពុជា កំពុងលើកកម្ពស់អក្ខរកម្មផ្នែកហិរញ្ញវត្ថុ តាមរយៈ (១) សហការជាមួយមូលនិធិអភិវឌ្ឍន៍មូលធន អង្គការសហប្រជាជាតិ ដើម្បីបង្កើតយុទ្ធសាស្ត្របរិយាបន្ន ហិរញ្ញវត្ថុជាតិ (២) ចូលជាសមាជិកនៃសហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ (៣) សហការជាមួយ World Education Australia Limited (WEL)/Good Return ពង្រឹងអក្ខរកម្មផ្នែកហិរញ្ញវត្ថុ និងសមត្ថភាព ផ្នែកហិរញ្ញវត្ថុ (៤) ពិភាក្សាជាមួយក្រសួងអប់រំ យុវជន និងកីឡា អំពីការដាក់បញ្ចូលអក្ខរកម្មផ្នែក ហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សា និង (៥) ធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈនៅតាម បណ្តាខេត្តជាច្រើន។

**២៩៦- ការអប់រំនិងកិច្ចការពារវិនិយោគិន**: ដោយសារកម្រិតនៃការចូលរួមក្នុងទីផ្សារមូលបត្រនៅ កម្ពុជាមានកម្រិតទាបនៅឡើយ ដូច្នេះ ការអប់រំវិនិយោគិន និងសាធារណជនអំពីឱកាសនៃការសន្សំ និងប្រាក់សោធននិវត្តន៍ កំពុងត្រូវបានបង្កើននិងពង្រឹង។ គណៈកម្មការមូលបត្រកម្ពុជាកំពុងពង្រឹង កិច្ចការពារវិនិយោគិន។

**២៥៧-** នៅឆ្នាំ២០១០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ឲ្យអនុវត្តប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍន៍អចលនវត្ថុ។ តាមរយៈប្រកាសនេះ តម្រូវឲ្យអ្នកអភិវឌ្ឍអចលនវត្ថុទាំងអស់ត្រូវៈ (១) ដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ២% នៃតម្លៃគម្រោងវិនិយោគសរុប ឬតម្លៃគម្រោងវិនិយោគតាមដំណាក់កាល (២) ត្រូវបើកគណនីអភិវឌ្ឍន៍អចលនវត្ថុមួយ ដាច់ដោយឡែក ដើម្បីរក្សាប្រាក់កក់ ឬប្រាក់បង់តាមដំណាក់កាលគ្រប់ប្រភេទរបស់អតិថិជន និង (៣) ការដកប្រាក់ពីគណនីនេះ ដើម្បីយកទៅបម្រើឲ្យការងារសាងសង់ ត្រូវតែសមាមាត្រទៅនឹងទំហំសំណង់ដែលបានធ្វើ។ ទោះបីយ៉ាងណា ដើម្បីពង្រឹងការគ្រប់គ្រងនិងការអនុវត្ត ក្រសួងបានធ្វើការកែសម្រួលប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មអចលនវត្ថុ ដោយចែងអំពីទោសទណ្ឌចំពោះអ្នកមិនអនុវត្តតាមខ្លឹមសារប្រកាសនេះ។

**២៥៨-** ការរៀបចំបទប្បញ្ញត្តិ និងការអនុវត្តពាក់ព័ន្ធនឹងទីផ្សារ និងកិច្ចការពារអ្នកប្រើប្រាស់កំពុងត្រូវបាន ពង្រឹងសំដៅធានាបាននូវការប្រព្រឹត្តដោយត្រឹមត្រូវ និងតម្លាភាព ដើម្បីរក្សាទំនុកចិត្តពីសំណាក់អ្នកប្រើប្រាស់សេវាធានារ៉ាប់រង។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននិងកំពុងរៀបចំប្រកាសមួយចំនួនរួមមាន ប្រកាសស្តីពីទីផ្សារ និងការលក់ ប្រកាសស្តីពីក្រមសីលធម៌សម្រាប់អភិបាល មន្ត្រី និងបុគ្គលិករបស់ក្រុមហ៊ុនធានារ៉ាប់រង ប្រកាសស្តីពីនីតិវិធីនៃការទាមទារសំណង និងប្រកាសស្តីពីនីតិវិធីនៃការផ្សះផ្សាវិវាទ។ ទន្ទឹមនឹងនេះ កម្មវិធីផ្សព្វផ្សាយអប់រំអតិថិជនស្តីពីវិស័យធានារ៉ាប់រង ក៏ត្រូវបានបញ្ចូលទៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំរបស់បញ្ញត្តិករ តាមរយៈការរៀបចំសិក្ខាសាលាផ្សព្វផ្សាយដល់សាធារណជន គោលដៅនៅតាមបណ្តាខេត្តនានា ដែលជាផ្នែកមួយនៃកម្មវិធីលើកកម្ពស់អក្ខរកម្មហិរញ្ញវត្ថុផងដែរ។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**២៥៩-** ទោះបីបញ្ហាមួយចំនួនទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់ត្រូវបានដោះស្រាយជាបន្តបន្ទាប់ ក៏នៅមានបញ្ហាប្រឈមមួយចំនួនទៀត ដែលធនាគារជាតិនៃកម្ពុជាត្រូវបន្តដោះស្រាយ ក្នុងនោះរួមមាន កង្វះការយល់ដឹងផ្នែកហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន និងក្រុមគ្រួសារ ដែលនាំឲ្យប្រជាពលរដ្ឋមួយចំនួនជ្រើសរើសសេវាហិរញ្ញវត្ថុក្រៅផ្លូវការ ជាពិសេសគឺប្រភេទឥណទាន Loan Shark ដែលអាចឲ្យពួកគេក្លាយជាជនរងគ្រោះនៃការកេងប្រវ័ញ្ចផ្សេងៗ។ លើសពីនេះ មន្ត្រីឥណទាននៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមួយចំនួនមិនមានជំនាញក្នុងការវាយតម្លៃលើលទ្ធភាពសងរបស់អតិថិជនឲ្យបានត្រឹមត្រូវ ដែលជាលទ្ធផល អ្នកខ្ចីប្រាក់មិនមានលទ្ធភាពសងបំណុលបាន។

**២៦០-** ទោះបីជាមានការបណ្តុះបណ្តាល ការផ្សព្វផ្សាយពីវិស័យមូលបត្រ និងការដាក់ឲ្យអនុវត្តនូវបទប្បញ្ញត្តិពាក់ព័ន្ធជាបន្តបន្ទាប់ក្នុងទិសដៅការពារវិនិយោគិនក្នុងវិស័យមូលបត្រក៏ដោយ ក៏ការយល់ដឹង និងការចូលរួមរបស់វិនិយោគិននៅក្នុងវិស័យនេះនៅមានកម្រិតនៅឡើយ។

**២៦១-** ការយល់ដឹង និងការអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធរបស់អ្នកអភិវឌ្ឍ និងសាធារណជន នៅមានកម្រិត។ ម្យ៉ាងវិញទៀត សាធារណជនភាគច្រើន មិនមានទម្លាប់ប្រើប្រាស់ប្រព័ន្ធធនាគារ និងមិនទាន់យល់ដឹង ទូលំទូលាយពីហានិភ័យនៃការប្រើប្រាស់សាច់ប្រាក់ក្រៅប្រព័ន្ធធនាគារ។

**២៦២-** ទន្ទឹមនឹងនេះដែរ មានបញ្ហាប្រឈមមួយចំនួនដែលកំពុងជួបប្រទះ ក្នុងដំណើរការអនុវត្តកិច្ច-ការពារអ្នកប្រើប្រាស់ដូចជា បទប្បញ្ញត្តិចាំបាច់ដែលត្រូវកែសម្រួលដើម្បីប្រក្រតីកម្មការប្រព្រឹត្តទៅនៃទីផ្សារធានារ៉ាប់រង កង្វះយន្តការនៃការចុះត្រួតពិនិត្យជាក់ស្តែងពាក់ព័ន្ធនឹងការអនុវត្តក្នុងទីផ្សាររបស់គ្រឹះស្ថានធានារ៉ាប់រង ការពង្រឹងសមត្ថភាព បច្ចេកទេសរបស់មន្ត្រីជំនាញ និងកង្វះយន្តការនៃការដោះស្រាយពាក្យបណ្តឹងរបស់អតិថិជនជាដើម។

## ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត

**២៦៣-** ក្រសួង ក៏ដូចជាភ្នាក់ងារពាក់ព័ន្ធនឹងបង្កើតស្តង់ដានៃការបង្ហាញព័ត៌មានសម្រាប់អង្គភាពក្រោមឱវាទ។ អង្គភាពទាំងនេះ រួមមាន ភ្នាក់ងារអចលនទ្រព្យ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនហិរញ្ញវត្ថុ និងអ្នកឲ្យប្រាក់កម្ចីជាដើម។ អ្នកចូលរួមក្នុងវិស័យហិរញ្ញវត្ថុទាំងអស់នឹងត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌និងប្រតិបត្តិ។ ការកសាងសមត្ថភាពនឹងត្រូវបានផ្តល់ជូនស្ថាប័នរាជរដ្ឋាភិបាល និងគ្រឹះស្ថានចំណុះច្បាប់។

**២៦៤-** ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់នឹងត្រូវបានអនុម័ត។ ក្រសួងពាណិជ្ជកម្ម នឹងរៀបចំច្បាប់ថ្មីស្តីពីសិទ្ធិអ្នកប្រើប្រាស់ ដែលច្បាប់នេះនឹងកំណត់អំពីកាតព្វកិច្ចរបស់អ្នកលក់ បន្ទាប់ពីប្រតិបត្តិការនៃការលក់ទិញត្រូវបានបញ្ចប់។

**២៦៥-** ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលនឹងរៀបចំឲ្យមានកម្មវិធីលើកកម្ពស់អក្ខរកម្មផ្នែកហិរញ្ញវត្ថុ ដើម្បីបញ្ជ្រាបការយល់ដឹងទៅដល់សាធារណជនទូទៅ ជាពិសេស ការរៀបចំកម្មវិធីសិក្សាទូទៅរបស់ប្រព័ន្ធអប់រំជាតិ។ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងពង្រីក និងលើកកម្ពស់កម្មវិធីអក្ខរកម្មហិរញ្ញវត្ថុ ដើម្បីឲ្យប្រជាពលរដ្ឋមានចំណេះដឹងជាមូលដ្ឋានទាក់ទងនឹងផលិតផល និងការជ្រើសរើសសេវាហិរញ្ញវត្ថុ ព្រមទាំងការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន ឬក្នុងក្រុមគ្រួសារ។ ធនាគារជាតិនៃកម្ពុជា ក៏នឹងបន្តផ្សព្វផ្សាយជូនប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន និងសាធារណជនឲ្យបានជ្រួតជ្រាបពីអត្ថ-ប្រយោជន៍នៃសេវាហិរញ្ញវត្ថុផ្លូវការ និងគុណវិបត្តិនៃការប្រើប្រាស់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ ដូចជា Loan Shark។ ធនាគារជាតិនៃកម្ពុជា នឹងតម្រូវឲ្យមានកម្មវិធីបណ្តុះបណ្តាលមន្ត្រីឥណទានសមស្រប ដើម្បីជៀសវាងការវាយតម្លៃលទ្ធភាពសងរបស់អ្នកខ្ចីលើសពីកម្រិតលទ្ធភាពសងជាក់ស្តែងរបស់អ្នកខ្ចី។

**២៦៦-** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងបន្តការផ្សព្វផ្សាយទៅដល់អ្នកអភិវឌ្ឍអចលនវត្ថុ និងសាធារណជន អំពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ និងហានិភ័យដែលអាចកើត

មានឡើង ដោយការមិនប្រើប្រាស់គណនីអភិវឌ្ឍន៍អចលនវត្ថុ ឬដោយការប្រើប្រាស់សាច់ប្រាក់នៅក្នុងការទូទាត់ទិញលក់អចលនវត្ថុក្រៅប្រព័ន្ធធនាគារ។

**២៦៧-** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងបន្តពិនិត្យកែសម្រួលបទប្បញ្ញត្តិដែលមានស្រាប់ និងរៀបចំបទប្បញ្ញត្តិបន្ថែមមួយចំនួនទៀត ដើម្បីធានាការអនុវត្តកិច្ចការពារអ្នកប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ ការជំរុញការចូលរួមរបស់អតិថិជនក្នុងការផ្តល់ព័ត៌មាន និងពាក្យបណ្តឹងពាក់ព័ន្ធនឹងភាពមិនប្រក្រតីរបស់គ្រឹះស្ថានធានារ៉ាប់រង គឺជាយន្តការដ៏សមស្របមួយដើម្បីធានានូវការត្រួតពិនិត្យគ្រឹះស្ថានធានារ៉ាប់រងប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ក៏ដូចជាការរួមចំណែកក្នុងការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិរបស់អតិថិជនផងដែរ។

## V. គណនេយ្យនិងសវនកម្ម

### ក. ទិដ្ឋភាពទូទៅ

**២៦៨- ស្តង់ដាគណនេយ្យ និងសវនកម្មនៅកម្ពុជា:** គណនេយ្យផ្តល់នូវក្របខ័ណ្ឌ ដើម្បីផលិតចេញជាព័ត៌មានហិរញ្ញវត្ថុសម្រាប់ការរាយការណ៍ហិរញ្ញវត្ថុគ្រប់វិស័យទាំងអស់នៃសេដ្ឋកិច្ច។

**២៦៩-** ច្បាប់ និងបទប្បញ្ញត្តិស្តីពីគណនេយ្យ និងសវនកម្មនាពេលបច្ចុប្បន្ននេះ តម្រូវឲ្យសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលបានចុះបញ្ជីទាំងអស់នៅក្នុងប្រទេសកម្ពុជា ត្រូវកាន់បញ្ជីគណនេយ្យ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដាគណនេយ្យជាធរមាន។ ស្តង់ដាគណនេយ្យមានជាអាទិ៍: (១) ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) និង (២) ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ជាដើម ហើយស្តង់ដាទាំងនេះដូចគ្នាទៅនឹងស្តង់ដារបស់អន្តរជាតិដែរ។ នៅក្នុងឆ្នាំ២០១០ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ឲ្យប្រើស្តង់ដាអន្តរជាតិនៃកម្ពុជាទាក់ទងនឹងសវនកម្ម និងការអះអាង (CISAA) ។

**២៧០-** គោលបំណងរបស់ CIFRS ៖

- ធ្វើឲ្យមាន *តម្លាភាព* ដោយបង្កើនភាពអាចប្រៀបធៀបគ្នាបានជាលក្ខណៈអន្តរជាតិ និងបង្កើនគុណភាពនៃព័ត៌មានហិរញ្ញវត្ថុ
- បង្កើន *គណនេយ្យភាព* ដោយកាត់បន្ថយនូវគម្លាតព័ត៌មានរវាងអ្នកផ្តល់មូលធន និងអ្នកទទួលមូលធន ។ CIFRS ផ្តល់ព័ត៌មានចាំបាច់សម្រាប់គណៈគ្រប់គ្រងដែលមានការទទួលខុសត្រូវនិងជាប្រភពព័ត៌មាន ដែលអាចប្រៀបធៀបគ្នាបានជាសកល ហើយក៏មានសារៈសំខាន់យ៉ាងខ្លាំងចំពោះបញ្ញត្តិករផងដែរ និង

- រួមចំណែកបង្កើន *ប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ច* ដោយជួយឲ្យវិនិយោគិនអាចកំណត់កាលានុវត្តភាព និងហានិភ័យនានា។ ដូចនេះ វាធ្វើឲ្យការបែងចែកមូលធនកាន់តែប្រសើរឡើង។ ចំពោះអាជីវកម្ម ការប្រើប្រាស់ស្តង់ដាគណនេយ្យដែលគួរឲ្យជឿទុកចិត្តរួមមួយ នឹងជួយកាត់បន្ថយថ្លៃចំណាយលើដើមទុន និងចំណាយលើការរាយការណ៍ហិរញ្ញវត្ថុ។

## ខ. វឌ្ឍនភាពនិងសមិទ្ធផល

**២៧១- ការបង្កើតគោលនយោបាយនិងដាក់ឲ្យប្រើច្បាប់:** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ឲ្យអនុវត្តបទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងគណនេយ្យសវនកម្ម និងវិជ្ជាជីវៈគណនេយ្យនៅកម្ពុជា ស្របតាមច្បាប់ជាធរមាន។ ច្បាប់ និងបទប្បញ្ញត្តិទាំងនោះ រួមមាន ច្បាប់ដែលបង្កើតតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ.) (អាជ្ញាធរ) និងវិទ្យាស្ថានគណនេយ្យករ និងសវនករជំនាញនៅកម្ពុជា (វ.គ.ស.ក.) ការដាក់ឲ្យប្រើនូវ CIFRS និង CISAA និងបទប្បញ្ញត្តិដទៃទៀត។

**២៧២- ការបណ្តុះបណ្តាលនិងការកសាងសមត្ថភាព:** ក.ជ.គ. និង វ.គ.ស.ក. សម្រេចបានសមិទ្ធផលមួយចំនួនក្នុងការបណ្តុះបណ្តាល និងការកសាងសមត្ថភាព។ វ.គ.ស.ក. បាននិងកំពុងរៀបចំកម្មវិធីសិក្សា CPA ជាតិ និងមានបំណងរៀបចំការប្រឡងគុណវុឌ្ឍិ ដោយខ្លួនឯង។ វ.គ.ស.ក. ក៏បានត្រួតពិនិត្យគុណភាពនៃក្រុមហ៊ុនសវនកម្មទាំងតូច មធ្យម និងធំ និងកំពុងរៀបចំផែនការសកម្មភាពសម្រាប់ពិនិត្យការងារសវនកម្មរបស់សវនករ ។ ក.ជ.គ. ក៏បានរៀបចំកម្មវិធីសិក្សាសម្រាប់បណ្តុះបណ្តាលលើ CIFRS ដែលនឹងត្រូវអនុវត្តនៅតាមបណ្តាគ្រឹះស្ថានឧត្តមសិក្សានានា (ទាំងរដ្ឋ និងឯកជន) ដែលផ្តល់វគ្គសិក្សាមុខវិជ្ជាធុរកិច្ចនៅក្នុងឆ្នាំ២០១៦ ។ ក.ជ.គ. ក៏បានបណ្តុះបណ្តាលសាស្ត្រាចារ្យមកពីគ្រឹះស្ថានឧត្តមសិក្សាទាំងរដ្ឋ និងឯកជនចំនួន ០៨ នៅរាជធានីភ្នំពេញ និងចំនួន ០៥ នៅតាមបណ្តាខេត្តសម្រាប់ឆមាសទី១ នៃឆ្នាំ២០១៦ ។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**២៧៣- ការអនុលោមតាម CIFRS ៖** ថ្វីបើមានបទប្បញ្ញត្តិតម្រូវឲ្យសហគ្រាសទាំងអស់ អនុវត្តតាម CIFRS ក៏ដោយ ក៏សហគ្រាសមួយចំនួនក្នុងវិស័យហិរញ្ញវត្ថុនៅមិនទាន់អនុវត្តស្តង់ដានេះនៅឡើយ។ សហគ្រាសទាំងនោះទទួលស្គាល់ថាមានចំណុចខ្វះខាតមួយចំនួន ដូចជា គណនេយ្យករមិនមានចំណេះគ្រប់គ្រាន់ពាក់ព័ន្ធនឹង CIFRS និងកង្វះធនធានក្នុងការរៀបចំប្រព័ន្ធគាំទ្រសមស្រប ដើម្បីសម្រួលលក្ខខណ្ឌតម្រូវដល់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

**២៧៤- ការកសាងសមត្ថភាព**: ទាំង ក.ជ.គ. និង វ.គ.ស.ក. ត្រូវការជំនួយបច្ចេកទេសដើម្បីកសាងសមត្ថភាព ពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងគណនេយ្យ សវនកម្ម និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ឃ. យុទ្ធសាស្ត្រនិងផែនការអនាគត

**២៧៥- ការអនុលោមតាម CIFRS**: ក្នុងនាមជាបញ្ញត្តិករសម្រាប់គ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ត្រូវរៀបចំក្របខ័ណ្ឌមួយដែលជួយឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុអនុវត្ត CIFRS ចាប់ពីឆ្នាំ២០១៩ តទៅ។ ធនាគារជាតិនៃកម្ពុជាកំពុងរង់ចាំជំនួយបច្ចេកទេសពីធនាគារពិភពលោកបន្តទៀត ដើម្បីបញ្ចប់ដំណើរការនេះ។ ក្នុងនាមជាបញ្ញត្តិករពាក់ព័ន្ធនឹងស្តង់ដាគណនេយ្យ ក.ជ.គ. ត្រូវពិនិត្យឡើងវិញអំពីការចេញបទប្បញ្ញត្តិអន្តរកាលបន្ថែមដល់គ្រឹះស្ថានហិរញ្ញវត្ថុនានាដើម្បីអនុវត្តតាម CIFRS។ ក្រសួងពាណិជ្ជកម្ម ដែលជាអាជ្ញាធរចុះបញ្ជីក្រុមហ៊ុន នឹងពិចារណាអំពីភាពចាំបាច់ ក្នុងការពន្យារពេលចំពោះការតម្រូវឲ្យក្រុមហ៊ុនដែលបានចុះបញ្ជី ផ្តល់របាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដា CIFRS ដើម្បីអនុលោមតាមលក្ខខណ្ឌចុះបញ្ជី។ គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុណា ដែលមិនបានរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំ ឆ្នាំ២០១៥ តាម CIFRS ត្រូវរៀបចំផែនការអន្តរកាលលម្អិតមួយ។

**២៧៦-** ក្នុងនាមជាបញ្ញត្តិករសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវរៀបចំបទប្បញ្ញត្តិអន្តរកាលផ្លូវការដែលតម្រូវឲ្យគ្រប់ក្រុមហ៊ុនធានារ៉ាប់រងអនុវត្តតាមស្តង់ដា CIFRS ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ក្រុមហ៊ុនធានារ៉ាបរងទាំងឡាយណាដែលមិនបានរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៥ តាមស្តង់ដា CIFRS ត្រូវរៀបចំផែនការអន្តរកាលលម្អិតមួយ។

**២៧៧- ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពពាក់ព័ន្ធនឹងគណនេយ្យនិងសវនកម្ម**: ដើម្បីធានាថាប្រព័ន្ធអប់រំនៅកម្ពុជាផ្តល់ការបណ្តុះបណ្តាលផ្នែកគណនេយ្យ និងសវនកម្ម ប្រកបដោយគុណភាពគ្រប់គ្រាន់ កម្មវិធីសិក្សាដែលរួមបញ្ចូល CIFRS គឺជាបុរេលក្ខខណ្ឌ ដើម្បីបន្តការបណ្តុះបណ្តាលថ្នាក់គណនេយ្យករជំនាញ CPA។ ការបណ្តុះបណ្តាលនាដំណាក់កាលអន្តរកាលនេះ ត្រូវបន្តរហូតដល់ពេលវិធានការទាំងនេះមានប្រសិទ្ធភាព។

**២៧៨-** និស្សិតមួយចំនួននិងសូម្បីតែគណនេយ្យករជំនាញ ក៏មានការលំបាកក្នុងការយល់ពីប្រធានបទស្មុគស្មាញមួយចំនួនដូចជា គណនេយ្យសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ និងឧបករណ៍និស្សន្ទ ដែលត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សា ដោយសមាគមគណនេយ្យករជំនាញ ACCA។ ដើម្បីឆ្លើយតបនឹងបញ្ហានេះ តម្រូវឲ្យមានការបណ្តុះបណ្តាលបន្ថែមដល់គណនេយ្យករជំនាញ និងនិស្សិតកំពុងសិក្សាថ្នាក់គណនេយ្យករជំនាញកម្រិតខ្ពស់។

**២៧៩-** ក.ជ.គ. បន្ត ពង្រឹងការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងគណនេយ្យ និងសវនកម្ម តាមរយៈការចុះត្រួតពិនិត្យផ្ទាល់នៅហ្នឹងកន្លែង ក៏ដូចជាការបន្តយន្តការផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់បណ្តាសហគ្រាស និងក្រុមហ៊ុនសវនកម្ម។ ក.ជ.គ. និង វ.គ.ស.ក. នឹងបន្តរៀបចំយន្តការផងដែរ សម្រាប់ត្រួតពិនិត្យគុណភាពសេវាសវនកម្មរបស់ក្រុមហ៊ុនសវនកម្ម និងសវនករ។ ក.ជ.គ. ត្រូវបន្តពង្រឹង និងពង្រីកសមត្ថភាពរបស់មន្ត្រីដើម្បីពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងគណនេយ្យ និងសវនកម្ម និងដើម្បីសម្របខ្លួនឲ្យទាន់ការវិវត្តនៃវិស័យគណនេយ្យ និងសវនកម្មក្នុងតំបន់ និងសកលលោក។

## VI. ច្បាប់ និង បទប្បញ្ញត្តិ

### ក. ទិដ្ឋភាពទូទៅ

**២៨០-** ប្រព័ន្ធទីផ្សារហិរញ្ញវត្ថុផ្អែកលើយន្តការទីផ្សារដ៏រឹងមាំ ទាមទារឲ្យមានក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និងស្ថាប័នសមស្រប ដើម្បីលើកកម្ពស់ទីផ្សារហិរញ្ញវត្ថុ និងគាំទ្រដល់អភិបាលកិច្ចល្អ និងនីតិរដ្ឋ។

### ខ. វឌ្ឍនភាពនិងសមិទ្ធផល

**២៨១-** ការរីកចម្រើនគួរឲ្យកត់សម្គាល់ក្នុងការបង្កើតក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិសម្រាប់វិស័យហិរញ្ញវត្ថុនៅកម្ពុជាចាប់តាំងពីការបង្កើតយុទ្ធសាស្ត្រនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០។ ច្បាប់ដែលត្រូវបានអនុម័ត និងដាក់ឲ្យអនុវត្ត រួមមាន ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីមជ្ឈត្តកម្មពាណិជ្ជកម្ម និងច្បាប់ស្តីពីការធានារ៉ាប់រង។ បន្ទាប់ពីមានការពិភាក្សាយ៉ាងល្អិតល្អន់ជាមួយវិស័យឯកជន សេចក្តីព្រាងច្បាប់ថ្មីៗមួយចំនួនត្រូវបានរៀបចំ រួមមាន: (១) ច្បាប់ស្តីពីការប្រកួតប្រជែង (២) ច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក (៣) ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ (៤) ច្បាប់ស្តីពីបរ-ធនបាលកិច្ច (៥) ច្បាប់ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍន៍អចលនវត្ថុ (៦) ច្បាប់ស្តីពីការគ្រប់គ្រងអាជីវកម្មផ្តល់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ និង (៧) ច្បាប់ស្តីពីការគ្រប់គ្រងអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន។

**២៨២-** ធនាគារជាតិនៃកម្ពុជា បាននិងកំពុងបន្តពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនៃវិស័យធនាគារ និងហិរញ្ញវត្ថុ និងបានចូលរួមជាមួយក្រសួងពាក់ព័ន្ធ ដើម្បីពិភាក្សា និងរៀបចំសេចក្តីព្រាងច្បាប់ថ្មីៗមួយចំនួនទៀត ដើម្បីសម្របទៅនឹងការប្រែប្រួលនៃទីផ្សារ និងស្តង់ដារអន្តរជាតិ។ ដើម្បីពង្រឹងភាពធន់នៃវិស័យធនាគារ ធនាគារជាតិនៃកម្ពុជា បានចេញនូវបទប្បញ្ញត្តិស្តីពី ការផ្តល់សន្ទនីយភាពចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ការតម្រូវឲ្យគ្រឹះស្ថានរក្សាទុកអនុបាតក្របខ័ណ្ឌសន្ទនីយភាពឲ្យបានសមស្រប និងការបង្កើនដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**២៨៣-** នៅក្នុងដំណើរការនៃការរៀបចំច្បាប់សម្រាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុ មានបញ្ហាប្រឈមមួយចំនួន ដូចជា (១) សមត្ថភាពមន្ត្រីមានកម្រិត (២) ខ្វះជំនួយបច្ចេកទេស និង (៣) ការផ្សព្វផ្សាយការអប់រំ និងការតាមដានការអនុវត្តនៅមានកម្រិត។

**២៨៤-** ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិដើម្បីធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រង និងត្រួតពិនិត្យប្រព័ន្ធគាំពារសង្គមនៅមានភាពខ្វះចន្លោះនៅឡើយ។

## ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត

**២៨៥- ការអនុម័តលើសេចក្តីព្រាងច្បាប់៖** សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងច្បាប់ស្តីពីបរធនបាលកិច្ចនឹងត្រូវដាក់ជូនអង្គនីតិបញ្ញត្តិអនុម័ត។ ច្បាប់មួយចំនួនដូចខាងក្រោមនេះ គឺជាលក្ខខណ្ឌតម្រូវរបស់ប្រទេសកម្ពុជាក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងនាមជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកដែលនឹងត្រូវរៀបចំ និងអនុម័តផងដែររួមមាន៖ (១) ច្បាប់ស្តីពីសិទ្ធិអ្នកប្រើប្រាស់ (ផ្តល់ឲ្យអ្នកទិញនូវសិទ្ធិ និងសំណងក្រោយពីការទិញលក់) (២) ច្បាប់ស្តីពីប្រាក់សោធននិវត្តន៍ (៣) ច្បាប់ស្តីពីអាជ្ញាបណ្ណ និងអាជ្ញាបណ្ណពិសេស (៤) ច្បាប់ស្តីពីព័ត៌មានសម្ងាត់ពាណិជ្ជកម្ម និងព័ត៌មានលាក់កំបាំង និង (៥) ច្បាប់ស្តីពីសន្តិសុខទិន្នន័យនិងឯកជន (Privacy and Data Security Law)។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងរៀបចំឲ្យមានច្បាប់ស្តីពីសន្តិសុខទិន្នន័យ និងឯកជន ( Privacy and Data Security Law ) ដែលអនុញ្ញាតឲ្យបុគ្គល និងអង្គភាពណាមួយចូលយកទិន្នន័យដែលខ្លួនបានធ្វើឡើងដោយខ្លួនឯង (រួមបញ្ចូលទាំងរបាយការណ៍ប្រវត្តិឥណទាន) និងតម្រូវឲ្យមានការការពារយ៉ាងពេញលេញនូវទិន្នន័យនោះ ហើយកំហុសឆ្គងណាមួយចំពោះទិន្នន័យនោះនឹងអាចត្រូវកែប្រែបាន។

**២៨៦-** បន្ថែមលើនេះ ស្ថាប័នអនុវត្តច្បាប់ថ្មីចំនួន២ នឹងត្រូវបានបង្កើតឡើងរួមមាន៖អាជ្ញាធរប្រកួតប្រជែង និងអាជ្ញាធរការពារអ្នកប្រើប្រាស់។

**២៨៧- ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា:** ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានានឹងត្រូវធ្វើវិសោធនកម្ម ដើម្បីដោះស្រាយបញ្ហានានាពាក់ព័ន្ធដល់ការចុះបញ្ជីភតិសន្យា និងអនុញ្ញាតឲ្យទំនិញអរូបិយអាចប្រើប្រាស់ជាទ្រព្យធានា និងអាចចុះបញ្ជីក្នុងប្រព័ន្ធចុះបញ្ជីនៃប្រតិបត្តិការដែលមានកិច្ចធានា។

**២៨៨- ច្បាប់សហគ្រាសពាណិជ្ជកម្ម:** ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មនាពេលបច្ចុប្បន្ន នឹងត្រូវធ្វើការត្រួតពិនិត្យឡើងវិញដោយលម្អិត ប្រសិនបើចាំបាច់។ ក្នុងចំណោមការត្រួតពិនិត្យនេះ ក្រសួង

ពាណិជ្ជកម្មនឹងផ្តោតសំខាន់លើការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដែលក្រសួងបាន ចាប់ផ្តើមដំណើរការនៅខែមករា ឆ្នាំ២០១៦។

**២៨៩- ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់:** ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់នាពេលបច្ចុប្បន្ននឹងត្រូវធ្វើវិសោធកម្ម ដោយ បទប្បញ្ញត្តិពាក់ព័ន្ធ និងម៉ាកវិញ្ញាតកម្មបន្ថែម។

**២៩០-** រាជរដ្ឋាភិបាលទទួលស្គាល់ពីសារៈសំខាន់នៃការចេញអនុក្រឹត្យ និងប្រកាស ដើម្បីដាក់ឲ្យ អនុវត្តខ្លឹមសារច្បាប់ថ្មីៗហើយក្នុងករណីចាំបាច់នឹងស្វែងរកជំនួយបច្ចេកទេស។ បទប្បញ្ញត្តិនៅក្នុង វិស័យធនាគារៈ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងកែប្រែ និងរៀបចំសេចក្តីព្រាងប្រកាសថ្មី រួមមាន ការធ្វើវិសោធនកម្មលើប្រកាសស្តីពីចំណាត់ថ្នាក់ទ្រព្យសកម្ម និងសំវិធានធន និងវិធានការកែតម្រូវបន្ទាន់ និងការរៀបចំសេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងហានិភ័យសន្ទនីយភាព និងសវនករឯករាជ្យ។

**២៩១- បទប្បញ្ញត្តិនៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ:** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងរៀបចំ ដាក់ឲ្យអនុម័តនូវសេចក្តីព្រាងច្បាប់មួយចំនួន ដូចជា ៖ (១) ច្បាប់ស្តីពីបរធនបាលកិច្ច (២) ច្បាប់ស្តីពី ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍន៍អចលនវត្ថុ (៣) ច្បាប់ស្តីពីការគ្រប់គ្រងអាជីវកម្មផ្តល់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ និង (៤) ច្បាប់ស្តីពីការគ្រប់គ្រងអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន។

**២៩២- ច្បាប់ស្តីពីប្រព័ន្ធគាំពារសង្គម និងច្បាប់ស្តីពីរបបសោធនឯកជនស្ម័គ្រចិត្ត:** ក្រុមការងារអភិវឌ្ឍន៍ ប្រព័ន្ធគាំពារសង្គម នឹងរៀបចំក្របខ័ណ្ឌគោលនយោបាយ ច្បាប់ស្តីពីប្រព័ន្ធគាំពារសង្គម និងច្បាប់ស្តីពី របបសោធនស្ម័គ្រចិត្តដើម្បីធានាឲ្យបាននូវការគ្រប់គ្រង និងត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព។

## VII.ការិយាល័យឥណទានកម្ពុជា

### ក. ទិដ្ឋភាពទូទៅ

**២៩៣-** ការិយាល័យឥណទានកម្ពុជា គឺជាប្រតិបត្តិករនៃមជ្ឈមណ្ឌលផ្ទុកទិន្នន័យព័ត៌មានឥណទាន ដែលស្ថិតក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ហើយមានតួនាទីជួយដល់គ្រឹះស្ថាន ធនាគារ និងហិរញ្ញវត្ថុក្នុងការចែករំលែកព័ត៌មានអំពីប្រវត្តិនៃការសងប្រាក់របស់អតិថិជន។ ការិយាល័យ ឥណទានកម្ពុជា គឺជាក្រុមហ៊ុនរួមទុន រវាងក្រុមហ៊ុន Credit Bureau Holding Cambodia ដែល តំណាងដោយសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជានិងក្រុមហ៊ុន Veda Cambodia Holding ដែលជាអ្នកផ្គត់ផ្គង់នូវបច្ចេកវិទ្យាការិយាល័យឥណទាន។ គោលបំណងនៃការ បង្កើតការិយាល័យឥណទានកម្ពុជា គឺពង្រឹងស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជា តាមរយៈការផ្តល់ទិន្នន័យ ដែលត្រឹមត្រូវ និងទាន់ពេលវេលាដល់អតិថិជន និងក្រុមហ៊ុនដែលស្ថិតក្នុងវិស័យហិរញ្ញវត្ថុ ដើម្បីជួយ

ពង្រឹងការគ្រប់គ្រងហានិភ័យឥណទាន។ គោលដៅរបស់ការិយាល័យឥណទានកម្ពុជា គឺជួយដល់អាជីវកម្មក្នុងការគ្រប់គ្រងហានិភ័យឥណទាន កំណត់ពាក្យសុំខ្ចីឥណទានដែលមិនត្រឹមត្រូវ និងគាំទ្រដល់ការធ្វើសេចក្តីសម្រេច។ ការិយាល័យឥណទានកម្ពុជា ក៏ជួយដល់អ្នកខ្ចីប្រាក់ផងដែរ ក្នុងការពិនិត្យមើលពីភាពត្រឹមត្រូវនៃរបាយការណ៍ឥណទាន ដើម្បីធានាថាពួកគេធ្លាប់បានទទួលកម្ចី ព្រមទាំងជួយដល់អតិថិជនក្នុងការការពារខ្លួនពីការលួចបន្លំអត្តសញ្ញាណ។

**២៩៤-** គ្រឹះស្ថានហិរញ្ញវត្ថុ បានស្នើសុំឲ្យការិយាល័យឥណទានកម្ពុជាដើរតួជាអ្នកនាំមុខ ក្នុងការជួយធានាឲ្យមានការផ្តល់ឥណទានប្រកបដោយការទទួលខុសត្រូវ និងការអនុវត្តធុរកិច្ចប្រកបដោយការទទួលខុសត្រូវ និងមានចីរភាពនៅក្នុងសហគមន៍ហិរញ្ញវត្ថុកម្ពុជា។ បេសកកម្មរបស់ការិយាល័យឥណទានកម្ពុជាគឺជំរុញដល់កំណើនសេដ្ឋកិច្ចកម្ពុជា តាមរយៈការពង្រឹងនូវការទទួលខុសត្រូវលើការខ្ចីប្រាក់ និងការឲ្យខ្ចី។ ភាពត្រឹមត្រូវ និងអាចជឿទុកចិត្តបាននៃរបាយការណ៍ឥណទាន មានសារៈសំខាន់ណាស់ក្នុងការគាំទ្រដល់ស្ថិរភាពហិរញ្ញវត្ថុ ការជំរុញការអភិវឌ្ឍ និងពិពិធកម្មសេដ្ឋកិច្ច។ ការិយាល័យឥណទានកម្ពុជាកំពុងដំណើរការយ៉ាងល្អ ឈានទៅសម្រេចបាននូវបេសកកម្មរបស់ខ្លួន តាមរយៈការផ្តល់ព័ត៌មាន ឥណទានដែលត្រឹមត្រូវ និងទាន់ពេលវេលាដល់អាជីវកម្ម និងអតិថិជននៅកម្ពុជា។ ការណ៍នេះកាត់បន្ថយហានិភ័យនៃការឲ្យខ្ចីដល់អាជីវកម្ម ព្រមទាំងជំរុញការផ្តល់ទុនដល់អ្នកខ្ចីប្រាក់ឲ្យបានច្រើនជាងមុន។

## ខ. វឌ្ឍនភាព និងសមិទ្ធផល

**២៩៥-** ការិយាល័យឥណទានកម្ពុជា បានចាប់ផ្តើមប្រតិបត្តិការអាជីវកម្ម នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២។ តាមរយៈបទប្បញ្ញត្តិដែលបានដាក់ចេញ គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងអស់នៅក្នុងប្រទេសត្រូវផ្តល់ទិន្នន័យឥណទានទៅក្នុងប្រព័ន្ធ។ ទន្ទឹមនេះ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងអស់ត្រូវតែពិនិត្យមើលរបាយការណ៍ឥណទាន ចំពោះរាល់ពាក្យខ្ចីប្រាក់ ដែលជាផ្នែកមួយនៃដំណើរការផ្តល់ឥណទាន។ បច្ចុប្បន្ន ការិយាល័យឥណទានកម្ពុជា មានមុខងារពេញលេញជាការិយាល័យឥណទានស្របតាមប្រកាសស្តីពីការចែករំលែកព័ត៌មាន។ ការិយាល័យឥណទានកម្ពុជាបានធ្វើការផ្សព្វផ្សាយយ៉ាងជោគជ័យដល់សាធារណជន ក្នុងការបង្កើនការយល់ដឹងអំពីសារប្រយោជន៍នៃការិយាល័យឥណទាន។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**២៩៦- ការទទួលបានព័ត៌មានអំពីក្រុមហ៊ុនដែលបានចុះបញ្ជី:** បច្ចុប្បន្នការិយាល័យឥណទានកម្ពុជាមិនទាន់បានទទួលព័ត៌មានអំពីក្រុមហ៊ុនដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនៅឡើយ។ ការដាក់ឲ្យប្រើប្រាស់ប្រព័ន្ធអនឡាញ សម្រាប់ការចុះបញ្ជីក្រុមហ៊ុនរបស់ក្រសួងពាណិជ្ជកម្ម ផ្តល់លទ្ធភាពអនឡាញ

ដល់ការិយាល័យឥណទានកម្ពុជាទទួលបានព័ត៌មានទាន់ពេលវេលា ក៏ដូចជាការផ្តល់ព័ត៌មានអំពីប្រវត្តិឥណទានរបស់ក្រុមហ៊ុនបន្ថែមលើប្រវត្តិឥណទានរបស់បុគ្គល។ ការទទួលបានព័ត៌មានអំពីក្រុមហ៊ុនដែលបានចុះបញ្ជីរបស់សាធារណជន អាចនឹងទាមទារឲ្យមានការកែសម្រួលច្បាប់តិចតួចនៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

**២៩៧- ការទទួលបានព័ត៌មានអំពីការចុះបញ្ជីបរធនបាលកិច្ច** (Trust Registry): បច្ចុប្បន្ន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពុំទាន់មានការចុះបញ្ជីបរធនបាលកិច្ចនៅឡើយទេ ព្រោះវិស័យនេះជាកិច្ចការថ្មីដែលទាមទារឲ្យមាន (១) ការចំណាយចរិកាខ្ពស់ក្នុងការដំឡើងប្រព័ន្ធព័ត៌មានវិទ្យា (២) ត្រូវពង្រឹងសមត្ថភាពមន្ត្រី (៣) ទាមទារការផ្សព្វផ្សាយឲ្យមានលក្ខណៈទូលំទូលាយដល់សាធារណជន និង (៤) តម្រូវការជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍ។

## ឃ. យុទ្ធសាស្ត្រនិងផែនការអនាគត

**២៩៨- បរធនបាលកិច្ចហិរញ្ញវត្ថុ**: បន្ទាប់ពីច្បាប់ស្តីពីបរធនបាលកិច្ច (Trust Law) ត្រូវបានដាក់ឲ្យអនុវត្ត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវការចេញអនុក្រឹត្យ ឬប្រកាសអនុញ្ញាតឲ្យចុះបញ្ជីបរធនបាលកិច្ចតាមប្រព័ន្ធ Online ដែលការិយាល័យឥណទានកម្ពុជា និងសាធារណជនទទួលបានព័ត៌មាន។

**២៩៩- ប្រសិទ្ធភាពអនុវត្តការងារ**: ធនាគារជាតិនៃកម្ពុជា នឹងបន្តពង្រឹងការត្រួតពិនិត្យការិយាល័យឥណទានកម្ពុជា ដើម្បីធានាបាននូវប្រសិទ្ធភាពការងារ និងដំណោះស្រាយផ្សេងៗ ដោយផ្តោតការយកចិត្តទុកដាក់លើបច្ចេកវិទ្យា សមត្ថភាព សុវត្ថិភាព និងកិច្ចការពារអ្នកប្រើប្រាស់។

**៣០០- ព័ត៌មានឥណទានពាណិជ្ជកម្ម** (Commercial Credit Report): ធនាគារជាតិនៃកម្ពុជានឹងបន្តជំរុញ និងសហការជាមួយការិយាល័យឥណទានកម្ពុជារៀបចំរបាយការណ៍ព័ត៌មានឥណទានពាណិជ្ជកម្មដែលគ្របដណ្តប់លើការផ្តល់កម្ចីទាំងអស់ទៅឲ្យក្រុមហ៊ុន និងបុគ្គលក្នុងនាមជាក្រុមហ៊ុនឬសាជីវកម្ម។

# VIII. ការធានាឥណទាន និងកិច្ចការពារអ្នកដាក់ប្រាក់បញ្ញើ

## ក. ស្ថានភាពទូទៅ

**៣០១-** ជាទូទៅ ប្រជាជនក្រីក្រនិងប្រជាជននៅតាមជនបទក្នុងប្រទេសកម្ពុជារស់នៅ និងធ្វើការដោយពឹងផ្អែកលើសេដ្ឋកិច្ចក្រៅផ្លូវការដោយសារមិនមានជម្រើស និងភាពចាំបាច់។ ប្រជាជនក្រីក្រ និងប្រជាជននៅតាមជនបទទាំងនេះត្រូវការសេវាហិរញ្ញវត្ថុជាច្រើន ដើម្បីរៀបចំ និងទ្រទ្រង់ការចិញ្ចឹមជីវិត បង្កើនទ្រព្យសម្បត្តិ គ្រប់គ្រងហានិភ័យ និងសម្រួលការប្រើប្រាស់ឲ្យមានភាពរលូន។ ចំពោះប្រជាជនក្រីក្រ ការគ្រប់គ្រងហិរញ្ញវត្ថុគឺជាផ្នែកមួយដែលចាំបាច់ និងទាមទារឲ្យមានការយល់ច្បាស់

សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ យោងតាមភស្តុតាង ការទទួលបាន និងការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ផ្តល់ផលប្រយោជន៍ និងផលវិជ្ជមានលើសូចនាករមីក្រូសេដ្ឋកិច្ចជាច្រើន រួមមានៈ ការប្រកបអាជីវកម្មដោយខ្លួនឯង ការប្រើប្រាស់ក្នុងគ្រួសារ និងសុខុមាលភាព។

**៣០២-** ជាធម្មតានៅក្នុងវិស័យជនបទ ស្ត្រីដើរតួយ៉ាងសំខាន់ក្នុងការរកប្រាក់ចំណូល និងផ្តល់សេវាថែទាំដល់តម្រូវការរបស់ក្រុមគ្រួសារ។ ស្ត្រីត្រូវបានទទួលការយកចិត្តទុកដាក់កាន់តែខ្លាំងពីអ្នកផ្តល់សេវាហិរញ្ញវត្ថុ។ ប្រមាណ ៧៥% នៃអ្នកខ្ចីប្រាក់ និង ៦៥% នៃអ្នកដាក់ប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគឺជាស្ត្រី ហើយភាគច្រើននៃគ្រឹះស្ថានទាំងនោះ បានយកចិត្តទុកដាក់លើការបង្កើតផលិតផលកម្ចី និងសេវាបញ្ញើថ្មីៗ ជាពិសេសសម្រាប់ស្ត្រី។

**៣០៣-** រាជរដ្ឋាភិបាលមានឧបករណ៍គោលនយោបាយមួយចំនួនសម្រាប់ ជំរុញដល់បរិយាបន្នហិរញ្ញវត្ថុ។ ឧបករណ៍ទាំងនេះ រួមមាន កម្មវិធីលើកកម្ពស់ការយល់ដឹងអំពីសេវា និងផលិតផលហិរញ្ញវត្ថុ គម្រោងធានាឥណទានធុនតូចនិងមធ្យម និងកិច្ចការពារអ្នកដាក់ប្រាក់បញ្ញើ។

## ខ. វឌ្ឍនភាពនិងសមិទ្ធផល

**៣០៤- គម្រោងធានាឥណទាន:** ប្រទេសជាច្រើនបានជួយជំរុញកំណើននៃការផ្តល់ឥណទានដល់សហគ្រាសធុនតូចនិងមធ្យមតាមរយៈគម្រោងធានាឥណទាន ដែលមានរចនាសម្ព័ន្ធច្បាស់លាស់។ ក្នុងរយៈពេលជាងពីរឆ្នាំកន្លងទៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាននិងកំពុងសិក្សាស្រាវជ្រាវនូវយន្តការសម្រាប់អភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ។ ការសិក្សាស្រាវជ្រាវបានបង្ហាញថា ប្រទេសដែលមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ភាគច្រើនបានបង្កើតគម្រោងធានាឥណទាន ដែលជាជម្រើសមួយក្នុងការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូចនិងមធ្យម ដើម្បីគាំទ្រការលូតលាស់អាជីវកម្ម។

**៣០៥-** បច្ចុប្បន្ន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំពុងសិក្សាលទ្ធភាព ដើម្បីអនុវត្តគម្រោងធានាឥណទានសម្រាប់សហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា។ មន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានទៅធ្វើកម្មសិក្សានៅសាជីវកម្មធានាលើឥណទានថៃនៃប្រទេសថៃ។ សាជីវកម្មធានាឥណទានថៃ គឺជាសហគ្រាសរដ្ឋ និងជាស្ថាប័នឯកទេសហិរញ្ញវត្ថុមួយ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងហិរញ្ញវត្ថុនៃប្រទេសថៃ។ ចាប់ពីឆ្នាំ១៩៩៥ សាជីវកម្មធានាឥណទានថៃ បានផ្តល់ការធានាឥណទានដល់សហគ្រាសធុនតូចនិងមធ្យមដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីទទួលបានឥណទានពីគ្រឹះស្ថានហិរញ្ញវត្ថុ។ សាជីវកម្មធានាឥណទានថៃ បានក្លាយជាយន្តការមួយដ៏សំខាន់របស់ប្រទេសថៃ ដើម្បីអភិវឌ្ឍវិស័យសហគ្រាសធុនតូចនិងមធ្យម។

**៣០៦- គម្រោងការពារអ្នកដាក់ប្រាក់បញ្ញើ:** ប្រទេសជាច្រើនបានបង្កើតគម្រោងការពារអ្នកដាក់ប្រាក់បញ្ញើដើម្បីការពារអ្នកដាក់ប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារ (ពិសេសអ្នកដាក់ប្រាក់បញ្ញើដែលមានប្រាក់

និងចំណេះដឹងហិរញ្ញវត្ថុតិចតួច) ក្នុងចំនួនទាំងស្រុង ឬមួយផ្នែកពីការខាតបង់ ដែលបណ្ដាលមកពីធនាគារពុំមានលទ្ធភាពក្នុងការបំពេញកាតព្វកិច្ចសងបំណុលរបស់ខ្លួន នៅពេលដល់ថ្ងៃកំណត់។ ការបង្កើតឲ្យមានគម្រោងការពារអ្នកដាក់ប្រាក់បញ្ញើ នឹងបង្កើនទំនុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ និងរួមចំណែកដល់ស្ថិរភាពហិរញ្ញវត្ថុ តាមរយៈការកាត់បន្ថយហានិភ័យនៃ "ការសម្រុកដកប្រាក់"។ ធនាគារជាតិនៃកម្ពុជា បានបង្កើតក្រុមការងារមួយដើម្បីទទួលបន្ទុកលើគម្រោងការពារអ្នកដាក់ប្រាក់បញ្ញើ។ ក្រុមការងារនេះ កំពុងពិនិត្យក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិចាំបាច់ និងម៉ូដែលគម្រោងការពារអ្នកដាក់ប្រាក់បញ្ញើដែលមានសក្ដានុពល ដោយមានជំនួយពីជំនាញការ/អ្នកពិគ្រោះយោបល់រតនាគារសហរដ្ឋអាមេរិក។ ការសិក្សាលទ្ធភាពស្ដីពីការបង្កើតគម្រោងការពារអ្នកដាក់ប្រាក់បញ្ញើក្នុងប្រទេសកម្ពុជាត្រូវបានគ្រោងអនុវត្តដើម្បីវាយតម្លៃនិង/ឬផ្ដល់អនុសាសន៍លើ៖(១) បុរេលក្ខខណ្ឌសម្រាប់ការបង្កើតគម្រោងការពារអ្នកដាក់ប្រាក់បញ្ញើ និងការត្រៀមខ្លួនជាស្រេចនាពេលបច្ចុប្បន្ន (២) កម្រិតនៃការទូទាត់សងអ្នកដាក់ប្រាក់បញ្ញើ (៣) ដើមទុនសម្រាប់គម្រោងការពារអ្នកដាក់ប្រាក់បញ្ញើដែលរួមបញ្ចូលនូវតម្លៃនៃបុព្វលាភដែលត្រូវកំណត់យកពីគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (៤) រចនាសម្ព័ន្ធ ទម្រង់ និងអភិបាលកិច្ចរបស់គម្រោងការពារអ្នកដាក់ប្រាក់បញ្ញើនិង (៥) ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិដែលត្រូវការសម្រាប់គម្រោងការពារអ្នកដាក់ប្រាក់បញ្ញើ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបញ្ចប់របាយការណ៍សិក្សាស្រាវជ្រាវលើកទី១ស្ដីពីស្ថាប័នធានារ៉ាប់រងលើប្រាក់បញ្ញើកាលពីឆ្នាំ២០១៤ និងកំពុងសិក្សាសមិទ្ធិលទ្ធភាពស្ដីពីការបង្កើតស្ថាប័នធានារ៉ាប់រងលើប្រាក់បញ្ញើ។

**៣០៧-** បច្ចុប្បន្នធនាគារជាតិនៃកម្ពុជា កំពុងសិក្សាពីលទ្ធភាពក្នុងការបង្កើតសាជីវកម្មមួយដើម្បីគ្រប់គ្រងគម្រោងការពារអ្នកដាក់ប្រាក់បញ្ញើ។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**៣០៨- គម្រោងធានាឥណទាន:** គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុជាច្រើនស្ទាក់ស្ទើរក្នុងការផ្ដល់ឥណទានដល់សហគ្រាសធុនតូចនិងមធ្យម ដោយសារសហគ្រាសធុនតូច និងមធ្យមមិនបានបំពេញកាតព្វកិច្ចដូចជា៖(១) មិនបានចុះបញ្ជី (២) មិនមានរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងតួលេខប្រៀបធៀប និង (៣) មិនមានទ្រព្យធានាគ្រប់គ្រាន់សម្រាប់ទទួលបានឥណទាន។

**៣០៩-** ដើម្បីដោះស្រាយបញ្ហានេះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាននិងកំពុងរៀបចំ៖ (១) គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់ (ក) ការចែករំលែកហានិភ័យរវាងអ្នកស្នើសុំឥណទាន អ្នកផ្ដល់ឥណទាន និងអ្នកធានា (ខ) ដោះស្រាយបញ្ហាហានិភ័យចិត្តសាស្ត្រ (moral hazard) និង (គ) បង្កើនសមត្ថភាពដល់សហគ្រាសធុនតូចនិងមធ្យមសម្រាប់រៀបចំផែនការអាជីវកម្ម បង្កើតគណនី និងគ្រប់គ្រងអាជីវកម្មរបស់សហគ្រាសធុនតូចនិងមធ្យម (២) យុទ្ធសាស្ត្រសម្រាប់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍ

និងអនុវត្តគម្រោងធានាឥណទានសម្រាប់សហគ្រាសធុនតូចនិងមធ្យម និង (៣) ផែនការសកម្មភាព ដែលចាំបាច់សម្រាប់អនុវត្តគម្រោងធានាឥណទាន ដើម្បីជួយពង្រឹងការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា។

**៣១០-** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើការស្រាវជ្រាវ និងរកឃើញនូវផលប្រយោជន៍សេដ្ឋកិច្ច ជាច្រើន ដែលនឹងទទួលបានពីគម្រោងធានាឥណទានដែលមានរចនាសម្ព័ន្ធច្បាស់លាស់ គឺជា រចនាសម្ព័ន្ធមួយដែលធ្វើឡើង ដើម្បីជំរុញការអនុវត្តអាជីវកម្មឲ្យកាន់តែប្រសើរឡើង។ គោលនយោបាយ ដែលត្រូវការស្រាវជ្រាវបន្ថែម គឺវិធីសាស្ត្រដើម្បីកាត់បន្ថយហានិភ័យ ដែលអាចកើតមានឡើងដោយ គម្រោងធានាឥណទានកម្ពុជា រួមមាន ជម្រើសនៃការចែករំលែកហានិភ័យនៅក្នុងឧស្សាហកម្ម និង វិធីសាស្ត្រដើម្បីពង្រឹងបទប្បញ្ញត្តិការធានាឥណទានសម្រាប់កម្មវិធីអប់រំផ្នែកហិរញ្ញវត្ថុ ការទទួលយក ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុដោយសហគ្រាសធុនតូចនិងមធ្យម និងដំណើរការរៀបចំផែនការអាជី-វកម្មសម្រាប់សហគ្រាសធុនតូចនិងមធ្យម។

**៣១១- របាយការណ៍ហិរញ្ញវត្ថុ:** ទោះបីជាមានប្រកាសតម្រូវឲ្យក្រុមហ៊ុនត្រូវធ្វើសវនកម្មលើរបាយ-ការណ៍ហិរញ្ញវត្ថុក៏ដោយ ក៏លក្ខខណ្ឌតម្រូវនេះមិនត្រូវបានរឹតបន្តឹងទេ និងអាចត្រូវបានចាត់ទុកជា បុរេលក្ខខណ្ឌសម្រាប់ទទួលបានការធានាឥណទានពីគម្រោងធានាឥណទាន។

## ឃ. យុទ្ធសាស្ត្រ និងផែនការអនាគត

**៣១២-** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកដឹកនាំសម្របសម្រួលការសិក្សាសមិទ្ធិលទ្ធភាព និង យថាហេតុនៃការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រនៃគម្រោងធានាឥណទាននៅកម្ពុជា។

**៣១៣-** ធនាគារជាតិនៃកម្ពុជា ជាអ្នកដឹកនាំសម្របសម្រួលការសិក្សាសមិទ្ធិលទ្ធភាព និងយថាហេតុ នៃការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រនៃគម្រោងការពារអ្នកដាក់ប្រាក់បញ្ញើ។ ធនាគារជាតិ នៃកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងបន្តខិតខំបង្កើនសមត្ថភាពមន្ត្រីបុគ្គលិក និងក្រុមការងារ របស់ខ្លួន តាមរយៈវគ្គបណ្តុះបណ្តាលផ្សេងៗទាក់ទងនឹងការសិក្សាបង្កើតប្រព័ន្ធការពារអ្នកដាក់ប្រាក់ បញ្ញើនៅកម្ពុជា។ លើសពីនេះ ក្រុមការងារនឹងធ្វើទស្សនកិច្ចសិក្សាដើម្បីស្វែងយល់បន្ថែមអំពីដំណើរការ និងបទពិសោធន៍ក្នុងការបង្កើតប្រព័ន្ធនេះនៅតាមបណ្តាប្រទេសមួយចំនួននៅក្នុងតំបន់ ជាពិសេសលើ ក្របខ័ណ្ឌបទប្បញ្ញត្តិ អភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ ប្រតិបត្តិការ យន្តការសហប្រតិបត្តិការ ជាមួយអាជ្ញាធរពាក់ព័ន្ធ និងដំណោះស្រាយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានបញ្ហា។

**៣១៤-** ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងបន្តអនុវត្តការងារ ស្របតាមផែនការសកម្មភាពរបស់ខ្លួន ក្នុងនោះរួមមាន ការរៀបចំឯកសារគោលនយោលបាយក្នុងការ បង្កើតប្រព័ន្ធការពារអ្នកដាក់ប្រាក់បញ្ញើនៅកម្ពុជានឹងត្រូវបញ្ចប់នាដំណាច់ឆ្នាំ២០១៦ និងឈានទៅធ្វើ

សេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិទាក់ទងនឹងប្រព័ន្ធការពារអ្នកដាក់ប្រាក់បញ្ញើនៅកម្ពុជានាដើមឆ្នាំ ២០១៧។ សេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិនេះ គ្រោងនឹងរួចរាល់សម្រាប់ការពិគ្រោះយោបល់ជាសាធារណៈជាមួយភាគីពាក់ព័ន្ធក្នុងឆ្នាំ២០១៨។

## IX. **បរធនបាលកិច្ច**

### ក. **ទិដ្ឋភាពទូទៅ**

**៣១៥-** បរធនបាលកិច្ច គឺជាទំនាក់ទំនងគតិយុត្តដែលបរធនបាលទាយកផ្តល់ទ្រព្យសម្បត្តិដល់បរធនបាលក្នុងការមើលថែរក្សា និងប្រើប្រាស់ជាប្រយោជន៍ដល់អត្ថគាហក។ ទំនាក់ទំនងនេះ គឺជាកាតព្វកិច្ចដែលចែងដោយច្បាប់ក្នុងការតម្រូវឲ្យបរធនបាលមានសិទ្ធិកាន់កាប់ និងគ្រប់គ្រងទ្រព្យសម្បត្តិសម្រាប់ជាប្រយោជន៍ដល់បុគ្គលដែលនឹងត្រូវទទួលបានអត្ថប្រយោជន៍ពីទ្រព្យសម្បត្តិនោះ។

**៣១៦-** បរធនមួយចំនួនត្រូវបានប្រើប្រាស់ជាលក្ខណៈពាណិជ្ជកម្ម ដែលនឹងអាចមានផលប៉ះពាល់លើវិស័យហិរញ្ញវត្ថុ រួមមាន: (១) ការកាន់កាប់សាច់ប្រាក់របស់អតិថិជន ដូចជាការរៀបចំធានារ៉ាប់រងឬកាលៈទេសៈនៃសាធនភាព (២) ជម្លោះ ឬសក្តានុពលនៃជម្លោះ ដែលរួមមាន ការបាត់បង់សុវត្ថិភាពឬវិវាទធ្ងន់ធ្ងរពាក់ព័ន្ធនឹងការគ្រប់គ្រងបរធន (៣) ផែនការលើកទឹកចិត្តនិយោជិត រួមមានផលប្រយោជន៍គ្រប់ប្រភេទសម្រាប់និយោជិត គ្រោងការភាគហ៊ុនបរធន និងមូលនិធិសោធន និង (៤) ទម្រង់ប្រមូលផ្តុំនៃការវិនិយោគ រួមមាន បរធនជាក្រុម និងបរធននៃការវិនិយោគទ្រព្យសម្បត្តិ។

**៣១៧-** បរធន គឺជាឧបករណ៍គតិយុត្តដ៏សំខាន់មួយ ដែលបានវិនិយោគទៅក្នុងទីផ្សារហិរញ្ញវត្ថុ។ បរធនបាលកិច្ចពាណិជ្ជកម្ម មាន ៣ផ្នែកសំខាន់ៗគឺ បរធននៃមូលនិធិសោធន បរធននៃការវិនិយោគ (រួមមាន មូលនិធិសង្គហៈ បរធននៃការវិនិយោគក្នុងវិស័យអចលនទ្រព្យ បរធនភាគលាភ និងបរធនទ្រព្យមូលបត្រ) និងអនុលោមភាពបរធនបាលគតិយុត្ត (ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងបន្តការទទួលខុសត្រូវដែលផ្តល់ដោយច្បាប់)។

**៣១៨-** អនុលោមភាពបរធនបាលគតិយុត្ត (១) បរធននៃអ្នកវិនិយោគអចលនទ្រព្យដែលមូលនិធិអ្នកវិនិយោគអចលនទ្រព្យត្រូវបានកាន់កាប់ក្នុងបរធនបាលកិច្ច ហើយផ្តល់បរធនបន្តដល់អ្នកអភិវឌ្ឍដោយផ្អែកលើកិច្ចព្រមព្រៀងជាឯករាជ្យ តាមដំណាក់នៃការអភិវឌ្ឍ(អគារសហកម្មសិទ្ធិ ការអភិវឌ្ឍលំនៅដ្ឋាន។ល។) (២) គណនីបរធនបាលកិច្ចនៃការិយាល័យច្បាប់ដែលមេធាវីដើរតួនាទីជាអ្នករក្សាទុកមូលនិធិជំនួស (៣) បរធនបង្ការដែលត្រូវបានប្រើប្រាស់ក្នុងវិវាទផ្នែកច្បាប់ ដើម្បីការទូទាត់សម្រាប់បច្ចុប្បន្នភាព និង/ឬការទាមទារសំណងទៅពេលអនាគត។ បរធនក៏ត្រូវបានប្រើប្រាស់ក្នុងទម្រង់ពាណិជ្ជកម្ម រួមមាន លក្ខខណ្ឌកិច្ចព្រមព្រៀង ការធានានិងទម្រង់នៃបំណុល ។

## ខ. វឌ្ឍនភាពនិងសមិទ្ធផល

**៣១៩-** ច្បាប់បរធនបាលកិច្ចថ្មីត្រូវបានរៀបចំជាសេចក្តីព្រាងច្បាប់ឡើង។ អនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ ត្រូវបានអនុម័តនៅឆ្នាំ២០១៣ និងបច្ចុប្បន្ន បានអនុវត្តចំពោះនីតិបុគ្គល ដែលបានទទួលមូលនិធិជំនួយអន្តរជាតិតតសំណាងក្នុងនាមប្រជាជនកម្ពុជា ក្នុងគោលបំណងអភិវឌ្ឍវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។ មូលនិធិនេះ ត្រូវបានប្រើប្រាស់ក្នុងរូបភាពជាបំណុលឬភាគហ៊ុននៅក្នុងគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជីត្រឹមត្រូវ តាមច្បាប់ក្នុងទម្រង់ជាក្រុមហ៊ុន។ អនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ និងប្រកាសស្តីពីការគ្រប់គ្រង និងត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ នៅតែបន្តអនុភាពអនុវត្ត បើទោះជាច្បាប់ស្តីពីបរធនបាលកិច្ច ត្រូវបានអនុម័តក៏ដោយ។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**៣២០-** វិស័យបរធនបាលកិច្ច មានភាពស្មុគស្មាញ និងប្រទាក់ក្រឡាវាងស្ថាប័នពាក់ព័ន្ធ។ ចំណែកឯការចុះបញ្ជីបរធនបាលកិច្ចនូវមានកម្រិតនៅឡើយ ដោយសារបរធនបាលមួយចំនួនមិនទាន់យល់ច្បាស់អំពីកាតព្វកិច្ច ការទទួលបានព័ត៌មាននៅមានកម្រិត និងសមត្ថភាពបញ្ញត្តិករនៅមានកម្រិតដែលទាមទារឲ្យមានការពង្រឹងសមត្ថភាព។

## ឃ. យុទ្ធសាស្ត្រនិងផែនការនាពេលអនាគត

**៣២១- សម្ព័ន្ធភាពនៃច្បាប់ស្តីពីបរធនបាលកិច្ច អនុក្រឹត្យ និងប្រកាស:** ច្បាប់បរធនបាលកិច្ចនឹងត្រូវបានអនុម័ត ហើយក្រសួងនិងស្ថាប័នពាក់ព័ន្ធនឹងរៀបចំជាអនុក្រឹត្យនិងប្រកាសផ្សេងៗគ្នា ដើម្បីបន្តអនុវត្តតាមគោលដៅរៀងៗខ្លួន ហើយស្ថិតក្រោមការធ្វើប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុ។ បទប្បញ្ញត្តិទាំងនេះ ក៏មានអនុភាពគតិយុត្តគ្របដណ្តប់លើប្រតិបត្តិការបរធនបាលកិច្ច និងរួមបញ្ចូលនូវកាតព្វកិច្ចស្របច្បាប់ និងប្រកាសស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**៣២២- ការចុះបញ្ជីបរធនបាលកិច្ច:** ការចុះបញ្ជីបរធនបាលកិច្ច មានលក្ខណៈស្រដៀងគ្នាទៅនឹងប្រព័ន្ធចុះបញ្ជីអនឡាញរបស់ក្រសួងពាណិជ្ជកម្ម ដែលបានអនុវត្តសម្រាប់ក្រុមហ៊ុននាពេលកន្លងមក។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងពិនិត្យលទ្ធភាពក្នុងការបង្កើតប្រព័ន្ធចុះបញ្ជីតាមអនឡាញ។ ការចុះបញ្ជីជាកម្មសិទ្ធិករដោយឡែក និងមានតែអាជ្ញាធរសាមីតែមួយគត់ដែលអនុញ្ញាតឲ្យប្រើប្រាស់ប្រព័ន្ធនេះ។

## X. ប្រព័ន្ធនិងស្តង់ដា

### ក. ទិដ្ឋភាពទូទៅ

**៣២៣-** សកម្មភាពក្នុងវិស័យហិរញ្ញវត្ថុ ពឹងផ្អែកលើបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍កាន់តែខ្លាំងឡើង ដើម្បីជំរុញប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពទាំងនោះ។ ចំណុចសំខាន់បំផុតនៃសកម្មភាពទាំងនេះផ្តោតលើប្រព័ន្ធ ដែលត្រូវប្រើប្រាស់សម្រាប់កត់ត្រាប្រតិបត្តិការផ្ទេរប្រាក់ និងមូលបត្រដែលអាចជឿទុកចិត្តបាន។

**៣២៤-** ប្រព័ន្ធទូទាត់សងប្រាក់ ផាត់ទាត់ និងទូទាត់ ប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព មានភាពចាំបាច់សម្រាប់ប្រតិបត្តិការនៅក្នុងវិស័យហិរញ្ញវត្ថុ។ រាជរដ្ឋាភិបាលបាននិងកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ជាតិ ដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍឧបករណ៍និងសេវាទូទាត់សងប្រាក់ទំនើបថ្មីៗ ផ្អែកលើមូលដ្ឋាននិងស្តង់ដាថ្នាក់ជាតិ។ ធនាគារជាតិនៃកម្ពុជាក៏កំពុងអភិវឌ្ឍប្រព័ន្ធនិងសេវារបស់ខ្លួន ជាមួយនឹងបទប្បញ្ញត្តិនិងការត្រួតពិនិត្យ ស្របតាមផែនទីមគ្គុទ្ទេសក៍ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនឆាប់រហ័សក្នុងវិស័យនេះ។

### ខ. វឌ្ឍនភាពនិងសមិទ្ធផល

**៣២៥-** ដើម្បីឆ្លើយតបនឹងការរីកចម្រើនទីផ្សារ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអភិវឌ្ឍតាមដំណាក់កាលដូចខាងក្រោម៖

- ក្នុងឆ្នាំ២០១២ ធនាគារជាតិនៃកម្ពុជាបានធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ ដោយបានដាក់ឲ្យប្រើប្រាស់សភាផាត់ទាត់ស្វ័យប្រវត្តិ សម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់អន្តរធនាគារ។ ដំណើរការទូទាត់ធ្វើឡើងជារៀងរាល់ថ្ងៃទៅតាមពេលវេលាកំណត់នៅក្នុងប្រព័ន្ធសភាផាត់ទាត់ស្វ័យប្រវត្តិ ដោយការចុះឥណពន្ធ និងឥណទានលើគណនីទូទាត់របស់ធនាគារនីមួយៗ
- បច្ចុប្បន្ន ការទូទាត់សងប្រាក់ធ្វើឡើងតាមរយៈការទូទាត់សុទ្ធតាមគ្រា
- ធនាគារជាតិនៃកម្ពុជា បានចេញផ្សាយវិញ្ញាបនបត្រប្រាក់បញ្ញើអាចជួញដូរបាន ជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក។ ធនាគារអាចប្រើប្រាស់មូលបត្រប្រាក់បញ្ញើអាចជួញដូរបាននេះជំនួសឲ្យប្រាក់បញ្ញើជាសាច់ប្រាក់ និងសន្ទនីយភាពបម្រុងដែលមាននៅធនាគារជាតិនៃកម្ពុជា និងធ្វើជាប្រាតិភោគសម្រាប់បំពេញមូលនិធិបន្ថែមដល់គណនីទូទាត់
- ប្រតិបត្តិការតាមម៉ាស៊ីនឆូតកាត (POS) បច្ចុប្បន្ន ត្រូវបានដំណើរការ តាមរយៈធនាគារក្រោមរូបភាពជាប្រតិបត្តិការឥណទានផង និងឥណពន្ធផង។ ធនាគារជាតិនៃកម្ពុជា

បាននិងកំពុងអភិវឌ្ឍប្រព័ន្ធថ្នាក់ជាតិ ដែលភ្ជាប់ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ និងម៉ាស៊ីនឆូតកាត (ATM/POS) សម្រាប់ប្រតិបត្តិការឥណពន្ធ និងប្រព័ន្ធហ្វាស (FAST) សម្រាប់ការផ្ទេរមូលនិធិជាអេឡិចត្រូនិក (EFT) និងប្រតិបត្តិការធនាគារចល័ត (Mobile Banking) រវាងធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ គម្រោងនេះរំពឹងទុកថានឹងត្រូវបញ្ចប់ក្នុងឆ្នាំ២០១៦

- ធនាគារជាតិនៃកម្ពុជា បានចេញផ្សាយប្រកាសស្តីពីអ្នកដំណើរការតតិយភាគីដែលកំណត់ពីមុខងារ និងការទទួលខុសត្រូវរបស់អ្នកផ្តល់សេវា វិសាលភាពនៃប្រតិបត្តិការ និងតម្រូវការផ្នែករបាយការណ៍ រួមបញ្ចូលទាំងនីតិវិធីប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មផងដែរ
- ធនាគារជាតិនៃកម្ពុជាបានអនុញ្ញាតឲ្យគ្រឹះស្ថានមួយចំនួនផ្តល់សេវាផ្ទេរប្រាក់ សេវាទូទាត់សងប្រាក់សេវាធនាគារចល័ត និងសេវាធនាគារតាមទូរស័ព្ទចល័ត ហើយសេវាទាំងនេះបានពង្រីកទៅដល់ជនបទ និងតំបន់ដាច់ស្រយាលដែលពុំមានការផ្តល់សេវាតាមបណ្តាញផ្លូវការ
- ធនាគារជាតិនៃកម្ពុជា កំពុងរៀបចំសេចក្តីព្រាងប្រកាស ដើម្បីគ្រប់គ្រងប្រព័ន្ធទូទាត់សងប្រាក់ ក្នុងគោលដៅលើកកម្ពស់ភាពរឹងមាំ សុវត្ថិភាព ប្រសិទ្ធភាព និងភាពប្រកួតប្រជែងនៃប្រព័ន្ធទូទាត់សងប្រាក់ជាតិ ធានាបានភាពអាចធ្វើប្រតិបត្តិការបញ្ចូលគ្នា និងសមាហរណកម្មប្រព័ន្ធ ព្រមទាំងការចូលប្រើសេវាទូទាត់សងប្រាក់ការពារផលប្រយោជន៍អ្នកប្រើប្រាស់ និងគាំទ្រដល់បរិយាបន្នហិរញ្ញវត្ថុ។

**៣២៦- សមាហរណកម្មហិរញ្ញវត្ថុអាស៊ាននិងប្រព័ន្ធទូទាត់សងប្រាក់:** ការចូលរួមក្នុងក្របខ័ណ្ឌសមាហរណកម្មហិរញ្ញវត្ថុអាស៊ាន ជាកត្តាយ៉ាងសំខាន់សម្រាប់កំណត់ទិសដៅនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុហើយប្រទេសកម្ពុជាមានវឌ្ឍនភាពល្អប្រសើរ ក្នុងការត្រៀមខ្លួនសម្រាប់សមាហរណកម្មនៅក្នុងសហគមន៍ហិរញ្ញវត្ថុអាស៊ាន។

**៣២៧-** ចំពោះសមាហរណកម្មប្រព័ន្ធទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជា បានសម្រេចតភ្ជាប់ប្រព័ន្ធពីររវាងសមាជិកអាស៊ាន៖ (១) ប្រព័ន្ធទូទាត់សងប្រាក់តម្លៃធំ (LVPS) (ដោយប្រើប្រាស់ស្តង់ដា ISO20022) ដែលសមាជិកទាំងអស់កំពុងពិចារណាតភ្ជាប់ប្រព័ន្ធ RTGS ជាមួយនឹងប្រព័ន្ធ SWIFT Closed User Group Platform (២) ភ្ជាប់ប្រព័ន្ធ Central Shared Switch (ATM/POS) ទៅនឹងប្រព័ន្ធ APN ដើម្បីជំរុញការប្រើប្រាស់បណ្ណឥណពន្ធក្នុងស្រុក។

- **ការអនុវត្ត ISO20022 និង ISO8583:** ប្រព័ន្ធផាត់ទាត់ជាតិអាចដំណើរការជាមួយនឹងស្តង់ដា ISO20022។ ប្រព័ន្ធទូទាត់សងប្រាក់រាយ ដែលរួមមានប្រព័ន្ធហ្វាសសម្រាប់ការផ្ទេរមូលនិធិជាអេឡិចត្រូនិក (EFT) និងប្រព័ន្ធ Central Shared Switch សម្រាប់

ភ្ជាប់ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ និងម៉ាស៊ីនឆូតកាត (ATM/POS) នឹងដាក់ឲ្យដំណើរការដោយប្រើប្រាស់ស្តង់ដា ឬអាចដំណើរការជាមួយនឹងស្តង់ដា ISO20022 និង ISO8583។

- **ការប្រើប្រាស់បណ្តាញទូទាត់សងប្រាក់អាស៊ី (APN) សម្រាប់បណ្ណឥណពន្ធ:** APN អាចឲ្យសមាជិកអាស៊ានដកសាច់ប្រាក់ឆ្លងដែន តាមម៉ាស៊ីន ATM ក្រោមរូបភាពជាប្រតិបត្តិការឥណពន្ធ។ មុខងារដកសាច់ប្រាក់ក្រោមរូបភាពជាប្រតិបត្តិការឥណពន្ធនេះ មានដាក់ឲ្យប្រើប្រាស់ក្នុងប្រព័ន្ធ Central Shared Switch ដែលដាក់ឲ្យដំណើរការដោយធនាគារជាតិនៃកម្ពុជា។ ប្រព័ន្ធ Central Shared Switch អាចតភ្ជាប់ទៅ APN បាន បន្ទាប់ពីប្រព័ន្ធនេះត្រូវបានអភិវឌ្ឍ និងនៅពេលដែលបញ្ហាផ្សេងៗពាក់ព័ន្ធនឹងគតិយុត្តនិងនីតិវិធីត្រូវបានដោះស្រាយ។
- **ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់រាយក្នុងស្រុក:** គម្រោងអភិវឌ្ឍប្រព័ន្ធហ្វាសនិងប្រព័ន្ធ Central Shared Switch ត្រូវបានផ្តួចផ្តើមនិងអនុវត្តដោយធនាគារជាតិនៃកម្ពុជា ហើយប្រព័ន្ធទាំងពីរត្រូវបានរំពឹងថានឹងដាក់ឲ្យដំណើរការក្នុងឆ្នាំ២០១៦ បន្ទាប់ពីការរៀបចំនីតិវិធី និងកិច្ចព្រមព្រៀងជាមួយធនាគារនិងសមាជិកដទៃទៀតត្រូវបានបញ្ចប់។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**៣២៨-** ក្របខ័ណ្ឌបទប្បញ្ញត្តិដែលមានស្រាប់ នៅមិនទាន់អាចឆ្លើយតបទៅនឹងការអភិវឌ្ឍនៃប្រព័ន្ធទូទាត់នាពេលបច្ចុប្បន្ន ជាពិសេស ការប្រើប្រាស់បច្ចេកវិទ្យាថ្មីក្នុងការផ្តល់សេវាទូទាត់។

**៣២៩-** ក្នុងក្របខ័ណ្ឌអាស៊ាន កម្ពុជានៅមិនទាន់មានហេដ្ឋារចនាសម្ព័ន្ធទូទាត់អេឡិចត្រូនិកគ្រប់គ្រាន់ ជាពិសេស ប្រព័ន្ធទូទាត់តម្លៃធំ (LVPS) ឬប្រព័ន្ធទូទាត់ដុលភ្លាមៗ (RTGS) សម្រាប់ធ្វើការតភ្ជាប់ជាមួយប្រទេសសមាជិកអាស៊ាន។

**៣៣០-** សមត្ថភាពក្នុងការអនុវត្តមុខងារគ្រប់គ្រងនិងត្រួតពិនិត្យប្រព័ន្ធទូទាត់ និងអ្នកផ្តល់សេវាទូទាត់នៅមានកម្រិត ដែលចាំបាច់ត្រូវពង្រីកបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃទីផ្សារ។

**៣៣១-** ការអនុវត្តទៅតាមគោលការណ៍ និងស្តង់ដាអន្តរជាតិក្នុងវិស័យហិរញ្ញវត្ថុ ដើម្បីជំរុញនិងសម្រួលដល់ការធ្វើសមាហរណកម្ម មិនទាន់មានភាពទូលំទូលាយនៅឡើយ។

## ឃ. យុទ្ធសាស្ត្រនិងផែនការអនាគត

**៣៣២- ការគាំទ្រដល់ការអនុវត្ត:** ធនាគារជាតិនៃកម្ពុជា នឹងពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិ វិធាននិងនីតិវិធីដើម្បីសម្រេចឲ្យបានការដាក់ឲ្យប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ និងសម្រាប់ការត្រួតពិនិត្យលើសេវាធនាគារអេឡិចត្រូនិកនិងតាមធនាគារចល័ត (Electronic and Mobile Banking)។

**៣៣៣-** ធនាគារជាតិនៃកម្ពុជា នឹងបន្តអនុវត្តវិធានការដើម្បីដាក់ចេញ (១) ក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់ និងសេវាទូទាត់សងប្រាក់ (២) គោលការណ៍ណែនាំលើស្តង់ដាសម្រាប់ការទូទាត់សងប្រាក់ (៣) ស្តង់ដាដើម្បីធានាថាអ្នកផ្តល់សេវាបានផ្តល់សេវាទាន់ពេលវេលា និងគួរឲ្យទុកចិត្ត និង (៤) ស្តង់ដាដើម្បីកំណត់ថាតើប្រតិបត្តិការធនាគារអេឡិចត្រូនិកបង្កើតជាប្រតិបត្តិការប្រាក់បញ្ញើការផ្ទេរប្រាក់ធម្មតា ឬប្រតិបត្តិការឆ្លងដែន។

**៣៣៤- ការវាយតម្លៃដោយខ្លួនឯង: គ.ម.ក.** នឹងធ្វើការសិក្សាអំពីលទ្ធភាពអនុវត្តតាមគោលការណ៍ស្នូលIOSCO។ ធនាគារជាតិនៃកម្ពុជានឹងអនុវត្តការវាយតម្លៃដោយខ្លួនឯង ដើម្បីបញ្ជាក់ថាប្រព័ន្ធបច្ចុប្បន្ន អនុលោមតាមគោលការណ៍សម្រាប់ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ។

**៣៣៥- ស្តង់ដានិងជម្រើសក្នុងការតភ្ជាប់:** ធនាគារជាតិនៃកម្ពុជានឹងពិនិត្យនូវជម្រើសក្នុងការភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់របស់កម្ពុជា ជាមួយនឹងប្រព័ន្ធទូទាត់សងប្រាក់របស់ប្រទេសដទៃនៅក្នុងតំបន់និងទូទាំងសកលលោក។ ក្នុងនាមជាសមាជិកមួយរបស់អាស៊ាន ប្រទេសកម្ពុជានឹងខិតខំជំរុញសមាហរណកម្មជាមួយសមាជិកផ្សេងទៀត ព្រមទាំងចូលរួមជាមួយបណ្តាញទូទាត់សងប្រាក់អាស៊ី (APN or AsiaPay)។

**៣៣៦- ការអនុវត្តប្រព័ន្ធទូទាត់ដុលភ្លាមៗ (RTGS):** ធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្តការងារដើម្បីអាចឲ្យធនាគារទូទាត់ទឹកប្រាក់ចំនួនធំ ដោយប្រើប្រាស់ប្រព័ន្ធទូទាត់ដុលភ្លាមៗ និងធានាថាកិច្ចសម្របសម្រួលរវាងប្រព័ន្ធផ្ទេរប្រាក់ជាអេឡិចត្រូនិក និងប្រព័ន្ធទូទាត់សងប្រាក់តម្លៃធំ ត្រូវបានអនុវត្ត ដើម្បីលុបបំបាត់ ឬកាត់បន្ថយគម្លាតនៃតម្លៃប្រតិបត្តិការរវាងប្រព័ន្ធទាំងពីរ។ ធនាគារជាតិនៃកម្ពុជា ក៏នឹងពិនិត្យឡើងវិញនូវការកំណត់តម្លៃប្រតិបត្តិការក្នុងប្រព័ន្ធហ្វាសថ្មីនេះ ដើម្បីកាត់បន្ថយគម្លាតរវាងតម្លៃប្រតិបត្តិការក្នុងប្រព័ន្ធហ្វាស និងទំហំប្រតិបត្តិការនៃប្រព័ន្ធទូទាត់សងប្រាក់តម្លៃធំ។

**៣៣៧-** ដំណាក់កាលក្នុងការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ រួមមាន: (១) ការទូទាត់សងប្រាក់ជាអេឡិចត្រូនិកសម្រាប់ប្រតិបត្តិការមូលបត្រ (២) ប្រព័ន្ធទូទាត់ដុលភ្លាមៗសម្រាប់ការទូទាត់សងប្រាក់តម្លៃធំ (៣) បន្តអនុញ្ញាតឲ្យគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ ដូចជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ បើកគណនីទូទាត់ (៤) ការអភិវឌ្ឍប្រតិបត្តិការទីផ្សាររូបិយវត្ថុសម្រាប់ធនាគារ រួមទាំងប្រតិបត្តិការមូលបត្ររដ្ឋ និង (៥) ការលើកកម្ពស់សេវាទូទាត់សងប្រាក់។

**៣៣៨- ស្តង់ដាក្នុងវិស័យហិរញ្ញវត្ថុ**: ប្រទេសកម្ពុជានឹងលើកកម្ពស់ និងប្រើប្រាស់យ៉ាងសកម្មនូវស្តង់ដាអន្តរជាតិក្នុងវិស័យហិរញ្ញវត្ថុ។

**៣៣៩-** ប្រទេសកម្ពុជាកំពុងប្រើប្រាស់ស្តង់ដាមួយសម្រាប់អត្តសញ្ញាណបណ្ណ និងពិនិត្យលើការប្រើប្រាស់លេខកូដកំណត់អត្តសញ្ញាណគតិយុត្តរបស់អង្គភាព (Legal Entity Identifier) ជាសកលដោយផ្អែកលើ ISO17442 ក្នុងប្រព័ន្ធដែលអនុវត្តសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម និងអត្តសញ្ញាណរបស់អង្គភាពហិរញ្ញវត្ថុ។ ប្រព័ន្ធ និងឃ្លាំងផ្ទុកទិន្នន័យ (Database) រួម រៀបចំដោយក្រសួងពាណិជ្ជកម្មសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម ក៏នឹងត្រូវប្រើប្រាស់សម្រាប់ការកំណត់អត្តសញ្ញាណ និងការចុះបញ្ជីចំពោះអ្នកចូលរួមទីផ្សារហិរញ្ញវត្ថុដទៃទៀត ព្រមទាំងបើកលទ្ធភាពឲ្យស្ថាប័នដទៃទៀតអាចចូលប្រើប្រាស់ប្រព័ន្ធនេះតាមមធ្យោបាយដាច់ដោយឡែក និងប្រកបដោយសុវត្ថិភាព។

**៣៤០- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (AML/CFT)**: គ្រប់ស្ថាប័នពាក់ព័ន្ធដែលទទួលខុសត្រូវលើការងារនេះ នឹងតាមដានព្រមទាំងធានាថាច្បាប់ ឬបទប្បញ្ញត្តិថ្មីៗ ឬដែលនឹងរៀបចំ ឬធ្វើវិសោធនកម្ម ស្តីពីដំណើរការ ឬវិធីសាស្ត្រទូទាត់សងប្រាក់ថ្មី នឹងរួមបញ្ចូលខ្លឹមសារពាក់ព័ន្ធនឹងកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មស្របតាមច្បាប់ និងប្រកាសស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**៣៤១- ការផាត់ទាត់មូលបត្រ**: ធនាគារជាតិនៃកម្ពុជា **គ.ម.ក.** និង ផ.ម.ក. នឹងធ្វើការជាមួយគ្នា ដើម្បីសម្រួលដល់ការទូទាត់នៃការជួញដូរនៅ ផ.ម.ក. ឲ្យមានភាពប្រសើរឡើងតាមរយៈការភ្ជាប់ប្រព័ន្ធទូទាត់របស់ធនាគារជាតិនៃកម្ពុជា និងការប្រើប្រាស់គណនីទូទាត់របស់ធនាគារពាណិជ្ជដែលមានចុះបញ្ជីស្រាប់នៅធនាគារជាតិនៃកម្ពុជា។

**៣៤២- ការទូទាត់ និងរក្សាទុកជាតិ**: ស.ហ.វ. ធនាគារជាតិនៃកម្ពុជា និង **គ.ម.ក.** នឹងសហការរៀបចំផែនការ និងដាក់ឲ្យអនុវត្តនូវរចនាសម្ព័ន្ធដ៏ល្អបំផុតមួយសម្រាប់គាំទ្រដល់ការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ។

## XI. សមាហរណកម្ម

### ក. សេចក្តីផ្តើម

**៣៤៣-** កម្ពុជា គឺជាសមាជិកអាស៊ាន ហើយបានប្តេជ្ញាអនុវត្តតាមផែនការអភិវឌ្ឍសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ឆ្នាំ២០២៥។ គ្រប់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល មានតួនាទីក្នុងការអភិវឌ្ឍដើម្បីរួមចំណែកដល់ការសម្រេចបានគោលដៅរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងបង្កើនសុខុមាលភាពជូនប្រជាពលរដ្ឋ។

**៣៤៤-** មូលនិធិរូបិយវត្ថុអន្តរជាតិ បានកត់សម្គាល់ពីភាពរីកលូតលាស់នៃសេដ្ឋកិច្ចរបស់កម្ពុជា និងបាន ជំរុញឲ្យអាជ្ញាធរពាក់ព័ន្ធបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងកំណើន ប្រកបដោយបរិយាបន្ន។ កិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើនភាពប្រកួតប្រជែង ត្រូវផ្តោតសំខាន់លើការ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍជនបទ ការពង្រឹងសមត្ថភាពធនធានមនុស្ស និងការធ្វើឲ្យប្រសើរ ឡើងនៃបរិស្ថានវិនិយោគ តាមរយៈការកាត់បន្ថយចំណាយក្នុងការប្រកបអាជីវកម្ម។

**៣៤៥-** រាជរដ្ឋាភិបាលបានរៀបចំកម្មវិធីអភិវឌ្ឍន៍ប្រកបដោយភាពប្រទាក់ក្រឡា ដើម្បីធានាថាកម្មវិធី អភិវឌ្ឍទាំងអស់មានភាពពាក់ព័ន្ធនិងសមស្របប្រកបដោយប្រសិទ្ធផល ប្រសិទ្ធភាព និងចីរភាព ព្រមទាំង មានការអនុវត្តប្រកបដោយភាពទទួលខុសត្រូវ ទាំងផ្នែកវិជ្ជាជីវៈ និងឥទ្ធិពលលើបរិស្ថាន។

**៣៤៦-** ផ្នែកនីមួយៗនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ បានគិតគូរអំពីបញ្ហាដែលពាក់ព័ន្ធនឹង វិស័យហិរញ្ញវត្ថុ។ វិស័យហិរញ្ញវត្ថុ ដែលមានតួនាទីជួយសម្រួលដល់ការអភិវឌ្ឍលើគ្រប់វិស័យ ពិតជា មានសារៈសំខាន់ ហើយតួនាទីនេះតម្រូវឲ្យយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ មានភាពស្របគ្នាជា មួយនឹងការអភិវឌ្ឍសង្គមធនធានមនុស្ស យែនឌ័រការអភិវឌ្ឍជនបទ ពាណិជ្ជកម្ម សមាហរណកម្ម ក្នុងតំបន់ និងកំណើនសេដ្ឋកិច្ចជាតិ។

**៣៤៧-** ការរៀបចំផែនការសកម្មភាព ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ គឺជាបញ្ហាប្រឈម មួយ ហើយការរៀបចំផែនការ និងយុទ្ធសាស្ត្រនេះឲ្យស្របនឹងវិស័យផ្សេងៗទៀត បានក្លាយជាបញ្ហា ប្រឈមកាន់តែខ្លាំង។ សកម្មភាព និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ដែលអាចចូលរួមចំណែក ដល់ការសម្រេចបានគោលដៅរបស់ថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់ត្រូវតែផ្តល់អាទិភាពខ្ពស់ ប្រសិនជាអាច។

## ខ. សមាហរណកម្មគោលនយោបាយសង្គម

**៣៤៨-** រាជរដ្ឋាភិបាល កំពុងបន្តអនុវត្តយ៉ាងសកម្មនូវគោលនយោបាយគាំពារសង្គម ដើម្បីដោះស្រាយ បញ្ហាប្រឈមមួយចំនួន ដូចជា ចំនួនប្រជាជនដែលមានវ័យចំណាស់ អាយុកាលមធ្យម ភាពក្រីក្រ និង វិសមភាពដែលមានកម្រិតខ្ពស់ សេដ្ឋកិច្ចក្រៅប្រព័ន្ធដែលមានទំហំធំ និងការបង្កើនប្រាក់ឈ្នួល។

**៣៤៩-** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដឹកនាំបង្កើត និងអនុវត្តក្របខ័ណ្ឌសម្រាប់ការអភិវឌ្ឍកិច្ចការ នេះដោយមានការចូលរួមពីក្រសួងស្ថាប័ន និងគណៈកម្មាធិការពាក់ព័ន្ធ។

**៣៥០-** នៅក្នុងវិស័យសោធន យុទ្ធសាស្ត្រនេះបង្ហាញអំពីតួនាទីកាន់តែសំខាន់ក្នុងការគ្រប់គ្រង និង អភិវឌ្ឍមូលនិធិដើម្បីការបំពេញកាតព្វកិច្ចសុខុមាលភាពសង្គម។

**៣៩១-** ជាការពិត វិស័យសោធននេះ គឺជាវិស័យដ៏សំខាន់ក្នុងការធ្វើសមាហរណកម្មជាមួយនឹងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ដោយសារតែមូលនិធិពីវិស័យសោធនបង្ហាញពីការសន្សំរបស់ប្រជាពលរដ្ឋក៏ដូចជាការផ្តល់វិភាគទានរបស់រាជរដ្ឋាភិបាល និងនិយោជកទៅក្នុងមូលនិធិនេះផងដែរ។

**៣៩២-** ដើម្បីបំពេញកាតព្វកិច្ចទូទាត់ទំនិញ និងសេវាកម្មនៅក្នុងសេដ្ឋកិច្ចនៅពេលដែលមានការដកប្រាក់មូលនិធិទាំងនេះនឹងត្រូវបង្វែរទៅជាហិរញ្ញប្បទានសម្រាប់ការវិនិយោគ ដើម្បីជំរុញកំណើនមូលនិធិទាំងនេះស្របជាមួយនឹងកំណើនសេដ្ឋកិច្ចជាតិ។ ដូច្នេះ ពួកគេត្រូវការឱកាសវិនិយោគនៅក្នុងសកម្មភាពសេដ្ឋកិច្ចជាតិ ដែលអាចអនុវត្តបានដោយមូលនិធិនេះ ប្រកបដោយប្រសិទ្ធភាពតាមរយៈការវិនិយោគលើមូលបត្រកម្មសិទ្ធិនៅក្នុងប្រទេសតំបន់ និងសកម្មភាពសេដ្ឋកិច្ចក្រៅប្រទេស។

**៣៩៣-** នៅកម្ពុជា កិច្ចការនេះទាមទារការអភិវឌ្ឍទីផ្សារមូលធន ដែលមានសន្ទនីយភាព និងពិពិធកម្ម។ ការអភិវឌ្ឍទីផ្សារនេះ គឺជាអាទិភាពនៅក្នុងវិស័យហិរញ្ញវត្ថុ។

**៣៩៤-** ដូច្នេះ ការអនុវត្តកម្មវិធីគោលនយោបាយសង្គម ត្រូវធ្វើសមាហរណកម្មជាមួយសមិទ្ធផលនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ។

## គ. ការធ្វើសមាហរណកម្មនៅក្នុងវិស័យ និងតំបន់

**៣៩៥-** ថ្នាក់ដឹកនាំអាស៊ាន បានអនុម័តផែនការអភិវឌ្ឍសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ឆ្នាំ២០២៥ នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី២៧ កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅទីក្រុងកូឡាឡាំពួ ប្រទេសម៉ាឡេស៊ី។ ផែនការអភិវឌ្ឍនេះ បានកំណត់គោលដៅតាមរយៈយុទ្ធសាស្ត្រគោលនយោបាយសម្រាប់ AEC ឆ្នាំ២០១៦ ដល់២០២៥។

**៣៩៦-** ផែនការអភិវឌ្ឍនេះ គឺស្របតាមការងារដែលបានអនុវត្តក្នុងផែនការអភិវឌ្ឍឆ្នាំ២០១៥ ដែលមានចក្ខុវិស័យដូចខាងក្រោម៖

- លុបបំបាត់ពន្ធនិងការសម្របសម្រួលការធ្វើពាណិជ្ជកម្ម
- ជំរុញការអនុវត្តរបៀបវារៈសេរីភាវូបនីយកម្មពាណិជ្ជកម្មផ្នែកសេវា
- សេរីភាវូបនីយកម្មនិងការសម្របសម្រួលការវិនិយោគ
- ពង្រឹងនិងសុខដុមភាវូបនីយកម្មក្របខ័ណ្ឌបទប្បញ្ញត្តិទីផ្សារមូលធន
- សម្របសម្រួលការចល័តពលកម្មជំនាញ
- លើកកម្ពស់ការអភិវឌ្ឍក្នុងក្របខ័ណ្ឌតំបន់លើផ្នែកគោលនយោបាយប្រកួតប្រជែង កិច្ចការពារអ្នកប្រើប្រាស់និងកម្មសិទ្ធិបញ្ញា
- លើកកម្ពស់ការតភ្ជាប់ទំនាក់ទំនងគ្នា
- កាត់បន្ថយគម្លាតនៃការអភិវឌ្ឍ និង
- ពង្រឹងទំនាក់ទំនងរវាងអាស៊ាននិងដៃគូខាងក្រៅ។

**៣៩៧-** ចក្ខុវិស័យនៃការធ្វើសមាហរណកម្មវិស័យហិរញ្ញវត្ថុឆ្នាំ២០២៥ មានគោលដៅយុទ្ធសាស្ត្រចំនួន៣ គឺសមាហរណកម្មហិរញ្ញវត្ថុ បរិយាបន្នហិរញ្ញវត្ថុ និងស្ថិរភាពហិរញ្ញវត្ថុ និងវិស័យពាក់ព័ន្ធគ្នាចំនួន៣ (សេរីភាវូបនីយកម្មគណនីមូលធន ប្រព័ន្ធទូទាត់ និងការកសាងសមត្ថភាព)។

**៣៩៨-** កម្ពុជា បានបង្ហាញឲ្យឃើញពីដំណើរការដ៏ល្អក្នុងការបង្កើតក្របខ័ណ្ឌ និងសេវាហិរញ្ញវត្ថុនៅក្នុងយុទ្ធសាស្ត្រនេះ ហើយយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនេះ បានកំណត់ពីសកម្មភាពដែលត្រូវបន្តនិងសកម្មភាពថ្មីៗបន្ថែមទៀតដែលចាំបាច់ត្រូវអនុវត្ត។

**៣៩៩-** ខណៈដែលការអភិវឌ្ឍប្រព័ន្ធកំពុងបន្តដំណើរការស្របតាមស្តង់ដានៅក្នុងតំបន់ដើម្បីសម្រួលដល់ការទទួលស្គាល់ការធ្វើសមាហរណកម្មសេវា ការយកចិត្តទុកដាក់ត្រូវផ្តោតលើការធ្វើសុខដុមនីយកម្មក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិនៅក្នុងវិស័យហិរញ្ញវត្ថុ។

# ជំពូក ៥
# ការកសាងសមត្ថភាព

## I. ទិដ្ឋភាពទូទៅ

**៣៦០-** ការកសាងសមត្ថភាពធនធានមនុស្ស គឺជាអាទិភាពសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា។ ភាពខ្វះចន្លោះជាមូលដ្ឋានដែលបន្ទុចបង្អាក់ដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា ក៏ដូចជានៅប្រទេសកំពុងអភិវឌ្ឍផ្សេងៗទៀត រួមមាន ក្របខ័ណ្ឌស្ថាប័ន និងពាណិជ្ជកម្មមិនទាន់មានការរីកចម្រើន កង្វះជំនាញបច្ចេកទេស និងសមត្ថភាពធនធានមនុស្សនៅមានកម្រិត។ កម្ពុជានៅមានបញ្ហាប្រឈមក្នុងការស្វែងរកអ្នកមានជំនាញ និងការបណ្តុះបណ្តាលសមស្របដើម្បីបំពេញតម្រូវការកើនឡើងនៃវិស័យហិរញ្ញវត្ថុ។ ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុនេះបានដាក់សម្ពាធលើការផ្តល់សេវាអតិថិជន និងបញ្ញត្តិកម្ម ដែលតម្រូវឲ្យមានការយកចិត្តទុកដាក់ក្នុងការកសាងសមត្ថភាព។

**៣៦១-** គោលនយោបាយបើកចំហទីផ្សាររបស់រាជរដ្ឋាភិបាល បានទាក់ទាញធនាគារិកបរទេស និងនាយកប្រតិបត្តិធានារ៉ាប់រង ដែលមានបទពិសោធន៍ជាច្រើន។ ដូចនេះ អ្នកគ្រប់គ្រងជាន់ខ្ពស់ភាគច្រើនជាធនាគារិក ដែលមានបទពិសោធ និងសមត្ថភាព។ ប៉ុន្តែ គ្រឹះស្ថានធនាគារមួយចំនួននៅមានការលំបាកក្នុងការស្វែងរកអ្នកគ្រប់គ្រងថ្នាក់កណ្តាលនិងថ្នាក់ក្រោម ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់។ ដូច្នេះ បុគ្គលិកភាគច្រើន ថ្នាក់កណ្តាល និងថ្នាក់ក្រោម ទាមទារការបណ្តុះបណ្តាលជំនាញប្រតិបត្តិការធនាគារ ឬធានារ៉ាប់រងជាមូលដ្ឋានបន្ថែមទៀត។ គ្រឹះស្ថានធនាគារនិងក្រុមហ៊ុនធានារ៉ាប់រងភាគច្រើនបានរៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមខាងលើ ដែលវគ្គនេះត្រូវបានផ្តល់ដោយវិទ្យាស្ថានធនាគារកម្ពុជា មណ្ឌលសិក្សាបច្ចេកទេសធនាគាររបស់ធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានក្នុងស្រុកផ្សេងទៀត។

**៣៦២-** ធនាគារជាតិនៃកម្ពុជា កំពុងលើកកម្ពស់ និងពង្រឹងសមត្ថភាពត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុតាមរយៈជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក និងរតនាគារសហរដ្ឋអាមេរិក ជាដើម។ អគ្គនាយកដ្ឋានត្រួតពិនិត្យនៃធនាគារជាតិនៃកម្ពុជាបានខិតខំប្រឹងប្រែងបណ្តុះបណ្តាល និងកសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យ។

**៣៦៣-** និយតករធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងបានបណ្តុះបណ្តាលបុគ្គលិកក្នុងស្រុក ហើយក៏មានមន្ត្រីជាន់ខ្ពស់មួយចំនួនបានទទួលការបណ្តុះបណ្តាលនៅក្រៅប្រទេស។ វិទ្យាស្ថានបរទេសមួយចំនួនបានមកបើកវគ្គបណ្តុះបណ្តាលជំនាញវិស័យនេះនៅកម្ពុជា និងដោយមានជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី ការិយាល័យបញ្ញត្តិកម្មធានារ៉ាប់រងបានរៀបចំកម្មវិធីកសាងសមត្ថភាពបច្ចេកទេស។

## II. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

**៣៦៤-** ក្នុងដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ កម្ពុជាចាំបាច់ត្រូវបន្តគាំទ្រជាប្រចាំដល់ការកសាងសមត្ថភាព។ ការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យមានការរីកចម្រើន ដូចជា ផ្នែកបទប្បញ្ញត្តិ និងការត្រួតពិនិត្យ ប្រព័ន្ធទូទាត់សងប្រាក់ ការផ្សព្វផ្សាយទិន្នន័យស្ថិតិនិងព័ត៌មានការប្រើប្រាស់បច្ចេកទេសព័ត៌មាន និងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

**៣៦៥-** ការធ្វើបច្ចុប្បន្នកម្ម និងការលើកកម្ពស់សមត្ថភាពជំនាញជាការងារអាទិភាព នឹងនៅតែសំខាន់សម្រាប់អភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុឲ្យកាន់តែស៊ីជម្រៅ និងដើម្បីបង្ការហានិភ័យដែលអាចកើតមានថ្មីៗទៀត។ បញ្ញត្តិករវិស័យហិរញ្ញវត្ថុត្រូវបន្តពង្រឹងនិងលើកកម្ពស់សមត្ថភាពមន្ត្រីត្រួតពិនិត្យរបស់ខ្លួនឲ្យមានសមត្ថភាពអាចគ្រប់គ្រងការអភិវឌ្ឍទាំងនេះប្រកបដោយប្រសិទ្ធភាព។

**៣៦៦-** ហេតុផល៣ដែលតម្រូវឲ្យអភិវឌ្ឍនិងលើកកម្ពស់សមត្ថភាព រួមមាន៖

- ការកើនឡើងយ៉ាងឆាប់រហ័សនៃទំហំធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនធានារ៉ាប់រង
- ការដាក់ឲ្យប្រើប្រព័ន្ធផលិតផល និងឧបករណ៍ថ្មីនៅពេលទីផ្សារហិរញ្ញវត្ថុរីកចម្រើន និងមានពិពិធកម្ម និង
- ការបាត់បង់បុគ្គលិកដែលបានបណ្តុះបណ្តាលរបស់រាជរដ្ឋាភិបាលទៅវិស័យឯកជនដោយសារមានការផ្តល់ការលើកទឹកចិត្តប្រសើរជាងពីផ្នែកឯកជន។

## III. យុទ្ធសាស្ត្រនិងផែនការអនាគត

**៣៦៧-** រាជរដ្ឋាភិបាលនឹងបន្តកសាងសមត្ថភាពនៅគ្រប់ផ្នែកនៃវិស័យហិរញ្ញវត្ថុ។ ការវាយតម្លៃពីតម្រូវការក្នុងផ្នែកនីមួយៗក្នុងវិស័យហិរញ្ញវត្ថុត្រូវធ្វើឡើង ដើម្បីផ្តោតលើតម្រូវការនៃការបណ្តុះបណ្តាល។ ដោយផ្អែកលើការវាយតម្លៃនេះ រាជរដ្ឋាភិបាលនឹងរៀបចំផែនការបណ្តុះបណ្តាលជំនាញជាយុទ្ធសាស្ត្រក្នុងការបែងចែកធនធាន ថវិកា និងការអនុវត្ត។ ក្រសួងនិងស្ថាប័នពាក់ព័ន្ធវិស័យហិរញ្ញវត្ថុ នឹងបន្តពិភាក្សាជាមួយក្រសួងអប់រំ យុវជន និងកីឡា គ្រឹះស្ថានឧត្តមសិក្សា និងវិទ្យាស្ថានបណ្តុះបណ្តាល ដើម្បីឲ្យយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិការរបស់ខ្លួនស្របនឹងផែនការបណ្តុះបណ្តាលផ្នែកជំនាញជាយុទ្ធសាស្ត្រសម្រាប់វិស័យហិរញ្ញវត្ថុ។ កិច្ចពិភាក្សានឹងរួមមានការពិនិត្យឡើងវិញនូវកម្មវិធីសិក្សា វិធីសាស្ត្រគរុកោសល្យ និងការវាយតម្លៃសមត្ថភាពសិស្សនិស្សិត។

# ជំពូក៦: ផែនការសកម្មភាពអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥

| គោលនយោបាយអភិវឌ្ឍន៍ | គោលដៅរយៈពេលខ្លី ២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម ២០១៩-២០២២ | គោលដៅរយៈពេលវែង ២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| **I. វិស័យធនាគារ** | | | | |
| **ក. ប្រតិបត្តិការធនាគារ** | | | | |
| **គោលនយោបាយ: ស្ថិរភាពហិរញ្ញវត្ថុ** | | | | |
| ១. ការតាមដានស្ថិរភាពហិរញ្ញវត្ថុ និងប្រព័ន្ធផ្តល់សញ្ញាជាមុន | • ពង្រឹងអង្គភាពតាមដានស្ថិរភាពហិរញ្ញវត្ថុ និងកែលម្អរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុ។ | • លើកកម្ពស់អនុសាសន៍ជាគោលនយោបាយ ដើម្បីគ្រប់គ្រងហានិភ័យចំពោះស្ថិរភាពហិរញ្ញវត្ថុឲ្យបានប្រសើរ។ | • អភិវឌ្ឍក្របខ័ណ្ឌទំនាក់ទំនងដើម្បីលើកកម្ពស់ស្ថិរភាពហិរញ្ញវត្ថុ។ | - ធនាគារជាតិនៃកម្ពុជា |
| | • បង្កើតប្រព័ន្ធផ្តល់ព័ត៌មានជាមុន។ | • អនុវត្តប្រព័ន្ធផ្តល់ព័ត៌មានជាមុន។ | • កែលម្អប្រព័ន្ធផ្តល់ព័ត៌មានជាមុន។ | - ធនាគារជាតិនៃកម្ពុជា<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- គណៈកម្មការមូលបត្រកម្ពុជា |
| | • បង្កើតក្រុមការងារបច្ចេកទេសរួមគ្នាលើស្ថិរភាពហិរញ្ញវត្ថុ។ | • បង្កើតគណៈកម្មាធិការស្ថិរភាពហិរញ្ញវត្ថុថ្នាក់ជាតិ។ | | - ធនាគារជាតិនៃកម្ពុជា<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- គណៈកម្មការមូលបត្រកម្ពុជា |
| ២. ក្របខ័ណ្ឌបង្ការ និងគ្រប់គ្រងវិបត្តិ | • បង្កើតក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ និងគ្រប់គ្រងវិបត្តិជាផ្លូវការ រួមបញ្ចូលទាំងជម្រើសហិរញ្ញប្បទាន។ | • បន្តធ្វើលំហាត់សាកល្បងក្នុងការគ្រប់គ្រងវិបត្តិ (Crisis Simulation Exercises)។ | | - ធនាគារជាតិនៃកម្ពុជា<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- គណៈកម្មការមូលបត្រកម្ពុជា |

| គោលនយោបាយអភិវឌ្ឍន៍ | គោលដៅរយៈពេលខ្លី ២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម ២០១៩-២០២២ | គោលដៅរយៈពេលវែង ២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| | • សិក្សាលទ្ធភាពបង្កើតយន្តការការពារអ្នកដាក់ប្រាក់បញ្ញើ។ | • ធ្វើសេចក្ដីព្រាងច្បាប់ ឬបទប្បញ្ញត្តិស្ដីពីកិច្ចការពារអ្នកដាក់ប្រាក់បញ្ញើ។ | | - ធនាគារជាតិនៃកម្ពុជា (ស្ថាប័នដឹកនាំ)<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| | • សិក្សាលទ្ធភាពបង្កើតក្របខ័ណ្ឌដោះស្រាយគ្រះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានបញ្ហា។ | • ធ្វើសេចក្ដីព្រាងច្បាប់ ឬបទប្បញ្ញត្តិស្ដីពីក្របខ័ណ្ឌដោះស្រាយគ្រះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានបញ្ហា។ | • អនុម័តច្បាប់ ឬបទប្បញ្ញត្តិ ស្ដីពីក្របខ័ណ្ឌ ដោះស្រាយគ្រះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានបញ្ហា។ | - ធនាគារជាតិនៃកម្ពុជា |
| **៣. ការជំរុញការប្រើប្រាស់ប្រាក់រៀល** | • អនុម័តគោលនយោបាយជាតិដើម្បីជំរុញការប្រើប្រាស់ប្រាក់រៀល។ | • អភិវឌ្ឍទីផ្សារ និងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការជំរុញការប្រើប្រាស់ប្រាក់រៀលបន្ថែមទៀត។ | • កែលម្អលក្ខខណ្ឌនានាដើម្បីលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ។ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ធនាគារជាតិនៃកម្ពុជា<br>- ស្ថាប័នពាក់ព័ន្ធ |
| **៤. ធ្វើឲ្យប្រសើរឡើងសុវត្ថិភាពនិងវត្ថុបញ្ចាំ** | • បណ្ណកម្មសិទ្ធិដីៈ រៀបចំផែនការដើម្បីពន្លឿនការផ្ដល់បណ្ណកម្មសិទ្ធិរឹង និងកាត់បន្ថយចំណាយ។<br>• បណ្ណសហកម្មសិទ្ធិៈ ចេញសេចក្ដីណែនាំទាក់ទងនឹងបណ្ណកម្មសិទ្ធិ។ | • អនុវត្តផែនការដើម្បីពន្លឿនការផ្ដល់បណ្ណកម្មសិទ្ធិរឹងនិងលុបបំបាត់ចោលទាំងស្រុងការប្រាក់សុវត្ថិភាពចុះបញ្ជីក្រៅផ្លូវការ។ | | - ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ |

| គោលនយោបាយ អភិវឌ្ឍន៍ | គោលដៅរយៈពេលខ្លី ២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម ២០១៩-២០២២ | គោលដៅរយៈពេលវែង ២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| | • ការចុះបញ្ជីប្រតិបត្តិការដែលមានកិច្ចធានា: អភិវឌ្ឍផែនការក្នុងការចុះបញ្ជីសិទ្ធិប្រាតិភោគសម្រាប់អចលនទ្រព្យ និងទ្រព្យអរូបី ក្នុងប្រព័ន្ធចុះបញ្ជីប្រតិបត្តិការដែលមានកិច្ច-ធានា។ | • អនុវត្តការចុះបញ្ជីសិទ្ធិប្រាតិភោគសម្រាប់អចលនទ្រព្យ និងទ្រព្យអរូបិយក្នុងប្រព័ន្ធចុះបញ្ជីប្រតិបត្តិការដែលមានកិច្ចធានា។ | | - ក្រសួងពាណិជ្ជកម្ម |
| | • អត្តសញ្ញាណបណ្ណ: ពន្លឿនការផ្តល់អត្តសញ្ញាណបណ្ណជាតិ។ | | | - ក្រសួងមហាផ្ទៃ |
| **គោលនយោបាយ៖ ធ្វើឲ្យការប្រព្រឹត្តទៅនៃទីផ្សារនិងការត្រួតពិនិត្យប្រសើរឡើង** | | | | |
| **៥. ការអនុលោមតាមគោល-ការណ៍ស្នូលបាសែលស្តីពីការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាព** | • ពង្រឹងការអនុលោមតាមគោលការណ៍ស្នូលបាសែល។ | • បន្តពង្រឹងការអនុលោមតាមគោលការណ៍ស្នូលបាសែល។ | | - ធនាគារជាតិនៃកម្ពុជា |
| **៦. ប្រព័ន្ធទូទាត់សងប្រាក់** | • ពង្រឹងការត្រួតពិនិត្យ និងគ្រប់គ្រងប្រព័ន្ធ និងសេវាទូទាត់សងប្រាក់។ | | | - ធនាគារជាតិនៃកម្ពុជា |

| គោលនយោបាយអនិវឌ្ឍន៍ | គោលដៅរយៈពេលខ្លី ២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម ២០១៩-២០២២ | គោលដៅរយៈពេលវែង ២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| **៧. កិច្ចការពារអ្នកប្រើប្រាស់** | • ពង្រឹងកិច្ចការពារអ្នកប្រើប្រាស់ដោយផ្តោតលើៈ ១/- ការផ្តល់ឥណទាន ២/- ការផ្សព្វផ្សាយពាណិជ្ជកម្ម ៣/- បណ្តឹង ៤/- កម្រៃ ៥/- អត្រាការប្រាក់ និង ៦/- ការប្រមូលឥណទាន។ | • អនុវត្តគោលការណ៍ និងបទប្បញ្ញត្តិស្តីពីកិច្ចការពារអ្នកប្រើប្រាស់។ | • វាយតម្លៃក្របខ័ណ្ឌបទប្បញ្ញត្តិ និងកែសម្រួលបទប្បញ្ញត្តិនានាតាមការចាំបាច់។ | - ធនាគារជាតិនៃកម្ពុជា |
| **៨. ភតិសន្យាហិរញ្ញវត្ថុ** | • ពង្រឹងយន្តការបទប្បញ្ញត្តិសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុដែលផ្តល់ឥណទានភតិសន្យា។ | | | - ធនាគារជាតិនៃកម្ពុជា |
| **៩. អាជីវករប្តូរប្រាក់** | • ពង្រឹងការត្រួតពិនិត្យអាជីវករប្តូរប្រាក់។ | | | - ធនាគារជាតិនៃកម្ពុជា |
| **១០. ប្រតិបត្តិការបង់រំលស់** | • រៀបចំយន្តការ និងបទ-ប្បញ្ញត្តិ ដើម្បីគ្រប់គ្រងប្រតិបត្តិការបង់រំលស់។ | • ពង្រឹងការអនុវត្តបទប្បញ្ញត្តិ<br>• បន្តពង្រឹងការគ្រប់គ្រងប្រតិបត្តិ-ការបង់រំលស់។ | | - ធនាគារជាតិនៃកម្ពុជា<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ស្ថាប័នពាក់ព័ន្ធផ្សេងទៀត |

| គោលនយោបាយ<br>អភិវឌ្ឍន៍ | គោលដៅរយៈពេលខ្លី<br>២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម<br>២០១៩-២០២២ | គោលដៅរយៈពេលវែង<br>២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| ១១. ពន្ធដារនៅក្នុងប្រតិបត្តិ-ការធនាគារ | • កំណត់ដំណោះស្រាយចំពោះបញ្ហាពន្ធដារពាក់ព័ន្ធនឹងការអនុវត្តបទប្បញ្ញត្តិប្រុងប្រយ័ត្ន។ | • រៀបចំបទប្បញ្ញត្តិសម្រាប់កំណត់មូលដ្ឋានគិតពន្ធឲ្យបានច្បាស់-លាស់សម្រាប់អនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ | | - ធនាគារជាតិនៃកម្ពុជា<br>- អគ្គនាយកដ្ឋានពន្ធដារ |
| **គោលនយោបាយ: បរិយាបន្នហិរញ្ញវត្ថុ** | | | | |
| ១២. បរិយាបន្នហិរញ្ញវត្ថុ | • រៀបចំយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ។ | • អនុម័ត និងអនុវត្តយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ។ | | - រាជរដ្ឋាភិបាល (ស្ថាប័នដឹកនាំ : ធនាគារជាតិនៃកម្ពុជា) |
| ១៣. គម្រោងធានាឥណទាន | • បង្កើតគោលនយោបាយ និងប្រឹក្សាលើការបង្កើតគម្រោងធានាឥណទាន។ | • ច្បាប់ និងបទប្បញ្ញត្តិដើម្បីអនុវត្តគម្រោងធានាឥណទាន។ | | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| **ខ. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** | | | | |
| **គោលនយោបាយ: យុទ្ធសាស្ត្រជាតិមីក្រូហិរញ្ញវត្ថុ** | | | | |
| ១៤. ធ្វើបច្ចុប្បន្នកម្មយុទ្ធ-សាស្ត្រជាតិមីក្រូហិរញ្ញវត្ថុ | • អនុម័តយុទ្ធសាស្ត្រជាតិមីក្រូ-ហិរញ្ញវត្ថុថ្មី។ | • បន្តអនុវត្តយុទ្ធសាស្ត្រជាតិមីក្រូ-ហិរញ្ញវត្ថុ។ | • ធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រជាតិមីក្រូហិរញ្ញវត្ថុតាមការចាំបាច់។ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ធនាគារជាតិនៃកម្ពុជា |

| គោលនយោបាយអភិវឌ្ឍន៍ | គោលដៅរយៈពេលខ្លី ២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម ២០១៩-២០២២ | គោលដៅរយៈពេលវែង ២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| **គោលនយោបាយ: ការប្រតិបត្តិនិងការត្រួតពិនិត្យទីផ្សារ** | | | | |
| **១៥. បទប្បញ្ញត្តិគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** | • បទប្បញ្ញត្តិគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ: ពង្រឹងការអនុលោមតាមគោលការណ៍ស្នូលបាសែលស្ដីពីការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាពសម្រាប់សកម្មភាពមីក្រូហិរញ្ញវត្ថុ។ | • បន្តពង្រឹងការអនុលោមតាមគោលការណ៍ស្នូលបាសែលស្ដីពីការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាពសម្រាប់សកម្មភាពមីក្រូហិរញ្ញវត្ថុ។ | | - ធនាគារជាតិនៃកម្ពុជា |
| **១៦.កិច្ចការពារអ្នកប្រើប្រាស់** | • ពង្រឹងកិច្ចការពារអ្នកប្រើប្រាស់ដោយផ្ដល់អាទិភាពលើ៖ ១/-ការឲ្យខ្ចី ២/-ការផ្សព្វផ្សាយពាណិជ្ជកម្ម ៣/-បណ្ដឹង ៤/-កម្រៃ ៥/-អត្រាការប្រាក់ និង ៦/-ការអនុវត្តលើការប្រមូលឥណទាន។ | • អនុវត្តគោលការណ៍ និងបទប្បញ្ញត្តិស្ដីពីកិច្ចការពារអ្នកប្រើប្រាស់។ | • វាយតម្លៃក្របខ័ណ្ឌបទប្បញ្ញត្តិ និងកែសម្រួលបទប្បញ្ញត្តិនានាដែលចាំបាច់។ | - ធនាគារជាតិនៃកម្ពុជា |

| គោលនយោបាយ អភិវឌ្ឍន៍ | គោលដៅរយៈពេលខ្លី ២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម ២០១៩-២០២២ | គោលដៅរយៈពេលវែង ២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| **គ. ទីផ្សារអន្តរធនាគារ/រូបិយវត្ថុ** | | | | |
| **គោលនយោបាយ: លើកទឹកចិត្តការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុជារូបិយវត្ថុជាតិ** | | | | |
| ១៧. មូលបត្ររដ្ឋ | • អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំនីតិវិធីប្រតិបត្តិការសម្រាប់មូលបត្ររដ្ឋ។ | • ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិចារណាបោះផ្សាយ និងចុះបញ្ជីសាធារណៈនូវមូលបត្ររដ្ឋ។ | | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ស្ថាប័នដឹកនាំ)<br>- ធនាគារជាតិនៃកម្ពុជា<br>- គណៈកម្មការមូលបត្រកម្ពុជា |
| | • ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំយុទ្ធសាស្ត្របោះផ្សាយមូលបត្ររដ្ឋ។ | | | |
| | • រៀបចំបទប្បញ្ញត្តិសម្រាប់ការបោះផ្សាយនិងជួញដូរមូលបត្ររដ្ឋ។ | | | |

| គោលនយោបាយអភិវឌ្ឍន៍ | គោលដៅរយៈពេលខ្លី ២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម ២០១៩-២០២២ | គោលដៅរយៈពេលវែង ២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| **ឃ. ភតិសន្យាហិរញ្ញវត្ថុ** | | | | |
| **គោលនយោបាយ: លើកកម្ពស់ទីផ្សារភតិសន្យាហិរញ្ញវត្ថុ** | | | | |
| ១៨.រៀបចំបទប្បញ្ញត្តិច្បាប់ទាំងអស់ឲ្យមានភាពស្របគ្នាសម្រាប់ចលនទ្រព្យដែលបានជួលចំពោះការផ្តល់ហិរញ្ញប្បទាន | • ធ្វើវិសោធនកម្មច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានា ដើម្បី: (១) ផ្តល់ការចុះបញ្ជីរួមលើទ្រព្យដែលបានជួលចំពោះការផ្តល់ហិរញ្ញប្បទាន (២) បញ្ចូលការចុះបញ្ជីទ្រព្យអរូបិយ និង (៣) បញ្ជាក់ការយកមកវិញនូវទ្រព្យដែលបានជួល។ | | | - ក្រសួងពាណិជកម្ម |
| ១៩. បទប្បញ្ញត្តិប្រុងប្រយ័ត្នសម្រាប់ភតិសន្យាហិរញ្ញវត្ថុ | • ពង្រឹងបទប្បញ្ញត្តិប្រុងប្រយ័ត្នសម្រាប់ភតិសន្យាហិរញ្ញវត្ថុ។ | • ពង្រឹងការត្រួតពិនិត្យវិស័យភតិ-សន្យាហិរញ្ញវត្ថុ។ | | - ធនាគារជាតិនៃកម្ពុជា |
| **II. វិស័យមិនមែនធនាគារ** | | | | |
| **ក. ទីផ្សារមូលធន** | | | | |
| **គោលនយោបាយ: ការពង្រីកការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុ** | | | | |
| ២០.ស្ថានភាពអាជីវកម្មរបស់ | • អង្កេតលើការបង្កើតនាយក- | • បន្តជំរុញការចុះបញ្ជីរបស់សហ- | | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |

| គោលនយោបាយ អភិវឌ្ឍន៍ | គោលដៅរយៈពេលខ្លី ២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម ២០១៩-២០២២ | គោលដៅរយៈពេលវែង ២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| **សហគ្រាសសាធារណៈ និងការលក់មូលបត្រកម្មសិទ្ធិ** | ដ្ឋាន ឬក្រុមហ៊ុនសម្រាប់គ្រប់គ្រងសហគ្រាសសាធារណៈ និងការត្រៀមខ្លួនចុះបញ្ជី។ | គ្រាសសាធារណៈ។ | | - គណៈកម្មការមូលបត្រកម្ពុជា |
| | • ពិចារណាលើការបង្កើតក្របខ័ណ្ឌ និងគោលនយោបាយលើកទឹកចិត្តដល់ការចុះបញ្ជីរបស់សហគ្រាសរដ្ឋ។ | • ពិនិត្យមើលអភិបាលកិច្ច និងស្ថានភាពអាជីវកម្មរបស់សហគ្រាសរដ្ឋ និងជំរុញការចុះបញ្ជីរបស់សហគ្រាសរដ្ឋ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ | | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- គណៈកម្មការមូលបត្រកម្ពុជា |
| **២១.ផលប្រយោជន៍ក្នុងគម្រោងវិនិយោគរួម និងមូលនិធិ** | • ជំរុញការបង្កើត និងការចុះបញ្ជីគម្រោងវិនិយោគរួម និងមូលនិធិដែលអាចជួញដូរបាន (Exchange Traded Funds: ETF) ដើម្បីប្រមូលមូលនិធិនៅក្នុងស្រុកសម្រាប់ការវិនិយោគក្នុងស្រុក និងបង្កើតមូលនិធិគ្រប់គ្រងសម្រាប់ការវិនិយោគមូលនិធិសង្គមរបស់រាជរដ្ឋាភិបាល។ | • បន្តជំរុញការចុះបញ្ជី គម្រោងវិនិយោគរួម ព្រមទាំងបង្កើត និងចុះបញ្ជីសន្ទស្សន៍ ឬមូលនិធិវិនិយោគមួយ ឬច្រើន។ | • ពិនិត្យឡើងវិញលើការវិនិយោគលើមូលនិធិដែលអាចជួញដូរបាន និងអភិវឌ្ឍឱកាសវិនិយោគក្នុងស្រុក និងសិក្សាពីលទ្ធភាពបង្កើតមូលនិធិទ្រព្យសម្បត្តិរដ្ឋ។ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- គណៈកម្មការមូលបត្រកម្ពុជា<br>- ផ្សារមូលបត្រកម្ពុជា |

| គោលនយោបាយអភិវឌ្ឍន៍ | គោលដៅរយៈពេលខ្លី ២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម ២០១៩-២០២២ | គោលដៅរយៈពេលវែង ២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| ២២. ការខ្ចីនិងការឲ្យខ្ចីមូលបត្រ | • ពិចារណាពីនីតិវិធីដើម្បីអនុញ្ញាតឲ្យមានការខ្ចី និងការឲ្យខ្ចីមូលបត្រ និងធ្វើការសិក្សាពីលទ្ធភាពក្នុងការបង្កើតក្រុមហ៊ុនហិរញ្ញប្បទានមូល-បត្រ ដើម្បីផ្តល់សេវាខ្ចី និងឲ្យខ្ចីមូលបត្រសម្រាប់ផ្សារមូលបត្រ។ | • បើសិនជាអាច អភិវឌ្ឍប្រព័ន្ធនិងនីតិវិធីសម្រាប់យន្តការនៃការខ្ចី និងឲ្យខ្ចីមូលបត្រ។ | • សម្រួលដល់ការអនុវត្តការខ្ចី និងការឲ្យខ្ចីមូលបត្រ។ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- គណៈកម្មការមូលបត្រកម្ពុជា (ស្ថាប័នដឹកនាំរួម) |
| ២៣. ទីផ្សារខុម៉ូឌីធី | • អភិវឌ្ឍទីផ្សារខុម៉ូឌីធីរូបវន្ត។ | • អភិវឌ្ឍក្របខ័ណ្ឌគតិយុត្តិសម្រាប់ទីផ្សារខុម៉ូឌីធីអនាគត។ | • អនុម័ត និងចាប់ផ្តើមប្រតិបត្តិការនៃទីផ្សារខុម៉ូឌីធីអនាគត។ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- គណៈកម្មការមូលបត្រកម្ពុជា (ស្ថាប័នដឹកនាំ) |
| ២៤. ដេរីវេទីវហិរញ្ញវត្ថុ | | • ពិនិត្យឡើងវិញលើស្ថានភាពទីផ្សារខុម៉ូឌីធីជារូបវន្ត និងសិក្សាអំពីតម្រូវការ និងក្របខ័ណ្ឌគតិ-យុត្តសម្រាប់ទីផ្សារអនាគត និងអុបសិន។ | • ពង្រីកក្របខ័ណ្ឌគតិយុត្តិសម្រាប់ដេរីវេទីវហិរញ្ញវត្ថុដើម្បីគ្រប់គ្រងទីផ្សារដេរីវេទីវ និងពិនិត្យឡើងវិញលើការអនុញ្ញាត ព្រមទាំងបង្កើតទីផ្សារអុបសិន សម្រាប់កិច្ចសន្យាអុបសិន និងនិស្សន្ទ។ | - គណៈកម្មការមូលបត្រកម្ពុជា |

| គោលនយោបាយ អាទិភាព | គោលដៅរយៈពេលខ្លី ២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម ២០១៩-២០២២ | គោលដៅរយៈពេលវែង ២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| **២៥. ឯកសារផ្តល់ព័ត៌មាន និងព័ត៌មានវិនិយោគិន** | • បង្កភាពងាយស្រួលក្នុងការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម :រៀបចំបទប្បញ្ញត្តិសម្រាប់សម្រួលដល់ការចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម។<br>• ទម្រង់សាមញ្ញ : អនុញ្ញាតឲ្យធនាគារ និងសហគ្រាសធុនតូចនិងមធ្យមប្រើប្រាស់ទម្រង់សាមញ្ញជំនួសឯកសារផ្តល់ព័ត៌មានពេញលេញ។ | • អនុវត្តលក្ខខណ្ឌតម្រូវថ្មី និងអភិវឌ្ឍគោលនយោបាយដើម្បីជំរុញកំណើនទីផ្សារ។ | • បន្តអនុវត្ត។ | - គណៈកម្មការមូលបត្រកម្ពុជា |
| **២៦. ការអភិវឌ្ឍក្រោជហ្វាន់ឌីង** | • ស្រាវជ្រាវ និងបង្កើតក្របខ័ណ្ឌគតិយុត្តសម្រាប់ក្រោជហ្វាន់-ឌីង ដើម្បីជំរុញក្រុមហ៊ុនបង្កើតថ្មី។ | • ពិនិត្យឡើងវិញនូវការអភិវឌ្ឍតម្រូវការ និងការវិវត្តថ្មីនៃទីផ្សារពាក់ព័ន្ធនឹងប្រតិបត្តិការក្រោជ-ហ្វាន់ឌីង និងកែសម្រួលបទ-ប្បញ្ញត្តិ។ | • ពិនិត្យឡើងវិញនូវតំណភ្ជាប់រវាងសហគ្រាសធុនតូចនិងមធ្យមនៅក្នុងក្រោជហ្វាន់ឌីង និងទីផ្សារមូលបត្រ និងកែសម្រួលបទប្បញ្ញត្តិដើម្បីទ្រទ្រង់កំណើន។ | - គណៈកម្មការមូលបត្រកម្ពុជា |

| គោលនយោបាយអាទិភាព | គោលដៅរយៈពេលខ្លី ២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម ២០១៩-២០២២ | គោលដៅរយៈពេលវែង ២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| | • ផ្តល់អាជ្ញាបណ្ណដល់អ្នកផ្តល់សេវា និងវេទិកាក្រោដហ្វាន់ឌីង។ | • រៀបចំបទប្បញ្ញត្តិដើម្បីពង្រឹងការត្រួតពិនិត្យដល់អ្នកផ្តល់សេវា និងវេទិកាក្រោដហ្វាន់ឌីង។ | | - គណៈកម្មការមូលបត្រកម្ពុជា |
| **២៧.បង្កើនការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់ការចូលរួមក្នុងទីផ្សារមូលបត្រ** | • ពិនិត្យប្រសិទ្ធភាពនៃការបន្តការលើកទឹកចិត្តផ្នែកពន្ធដារ និងការលើកទឹកចិត្តផ្នែកមិនមែនពន្ធដារ ធ្វើការអង្កេតលើការលើកទឹកចិត្តផ្នែកពន្ធដារបន្ថែមទៀតតាមរយៈក្រុមការងារបច្ចេកទេសរួម (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **គ.ម.ក.** និងអគ្គនាយកដ្ឋានពន្ធដារ) ដែលរួមបញ្ចូលគោលនយោបាយពន្ធដារសម្រាប់សន្ទស្សន៍ និងមូលនិធិវិនិយោគ ព្រមទាំងអនុវត្តគោលនយោបាយថ្មី។ | | | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- អគ្គនាយកដ្ឋានពន្ធដារ<br>- គណៈកម្មការមូលបត្រកម្ពុជា |

| គោលនយោបាយអភិវឌ្ឍន៍ | គោលដៅរយៈពេលខ្លី ២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម ២០១៩-២០២២ | គោលដៅរយៈពេលវែង ២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| | • ផ្តល់ផលប្រយោជន៍ដូចគ្នារវាងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ និងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ | | | - គណៈកម្មការមូលបត្រកម្ពុជា<br>- អគ្គនាយកដ្ឋានពន្ធដារ |
| ២៨.ជំរុញការចុះបញ្ជីលក់មូលបត្ររបស់ស្ថាប័នហិរញ្ញវត្ថុ | • ពិនិត្យឡើងវិញនូវបទប្បញ្ញត្តិ និងគោលនយោបាយបច្ចុប្បន្ន កំណត់និងលុបចោលឧបសគ្គនានាដែលរាំងស្ទះដល់ការចុះបញ្ជីរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ជំរុញការចុះបញ្ជីលក់មូលបត្រ និងរៀបចំចុះបញ្ជីលក់មូលបត្ររបស់ស្ថាប័នហិរញ្ញវត្ថុ។ | • បន្តជំរុញការចុះបញ្ជីលក់មូលបត្ររបស់ស្ថាប័នហិរញ្ញវត្ថុ។ | | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- គណៈកម្មការមូលបត្រកម្ពុជា<br>- ធនាគារជាតិនៃកម្ពុជា |

| គោលនយោបាយ អភិវឌ្ឍន៍ | គោលដៅរយៈពេលខ្លី ២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម ២០១៩-២០២២ | គោលដៅរយៈពេលវែង ២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| ២៩. ចុះបញ្ជីគ្រឹះស្ថានហិរញ្ញវត្ថុសំខាន់ៗ | • កំណត់នូវគោលនយោបាយ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងគ្រឹះស្ថានហិរញ្ញវត្ថុសំខាន់ៗ ដែលអាចមានលទ្ធភាពចុះបញ្ជីឲ្យបោះផ្សាយលក់មូលបត្រ ក្នុងកម្រិតណាមួយ សម្រាប់បរិវិសកម្ម និងការចុះបញ្ជីជាសាធារណៈ។ | • ពិនិត្យមើលលើតម្រូវការសម្រាប់ការបន្ថយលក្ខខណ្ឌតម្រូវពិសេសសម្រាប់ការចុះបញ្ជី។ | | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- គណៈកម្មការមូលបត្រកម្ពុជា<br>- ធនាគារជាតិនៃកម្ពុជា |
| ៣០. អនុវត្តគំនិតផ្តួចផ្តើមពាក់ព័ន្ធនឹង ACU | • លើកទឹកចិត្តក្រុមហ៊ុនចុះបញ្ជីទាំងអស់ឲ្យចុះ MOU ជាមួយ ACU។ | | | - គណៈកម្មការមូលបត្រកម្ពុជា<br>- អង្គភាពប្រឆាំងអំពើពុករលួយ<br>- ក្រសួងពាណិជ្ជកម្ម<br>- ស្ថាប័នពាក់ព័ន្ធផ្សេងទៀត |
| **គោលនយោបាយ: ពង្រឹងស្ថិរភាព និងទំនុកចិត្ត** | | | | |
| ៣១.លើកកម្ពស់អក្ខរកម្មហិរញ្ញវត្ថុ | • ធ្វើការងារជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបញ្ចូលអក្ខរកម្មហិរញ្ញវត្ថុទៅក្នុងកម្មវិធីអប់រំថ្នាក់ជាតិ។ | • ធ្វើបច្ចុប្បន្នកម្មនិងអនុវត្តកម្មវិធីអប់រំវិនិយោគិន និងការយល់ដឹងជាសាធារណៈ ដោយផ្អែកលើមតិឆ្លើយតប និងការអភិវឌ្ឍទីផ្សារ/តម្រូវការទីផ្សារជាក់ស្តែង។ | • ចូលរួមកម្មវិធីអក្ខរកម្មហិរញ្ញវត្ថុទ្រង់ទ្រាយធំ (សូមមើលផ្នែកការកសាងសមត្ថភាព និងសមាហរណកម្ម)។ | - គណៈកម្មការមូលបត្រកម្ពុជា |

| គោលនយោបាយ អនិវឌ្ឍន៍ | គោលដៅរយៈពេលខ្លី ២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម ២០១៩-២០២២ | គោលដៅរយៈពេលវែង ២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| **៣២.ជំរុញការអប់រំនិងការយល់ដឹងសម្រាប់សារព័ត៌មាន** | • បន្តរៀបចំវគ្គបណ្តុះបណ្តាលស្តីពី របាយការណ៍ហិរញ្ញវត្ថុ និងសារព័ត៌មានពាក់ព័ន្ធនឹងអាជីវកម្មមូលបត្រ។ | • កសាងសមត្ថភាពចំពោះការផ្សព្វផ្សាយសារព័ត៌មានជាភាសាខ្មែរនិងភាសាអង់គ្លេស ព្រមទាំងការផ្តល់ព័ត៌មាន ជាសាធារណៈតាមរយៈប្រព័ន្ធអ៊ីន-ធឺណែត និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ | • ផ្តល់ការដាក់បង្ហាញព័ត៌មានដែលមានលក្ខណៈគ្រប់គ្រាន់ ព្រមទាំងឆ្លើយតបទៅនឹងរាល់បញ្ហាដែលពាក់ព័ន្ធ។ | - គណៈកម្មការមូលបត្រកម្ពុជា |
| **៣៣. គណនេយ្យនិងសវនកម្ម** | • ពិភាក្សាជាមួយក្រុមប្រឹក្សា-ជាតិគណនេយ្យ លើការធ្វើឲ្យប្រសើរឡើងនូវការត្រួត-ពិនិត្យក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវាក្នុងវិស័យមូលបត្ររបស់ KICPAA (សូមមើលផ្នែកគណនេយ្យនិងសវនកម្ម)។ | | | - គណៈកម្មការមូលបត្រកម្ពុជា |
| **៣៤. ការអនុវត្តនិងការដោះ-ស្រាយវិវាទ** | • បញ្ចប់ការកែសម្រួលបទ-ប្បញ្ញត្តិ និងនីតិវិធីដោះស្រាយវិវាទផ្លូវការ។ | | | - គណៈកម្មការមូលបត្រកម្ពុជា |

| គោលនយោបាយអភិវឌ្ឍន៍ | គោលដៅរយៈពេលខ្លី ២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម ២០១៩-២០២២ | គោលដៅរយៈពេលវែង ២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| **៣៥. ពង្រឹងកិច្ចសហប្រតិបត្តិ-ការអន្តរស្ថាប័ន** | • ចុះអនុស្សរណៈយោគយល់គ្នាស្តីពីការចែករំលែកព័ត៌មាន និងសហប្រតិបត្តិការលើប្រព័ន្ធផាត់ទាត់និងទូទាត់។ | • បន្តអភិវឌ្ឍ និងពង្រឹងភាពជាដៃគូនិងសហប្រតិបត្តិការទៅវិញទៅមកជាមួយនឹងនិយ័តករ និងទីផ្សារមូលបត្របរទេស។ | | - ធនាគារជាតិនៃកម្ពុជា<br>- គណៈកម្មការមូលបត្រកម្ពុជា |
| **៣៦.ការកសាងសមត្ថភាព/អភិបាលកិច្ច** | • សម្របសម្រួលការបណ្តុះ-បណ្តាលទូទៅ និងការបណ្តុះ-បណ្តាលចំគោលដៅស្តីពីអភិបាលកិច្ច។ | | | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- គណៈកម្មការមូលបត្រកម្ពុជា<br>- ធនាគារជាតិនៃកម្ពុជា |
| | • ពិនិត្យឡើងវិញនូវការអនុវត្តប្រកាសស្តីពី អភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមិនបោះផ្សាយរួមទាំងសហគ្រាសធុនតូចនិងមធ្យម។ | • បន្តអភិវឌ្ឍ និងពង្រឹងបទប្បញ្ញត្តិពាក់ព័ន្ធនឹងអភិបាលកិច្ចសាជីវកម្មដោយផ្អែកលើតម្រូវការចាំបាច់និងការអនុវត្តល្អ។ | • អនុវត្តការវាយតម្លៃកម្រិតអភិបាល-កិច្ចសាជីវកម្មក្នុងក្របខ័ណ្ឌអាស៊ាន (ASEAN Corporate Governance Scorecard) សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈនៅកម្ពុជា។ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- គណៈកម្មការមូលបត្រកម្ពុជា<br>- ធនាគារជាតិនៃកម្ពុជា |

| គោលនយោបាយអភិវឌ្ឍន៍ | គោលដៅរយៈពេលខ្លី ២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម ២០១៩-២០២២ | គោលដៅរយៈពេលវែង ២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| | • ជំរុញការអនុវត្តអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនមិនបោះផ្សាយ រួមទាំងសហគ្រាសធុនតូចនិងមធ្យម។ | • អនុវត្តយុទ្ធនាការអប់រំស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមិនបោះផ្សាយ រួមទាំងសហគ្រាសធុនតូចនិងមធ្យមដោយផ្តោតសំខាន់ទៅលើការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល លេខាធិការក្រុមហ៊ុន និងគណៈគ្រប់គ្រង។ | • ជំរុញការអនុវត្តការវាយតម្លៃកម្រិតអភិបាលកិច្ចសាជីវកម្មក្នុងក្របខ័ណ្ឌអាស៊ាន (ASEAN Corporate Governance Scorecard) សម្រាប់ក្រុមហ៊ុនមិនបោះផ្សាយនៅកម្ពុជា ព្រមទាំងអង្កេត និងជំរុញការរៀបចំព្រឹត្តិការណ៍ ឬការប្រកួតប្រជែងនានាដើម្បីទទួលស្គាល់ក្រុមហ៊ុនដែលទទួលបានចំណាត់ថ្នាក់ល្អ។ | - គណៈកម្មការមូលបត្រកម្ពុជា |
| ៣៧. សិក្សាលទ្ធភាពដើម្បីចូលជាសមាជិករបស់ IOSCO | • សិក្សាលទ្ធភាពលើការអនុវត្តតាមគោលការណ៍ជាសារវន្តរបស់ IOSCO និងការស្នើសុំចូលជាសមាជិក IOSCO។ | • ប្រសិនបើអាចមានលទ្ធភាពនឹងស្នើសុំចូលជាសមាជិក IOSCO។ | | - គណៈកម្មការមូលបត្រកម្ពុជា |
| **គោលនយោបាយ: គាំទ្រផ្នែកហេដ្ឋារចនាសម្ព័ន្ធ** | | | | |
| ៣៨.បទប្បញ្ញត្តិមូលបត្របំណុលនិងឧបករណ៍និស្សន្ទ | • បង្កើត និងអនុវត្តក្របខ័ណ្ឌគតិយុត្តសម្រាប់មូលបត្របំណុលនិងឧបករណ៍និស្សន្ទ។ | • ពង្រឹងការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងមូលបត្របំណុលនិងឧបករណ៍និស្សន្ទ។ | • ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មសកម្មភាពចាំបាច់បន្ថែមទៀត។ | - គណៈកម្មការមូលបត្រកម្ពុជា |

| គោលនយោបាយ អភិវឌ្ឍន៍ | គោលដៅរយៈពេលខ្លី ២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម ២០១៩-២០២២ | គោលដៅរយៈពេលវែង ២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| ៣៩. ការត្រួតពិនិត្យ និងការរៀបចំបទប្បញ្ញត្តិ ស្តីពីគម្រោងវិនិយោគរួម | • អភិវឌ្ឍ និងដាក់ឲ្យអនុវត្តបទប្បញ្ញត្តិសម្រាប់ប្រតិបត្តិករគម្រោងវិនិយោគរួម និងអ្នកគ្រប់គ្រងមូលនិធិ និងផ្តល់អាជ្ញាបណ្ណដល់ប្រតិបត្តិករគម្រោងវិនិយោគរួម។ | • ពង្រឹងការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងគម្រោងវិនិយោគរួម និងពិនិត្យឡើងវិញពីស្ថានភាពរបស់បុគ្គលគ្រប់គ្រងមូលនិធិ និងកម្មវិធីកសាងសមត្ថភាពសម្រាប់ការគ្រប់គ្រងមូលនិធិ។ | • ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មសកម្មភាពចាំបាច់បន្ថែមទៀត។ | - គណៈកម្មការមូលបត្រកម្ពុជា |
| ៤០.បរធនបាលកិច្ច និងប្រតិបត្តិការវិនិយោគស្ថិតក្រោមច្បាប់ស្តីពីបរធនបាលកិច្ច | • អភិវឌ្ឍចំណេះដឹង និងសមត្ថភាពពាក់ព័ន្ធនឹងបរធនបាលកិច្ច និងប្រតិបត្តិការវិនិយោគ។ | • ធានាឲ្យបាននូវបរធនបាលកិច្ច និងប្រតិបត្តិការវិនិយោគរបស់ស្ថាប័នហិរញ្ញវត្ថុមិនមែនធនាគារ ដែលផ្តោតលើក្របខ័ណ្ឌប្រុងប្រយ័ត្ន និងគ្រប់គ្រងហានិភ័យ ព្រមទាំងគោលការណ៍ណែនាំ និងនីតិវិធីសមស្រប។ | • ពិនិត្យឡើងវិញ និងពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងឯកសារគតិយុត្តិពាក់ព័ន្ធនឹងបរធនបាលកិច្ចវិនិយោគ។ | - គណៈកម្មការមូលបត្រកម្ពុជា |
| ៤១.ពង្រឹងលក្ខខណ្ឌតម្រូវការប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម | • ធ្វើការជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាដើម្បីបញ្ចូលវិធានការបង្ការការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិមូលបត្រ | | | - គណៈកម្មការមូលបត្រកម្ពុជា<br>- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា |

| គោលនយោបាយអភិវឌ្ឍន៍ | គោលដៅរយៈពេលខ្លី ២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម ២០១៩-២០២២ | គោលដៅរយៈពេលវែង ២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| | មហាជន។ | | | |
| **ខ. អន្តរការី និងអ្នកផ្តល់សេវាវិជ្ជាជីវៈជំនាញ** | | | | |
| ៤២. ដាក់បទប្បញ្ញត្តិលើអន្តរការី និងអ្នកផ្តល់សេវាវិជ្ជាជីវៈជំនាញ | • បង្កើតគុណវុឌ្ឍិ និងបទដ្ឋានស្របតាមលក្ខខណ្ឌតម្រូវរបស់អាស៊ាន។ | • អនុវត្តជំនួយអភិវឌ្ឍការកសាងសមត្ថភាពនិងជំនាញ។ | • បន្តអភិវឌ្ឍការកសាងសមត្ថភាពជំនាញ។ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- គណៈកម្មការមូលបត្រកម្ពុជា<br>- ធនាគារជាតិនៃកម្ពុជា<br>- ក្រសួងពាណិជ្ជកម្ម |
| | • អភិវឌ្ឍគោលនយោបាយសម្រាប់ចុះបញ្ជីបរធនបាល។ | • ចុះបញ្ជីក្រុមហ៊ុនបរធនបាល។ | | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- គណៈកម្មការមូលបត្រកម្ពុជា |
| **គ. វិស័យធានារ៉ាប់រង** | | | | |
| **គោលនយោបាយ: ក្របខ័ណ្ឌបទប្បញ្ញត្តិល្អប្រសើរ** | | | | |
| ៤៣. អនុក្រឹត្យ និងប្រកាសថ្មីៗ ដើម្បីគាំទ្រដល់ច្បាប់ស្តីពីការធានារ៉ាប់រង | • រៀបចំសេចក្តីព្រាង និងអនុវត្តអនុក្រឹត្យ និងប្រកាសសម្រាប់ការធានារ៉ាប់រង និងការធានារ៉ាប់រងខ្នាតតូច។ | • ពិនិត្យឡើងវិញនូវអនុក្រឹត្យ និងប្រកាសដែលពាក់ព័ន្ធ។ | • បន្តពិនិត្យ និងធ្វើបច្ចុប្បន្នភាពប្រកាសដែលពាក់ព័ន្ធនឹងការអនុវត្តជាក់ស្តែងក្នុងទីផ្សារ។<br>• បន្តរៀបចំប្រកាសថ្មីៗ និងអនុវត្តតាមការចាំបាច់។ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |

| គោលនយោបាយអាទិភាព | គោលដៅរយៈពេលខ្លី ២០១៦-២០១៩ | គោលដៅរយៈពេលមធ្យម ២០១៩-២០២២ | គោលដៅរយៈពេលវែង ២០២២-២០២៥ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| ៤៤.អនុលោមភាពតាមគោលការណ៍គ្រឹះធានារ៉ាប់រង | • ធ្វើការសិក្សាពីតម្រូវការផ្សេងៗនៃគោលការណ៍គ្រឹះធានារ៉ាប់រង។ | • វាយតម្លៃអនុលោមភាពជាមួយនឹងតម្រូវការនៃគោលការណ៍គ្រឹះធានារ៉ាប់រង។<br>• ពិចារណាឡើងវិញការចូលជាសមាជិករបស់ IAIS។ | • បន្តការវាយតម្លៃជាទៀងទាត់នូវគោលការណ៍គ្រឹះធានារ៉ាប់រង។ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៤៥. តម្រូវតាមលក្ខខណ្ឌរបស់ AML/CFT | • រៀបចំអនុវត្តកម្មវិធីបណ្តុះបណ្តាលសម្រាប់បុគ្គលិក និងជួយ CAFIU តាមរយៈការតាមដានការអនុវត្តច្បាប់។ | • សម្របសម្រួលជាមួយក្រុមហ៊ុនធានារ៉ាប់រង ដោយអនុលោមតាមតម្រូវការរបស់ AML/CFT។ | | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៤៦. ផលិតផលធានារ៉ាប់រងជាកាតព្វកិច្ច | • រៀបចំប្រកាសសម្រាប់ការធានារ៉ាប់រងតតិយជន។ | • រៀបចំត្រួតពិនិត្យសម្រាប់ការធានារ៉ាប់រងជាកាតព្វកិច្ច។ | • ជំរុញការអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច។ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
